# សង្គ្រាមការណ៍ ២២

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



ខៀវ សំផន កំពុងថ្លែងសុន្ទរកថាទៅកាន់គណៈប្រតិភូបរទេស ពេលធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org

ខែកក្កដា ឆ្នាំ២០១៣

# មាតិកា

ខែកក្កដា ឆ្នាំ២០១៣



សវនាការស្តាប់សក្ខីកម្ម


៣ សាក្សី ហ្វីលីព ហ្ស៊ូល្យាន-ហ្គោលប៉ុហ្វស៍

៩ សាក្សី ចៅ សុគុណ

១៤ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី

៤២ ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី,...

៥១ សាក្សីជំនាញ ឈឹម សុធារ៉ា

៥៩ សាក្សី ស៊ីជនី ស្តេនបឹក

៦៥ សាក្សី សុខ រឿ

៦៧ សាក្សី ទុន សឿន ស្តីពីអត្តចរិត...

១៩ ការស្តាប់សេចក្តីថ្លែងទុក្ខសោក...

២៥ ការស្តាប់សេចក្តីថ្លែងទុក្ខរបស់..

៣១ ការស្តាប់សេចក្តីថ្លែងទុក្ខសោក...

៦៣ សេចក្តីថ្លែងការណ៍របស់ នួន ជា...



ក្រុមសង្កេតការណ៍ ៖

ឆាយ ឈុនលី, លឹម ជ័យទ័ត្ត,

ឌី សុជាតា, និង ចាន ប្រាថ្នា

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ ជី ទេវិទ្ធិ


កម្មាភិបាលខ្មែរក្រហម កំពុងឈរថតរូបនៅជិតវិមានឯករាជ្យ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

## ថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣

### សេចក្តីផ្តើម

ចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី, សាក្សីជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី សរុប២២រូប ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីការដំណោះស្រាយបញ្ជូនរឿង ទៅជំនុំជម្រះក្នុងសំណុំរឿង០០២ អំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសវនាការស្តាប់នូវការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សាក្សីចំនួន៥រូប សាក្សីជំនាញចំនួន១រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៦រូប ត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មតាមលំដាប់លំដោយ ។ សាក្សីចំនួន៥រូប ដែលបានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះមានដូចជា ទី១) សាក្សី ហ្វីលីព ហ្សូលាន-ហ្គោលប្រែស ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន តាមរយៈប្រព័ន្ធអ៊ីនធឺណែតពីប្រទេសបារាំង ។ សាក្សី ហ្វីលីព ហ្សូលាន-ហ្គោលប្រែស ស្គាល់ ខៀវ សំផន នៅក្នុងឆ្នាំ១៩៥៧ នៅទីក្រុងប៉ារីស ប្រទេសបារាំង ហើយសាក្សីបានអះអាងថា ខៀវ សំផន ជាបុគ្គលដែលមានប្រជាប្រិយភាពខ្ពស់ ចង់លុបបំបាត់អំពើពុករលួយ និងការរំលោភអំណាច ប៉ុន្តែចូលចិត្តរស់នៅក្នុងជីវភាព



សមាជិកក្រុមការងារគម្រោងឃ្លាំមើលសាលាក្តីខ្មែរក្រហមថតរូបអនុស្សាវរីយ៍ជាមួយនិស្សិត បន្ទាប់ការធ្វើបទបង្ហាញ

សាមញ្ញ ទោះបីមានឋានៈជារដ្ឋមន្ត្រីក៏ដោយ ។ ទី២) សាក្សី ចៅ សុគុណ បានផ្តោតសំខាន់តែទៅលើអត្តចរិត និងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ។ ទី៣) សាក្សី ស៊ីដនី ស្កេនបឺក អតីតភ្នាក់ងារសារព័ត៌មាននៃការសែតញូវយ៉កថាមស៍ ដែលបានបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជា មុន និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងទិដ្ឋភាពជម្លៀសប្រជាជនកម្ពុជាចេញពីទីក្រុងភ្នំពេញ ស្ថានភាពនៅក្នុងស្ថានទូត និងមន្ទីរពេទ្យធំៗ ។ ទី៤) សាក្សី សុខ រឿ ផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចិតរបស់ជនជាប់ចោទ ខៀវ សំផន ដោយហេតុថា សាក្សីជាកងការពារ ខៀវ សំផន នៅក្នុងឆ្នាំ១៩៨៩-៩៦ ។ ទី៥) សាក្សី ទុន សឿន ផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ។ សាក្សី ទុន សឿន ជាកូនប្រសារ និងអតីតអ្នកនាំសាររបស់ជនជាប់ចោទ ខៀវ សំផន ។ ទី៦) សាក្សីជំនាញវេជ្ជបណ្ឌិត ឈឹម សុធារ៉ា ជាអ្នកឯកទេសផ្លូវចិត្តធ្លាប់មានបទពិសោធព្យាបាលជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងរយៈពេលប្រហែល១៩ឆ្នាំ ។ អ្នកជំនាញ ឈឹម សុធារ៉ា បានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការរកឃើញនូវរោគសញ្ញាមួយចំនួននៃជំងឺផ្លូវចិត្តរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម និងផលប៉ះពាល់ ដែលជនរងគ្រោះទទួលរងរហូតដល់ពេលបច្ចុប្បន្ន ។ ចំពោះសវនាការស្តីពីការថ្លែងទុក្ខសោក និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៦រូប អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ឱកាសជូនភាគីទាំងអស់ក្នុងការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់វេទិការជូនដើមបណ្តឹងរដ្ឋប្បវេណី មានឱកាសថ្លែងនូវទុក្ខសោកដែលខ្លួនទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ព្រមទាំងការប៉ះពាល់ដែលកើតមានរហូតដល់ពេលបច្ចុប្បន្ន ។ នៅក្នុងការថ្លែងរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាស្វែងរកនូវយុត្តិធម៌ ព្រមទាំងបានស្នើសុំសំណងផ្លូវចិត្ត ជូនជនរងគ្រោះនៃរបបខ្មែរក្រហមផងដែរ ។ គួរបញ្ជាក់ថា អង្គជំនុំជម្រះបានផ្តល់លទ្ធភាពជូនដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចោទសួរសំណួរមួយចំនួនទៅជនជាប់ចោទ នួន ជា និង ខៀវ សំផន ។

ចំពោះនីតិវិធីស្តាប់សក្ខីកម្ម អង្គជំនុំជម្រះសាលាដំបូង បានធ្វើឡើងដោយមានភាពបត់បែនទៅតាមស្ថានភាពរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំដោយភាគីនៃសំណុំរឿង និងពេលវេលាសួរដេញដោល ។ ដោយហេតុថា ការផ្តល់សក្ខីកម្មខ្លះត្រូវធ្វើពីបរទេស ដូច្នេះតម្រូវឲ្យអង្គជំនុំជម្រះបើកសវនាការលឿនជាងពេលវេលាដែលបានកំណត់ជាដើម ។ ជាទូទៅការសួរដេញដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ចាប់ផ្តើមពីភាគីណាដែលស្នើឲ្យមានការស្តាប់សក្ខីកម្មបុគ្គលនោះ បន្ទាប់ពីប្រធានអង្គជំនុំជម្រះ ។ ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ចាប់ផ្តើមពីមេធាវីនាំមុខដំណាងដើមបណ្តឹងរដ្ឋប្បវេណីសហព្រះរាជអាជ្ញា និងចុងក្រោយ មេធាវីការពារក្តីជាបន្តបន្ទាប់ ។ សាក្សីជំនាញ ឬសាក្សីធម្មតា ដែលផ្តល់សក្ខីកម្មតាមសំណើរសហព្រះរាជអាជ្ញា ត្រូវចាប់ផ្តើមតាមលំដាប់លំដោយពីអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ។ នៅក្នុងការស្តាប់សក្ខីកម្មសាក្សី ឬអ្នកជំនាញ តាមសំណើររបស់មេធាវីការពារក្តី ត្រូវចាប់ផ្តើមពីអង្គជំនុំជម្រះ មេធាវីការពារក្តី សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។



សិស្សកំពុងឈរតម្រង់ជួរដើម្បីចូលក្នុងបន្ទប់សវនាការ

# សវនាការស្តាប់សក្ខីកម្មសាក្សី ហ្វីលីព ហ្ស៊ូល្យាន-ហ្គោលហ្វ្រេស

## ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣

នៅរសៀលថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ ហ្វីលីព ហ្ស៊ូល្យាន-ហ្គោលហ្វ្រេស (Philippe Max Jullian-Gaufres) ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន តាមរយៈប្រព័ន្ធវីដេអូភ្ជាប់ពីប្រទេសបារាំង ។ សវនាការសួរដេញដោលសាក្សី ហ្គោលហ្វ្រេស ធ្វើឡើងរយៈពេលតែមួយរសៀលតែប៉ុណ្ណោះ ។

ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម សាក្សី ហ្គោលហ្វ្រេស បានបញ្ជាក់ថា លោកបានជួប ខៀវ សំផន ដំបូងបង្អស់នៅក្នុងឆ្នាំ១៩៥៧ នៅទីក្រុងប៉ារីស ប្រទេសបារាំង ។ សាក្សីរូបនេះបានអះអាងនៅចំពោះមុខអង្គជំនុំជម្រះថា ខៀវ សំផន ជាបុគ្គលដែលមានប្រជាប្រិយភាពខ្ពស់ ចង់លុបបំបាត់អំពើពុករលួយ និងការរំលោភអំណាច ប៉ុន្តែចូលចិត្តរស់នៅក្នុងជីវភាពសាមញ្ញ ទោះបីមានឋានៈជារដ្ឋមន្ត្រីក៏ដោយ ។ ទោះបីជាយ៉ាងណាក្តី សាក្សី ហ្គោលហ្វ្រេស បានអះអាងថា គាត់ពុំធ្លាប់ជួប ខៀវ សំផន នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ទេ ហើយក៏ពុំបានដឹងលម្អិតអំពីជីវិត និងតួនាទីរបស់ ខៀវ សំផន នៅចន្លោះពេលនោះដែរ ។

នីតិវិធីនៃការសួរសំណួរលើសាក្សីរូបនេះ ចាប់ផ្តើមដោយមេធាវីការពារក្តី ខៀវ សំផន ដោយសារតែ ខៀវ សំផន ជាអ្នកស្នើសុំឲ្យសាក្សីរូបនេះចូលមកផ្តល់សក្ខីកម្ម ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ ដើម្បីសួរសាក្សីមុនពេលប្រគល់វេទិកាជូនសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណែកឯក្រុមមេធាវីការពារក្តី នួន ជា ពុំមានសំណួរចោទសួរលើសាក្សីរូបនេះឡើយ ។

### ១) ប្រវត្តិសាវតា

សាក្សី ហ្វីលីព ហ្ស៊ូល្យាន-ហ្គោលហ្វ្រេស កើតនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៣០ នៅប្រទេស បារាំង ។ នៅក្នុងឆ្នាំ១៩៥០ សាក្សីទទួលបានសញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម នៅទីក្រុងប៉ារីស និងបានធ្វើការនៅក្នុងធនាគារមួយនៅក្នុងប្រទេសបារាំង ។ នៅចន្លោះឆ្នាំ១៩៥៥-១៩៥៦ លោកបានមករស់នៅ និងធ្វើការនៅតំបន់អាស៊ីអាគ្នេយ៍ ក្នុងនាមជាទាហានជាប់កាតព្វកិច្ចក្រោយពេលមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ។ បន្ទាប់មក សាក្សីបានត្រឡប់ទៅរស់នៅប្រទេសបារាំងវិញ ។ នៅពេលទៅដល់ប្រទេសបារាំងវិញ សាក្សីបានជួបនិស្សិតខ្មែរជាច្រើនដែលកំពុងរៀននៅសាលាពាណិជ្ជកម្ម ដែលនាំឲ្យគាត់មានចំណាប់អារម្មណ៍ចង់ទៅធ្វើការនៅក្នុងប្រទេសកម្ពុជា ហើយព្យាយាមរៀនសូត្រអក្សរខ្មែរ ។

នៅក្នុងឆ្នាំ១៩៦១ សាក្សីបានផ្លាស់មកធ្វើការឲ្យក្រុមហ៊ុន



ហ្វីលីព ហ្ស៊ូល្យាន-ហ្គោលហ្វ្រេស

បារាំងមួយនៅប្រទេសកម្ពុជា ដែលមានឈ្មោះថា ក្រុមហ៊ុន អ៊ែ-លីគីដ ដែលជាក្រុមហ៊ុនឧស្សាហកម្ម ឯកទេសខាងផលិតឧស្ម័ន ។ ក្រោយមក សាក្សីត្រូវបានតែងតាំងជាអគ្គនាយករបស់ក្រុមហ៊ុនមួយនេះ ដោយមានលោក ស៊ុន វ៉ាន់សៃ ជាប្រធានក្រុមហ៊ុន ។

នៅឆ្នាំ១៩៦៧ សាក្សី ហ្គោលហ្វ្រេស បានចាកចេញពីប្រទេសកម្ពុជា និងបានត្រឡប់មកប្រទេសកម្ពុជាម្តងទៀតនៅអំឡុងឆ្នាំ១៩៧៤ ដើម្បីបំពេញបេសកកម្មការងាររយៈពេលខ្លី ។

ពេលរស់នៅប្រទេសកម្ពុជា សាក្សីបានរៀបអាពាហ៍ពិពាហ៍ជាមួយភរិយាដែលជាជនជាតិខ្មែរ និងមានកូនបួននាក់ ។

## ២) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន លោក អាកទួរ វែកគែន បានចោទសួរសាក្សីដោយផ្តោតជាសំខាន់លើការយល់ដឹងរបស់សាក្សីអំពីប្រទេសកម្ពុជា និងទំនាក់ទំនងរវាងសាក្សី ជាមួយនឹង ខៀវ សំផន ថាតើសាក្សីបានស្គាល់ ខៀវ សំផន ដោយរបៀបណា និងស្គាល់ ខៀវ សំផន ច្បាស់ប៉ុណ្ណា ។ ឆ្លើយតបនឹងសំណួររបស់មេធាវី ខៀវ សំផន ទាក់ទងនឹងការយល់ដឹងអំពីវប្បធម៌នៃប្រទេសកម្ពុជា សាក្សី ហ្គោលហ្វ្រែស អត្ថាធិប្បាយថា ពេលរៀននៅសាលាជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម សាក្សីបានជួបនឹងជនជាតិខ្មែរពីរនាក់ដែលកំពុងរៀននៅទីនោះ ហើយដោយសារចង់រៀនសូត្រភាសា និងអក្សរសាស្ត្រខ្មែរ សាក្សីបានស្នើសុំ ខៀវ សំផន ដែលជាប្រធានសមាគមនិស្សិតនៅទីក្រុងប៉ារីសប្រទេសបារាំង ដើម្បីជួបនិយាយជាមួយជនជាតិខ្មែរម្នាក់ ឬពីរនាក់ ដើម្បីអាចរៀនសូត្រពីវប្បធម៌ខ្មែរ ។ ក្រោយមកទៀត សាក្សីធ្លាប់បានជួបជាមួយនឹង ខៀវ សំផន ជាច្រើនលើកនៅបុរីសាកលវិទ្យាល័យ និងជួបនៅកន្លែងសន្និសីទស្តីពីបណ្តាប្រទេសឥណ្ឌូចិនក្រោមអាណានិគមបារាំង មាន ខៀវ សំផន ជាអ្នកធ្វើបទបង្ហាញ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៩ ។ ប្រធានបទសំខាន់នៅពេលនោះ ផ្តោតលើការផ្លាស់ប្តូរពីសេដ្ឋកិច្ចអាណានិគម ទៅជាសេដ្ឋកិច្ចដែលលើកតម្លៃផលិតកម្មក្នុងស្រុកជាសេដ្ឋកិច្ច ដែលមានស្វ័យភាព ប៉ុន្តែពុំមែនពឹងផ្អែកលើខ្លួនឯងទាំងស្រុងនោះទេ ។

បន្ទាប់មក មេធាវី វែកគែន បានបន្តសួរទាក់ទងនឹងការសន្ទនារវាងសាក្សី ហ្គោលហ្វ្រែស និង ខៀវ សំផន ក្នុងអំឡុងពេលនៃសន្និសីទនោះ ។ សាក្សីបានបញ្ជាក់ត្រង់ចំណុចនេះថា នៅពេលសន្និសីទនោះ សាក្សីពិតជាបានសន្ទនាជាមួយនឹង ខៀវ សំផន ប្រាកដមែន ដោយការសន្ទនានោះ ផ្តោតលើបញ្ហាសង្គមកិច្ច ទោះបីជាប្រធានបទនៃសន្និសីទនិយាយអំពីការវិនិយោគក៏ដោយ ព្រោះការអភិវឌ្ឍសេដ្ឋកិច្ចចាំបាច់ត្រូវតែធ្វើ ប៉ុន្តែមិនត្រូវភ្លេចអំពីជីវភាពរបស់ប្រជាជន ជាពិសេសប្រជាកសិករទេ ។ សាក្សីបន្តថា នៅពេលនោះសាក្សីពុំឮ ខៀវ សំផន លើកឡើងអំពីការលុបបំបាត់កម្មសិទ្ធិឯកជន ឬលុបបំបាត់រូបិយវត្ថុទេ ។

នៅចន្លោះពីឆ្នាំ១៩៦១ ដល់១៩៦៦ ក្នុងអំឡុងពេលរស់នៅប្រទេសកម្ពុជា សាក្សីបានអះអាងថា ធ្លាប់ជួបជាមួយ ខៀវ សំផន ជាច្រើនលើក ព្រមទាំងស្គាល់ក្រុមគ្រួសាររបស់ ខៀវ សំផន ថែមទៀត ។ នៅពេលនោះសាក្សីបានអញ្ជើញ ខៀវ សំផន ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មឲ្យមកធ្វើទស្សនកិច្ចនៅរោងចក្រផលិតខ្សែន ។ ខៀវ សំផន បានផ្តល់សុន្ទរកថាខ្លីមួយ ដែលបានធ្វើឲ្យបុគ្គលិកពេញចិត្តចំពោះអត្ថន័យសុន្ទរកថានោះជាខ្លាំង ទោះបីជាពុំសូវយល់អំពីភាសាខ្មែរច្បាស់ក៏ដោយ ។

សាក្សីបានបង្ហាញពីការយល់ឃើញចំពោះអត្តចរិត ខៀវ សំផន ថា ខៀវ សំផន ជាបុគ្គលដែលចង់លុបបំបាត់អំពើពុករលួយ និងការរំលោភអំណាច និងធ្វើឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច ។ ខៀវ សំផន ចូលចិត្តជីវភាពបែបសាមញ្ញ រស់នៅផ្ទះឈើប្រក់ក្បឿងជាមួយម្តាយ និងជិះកង់ទៅធ្វើការដោយមិនសម្តែងអំពីទ្រព្យសម្បត្តិដូចអ្នកធ្វើការរាជការផ្សេងទៀតទេ ។ ក្រោយពី ខៀវ សំផន ជាប់ជាតំណាងរាស្ត្រ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ខៀវ សំផន បានប្តូរពីការជិះកង់មកជិះរថយន្តវិញម្តង ប៉ុន្តែរថយន្តនោះជារថយន្តជជុះទេ ។

ទោះបីជាយ៉ាងណាក្តី សាក្សី ហ្គោលហ្វ្រែស បានអះអាងថា សាក្សីពុំបានរស់នៅប្រទេសកម្ពុជា នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែយល់ថា តួនាទីជាប្រមុខរដ្ឋរបស់ ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្រាន់តែជាតួនាទីដែលខ្មែរក្រហមប្រគល់ឲ្យអ្នកដែលមានប្រជាប្រិយភាពកាន់តែប៉ុណ្ណោះ ។ សាក្សីបានលើកយកឧទាហរណ៍ជាក់ស្តែងមួយ ដែលខ្មែរក្រហមបានប្រគល់តំណែងនេះជូនសម្តេច នរោត្តម សីហនុ ដោយសារព្រះអង្គមានប្រជាប្រិយភាពខ្លាំងក្នុងចំណោមប្រជាជនកម្ពុជា និងនៅលើឆាកអន្តរជាតិ ។ ដូច្នេះការដែលខ្មែរក្រហមប្រគល់តំណែងជាប្រមុខរដ្ឋនេះទៅឲ្យ ខៀវ សំផន ក៏ដោយសារតែ ខៀវ សំផន ជាបុគ្គលដែលមានប្រជាប្រិយភាពដែរ ។

នៅចន្លោះពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ២០០៥ សាក្សី ហ្គោលហ្វ្រែស បានអះអាងថា សាក្សីបានជួប ខៀវ សំផន ជាច្រើនសារ ។ នៅក្នុងឆ្នាំ២០០៥ សាក្សីបានទៅលេងផ្ទះរបស់ ខៀវ

សំផន ដោយផ្ទាល់នៅក្នុងខេត្តប៉ៃលិន ដែលជាផ្ទះក្បឿងពុំមានផាសុកអ្វីទេ ព្រោះពុំមានសូម្បីម៉ាស៊ីនទឹកដើម្បីប្រើប្រាស់ ។ សាក្សីបន្តថា អ្នកភូមិដែលរស់នៅតំបន់នោះនៅតែគោរពស្រឡាញ់ ខៀវ សំផន ។

### ៣) ការសួរដេញដោលសាក្សីដោយចៅក្រម ហ្វង់ម៉ាក ឡាវែីញ

បន្ទាប់ពីក្រុមមេធាវី ខៀវ សំផន បានបញ្ចប់ការសួរសំណួររបស់ខ្លួន ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនចៅក្រមអន្តរជាតិ ហ្វង់ម៉ាក ឡាវែីញ សញ្ជាតិបារាំង ចោទសួរសំណួរមួយចំនួនទាក់ទងនឹងជំនួបរវាងសាក្សី និង ខៀវ សំផន នៅក្នុងអំឡុងទសវត្សរ៍៥០ ។ សូមបញ្ជាក់ថា ចៅក្រមអាចសួរសាក្សីទាំងសំណួរដែលអាចដាក់បន្ទុក និងសំណួរដែលដោះបន្ទុកដល់ជនជាប់ចោទទៅតាមអង្គហេតុ និងភស្តុតាងដែលមាន ។

សាក្សី ហ្គោលហ្វ្រេស បានឆ្លើយបញ្ជាក់ជូនលោកចៅក្រម ឡាវែីញ ដោយរៀបរាប់ថា នៅពេលជួបជាមួយ ខៀវ សំផន នៅទីក្រុងប៉ារីស ពុំមានការនិយាយគ្នាច្រើនអំពីបញ្ហានយោបាយទេ ប៉ុន្តែសាក្សីដឹងថា ខៀវ សំផន ពិតជាចង់ឲ្យប្រទេសកម្ពុជាវិវត្តន៍ទៅរករបបនយោបាយប្រជាធិបតេយ្យ សាធារណៈប្រជាមានិតដោយសន្សឹមៗ ពុំមែនដោយការធ្វើបដិវត្តដើម្បីផ្លាស់ប្តូរទេ ។ សាក្សីបន្តថា ការដែល ខៀវ សំផន ចូលប្រឡូកក្នុងចលនាកុម្មុយនីស្ត ពុំមែនដោយសារតែការគាំទ្រមនោគមវិជ្ជានេះទេ ប៉ុន្តែដោយសារប្រាថ្នាចង់ឲ្យប្រទេសកម្ពុជាមានការអភិវឌ្ឍ ធ្វើឲ្យលក្ខខណ្ឌជីវិត ជីវភាពប្រជាជនប្រសើរជាងមុន ។ បន្ទាប់ពីទទួលបានចម្លើយនេះ ចៅក្រម ឡាវែីញ បានសង្ខេបសម្តីរបស់ ខៀវ សំផន ដែលធ្លាប់បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសវនាការកាលពីឆ្នាំ២០១១ ដែលពេលនោះ ខៀវ សំផន បានអះអាងថា «នៅក្នុងប្រទេសបារាំង គាត់បានចូលរួមក្នុងវង់ម៉ាក្សស៊ីស ដោយសារមិត្តដែលរៀននៅវិទ្យាល័យស៊ីសុវត្ថិម្នាក់ ឈ្មោះ អ៊ុក សុគន្ធ បង្ខំឲ្យគាត់ចូលរួម ។ បន្ទាប់ គាត់ក៏យល់ព្រម ដោយសារតែមានការទទូចខ្លាំងពេក ដើម្បីកុំឲ្យ អ៊ុក សុគន្ធ ចាត់ទុកគាត់ជាមនុស្សកំសាក» ។ ចៅក្រម ឡាវែីញ បានសួរបញ្ជាក់សាក្សី ហ្គោល-ហ្វ្រេស ថា តើសាក្សីមានការភ្ញាក់ផ្អើលចំពោះការលើកឡើងបែបនេះ ដែរឬទេ? សាក្សីបានឆ្លើយតបចំពោះសំណួរនេះថា សាក្សីពុំមានការភ្ញាក់ផ្អើលចំពោះការលើកឡើងបែបនេះរបស់ ខៀវ សំផន ទេ ដោយសារនៅក្នុងទសវត្សរ៍៥០ មានតែបក្សកុម្មុយនីស្តទេ ដែលទទួលយកអ្នកនិយមឯករាជ្យមកពីប្រទេសក្រោមអាណានិគម ហើយនេះជាមធ្យោបាយតែមួយគត់ដែលអនុញ្ញាតឲ្យ ខៀវ សំផន អាចផ្សារភ្ជាប់ទៅនឹងបក្សកុម្មុយនីស្តបារាំង ។

សាក្សីរៀបរាប់អំពីប្រជាប្រិយភាពរបស់ ខៀវ សំផន ទៀតថា ខៀវ សំផន ជាមនុស្សមានប្រជាប្រិយ គួរជាទីគោរព ហ្មត់ចត់ និងស្មោះត្រង់ ។ សូម្បីនៅក្នុងសៀវភៅរបស់លោក ហ្វ្រង់ស័រ ប៉ុងសូដ៍ ដែលជាអ្នកនិពន្ធសៀវភៅ «កម្ពុជាឆ្នាំសូន្យ» ក៏បានសរសើរ ខៀវ សំផន ថាជាមនុស្សស្អាតស្អំ និងជាមនុស្សស្មោះត្រង់ ។

ចៅក្រម ឡាវែីញ បានបន្តសួរទៀតថា តើសាក្សីធ្លាប់បាននិយាយជាមួយ ខៀវ សំផន អំពី ការបាត់ខ្លួនលោក អ៊ិន សុកាន, អ៊ិន សុផាន់, តូច ខាំឌឿន និង ឌី ផុន ដែរឬទេ? សាក្សីបានជម្រាបចៅក្រមចំពោះចំណុចនេះថា សាក្សីគិតថា ខៀវ សំផន ពិតជាស្គាល់អ្នកទាំងអស់នេះ ព្រោះជាអ្នកដែលបានទៅសិក្សានៅប្រទេសបារាំង ប៉ុន្តែសាក្សីពុំដែលពិភាក្សាអំពីការបាត់ខ្លួនអ្នកទាំងនេះជាមួយ ខៀវ សំផន ទេ សាក្សីពិភាក្សាតែអំពីបញ្ហាគ្រួសារ និងបញ្ហាបុគ្គលផ្ទាល់ប៉ុណ្ណោះ ដោយសារគិតថា ជាការមិនសមរម្យដែលសួរ ខៀវ សំផន អំពីសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ចៅក្រម ឡាវែីញ បានបញ្ជាក់ប្រាប់សាក្សីវិញថា អ្វីដែលតុលាការចាប់អារម្មណ៍បំផុត គឺសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពុំមែនរយៈកាលមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យទេ ។ លោកចៅក្រមបានលើកឡើងថា ៖

«លោកមិនដឹងច្បាស់ថាអ្វីដែលយើងចាប់អារម្មណ៍បំផុតនៅទីនេះ គឺថារយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យនុ៎ងហើយ ។ ដូច្នេះប្រហែលជាលោកមានការខ្មាស់អៀនក្នុងការសួរលោក ខៀវ សំផន អំពីរបបនេះ ។ ក៏ប៉ុន្តែចំពោះយើង យើងចាប់អារម្មណ៍ទៅលើរបបនេះ» ។

បន្ទាប់មក ចៅក្រម ឡាវែីញ បានបន្តសួរអំពីស្ថានភាពក្រុមគ្រួសាររបស់ ខៀវ សំផន និង ឋានៈជាប្រមុខរដ្ឋរបស់ ខៀវ

សំផន ថាតើសាក្សីធ្លាប់ពិភាក្សាអំពីបញ្ហានេះជាមួយ ខៀវ សំផន ដែរឬទេ? សាក្សី ហ្គោលហ្វែស បានអះអាងថា សាក្សីពុំធ្លាប់ពិភាក្សាអំពីបញ្ហានេះជាមួយនឹង ខៀវ សំផន ទេ ប៉ុន្តែសាក្សីអាចធ្វើការសន្និដ្ឋានបានថា នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យស្ថានភាពក្រុមគ្រួសាររបស់ ខៀវ សំផន ពុំមានស្ថានភាពល្អប្រសើរជាងក្រុមគ្រួសារដទៃទៀតឡើយ ។ ឋានៈជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ ខៀវ សំផន ក៏ពុំខុសគ្នាពីស្ថានភាពរបស់សម្តេច នរោត្តម សីហនុ ដែរ ដែលជាតួនាទីមានតែនាម និងគ្មានអំណាច ។ សាក្សីបានលើកយកឧទាហរណ៍ជាក់ស្តែង ទាក់ទងនឹងប្រទេសចិន ដោយអះអាងថា នៅក្នុងពេលនៃការគ្រប់គ្រងរបស់ ម៉ៅ សេទុង ប្រធានាធិបតី ឈ្មោះ យូស៊ាវជី ត្រូវបានកម្ទេចដោយ ម៉ៅ សេទុង នៅក្នុងបដិវត្តន៍វប្បធម៌ ។ បច្ចុប្បន្ន គីម យុងណាម ជាប្រមុខរដ្ឋនៅប្រទេសកូរ៉េខាងជើង តាំងពីឆ្នាំ១៩៩៨មក ពុំមានអំណាចអ្វីឡើយ ព្រោះនៅក្នុងរដ្ឋធម្មនុញ្ញកូរ៉េខាងជើង ក៏ដូចជារដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីជាប្រមុខរដ្ឋ ឬប្រធានគណៈប្រធានរដ្ឋនេះ គ្រាន់តែជាតួនាទីតំណាងក្នុងការទទួលឯកអគ្គរដ្ឋទូតបរទេសតែប៉ុណ្ណោះ ។ ប៉ុន្តែ ការលើកឡើងដូច្នេះ ត្រូវបានចៅក្រម ឡាវ៉ែញ ចាត់ទុកថាគ្រាន់តែជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់សាក្សីតែប៉ុណ្ណោះ ។ បន្ទាប់មក លោកចៅក្រមបានសួរថា តើសាក្សីធ្លាប់បានពិភាក្សាជាមួយ ខៀវ សំផន អំពីតួនាទីជាប្រមុខរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ ខៀវ សំផន ដែរឬទេ? សាក្សីបានទទួលស្គាល់ថា ខ្លួនពុំធ្លាប់ពិភាក្សាស៊ីជម្រៅអំពីចំណុចនេះទេ ហើយខ្លួនក៏ពុំបានដឹងអំពីជីវិតរបស់ ខៀវ សំផន នៅចន្លោះឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ដែរ ។

ចៅក្រម ឡាវ៉ែញ បានបន្តសួរទាក់ទងនឹងការតាក់តែងរដ្ឋធម្មនុញ្ញ និងសេចក្តីថ្លែងសុន្ទរកថារបស់ ខៀវ សំផន ទាក់ទងនឹងបទខុទ្ទេសនាមអំពីរដ្ឋធម្មនុញ្ញជូនប្រជាជាតិកម្ពុជា ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី ហ្គោលហ្វែស បានធ្វើការសន្និដ្ឋានទៀតថា ជាទូទៅ សុន្ទរកថារបស់ប្រមុខរដ្ឋ ពុំត្រូវបានសរសេរដោយប្រមុខរដ្ឋខ្លួនឯងទេ សូម្បីសុន្ទរកថារបស់ស្តេចអង់គ្លេស ក៏រដ្ឋាភិបាលជាអ្នកសរសេររៀបចំឲ្យដែរ ពុំមែនព្រះមហាក្សត្រជាអ្នកសរសេរដោយផ្ទាល់ព្រះអង្គទេ ។ ចំណែកឯតួនាទីក្នុងការរៀបចំតាក់តែងរដ្ឋធម្មនុញ្ញវិញ ខ្លួនពុំមានព័ត៌មានលម្អិតអំពីបញ្ហានេះទេ ។

ចំពោះសំណួររបស់ចៅក្រម ឡាវ៉ែញ ទាក់ទងនឹងមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សី ហ្គោល-ហ្វែស បានបញ្ជាក់ថា ខៀវ សំផនពុំដែលនិយាយប្រាប់សាក្សីអំពីមូលហេតុនៃការជម្លៀសនេះទេ ប៉ុន្តែសាក្សីយល់ថា ការជម្លៀសនេះធ្វើឡើងដោយសារមូលហេតុចាំបាច់ខាងផ្នែកសេដ្ឋកិច្ច ព្រោះទីក្រុងភ្នំពេញអស់ស្បៀងអាហារដើម្បីប្រើប្រាស់ ដូច្នេះប្រជាជនត្រូវតែត្រឡប់ទៅផលិតស្បៀងឡើងវិញ ។ ប៉ុន្តែសាក្សី បានទទួលស្គាល់ថា ការជម្លៀសនៅពេលនោះ ពិតជាមានសភាពគួរឲ្យអាណោចអាធ័មជាពុនពេកណាស់ ។

## ៤) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ សញ្ជាតិបារាំង លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាជូនដើម្បីសួរដេញដោលសាក្សី ហ្គោលហ្វែស ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ។ ជាដំបូង សហព្រះរាជអាជ្ញាបានស្នើឲ្យសាក្សីបញ្ជាក់អំពីហេតុផលដែលនាំឲ្យមានការចូលមកផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ ខៀវ សំផន ។ ឆ្លើយតបចំពោះសំណួរនេះ សាក្សី ហ្គោលហ្វែស បានរៀបរាប់ថា សាក្សីចូលមកផ្តល់សក្ខីកម្មដោយសារតែនៅឆ្នាំ២០១០ មានមេធាវីអន្តរជាតិរបស់ ខៀវ សំផន លោក ហ្សាក់ វែកហ្សេស បានមកទាក់ទង ដើម្បីចូលរួមផ្តល់សក្ខីកម្មគាំទ្រ ខៀវ សំផន ។ បន្ទាប់មកមួយសប្តាហ៍មុនចូលមកផ្តល់សក្ខីកម្មនេះ មេធាវី ខៀវ សំផន មួយរូបទៀត លោក អាកទួរ វែកគែន ក៏បានទាក់ទងខ្លួនដើម្បីជូនដំណឹងអំពីការបើកសវនាការទាក់ទងនឹងអត្តចរិតរបស់ ខៀវ សំផន ។ សាក្សីបន្តថា ការចូលមកផ្តល់សក្ខីកម្មដើម្បីគាំទ្រ ខៀវ សំផន នៅពេលនេះ គឺដោយសារតែទំនាក់ទំនងជាមិត្តភាព និងការគោរពសរសើរចំពោះ ខៀវ សំផន ។ ទោះបីជាយ៉ាងណាក្តី សាក្សី ហ្គោលហ្វែស បានទទួលស្គាល់ថា ចាប់តាំងពីឆ្នាំ១៩៦៧ នៅពេល ខៀវ សំផន រត់ចូលព្រៃរហូតដល់ឆ្នាំ១៩៩០ ដែលមានរយៈកាលជាង២៣ឆ្នាំ សាក្សីពុំដែលបានទាក់ទងនឹងជាមួយនឹង ខៀវ សំផន ទេ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ បានលើកយកសេចក្តីថ្លែងសុន្ទរកថារបស់ ខៀវ សំផន ទាក់ទងនឹងរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅត្រង់ជំពូកដែលនិយាយអំពីការគោរពប្រតិបត្តិសាសនា ដែលមានចែងនៅក្នុងមាត្រា២០ ដើម្បីស្នើឲ្យសាក្សីធ្វើការបញ្ជាក់បន្ថែម ។ នៅក្នុងសេចក្តីថ្លែងនោះ ខៀវ សំផន បានលើកឡើងថា ៖

“ប្រជាជនយើងមានសិទ្ធិប្រកាន់ជំនឿ សាសនាអ្វីក៏បានឲ្យតែខ្លួនពេញចិត្ត និងមានសិទ្ធិ មិនប្រកាន់ជំនឿសាសនាអ្វីក៏បាន គឺជាសេរីភាពនៃប្រជាជនយើង ។ លើសពីនេះទៅទៀត ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញយើង ជំហររបស់យើងមិនត្រូវអនុញ្ញាតឲ្យពួកចក្រពត្តិ បរទេសណាមួយប្រើប្រាស់សាសនាដើម្បីធ្វើវិទ្ធង្សនាមកលើយើងទេ ។ យើងប្តេជ្ញាវាយប្រយុទ្ធពួកគេ ទោះបីជាប្រើរូបភាពលាក់បាំងអ្វីក៏ដោយ ពួកចក្រពត្តិនិយមស្វែងរកមធ្យោបាយវាយប្រហារយើង ។ ពួកគេប្រើសាសនាជារូបភាពលាក់បាំងមួយ ដើម្បីជ្រៀតចូលក្នុងប្រទេសយើង ។ ដូច្នេះ យើងគួរតែប្រឆាំងនឹងពួកគេ ទោះបីជាក្នុងកាលៈទេសៈណាក្តី ។”

ទាក់ទងនឹងបញ្ហានេះ តំណាងសហព្រះរាជអាជ្ញាបានសួរសាក្សីថា តើនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ធ្លាប់បានពិភាក្សាអំពីបញ្ហាសាសនាដែរឬយ៉ាងណា? ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា សាក្សីពុំបានចាំថាបានពិភាក្សាអំពីបញ្ហាសាសនា ឬក៏ពុំមាននោះទេ ។ ប៉ុន្តែបើតាមការយល់ឃើញរបស់សាក្សី ការលើកឡើងរបស់ ខៀវ សំផន មានលក្ខណៈត្រឹមត្រូវ ដោយសារក្នុងអំឡុងពេលនោះ មានអ្នកដើរផ្សព្វផ្សាយសាសនាមួយចំនួនជាភ្នាក់ងារសម្ងាត់ សេ.អ៊ី.អា ដែលចេះនិយាយភាសាខ្មែរ ។

តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ បានបន្តសួរសាក្សី ហ្គោលហ្វ្រែស ទាក់ទងនឹងសុន្ទរកថា របស់ ខៀវ សំផន ដែលនិយាយអំពីជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នៅក្នុងសុន្ទរកថា នោះ ខៀវ សំផន បាននិយាយថា ៖

“យើងត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍គ្រប់ពេលវេលា ប្រឆាំងនឹងសត្រូវពីគ្រប់ទិសទី ទាំងនៅក្នុង និងក្រៅប្រទេស ដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ ការពាររដ្ឋបាលកម្មករ កសិករ និងរក្សាឲ្យបាននូវសមិទ្ធិផលនៃបដិវត្តន៍យើងជាដាច់ខាត និងជាអចិន្ត្រៃយ៍ ។”

ចំពោះការលើកឡើងនេះ សាក្សី ហ្គោលហ្វ្រែស បានសន្និដ្ឋានថា រាប់សតវត្សរ៍មកហើយ ដែលប្រទេសកម្ពុជាបានក្លាយជាចំណីរបស់វៀតណាម និងថៃ ។ ប៉ុន្តែ នៅក្នុងរយៈកាលណាមួយនោះ វៀតណាម ដែលគាំទ្រដោយសហភាពសូវៀតបានដណ្តើមយកប្រទេសកម្ពុជា ។ ហេតុដូច្នេះ ខ្មាំងខាងក្រៅដែល ខៀវ សំផន បានលើកឡើង ប្រហែលជាចង់សំដៅលើវៀតណាម ហើយខ្មាំងផ្ទៃក្នុង សំដៅលើខ្មែរដែលធ្លាប់ទៅវៀតណាមខាងជើងដើម្បីទទួលការបណ្តុះបណ្តាលអប់រំ ដែលក្រោយមកត្រូវបានដុះខាត់លាងខួរក្បាល ។

ទាក់ទងនឹងចំនួនមនុស្សដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរយៈកាលនោះ សាក្សី ហ្គោលហ្វ្រែស បានបញ្ជាក់ថា នៅអំឡុងទសវត្សរ៍៨០ នាយករដ្ឋមន្ត្រីវៀតណាមបានធ្វើដំណើរទៅទីក្រុងប៉ារីសដើម្បីចូលរួមក្នុងកិច្ចប្រជុំមួយរៀបចំឡើងដោយស្ថាប័នមួយរបស់បារាំង ។ នៅពេលនោះ នាយករដ្ឋមន្ត្រីវៀតណាមបាននិយាយថា ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតមានចំនួន៣លាននាក់ ។ សាក្សីយល់ថា ការលើកឡើងរបស់នាយករដ្ឋមន្ត្រីវៀតណាមនៅត្រង់ចំណុចនេះ ជាការបំប៉ោងតួលេខនៃ មនុស្សដែលបានស្លាប់ ដើម្បីបង្ហាញថា ការចូលវាយចូលប្រទេសកម្ពុជារបស់ខ្លួនជារឿងត្រឹមត្រូវ ។ សាក្សី ហ្គោលហ្វ្រែស បានបន្តទៀតថា នៅចន្លោះពីឆ្នាំ១៩៧០ ដល់១៩៧៥ មានប្រជាជនស្លាប់ដោយសារតែសង្គ្រាមស៊ីវិល និងការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ បន្ទាប់មក នៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ មានអ្នកដែលត្រូវបានកម្ទេច អ្នកខ្លះស្លាប់ដោយសារខ្វះថ្នាំសង្កូវ និងអ្នកខ្លះ ស្លាប់ដោយសារវៀតណាមឈ្លានពានប្រទេសកម្ពុជានៅខែមករា ឆ្នាំ១៩៧៩ ហើយអ្នកដែលរត់គេច ខ្លួនខ្លះត្រូវបានសម្លាប់ និងខ្លះទៀតបានរត់ជាន់មីនស្លាប់ ។ ដូច្នេះចំនួនអ្នកស្លាប់ពុំមានតួលេខច្បាស់លាស់ទេ ដោយសារអ្នកស្លាប់នៅអំឡុងពេលនោះមានមូលហេតុផ្សេងៗគ្នាជាច្រើន ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា

វ៉ាំងសង់ ទាក់ទងនឹងការពិភាក្សាអំពីការស្លាប់របស់ប្រជាជននៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីបានបញ្ជាក់ថា ក្នុងអំឡុងពេលជួបជាមួយនឹង ខៀវ សំផន ក្រោយឆ្នាំ១៩៧៩ សាក្សីពុំដែលលើកឡើងអំពីការស្លាប់នៃប្រជាជនខ្មែរក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹង ខៀវ សំផន ទេ។ លោក វ៉ាំងសង់ បានសួរទៀតថា "ចំពោះលោកសាក្សីផ្ទាល់ដែលពុំមែនជាជនរងគ្រោះនៃរបបនេះ ប៉ុន្តែពុំព្រមនិយាយអំពីបញ្ហាមនុស្សស្លាប់នៅពេលនោះជាមួយ ខៀវ សំផន ដែលជាប្រមុខរដ្ឋ តើលោកសាក្សីពុំមានអារម្មណ៍ថា ក្បត់សតិសម្បជញ្ញៈខ្លួនឯងទេឬ?" សាក្សីហាក់បីដូចជាពុំពេញចិត្តនឹងសំណួរនេះទេ ប៉ុន្តែទោះបីជាយ៉ាងណាក្តីលោកបានបញ្ជាក់ថា ដោយសារតែគាត់មានបញ្ហាជាច្រើនទៀតដែលត្រូវនិយាយជាមួយ ខៀវ សំផន ហើយពេលវេលាស្នាក់នៅប្រទេសកម្ពុជានៅពេលនោះក៏មានរយៈពេលខ្លី ។ សាក្សីបានបញ្ជាក់ចុងក្រោយថា នេះជាចេតនារបស់គាត់តែម្តងដែលពុំចង់លើកយកបញ្ហានេះមកនិយាយជាមួយ ខៀវ សំផន។

ចុងក្រោយសាក្សី ហ្គោលប្រែហ្វ បានបញ្ជាក់ថា បើតាមការសង្កេតនៅពេលធ្វើដំណើរមកកម្ពុជាប្រជាជន ដែលរស់នៅតាមតំបន់ព្រំដែន ជាពិសេសនៅតំបន់អន្លង់វែង នៅតែសម្តែងនូវសមានចិត្ត និងគោរពចំពោះ ខៀវ សំផន ហើយពុំមានការជេរប្រទេចអ្វីឡើយ ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបញ្ចប់ការសួរដេញដោល អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចោទសួរសាក្សី ហ្គោលប្រែហ្វ អំពីអត្តចរិតរបស់ ខៀវ សំផន។

គួរកត់សម្គាល់ថា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានសំណួរច្រើនដើម្បីចោទសួរលើសាក្សី ហ្គោលប្រែហ្វ ទេ ប៉ុន្តែ បានធ្វើការកត់សម្គាល់ខ្លីទាក់ទងនឹងសក្ខីកម្មរបស់សាក្សីរូបនេះថា ការលើកឡើងរបស់សាក្សីនៅក្នុងសវនាការ ពុំមានសារៈប្រយោជន៍សម្រាប់តុលាការទេ ដោយសារតែសាក្សីពុំបានដឹងពីតួនាទីពិតប្រាកដរបស់ ខៀវ សំផន នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ប៉ុន្តែ ការកត់សម្គាល់នេះ ត្រូវបានជំទាស់ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ដោយអះអាងថា ជាការពុំសមរម្យ ពីព្រោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសឲ្យសួរសំណួរតែប៉ុណ្ណោះ ពុំមែនផ្តល់ឱកាសឲ្យដើម្បីធ្វើសេចក្តីសន្និដ្ឋាននោះទេ ។

ការស្តាប់សក្ខីកម្មរបស់សាក្សី ហ៊ីលីព ហ៊្វូលប្យាន-ហ្គោលប្រែហ្វ បានបញ្ចប់នៅរសៀលថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ ។



*អៀង សារី (ទីបួនរាប់ពីស្តាំ) កំពុងជួបពិភាក្សាជាមួយគណៈប្រតិភូបរទេស ។ អង្គុយខាងស្តាំដៃ អៀង សារី គឺ ជួន ប្រាសិទ្ធិ ជាអ្នកបកប្រែភាសាអង់គ្លេស-ខ្មែរ និង សាឡុត បាន ជាអគ្គលេខាធិការនៃក្រសួងការបរទេស និងជាក្មួយបង្កើតរបស់ ប៉ុល ពត ។*

# សវនាការស្តាប់សក្ខីកម្មសាក្សី ចៅ សុគុណ

## ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣

នៅរសៀលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការ កោះហៅសាក្សីម្នាក់ទៀតឈ្មោះ ចៅ សុគុណ នៅពេលរសៀលបន្ទាប់ពីបញ្ចប់ការសួរដេញដោលសាក្សី ហ្វីលីព ហ្ស៊ីលប្បាន-ហ្គោលហ្វ្រែស នៅពេលព្រឹក ។ សវនាការសួរដេញដោលលើសាក្សីរូបនេះ ត្រូវបានប្រព្រឹត្តទៅតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង ។ ការសួរដេញដោលនេះបានប្រព្រឹត្តទៅដោយចាប់ផ្តើម ដោយប្រធានអង្គជំនុំជម្រះសួរទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សីព្រមទាំងណែនាំអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សីក្នុងការចូលរួមក្នុងនីតិវិធីសវនាការ ។ បន្ទាប់មក វេទិកានេះត្រូវបានផ្ទេរជូនក្រុម មេធាវីការពារក្តី (ដោយសារតែសាក្សីត្រូវបានស្នើឡើងដោយមេធាវីការពារក្តី) សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ គួរបញ្ជាក់ថា សវនាការស្តាប់សក្ខីកម្មសាក្សី ចៅ សុគុណ នេះ ក្រុមមេធាវីការពារក្តី នួន ជា ពុំមានសំណួរចោទសួរសាក្សីទេ ដោយសារសក្ខីកម្មនេះ បានផ្តោតសំខាន់តែទៅលើអត្តចរិត និងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ប៉ុណ្ណោះ ។

ឆ្លើយតបនឹងសំណួរមួយចំនួនរបស់ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន សាក្សីបានបញ្ជាក់ថា សាក្សីមានអាយុ៦៧ឆ្នាំ មានឪពុកឈ្មោះ ចៅ កាន និងម្តាយឈ្មោះ នាង ជ្រុន ហើយសព្វថ្ងៃសាក្សីបានចូលនិវត្តពីការងារនៅក្នុងរោងពុម្ព និងការងារផ្សេងៗទៀត ។

### ១) ការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន

ជាដំបូង សហមេធាវីជាតិ គង់ សំអុន បានសួរសាក្សីអំពីប្រវត្តិនៃការអប់រំ ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានបញ្ជាក់ថា សាក្សីកើតនៅក្នុងឆ្នាំ១៩៤៦នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក ។ កាលពីនៅអាយុ៧ឆ្នាំ សាក្សីបានទៅរៀននៅក្នុងវត្តមួយស្ថិតក្នុងស្រុកស្វាយទងរហូតដល់ឆ្នាំ១៩៥៨ សាក្សីបានមករៀនថ្នាក់អនុវិទ្យាល័យថ្នាក់ទី៦នៅសាលាគរុកោសល្យ ។ ក្រោយមក សាក្សីបានបន្តមករៀននៅវិទ្យាល័យស៊ីសុវត្ថិ និងបានសិក្សានៅមហាវិទ្យាល័យវិទ្យាសាស្ត្រជាបន្តបន្ទាប់បានតែ១ឆ្នាំ សាក្សីក៏ទទួលបានអាហារូបករណ៍ទៅរៀននៅប្រទេសបារាំង ផ្នែកសេដ្ឋកិច្ច ។ ក្រោយមក សាក្សីបានបន្តរស់នៅទីនោះរហូតហើយធ្លាប់ត្រឡប់មកប្រទេសកម្ពុជាវិញតែម្តងគត់នៅឆ្នាំ២០០២ ។

បន្ទាប់មក មេធាវីបានបន្តសួរអំពីទស្សនៈនយោបាយដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សី សុគុណ បានរៀបរាប់ថា នៅពេលគាត់រៀននៅថ្នាក់អនុវិទ្យាល័យ សាក្សីមានការចាប់អារម្មណ៍ចំពោះបញ្ហាសង្គមនៅក្នុងប្រទេសកម្ពុជា ពេលបានស្តាប់ពួកសិស្សច្បងនិយាយគ្នា ។ ទាក់ទងនឹងពាក្យ “ចម្រើននិយម” សាក្សីបានពន្យល់ថា ពាក្យនោះសំដៅទៅលើយុត្តិធម៌នៅក្នុងសង្គមរវាងអ្នកតូចតាច


ចៅ សុគុណ

និងអ្នកមានអំណាច ។ សាក្សី ចៅ សុគុណ បានបន្តរៀបរាប់អំពីថា ក្រោយពេលមានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ សាក្សីបានចូលរួមគាំទ្ររណសិរ្សមួយនៅឯប្រទេសបារាំងដោយសារមូលហេតុពីរយ៉ាង៖ ទី១) ដោយសាររដ្ឋប្រហារនោះធ្វើឡើងដោយមានសហរដ្ឋអាមេរិកនៅពីក្រោយ និងទី២) ព្រឹត្តិការណ៍នោះអាចនាំឲ្យមានសង្គ្រាមកើតឡើង ។ រណសិរ្សនោះ ដឹកនាំដោយសម្តេច នរោត្តម សីហនុ នៅក្នុងប្រទេសកម្ពុជាចំណែក

នៅប្រទេសបារាំងវិញដឹកនាំដោយលោក អ៊ិន សូកាន ។ សាក្សីបានបន្តថា គាត់បានជួប ខៀវ សំផន នៅទីក្រុងប៉ិយការ៉េស ប្រទេសរ៉ូម៉ានីខណៈពេលដែល ខៀវ សំផន បានដឹកនាំគណៈប្រតិភូមួយក្រុមទៅធ្វើទស្សនកិច្ចនៅទីនោះក្នុងឆ្នាំ១៩៧៤ ។ ក្នុងពេលធ្វើទស្សនកិច្ចនោះ ខៀវ សំផន បាននិយាយអំពីរឿងរ៉ាវនៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងផលប៉ះពាល់ទៅលើប្រជាជនកម្ពុជា ។ ដូច្នេះ ដើម្បីបញ្ចប់សង្គ្រាម ខៀវ សំផន បានអំពាវនាវឲ្យខ្មែរចេះរួមសាមគ្គីប្រមូលកម្លាំងឲ្យបានច្រើនដើម្បីទុករបប លន់ នល់ ឲ្យនៅឯកា ។ ចំពោះព្រឹត្តិកាណ៍នៅថ្ងៃទី១៧ មេសា សាក្សីបានបញ្ជាក់ថា នោះជាព្រឹត្តិការណ៍ដែលមិនគួរឲ្យស្មានដល់ដោយសារហេតុការណ៍នោះបានកើតឡើងលឿន ក្នុងរយៈពេលដ៏ខ្លី ។

## តួនាទីរបស់ ខៀវ សំផន

មេធាវីជាតិ គង់ សំអុន បានបន្តសំណួរមួយចំនួនទាក់ទងនឹងនិក្ខេបបទថ្នាក់បណ្ឌិតរបស់ ខៀវ សំផន ដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សី ចៅ សុគុណ បានរៀបរាប់ថា នៅពេលទៅដល់ប្រទេសបារាំង គាត់បានអាននិក្ខេបបទរបស់ ខៀវ សំផន ដោយសារពាក់ព័ន្ធនឹងផ្នែកសេដ្ឋកិច្ចដែលសាក្សីសិក្សានៅទីនោះ ។ តាមរយៈនិក្ខេបបទនោះ ខៀវ សំផន ចង់ឲ្យកម្ពុជាមានការរីកចម្រើនដោយផ្អែកលើវិស័យកសិកម្មជាធំ ។ តាមរយៈនេះ ខៀវ សំផន ជាមនុស្ស ដែលស្រឡាញ់យុត្តិធម៌ និងស្រឡាញ់លិទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន សាក្សីបានរៀបរាប់ថា នៅក្នុងរបបសង្គមរាស្ត្រនិយម ខៀវ សំផន បានឈរឈ្មោះជាតំណាងរាស្ត្រដែលមានគោលជំហរប្រឆាំងនឹងអំពើពុករលួយ ដែលមានការគាំទ្រជាច្រើនពីអ្នកដែលមានឋានៈតូចតាច អ្នកធាក់រ៉ឺម៉ក អ្នកធាក់ស៊ីក្លូជាដើម ។ ប៉ុន្តែ នៅឆ្នាំ១៩៦៧ សាក្សីបាន ឮពាក្យចចាមអារ៉ាមថា ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានយកទៅសម្លាប់នៅក្នុងអាងទឹកអាស៊ិត ហើយក៏បាត់ដំណឹងឈឹងតែម្តង ។ ក្រោយមកសាក្សីមានការភ្ញាក់ផ្អើល ដោយសារបានឃើញអ្នកទាំងបីទៅទទួលសម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៧៣ ។ សាក្សីបានបន្ថែមថា បន្ទាប់ពីនោះមក សាក្សីនៅតែមានការចាប់អារម្មណ៍ចំពោះ ខៀវ សំផន ដែលជាមនុស្សស្រឡាញ់យុត្តិធម៌ ។ សាក្សីបានបន្តថា នៅពេលបានជួប ខៀវ សំផន នៅប៉ិយការ៉េស ក្នុងឆ្នាំ១៩៧៤ ខៀវ សំផន មានតួនាទីជារដ្ឋមន្ត្រីក្រសួងការពារជាតិ ប៉ុន្តែដោយសារប្រជាប្រិយភាព ខៀវ សំផន ទទួលបន្ទុកការងារច្រើនខាងទំនាក់ទំនងការទូត ។ មេធាវីជាតិបានបន្តសួរដើម្បីឲ្យសាក្សីពន្យល់អំពីភាពខុសគ្នារវាងខ្មែរក្រហម និងរណសិរ្សរួបរួមជាតិកម្ពុជា ។ សាក្សី ចៅ សុគុណ បានពន្យល់ថា សាក្សីពុំបានដឹងទាក់ទងនឹងខ្មែរក្រហមទេ ប៉ុន្តែគ្រាន់តែដឹងថា រណសិរ្សរួបរួមជាតិកម្ពុជា ជាក្រុមប្រឆាំងនឹងសហរដ្ឋអាមេរិក និងរបប លន់ នល់ ។ ម្យ៉ាងទៀត នៅពេលនោះពុំទាន់ស្គាល់បក្សកុម្មុយនីស្តកម្ពុជានៅឡើយទេ ។ ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីបានបញ្ជាក់ថា ក្រោយពេលដែលសម្តេច នរោត្តម សីហនុ បានលាលែងពីតំណែង ខៀវ សំផន ត្រូវបានតែងតាំងជំនួសទ្រង់ជាប្រធានគណៈប្រធានរដ្ឋវិញ ។ សាក្សី សុគុណ បានបញ្ជាក់ថា ក្រោយឆ្នាំ១៩៧៤ សាក្សីបានជួប ខៀវ សំផន បីលើកទៀត ជំនួបលើកទី២ នៅប្រទេសបារាំងខណៈដែល ខៀវ សំផន បានដឹកនាំគណៈប្រតិភូទៅរៀបចំចរចាកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។ ជំនួបលើកទី៣ ធ្វើនៅប្រទេសកម្ពុជាខណៈពេលសាក្សីបានទៅចូលរួមពិធីបុណ្យមួយរបស់មិត្តភក្តិ និងលើកទី៤នៅអន្លង់វែង ។ បន្ទាប់មក មេធាវីបានបន្តសួរឲ្យសាក្សីពន្យល់អំពីព្រឹត្តិការណ៍នៃការប្រមូលនិស្សិតខ្មែរដែលរស់នៅឯបរទេសឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានរៀបរាប់ថា ក្រោយពេលខ្មែរក្រហមចូលកាន់អំណាចនៅថ្ងៃទី១៧មេសា ពុំមានការបង្ខិតបង្ខំដល់និស្សិត បញ្ញវន្ត ឲ្យត្រឡប់មកស្រុកខ្មែរឡើយ ។ ផ្ទុយទៅវិញ អ្នកដែលចង់ត្រឡប់មកវិញត្រូវតែដាក់ពាក្យសុំ ។ សាក្សីផ្ទាល់ ក៏បានដាក់ពាក្យសុំត្រឡប់មកប្រទេសកម្ពុជាដែរ ប៉ុន្តែមិនបានទទួលការឆ្លើយតប ។ ម្យ៉ាងទៀត សាក្សីក៏មិនបានដឹងថា អ្នកណាជាអ្នកមានសិទ្ធិសម្រេចលើការជ្រើសរើសបេក្ខជនណាមួយដែរ ។ ចំពោះសំណួរចុងក្រោយ មេធាវីបានស្នើឲ្យសាក្សីបញ្ជាក់អំពីអត្តចរិតរបស់ ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា ដើម្បីបន្ថែមលើអ្វីដែលបានរៀបរាប់នោះ មានតែការសួរនាំពីប្រជាជនកម្ពុជាផ្សេងទៀតប៉ុណ្ណោះ ពីព្រោះការសួរ

មនុស្សតែមួយចំនួនតូចមិនអាចយកជាការបានទេ ។

### ២) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវីញ

ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានផ្តើមសំណួរទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះ ខៀវ សំផន មាននាទីជាប្រមុខរដ្ឋ ប៉ុន្តែការងាររចម្បងទាក់ទងនឹងផ្នែកការទូត ។ ចំណែកប្រភពព័ត៌មានអំពី ខៀវ សំផន សាក្សីទទួលបានតាមរយៈកាសែត និងមិត្តភក្តិដែលបានជួប ខៀវ សំផន ខណៈពេលធ្វើទស្សនកិច្ចទៅប្រទេសផ្សេងៗ ។ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងការសម្លាប់រង្គាល ដែលកើតឡើងចំពោះប្រជាជនកម្ពុជាវិញ សាក្សី ចៅ សុគុណា បានរៀបរាប់ថា សាក្សីធ្លាប់អានសៀវភៅរបស់អ្នកនិពន្ធ ហ្វ្រង់ស័រ ប៉ុនសូដ៍ ប៉ុន្តែពុំដែលបានសួរនាំដោយផ្ទាល់ទៅ ខៀវ សំផន ទាក់ទងនឹងបញ្ហានេះទេ ។ ចៅក្រម ឡាវីញ បានបន្តសួរទាក់ទងនឹងតួនាទីរបស់សាក្សីខណៈពេលដែលសាក្សីកំពុងចូលរួមគាំទ្ររាជរដ្ឋាភិបាលរួបរួមជាតិ ។ សាក្សី ចៅ សុគុណា បានឆ្លើយតបថា នៅពេលនោះ សាក្សីជាសកម្មជនរបស់សមាគម "ហ្វុង" (FUNK) ។ សាក្សីបានបន្តថា ចាប់ពីឆ្នាំ១៩៧៦មក សាក្សីមិនបានទទួលពត៌មានទំលំទូលាយពាក់ព័ន្ធនឹងប្រទេសកម្ពុជាទេ ។ ក្រោយពេលមានការរំដោះនៅឆ្នាំ១៩៧៩ សុគុណា បានជួបមិត្តភក្តិមួយចំនួនដែលបានចាកចេញពីប្រទេសបារាំងមកនៅកម្ពុជា ប្រាប់អំពីរឿងរ៉ាវដែលអ្នកទាំងនោះបានរត់គេចពីការចូលមកដល់នៃកងទ័ពវៀតណាម ។ សាក្សីបានបន្តថា នៅក្នុងចំណោមនោះ អ្នកខ្លះបាត់ខ្លួន អ្នកខ្លះទៅនៅក្នុងមន្ទីរបឹងត្របែក ហើយខ្លះទៀតក៏បានត្រឡប់ទៅនៅប្រទេសបារាំងវិញ ។ ចំណែកព័ត៌មានដែលទាក់ទងនឹងមន្ទីរស-២១ សាក្សីបានដឹងតាមកាសែតផ្សេងៗប៉ុណ្ណោះ ។ បន្ទាប់មកចៅក្រម ឡាវីញ បានសួរសំណួរទាក់ទងនឹងមូលហេតុ ដែលនាំឲ្យសាក្សីដាក់ពាក្យត្រឡប់មកប្រទេសកម្ពុជាវិញ ។ សាក្សី ចៅ សុគុណា បានបញ្ជាក់ថា គាត់មានបំណងត្រឡប់មកវិញដោយសារចង់ចូលរួមបម្រើប្រទេសជាតិ និងដោយសារចង់ជួបជុំគ្រួសារបន្ទាប់ពីបែកគ្នាអស់រយៈពេលជាយូរមក ។ សំណួរចុងក្រោយទាក់ទងនឹងព័ត៌មានអំពីលោក ចៅ សេង ។ សាក្សី សុគុណា បានរៀបរាប់ថា សាក្សី បានជួបលោក ចៅ សេង ដែលបានទៅរៀននៅប្រទេសបារាំង និងជាអ្នកដែលគាំទ្រលទ្ធិប្រជាធិបតេយ្យមួយរូបព្រមទាំងមានទំនាក់ទំនងជាមួយ ខៀវ សំផន ដែរ ។ ប៉ុន្តែ ក្រោយមក សាក្សីពុំបានទទួលព័ត៌មានទាក់ទងនឹងលោក ចៅ សេង ទៀតទេ ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រ៉េយ៍ន័រ បានផ្តើមសំណួរទាក់ទងនឹងព័ត៌មានអំពីការសម្លាប់មនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ សាក្សី ចៅ សុគុណា បានរៀបរាប់ថា នៅចន្លោះពេលនោះ សាក្សីបានទទួលដំណឹងតិចតួចតាមរយៈព័ត៌មានប៉ុណ្ណោះ ដោយសារនៅពេលនោះដំណឹងនៅក្នុងប្រទេសកម្ពុជាត្រូវបានបិទជិត ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា បានបង្ហាញឯកសារដែលសរសេរថា "គណៈកម្មការអ្នកស្នេហាជាតិបានបោះពុម្ព និងផ្សព្វផ្សាយនូវឯកសារដូចជា រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ការផ្សាយរបស់វិទ្យុភ្នំពេញ សន្ទរកថារបស់ ប៉ុល ពត សុន្ទរកថារបស់ អៀង សារី សន្ទរកថារបស់ ខៀវ សំផន និងទស្សនាវដ្តី វិចារណកថា ប្រចាំសប្តាហ៍" ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបញ្ជាក់ថា ពុំធ្លាប់បានដឹងអំពីឯកសារដូចដែលតំណាងសហព្រះរាជអាជ្ញាបានរៀបរាប់នោះទេ ។ ប៉ុន្តែសាក្សីដឹងអំពីឯកសារផ្សេងៗទៀតដែលបានចាក់ផ្សាយ ហើយឯកសារទាំងនោះត្រូវបានផ្ញើតាមប្រៃសណីយ៍មកឲ្យស្ថានទូតកម្ពុជាប្រជាធិបតេយ្យ ដែលតាំងទីនៅទីក្រុងប៉េកាំង ទើបសមាគមរបស់គាត់បានយកមកផ្សព្វផ្សាយ ។ ចំណែកព័ត៌មានទាន់ហេតុការណ៍ពីប្រទេសកម្ពុជាវិញ សាក្សីបានបញ្ជាក់ថា នៅពេលនោះព័ត៌មានមិនអាចទទួលបានភ្លាមៗទេ ដោយសារព័ត៌មានត្រូវផ្ញើតាមប្រៃសណីយ៍ដែលត្រូវចំណាយពេលច្រើនថ្ងៃ ។ ពាក់ព័ន្ធនឹងគណៈកម្មការអ្នកស្នេហាជាតិវិញ សាក្សីបានបញ្ជាក់ថា គណៈកម្មការនោះជាសមាគម ដែលសាក្សីក៏ជាសមាជិកមួយរូបនៅក្នុងប្រទេសបារាំងដែរ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានបន្តដកស្រង់នៅក្នុងឯកសារសន្ទរកថារបស់ ខៀវ សំផន កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៨ នៅពេលបំពេញទស្សនកិច្ចទៅប្រទេសរ៉ូម៉ានី ដែលនិយាយអំពីជ័យជម្នះលើការកំចាត់ខ្មាំងនៅខត្តគុ ។ សាក្សី ចៅ សុគុណា បាន

បដិសេធថា សាក្សីពុំធ្លាប់បានទទួលព័ត៌មានទាំងនោះទេ ។

ទាក់ទងនឹងគោលនយោបាយនៃការចាប់ចងផ្សេងៗ សាក្សីបានបញ្ជាក់ថា ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន មិនអាចអនុវត្តគោលនយោបាយនេះដោយផ្ទាល់ទេ ។ ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅមន្ទីរ៨៧០វិញ សាក្សីបញ្ជាក់ថា សាក្សីពុំដែលបានដឹងអំពីព័ត៌មាននេះទេ ហើយសាក្សីក៏ពុំបានដឹងអំពីតួនាទីរបស់មន្ទីរ៨៧០ដែរ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរជាច្រើនទាក់ទងនឹងព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអំពីការចាប់ខ្លួន ឌឿន នៅមន្ទីរ៨៧០ ការបង្កើតរដ្ឋធម្មនុញ្ញ ការថ្លែងសន្ទរកថាផ្សេងៗរបស់ ខៀវ សំផន ស្ថានភាពរស់នៅ និងការសម្លាប់ប្រជាជន ប៉ុន្តែសំណួរទាំងនោះត្រូវបានសាក្សីបដិសេធថា សាក្សីមិនដែលទទួលបានព័ត៌មានអ្វីច្រើនទេ ដោយសារតែមានការបិទព័ត៌មានមិនឲ្យផ្សាយចេញពីប្រទេសកម្ពុជា ។ សំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងឯកសារសំខាន់ ដែលសាក្សីបានអានអំពីស្ថានភាពកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ សាក្សី ចៅ សុគុណ បានបញ្ជាក់ថា ដោយសារឯកសារដែលទទួលបាននោះមានចំនួនតិចតួច សាក្សីមិនអាចវាយតម្លៃថាព័ត៌មានណាសំខាន់និងមិនសំខាន់បានទេ ។ ប៉ុន្តែ អ្វីដែលសាក្សីបានដឹងអំពី ខៀវ សំផន នោះគឺថា ខៀវ សំផន ជាមនុស្សល្អ ដែលសាក្សីគោរព និងជាអ្នកដែលមានកេរ្តិ៍ឈ្មោះតាំងពីឆ្នាំ១៩៦៧មក ។

### ៤) ការសួរដេញដោលដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងការសួរដេញដោលសាក្សី ចៅ សុគុណ សហមេធាវីជាតិ ឡោ ជុនធី បានផ្តោតសំខាន់ទៅលើព័ត៌មានរបស់លោក ចៅ សៅ ព្រឹត្តិកាណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ព្រមទាំងតួនាទីនិងគោលជំហរនយោបាយរបស់ ខៀវ សំផន ។ ចំណែកសហមេធាវីអន្តរជាតិ ប៉ាស្កាល់ អូបូអ៊ីន បានផ្តោតសំខាន់អំពីបទចោទ



គណៈប្រតិភូភូមា ដឹកនាំដោយប្រធានាធិបតី ណេ វីន ទស្សនកិច្ចប្រទេសកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ខៀវ សំផន (ស្តាំដើរខាងមុខ) ជាអ្នកជូនដំណើរគណៈប្រតិភូដើរកំសាន្តនៅខេត្តសៀមរាប ។ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រកាន់ប្រឆាំងនឹង ខៀវ សំផន និងមុខងាររបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

### ក) សហមេធាវីជាតិ

សហមេធាវីជាតិ ឡោ ជុនធី បានផ្តើមសំណួរទាក់ទងនឹងលោក ចៅ សៅ ។ សាក្សីបានបញ្ជាក់ថា ចៅ សៅ ជាប្រធានឥណទានជាតិ ហើយត្រូវជាបងប្អូនខាងភរិយារបស់សាក្សី ប៉ុន្តែក្រោយមក សាក្សីបានទទួលដំណឹងថា ចៅ សៅ បានស្លាប់ ។ ម្យ៉ាងទៀត សាក្សីមិនដែលបានទទួលព័ត៌មានពីគ្រួសាររបស់ ចៅ សៅ ទៀតឡើយ ។ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញវិញ សាក្សី ចៅ សុគុណា បានបញ្ជាក់ថា គាត់បានគាំទ្រចំពោះការជម្លៀសប្រជាជន ដោយសារតែនៅពេលនោះជាពេលមានសង្គ្រាម និងមានការទម្លាក់គ្រាប់បែកដែលបណ្តាលឲ្យប្រជាជនមកពីជនបទបានមករស់នៅក្នុងទីក្រុងកាន់តែច្រើនឡើង ដូច្នេះមធ្យោបាយតែមួយសម្រាប់អ្នកដឹកនាំ គឺការជម្លៀសប្រជាជនឲ្យទៅនៅតាមជនបទវិញដើម្បីទទួលបានស្បៀងអាហារហូបចុកគ្រប់គ្រាន់ ។ ម្យ៉ាងទៀត ការជម្លៀសនោះគ្រាន់តែធ្វើឡើងជាបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណា ខ្លួនមានការសោកស្តាយ ដោយសារតែការជម្លៀសនោះបានបណ្តាលឲ្យប្រជាជនកម្ពុជាជាច្រើនធ្លាក់ឈឺ និងស្លាប់នៅពេលធ្វើដំណើរនោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងគំរូបដិវត្តន៍នៅក្នុងប្រទេសផ្សេងៗវិញ សាក្សី ចៅ សុគុណា បានបញ្ជាក់ថា សាក្សីពុំបានដឹងពីគំរូនៅតាមបណ្តាប្រទេសផ្សេងៗទេ ប៉ុន្តែអ្វីដែលខ្លួនមើលឃើញចំពោះកម្ពុជានៅពេលនោះ ជម្រើសដែលល្អមានតែការជម្លៀសប្រជាជនប៉ុណ្ណោះ ។ មេធាវីបានបន្តសំណួរពាក់ព័ន្ធនឹងទំនាក់ទំនងរវាង ចៅ សៅ និង ខៀវ សំផន ហើយសាក្សី សុគុណា បានបញ្ជាក់ថា គាត់ពុំបានដឹងថា អ្នកទាំងពីរមានទំនាក់ទំនងនឹងគ្នាដល់កម្រិតណាឡើយ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងគោលជំហររបស់ ខៀវ សំផន កាលពីមុនរហូតមកដល់បច្ចុប្បន្នវិញ សាក្សី ចៅ សុគុណា បានបញ្ជាក់ថា ខៀវ សំផន នៅតែប្រកាន់ជំហរជាមនុស្សស្អាតស្អំ និងស្នេហាជាតិ ។ សាក្សីបានសង្កត់ធ្ងន់ថា គាត់បានផ្តល់សក្ខីកម្មនៅពេលនេះដើម្បីរួមចំណែកស្វែងរកយុត្តធម៌នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទន្ទឹមនឹងនេះ សាក្សីក៏មានបំណងស្វែងរកយុត្តិធម៌ និងការពិតជូន ខៀវ សំផន ដែរ ។ បន្ទាប់មក មេធាវីបានបន្តសួរឲ្យសាក្សីបញ្ជាក់ថា តើ ខៀវ សំផន បានផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជាដែរទេ ក្រោយពេលដែលខ្លួនបានតស៊ូដើម្បីស្វែងរកយុត្តិធម៌នោះ? ចំពោះសំណួរនេះ មេធាវី គង់ សំអុន បានជំទាស់ដោយស្នើសុំឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អំពីអំណាចរបស់ ខៀវ សំផន និងបង្ហាញឯកសារដែលពាក់ព័ន្ធ ។ ឆ្លើយតបនឹងការជំទាស់នេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ឯកសារដែលពាក់ព័ន្ធនោះជាឯកសារដែលនិយាយអំពីការតែងតាំង ខៀវ សំផន ឲ្យធ្វើជាប្រមុខរដ្ឋ ។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះបានបដិសេធការជំទាស់របស់មេធាវីការពារក្តី ដោយបង្គាប់ឲ្យសាក្សីឆ្លើយតបនឹងសំណួរដែលចោទឡើង ។ សាក្សី ចៅ សុគុណា គ្រាន់តែបានបញ្ជាក់ថា មានកាសែតបរទេសជាច្រើនដែលសរសេរថា ខៀវ សំផន មានតំណែងជាប្រធានរដ្ឋដែលមានតែឈ្មោះ ។

### ខ) សហមេធាវីអន្តរជាតិ

បន្ទាប់មក សហមេធាវីអន្តរជាតិ ប៉ាស្កាល់ អូបូអ៊ីន បានផ្តើមសំណួរថា តើសាក្សីជាសមាជិកនៃបក្សកុម្មុយនីស្តបារាំងដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបដិសេធថា សាក្សីពុំមែនជាសមាជិករបស់បក្សកុម្មុយនីស្តបារាំងទេ ។ មេធាវីបានបន្តសួរទាក់ទងនឹងបទចោទប្រកាន់ទៅលើ ខៀវ សំផន ហើយសាក្សីបានបញ្ជាក់ថា សាក្សីបានឮតាមរយៈសារព័ត៌មានតែប៉ុណ្ណោះដែលថា ខៀវ សំផន ប្រឈមនឹងបទចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ទាក់ទងនឹងការជួបគ្នារវាងសាក្សីនិង ខៀវ សំផន វិញ សុគុណា បានបញ្ជាក់ម្តងហើយម្តងទៀតថា នៅពេលនោះ គាត់ពុំបានសួរនាំអំពីរឿងនយោបាយ ឬក៏តួនាទីរបស់ ខៀវ សំផន ទេ ដោយគ្រាន់តែបានសួរសុខទុក្ខធម្មតាប៉ុណ្ណោះ ។ ម្យ៉ាងទៀត សាក្សីក៏មិនបានគិតថា ខៀវ សំផន មានការលាក់បាំងអំពីរឿងរ៉ាវនៅក្នុងជីវិតដែរ ។ សំណួរចុងក្រោយរបស់មេធាវី ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែសាក្សីនៅតែប្រកាន់ជំហរឆ្លើយតបថា តួនាទីរបស់ ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋដែលមានតែឈ្មោះ ។

# សវនាការសួរដេញដោលបន្ថែមលើដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី
## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការ ដោយកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី មកធ្វើការសួរដេញដោលបន្ថែម បន្ទាប់ពីត្រូវបានស្នើឡើងដោយក្រុមមេធាវីការពារក្តីខៀវសំផន ។ គួររំឭកថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះធ្លាប់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងកោះហៅមកផ្តល់សក្ខីកម្មម្តងរួចមកហើយ កាលពីខែធ្នូ ឆ្នាំ២០១២ ទាក់ទងនឹងអង្គហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧មេសា និងការជម្លៀសនៅដំណាក់កាលទីពីរ ។ នៅក្នុងសវនាការកាលពីលើកមុនដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ឆ្លងកាត់របបខ្មែរក្រហម ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះដើម្បីចោទសំណួរដោយផ្ទាល់ទៅកាន់ជនជាប់ចោទ ខៀវសំផន ទាក់ទងនឹងការស្លាប់របស់ឪពុកមា ឈ្មោះ ចៅ សាយ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ការស្លាប់នោះមានពាក់ព័ន្ធយ៉ាងជិតស្និទជាមួយ ខៀវ សំផន ។ បន្ទាប់ពីបានចោទសំណួរទៅកាន់ជនជាប់ចោទតាមការស្នើសុំមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំអង្គជំនុំជម្រះ ដើម្បីមានឱកាសសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិញដោយអះអាងថា ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាការបង្ហាញនូវអង្គហេតុថ្មីទៀត ដែលចាំបាច់ឲ្យគាត់មានឱកាសបានសួរដេញដោល ។

មុនពេលចាប់ផ្តើមការសួរដេញដោលនេះលោកប្រធានអង្គជំនុំជម្រះចៅក្រម និល ណុន បានរំឭកអំពីប្រវត្តិនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ព្រមទាំងណែនាំដល់ភាគីនានាកុំឲ្យសួរសំណួរ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មកាលពីលើកមុន ដោយសារសវនាការលើកនេះ ផ្តោតតែទៅលើអង្គហេតុដែលទាក់ទងនឹងការស្លាប់របស់ ចៅ សាយ ប៉ុណ្ណោះ ។ ដូច្នេះនៅក្នុងនីតិវិធីនេះប្រធានអង្គជំនុំជម្រះបានផ្តល់វេទិកាជូនមេធាវីការពារក្តីដើម្បីមានឱកាសតាំងសំណួរមុនគេ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាបន្តបន្ទាប់ ។

### ១) ការសួរដេញដោលដោយមេធាវីការពារក្តី

#### ក) មេធាវីជនជាប់ចោទ ខៀវ សំផន

ជាការចាប់ផ្តើមមេធាវីអន្តរជាតិ អាកទូរ វែកគែន បានស្នើសុំឲ្យអង្គជំនុំជម្រះអនុវត្តនីតិវិធីនៃការសួរដេញដោលដូចការអនុវត្តមុនៗ តាមលំដាប់លំដោយចាប់ពីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយសារសវនាការនេះធ្វើឡើងដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ។ ឆ្លើយតបទៅនឹងសំណើនេះ សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ាឌីវ ម៉ូហាន បានបដិសេធចំពោះការលើកឡើងរបស់មេធាវីការពារក្តី ខៀវសំផន ដោយលោកអះអាងថា ការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ ជាសំណើរបស់មេធាវីការពារក្តី ដូច្នេះសហមេធាវី ត្រូវតែអនុវត្តតាមការសម្រេចរបស់អង្គជំនុំជម្រះ ។ ពាក់ព័ន្ធនឹងបញ្ហានេះអង្គជំនុំជម្រះនៅតែរក្សាសេចក្តីសម្រេចដដែល ដោយកំណត់ឲ្យមេធាវីការពារក្តីជាអ្នកសួរដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីផ្សេងទៀត ។

សហមេធាវីអន្តរជាតិ អាកទូរ វែកគែន បានចាប់ផ្តើមដោយសួរដើមបណ្តឹងរដ្ឋប្បវេណីថាតើ ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលឯកសារកាលពីសវនាការមុនពីមេធាវីដែរឬទេ? ប៉ុន្តែដើមបណ្តឹងបានឆ្លើយបញ្ជាក់ថា គាត់ពុំបានទទួលឯកសារណាមួយពីមេធាវីរបស់គាត់ឡើយ ។ បន្ទាប់មកមេធាវីអន្តរជាតិ អាកទូរ វែកគែន បានដកស្រង់នូវសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការលើកមុន ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់សាជាថ្មី ។ បន្ទាប់មកមេធាវីបានបន្តសួរទាក់ទងនឹងព័ត៌មាន ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលអំពីការបាត់ខ្លួនរបស់ ចៅ សៅ ។ ឆ្លើយតបនឹងសំណួរនេះដើមបណ្តឹងរដ្ឋប្បវេណី បានរំឭកថានៅឆ្នាំ១៩៧៩ ដើមបណ្តឹងបានជួបជាមួយឈ្មោះ ឈៀង ជាអ្នកបើកឡានឲ្យ ចៅ សៅ ។ នៅពេលនោះ ឈៀង បានប្រាប់គាត់ និងក្រុមគ្រួសារថា នៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ចៅ សៅ បានចាកចេញពីទីក្រុង

ភ្នំពេញ ហើយបីថ្ងៃក្រោយមកទើបធ្វើដំណើរទៅដល់ព្រែកក្តាម ។ ពេលនោះ ចៅ សោ បានទទួលសំបុត្រពី ខៀវ សំផន ដែលមានខ្លឹមសារថា ឲ្យ ចៅ សោ ត្រឡប់មកធ្វើការនៅទីក្រុងភ្នំពេញវិញ ប៉ុន្តែ សំណើនោះត្រូវបាន ចៅ សោ បដិសេធ ។ ក្រោយមក ចៅ សោ ទទួលបាមសំបុត្រមួយទៀត ប៉ុន្តែអ្នកបើកឡាននោះពុំដឹងថាសំបុត្រនោះមានអត្ថន័យយ៉ាងណាទេ ។ អ្នកបើកឡាននោះ គ្រាន់តែបានប្រាប់ថា ចៅ សោ បានប្រាប់ឲ្យគាត់ត្រឡប់មករកគ្រួសារវិញហើយ ចាប់ពីពេលនោះ មកគាត់ក៏បាត់ដំណឹងពី ចៅ សោ រហូត ។

បន្ទាប់មក មេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងកាលបរិច្ឆេទនៃការសរសេរសំបុត្រទៅកាន់ ចៅ សោ ។ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានរៀបរាប់ថា គាត់មានការជឿជាក់ថាសំបុត្រនោះត្រូវបានសរសេរនៅថ្ងៃទី១៧ ខែមេសា ដោយសារពេលខ្មែរក្រហមចូលមក ចៅ នី បានស្តាប់ឮការផ្សាយតាមវិទ្យុជាតិ ដោយប្រកាសរកឈ្មោះ ចៅ សោ, ឡុង បូរ៉េត, ចេង ហេង, សិរិមតៈ ប៉ុន្តែបីថ្ងៃក្រោយមកទើប ចៅ សោ បានទទួលសំបុត្រ ។ បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយមេធាវីអន្តរជាតិមេធាវីជាតិ គង់ សំអុន បានជម្រាបជូនអង្គជំនុំជម្រះថា កូនក្តីរបស់គាត់ ខៀវ សំផន មានបំណងឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចោទសួរកាលពីសវនាការមុន ។ ឆ្លើយតបនឹងសំណើនេះ អង្គជំនុំជម្រះបានប្រគល់វេទិកាដល់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចោទសំណួរសាជាថ្មី ដើម្បីឲ្យជនជាប់ចោទមានឱកាសឆ្លើយតប ។ ខណៈនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានអានឡើងវិញនូវសំណួរដូចតទៅ៖

ទី១) តើអត្ថន័យនៅក្នុងសំបុត្រដែល ខៀវ សំផន ផ្ញើរទៅកាន់ឪពុកមារបស់ខ្ញុំនោះមានអត្ថន័យយ៉ាងណាខ្លះបានជាគាត់មិនត្រឡប់មកភ្នំពេញវិញ?

ទី២) តើហេតុអ្វីបានជាឪពុកមាខ្ញុំឲ្យអ្នកបើកឡានត្រឡប់មកផ្ទះវិញ?

ទី៣) តើអ៊ំរបស់ខ្ញុំជម្លៀសទៅណា? ស្លាប់ដោយសារអី? នៅកន្លែងណា? ដើម្បីខ្ញុំបានយកធាតុរបស់គាត់ទៅធ្វើបុណ្យតាមព្រះពុទ្ធសាសនា ។

### ១) ការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងសំណួររបស់ដើមបណ្តឹង រដ្ឋប្បវេណី

បាទ! សូមគោរពលោកប្រធាន ។ សូមគោរពអស់លោក លោកស្រីចៅក្រម ។ សូមគោរពអង្គសវនាការទាំងមូល ។ (សុំទោស) សូមគោរពបងប្អូនរួមជាតិទាំងអស់ ។ ជម្រាបសួរ លោក ចៅ នី!

ខ្ញុំសូមជម្រាបលោកថា ខ្ញុំធ្លាប់ស្គាល់លោក ចៅ សោ ។ កាលក្នុងអំឡុងឆ្នាំ៦០ គាត់បានធ្វើជាប្រធានធនាគារមួយហៅថា “ធនាគារគេណាទានជាតិ” ។ ហើយខ្ញុំយល់នូវទឹកចិត្តសោកសង្រេងរបស់លោក និងក្រុមគ្រួសាររបស់លោកខិតខំស្វែងរកដំណឹងពីលោកអ៊ំរបស់លោក ពីជោគវាសនារបស់អ៊ំរបស់លោកហើយ ប្រសិនបើ លោកបានចាកឋានទៅហើយ នឹងយកសពរបស់លោកទៅធ្វើបុណ្យតាមគន្លងប្រពៃណីព្រះពុទ្ធសាសនារបស់យើង ។ ប៉ុន្តែជាការគួរឲ្យសោកស្តាយខ្ញុំមិនមានដំណឹងអ្វីពាល់តែសោះអំពីជោគវាសនារបស់អ៊ំលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពាក្យថា មានអ្នកណាអាចជម្រាបលោកថា ខ្ញុំបានសរសេរសំបុត្រទៅអ៊ំរបស់លោកនោះមិនមែនការពិតទេ ។ ខ្ញុំគ្មានទាហានណានៅក្រោមបង្គាប់ ដើម្បីខ្ញុំផ្ញើសំបុត្រទៅតាមគេនោះទេ ។ ហើយម្យ៉ាងទៀត ដូចលោកជ្រាបហើយ[ខ្ញុំ]ត្រូវបង្ខំចិត្តរត់គេចខ្លួនពីទីក្រុងភ្នំពេញ ចោលម្តាយរបស់ខ្ញុំដែលគាត់ចាស់ជរា ។ គាត់នៅជាមួយខ្ញុំ ធ្លាប់នៅជាមួយខ្ញុំ ។ ចោលប្អូនៗដែលធ្លាប់តែពឹងពាក់ខ្ញុំ តាំងពីឆ្នាំ១៩៦៧មក ។ ហើយតាំងពីពេលនោះមក អ៊ំរបស់លោកហើយនឹងខ្ញុំ មិនដែលជួបមុខគ្នាម្តងណាពាល់តែសោះ ។ សរុបមក ខ្ញុំមិនមានមធ្យោបាយអីនឹងផ្ញើសំបុត្រទៅអ៊ំរបស់លោកពាល់តែសោះ ។

ម្យ៉ាងទៀតខ្ញុំមិនដែលមានគំនិតនឹកភ្នកទៅរកអ៊ំរបស់លោក អញ្ជើញអ៊ំរបស់លោកឲ្យមកភ្នំពេញវិញក៏អត់សោះ អត់ពាល់តែសោះហ្នឹង ខ្ញុំសូមជម្រាបលោកដូច្នេះ ។ ថ្ងៃនេះ ខ្ញុំដោយសារមនោសញ្ចេតនារបស់ខ្ញុំគោរព និងយល់ច្បាស់នូវសោកសង្រេងរបស់លោក និងក្រុមគ្រួសាររបស់លោក នឹករឭកដល់អ៊ំរបស់លោកនេះហើយ ដែលខ្ញុំត្រូវការជួបលោកដោយផ្ទាល់ដើម្បីជម្រាបលោកដោយផ្ទាល់មាត់ដោយអស់ពីថ្លើមពីចិត្តរបស់ខ្ញុំ

ដើម្បីយើងទាំងពីរនាក់ជជះស្រឡះជាមួយគ្នា ។ ខ្ញុំស្តាយណាស់ ដោយខ្ញុំគ្មានមធ្យោបាយ ដើម្បីរួមចំណែកបំពេញសំណូមពររបស់លោក ។ ខ្ញុំសង្ឃឹមថា លោកយល់អធ្យាស្រ័យដល់ខ្ញុំ ។ សូមអរ ។ អគុណបាទ!

បន្ទាប់ពីបញ្ចប់ការឆ្លើយរបស់ ខៀវ សំផន ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ទោះបីជាយ៉ាងណា គាត់នៅតែមិនអស់ចិត្តនឹងចម្លើយរបស់ជនជាប់ចោទ ដោយសារជនជាប់ចោទមានទំនាក់ទំនងជិតស្និតជាមួយឪពុកមារបស់គាត់ ។ ដោយឃើញស្ថានភាពដូច្នេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ព័ត៌មានដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលបានទាក់ទងនឹងសំបុត្រ ដែល ចៅ សៅ បានទទួលនោះហាក់មានការមិនច្បាស់លាស់ទេ ដូច្នេះអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនតំណាងសហព្រះរាជអាជ្ញា ដើម្បីសួរដេញដោលបន្ត ។

### ២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិអាប់ឌុលហាក់ ថារីកបានផ្តើមសំណួរថា តើអ្នកបើកឡាននោះបានឃើញសំបុត្រដោយផ្ទាល់ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា អ្នកបើកឡាននោះគ្រាន់តែបានប្រាប់ថា គាត់បានឃើញសំបុត្រទាំងពីរដែលទី១ បានមកដល់ ចៅ សៅ ពីរទៅបីថ្ងៃក្រោយថ្ងៃទី១៧មេសា ហើយនៅក្នុងនោះ ខៀវ សំផន បានហៅ ចៅ សៅ ឲ្យចូលមកទីក្រុងភ្នំពេញវិញ ។ ចំណែកសំបុត្រទី២ ទទួលបាន២ថ្ងៃក្រោយពេលទទួលបានសំបុត្រទី១នោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា ឈៀង មិនដឹងអំពីអត្ថន័យនៅក្នុងសំបុត្រនោះយ៉ាងណាទេ ប៉ុន្តែ ចៅ សៅ គ្រាន់តែប្រាប់ឲ្យ ឈៀង ត្រឡប់ទៅរកគ្រួសារវិញប៉ុណ្ណោះ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តសួរអំពីទំនាក់ទំនងរវាង ខៀវ សំផន និង ចៅ សៅ ព្រមទាំងតួនាទីរបស់ ចៅ សៅ នៅចន្លោះឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះ ចៅ នី បានរៀបរាប់ថា កាលពីនៅតូច ខៀវ សំផន បានទៅលេងផ្ទះរបស់ ចៅ សៅ ដែលស្ថិតនៅម្តុំទួលគោក ប៉ុន្តែពុំបានដឹងថានៅពេលនោះ ខៀវ សំផន និយាយអ្វីខ្លះជាមួយ ចៅ សៅ ទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ចៅ សៅ មានតួនាទីជាប្រធានធនាគារ ហើយក្រោយមកបានបង្កើតគណៈបក្សនយោបាយមួយឈ្មោះថា បក្សប្រជាធិបតេយ្យ ។ សំណួរចុងក្រោយតំណាងសហព្រះរាជអាជ្ញាសួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អំពីទំនាក់ទំនងរវាង ចៅ សៅ និងដើមបណ្តឹងរដ្ឋប្បវេណី ។ លោក ចៅ នី បានបញ្ជាក់ថា ចៅ សៅ ជាឪពុកមាបង្កើតរបស់ប្រពន្ធដើមបណ្តឹងរដ្ឋប្បវេណី ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀត ។

### ៣) ការសួរដេញដោលដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីអន្តរជាតិ ម៉ាឌីវ ម៉ូហាន បានបន្តសួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីពន្យល់អំពីកេរ្តិ៍ឈ្មោះរបស់ ចៅ សៅ ក្នុងចំណោមខ្មែរកម្ពុជាក្រោមខណៈពេលធ្វើការនៅក្នុងធនាគារជាតិ ។ ឆ្លើយតបនឹងសំណួរនេះដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានរៀបរាប់ថា ចៅ សៅ ជាមនុស្សល្អ ស្រឡាញ់យុត្តិធម៌ ហើយបានជួយឲ្យប្រជាជនខ្មែរមកពីកម្ពុជាក្រោមចូលមកធ្វើការនៅធនាគារជាច្រើននាក់ ដូច្នេះប្រជាជនខ្មែរកម្ពុជាក្រោមបានគោរពស្រឡាញ់ ចៅ សៅ ជាខ្លាំង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ចៅ សៅ មានបងប្អូនបីនាក់ ដែលក្នុងនោះម្តាយក្មេក ជាប្អូនស្រីបង្កើតរបស់ ចៅ សៅ ។ សហមេធាវីអន្តរជាតិ បានបន្តសួរទាក់ទងនឹងព័ត៌មានផ្សព្វផ្សាយតាមវិទ្យុជាតិ ដែលប្រកាសរកឈ្មោះបុគ្គលមួយចំនួនមានឈ្មោះ ចេង ហេង, សិរិមតៈ និង ចៅ សៅ ដើម្បីឲ្យអ្នកទាំងបីនាក់នោះត្រឡប់មកទីក្រុងភ្នំពេញវិញ ។ ឆ្លើយតបនឹងសំណួរនេះ ចៅ នី បានបញ្ជាក់ថា គាត់ពិតជាបានឮព័ត៌មាននោះពិតមែន ប៉ុន្តែក្រោយមក គាត់មិនបានឮឈ្មោះ ចៅ សៅ ទេមានតែ សិរិមតៈ និង ចេង ហេង ប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងការកោះហៅឈ្មោះ ចៅ សៅ ឲ្យត្រឡប់មកភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា គាត់មិនដឹងអំពីមូលហេតុដែលនាំឲ្យមានការហៅ ចៅ សៅ ឲ្យត្រឡប់មកភ្នំពេញវិញទេ ប៉ុន្តែមូលហេតុមួយទៀតអាចបណ្តាលមកពី ចៅ សៅ ជាខ្មែរកម្ពុជាក្រោម ។ ជាចុងក្រោយ សហមេធាវីបានស្នើឲ្យសាក្សីបញ្ជាក់អំពីមូលហេតុដែលនាំឲ្យខ្លួនដាក់ពាក្យបណ្តឹងមកតុលាការទាក់ទងនឹង

ការបាត់ខ្លួនរបស់ ចៅ សៅ ។ ឆ្លើយតបនឹងសំណួរនេះដែរដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានបញ្ជាក់ថា ខ្លួនដាក់ពាក្យបណ្តឹងដោយសារមានការសោកស្តាយជាខ្លាំងចំពោះការបាត់បង់ ចៅ សៅ ដែលជាមនុស្សល្អធ្លាប់ជួយគ្រួសាររបស់ខ្លួន និងខ្មែរកម្ពុជាក្រោមជាច្រើនទៀត ។ បន្ទាប់មក សហមេធាវីជាតិ ពេជ អង្គ បានបន្តសំណួរទាក់ទងនឹងបុគ្គលភាពរបស់អ្នកបើកឡានឈ្មោះ ឈៀង ។ ជាការឆ្លើយតប ចៅ នី បានបញ្ជាក់ថា ប្រពន្ធរបស់គាត់ធ្លាប់បានរស់នៅជាមួយ ចៅ សៅ តាំងពីនៅតូចដូច្នេះប្រពន្ធរបស់គាត់បានស្គាល់ ឈៀង ច្បាស់ថា ជាមនុស្សល្អនិងមិនចេះនិយាយកុហក ហើយនេះក៏ជាមូលហេតុដែល ចៅ សៅ មានការទុកចិត្តឲ្យធ្វើជាអ្នកបើកឡានរហូតមក ។

នៅមុនពេលបញ្ចប់ អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសថ្លែងអំពីទុក្ខវេទនារបស់ខ្លួនដែលបានឆ្លងកាត់ និងការបាត់បង់សាច់ញាតិនៅក្នុងរបបខ្មែរក្រហមសាជាថ្មីម្តងទៀត បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីថ្លែងទុក្ខសោកម្តងរួចទៅហើយ ។

## ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីចៅនី

«សូមជម្រាបលោកចៅក្រម! ការទុក្ខសោកដែលខ្ញុំឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នេះបើរៀបរាប់ទៅវាមិនចេះអស់មិនចេះហើយទេ ។ ប៉ុន្តែ ការទុក្ខសោក ដែលខ្ញុំបាត់បង់បងប្អូនគ្រួសារនៅក្នុងរបបនោះគឺការឈឺចាប់រហូតមកដល់សព្វថ្ងៃនេះ គឺនៅតែនឹកឃើញការឈឺចាប់ ។ កាលពីមុនខ្ញុំខំបំភ្លេចដែរតាំងពីឆ្នាំ៧៩រហូតមកដល់ឆ្នាំ៨៥, ៨៦ ក៏ខ្ញុំបំភ្លេចដែរ ខំបំភ្លេច កុំឲ្យនឹកឃើញរឿងអតីតកាលរហូតមកដល់មានតុលាការរដ្ឋាភិបាលបង្កើតតុលាការក្នុនកាត់មានអង្គការសហប្រជាជាតិ និងជាតិបង្កើតតុលាការនេះឡើងធ្វើឲ្យខ្ញុំនឹកឃើញ ដែលការឈឺចាប់របស់ខ្ញុំជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ ហេតុដូច្នេះហើយ បងប្អូនខ្ញុំពីជំនាន់មុនឪពុកធំឪពុកមាបងប្អូនអីហ្នឹង គាត់សុទ្ធតែអ្នកមានមុខមាត់នៅក្នុងការងាររដ្ឋាភិបាលកម្ពុជា ។ ក្រោយពីថ្ងៃ១៧មេសាមករហូតដល់ឆ្នាំ៧៩ កងទ័ពរដ្ឋាភិបាលបានរំដោះមក ខ្ញុំបាត់អស់បងប្អូនក្រុមគ្រួសារអស់រលីង ។ ហេតុដូច្នេះ ហើយការឈឺចាប់របស់ខ្ញុំនៅតែឈឺចាប់គ្មានពេលណាស្រាក ។

ដល់ពេលនេះហើយ ខ្ញុំបានឡើងធ្វើសក្ខីកម្ម ចង់សួររកឪពុកមាដែលធ្លាប់ចិញ្ចឹមបី បាច់ថែរក្សាពីតូច ក្រុមគ្រួសារខ្ញុំ ទាំងគ្រួសារប្រពន្ធខ្ញុំទាំងអស់ ដើម្បីរកអដ្ឋិធាតុគាត់ ដើម្បីឧទ្ទិសមផលឲ្យគាត់នៅតែមិនបានដឹង មិនបានឮ ។ ហេតុដូច្នេះហើយ ខ្ញុំនៅការឈឺចាប់របស់ខ្ញុំគឺនៅជាប់រហូត ។ នៅក្នុងពេលនោះគ្រាន់តែទៅជាមួយលោក ចៅ សៅ នេះមានបងបង្កើតប្រពន្ធខ្ញុំពីរនាក់បានស្លាប់ទៅជាមួយគាត់ ។ ក្មួយពីរនាក់ក៏ស្លាប់ទៅជាមួយ ចៅ សៅ ។ អ៊ីចឹងហេតុដូច្នេះហើយ ពូនៅពោធិ៍សាត់នោះក៏ស្លាប់ ចូលមកបានតែបីថ្ងៃគេសម្លាប់ចោលហើយ ។ ឲ្យតែខ្មែរក្រោម គឺគេសម្លាប់ចោលហើយ ហេតុអីបានជាគេខាងកម្ពុជាប្រជាធិបតេយ្យ ខាងខ្មែរក្រហម គេស្អប់ខ្មែរក្រោមម្ល៉េះ ។ សូម្បីតែក្មេងមិនទាន់ដឹងអីផងក៏សម្លាប់ចោលដែរឲ្យតែខ្មែរកម្ពុជាក្រោម ។ ហេតុដូច្នេះហើយលោកអ៊ំ ខៀវ សំផន គួរតែយល់ហើយ ។ លោកធ្លាប់ហូបបាយខ្មែរកម្ពុជាក្រោម ។ ហេតុដូច្នេះហើយលោកអ៊ំ ខៀវ សំផន គួរតែយល់ហើយ ។ លោកធ្លាប់ហូបបាយខ្មែរកម្ពុជាក្រោមដែរ មិនមែនថា មិនធ្លាប់ហូបទេ ។ លោកនៅក្នុងរបបនោះហេតុអី? មានអ្នកណាបង្ខំឲ្យគេសម្លាប់ខ្មែរកម្ពុជាក្រោម ។

ការទុក្ខសោករបស់ខ្ញុំ គឺគ្មានអ្វីក្រៅពីការបាត់បង់ឪពុកម្តាយឪពុកមា និងពូរបស់ខ្ញុំទេ ។ អ៊ីចឹងខ្ញុំគ្មានអ្វីតទៅមុខទៀតទេ ។ ខ្ញុំបានសូមនិយាយតែប៉ុណ្ណឹងសិនបាន ។ សូមអគុណលោកចៅក្រម!»

**កំណត់សម្គាល់** ៖ ខណៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែរៀបរាប់អំពីទុក្ខសោករបស់ខ្លួនទាក់ទងនឹងការសម្លាប់ប្រជាជនខ្មែរកម្ពុជាក្រោមចៅក្រម និល ណុន បានរំឭកដល់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យរៀបរាប់តែលើអង្គហេតុទាំងឡាយណាដែលទាក់ទងនឹងចំនុចដែលលើកយកមកពិភាក្សាដោយចៀសវាងការលើកឡើងនូវអង្គហេតុថ្មីដែលអាចនាំឲ្យមានការស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមកសួរដេញដោលម្តងទៀត ។

មុនពេលបញ្ចប់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិអាប់ឌុលហាក់ ថារីក បានបញ្ជាក់ថា គាត់មិនបានដឹងមុនថា ខៀវ សំផន បានឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ដូច្នេះ លោកបានស្នើសុំឲ្យមានការបញ្ជាក់ពីជំហររបស់ ខៀវ សំផន ថាតើជនជាប់ចោទរូបនេះនៅតែរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយ

តប ឬនឹងឆ្លើយតបខ្លះចាប់ពីពេលនេះតទៅ? ការបញ្ជាក់បែបនេះ នឹងមានភាពងាយស្រួលសម្រាប់តំណាងសហព្រះរាជអាជ្ញាក្នុងការរៀបចំសំណួរដើម្បីសួរជនជាប់ចោទ ។ បន្ទាប់មក សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានលើកឡើងថា ការដែលជនជាប់ចោទបានឆ្លើយតបនឹងសំណួររបស់រងគ្រោះជាឱកាសមួយ ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធូរស្បើយផ្លូវចិត្តមួយផ្នែកដែរ ។ម្យ៉ាងទៀត មេធាវីក៏បានគាំទ្រឲ្យមានការជូនដំណឹងជាមុនដែរប្រសិនបើជនជាប់ចោទមានជំហរក្នុងការឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ថែមលើនេះទៅទៀត មេធាវីបានធ្វើការកត់សម្គាល់ថា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីធ្វើការរៀបរាប់ថ្លែងទុក្ខសោករបស់ខ្លួនអាចនឹងរៀបរាប់អំពីអង្គហេតុថ្មី ដែលករណីនេះពុំមែនជាបញ្ហាដែលត្រូវបានហាមឃាត់នោះទេ ។

ឆ្លើយតបនឹងការលើកឡើងនេះចៅក្រម និល ណុន បានបញ្ជាក់ថា ការកំណត់វិសាលភាពនៃការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីជាកាតព្វកិច្ចរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចៀសវាងនៅពេលដែលមានការលើកឡើងនូវអង្គហេតុថ្មី ដែលអាចបង្កឲ្យមានការស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមកសួរដេញដោលបន្ថែម ដូចករណីដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ជាដើម ។

បន្ទាប់មកចៅក្រម ស៊ិលវៀ ខាតព្រ៉ូយតឺ បានសួរជនជាប់ចោទ ខៀវ សំផន និង នួន ជា ឲ្យបញ្ជាក់អំពីគោលជំហររបស់ខ្លួនក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬឆ្លើយតបដោយមានលក្ខខណ្ឌដូចដែលបានលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា ។ ឆ្លើយតបនឹងសំណួរនេះ ខៀវ សំផន បានបញ្ជាក់ថា «រឿងនេះជារឿងកាត់ក្តីរបស់ខ្ញុំ ហើយការចោទប្រកាន់មកលើខ្ញុំវាសុទ្ធតែចោទប្រកាន់ធ្ងន់ធ្ងរណាស់ ។ ហើយខ្ញុំក៏មិនសូវយល់នីតិក្រមរបស់តុលាការដែរទេ ។ ដូច្នេះខ្ញុំសូមពេលវេលា ពិគ្រោះពិភាក្សាជាមួយមេធាវីរបស់ខ្ញុំសិន ។ ហើយខ្ញុំឆ្លើយជម្រាបទៅលោក ចៅ នី ពីព្រឹកមិញនេះ ក៏ដោយខ្ញុំយល់មនោសញ្ចេតនាសោកសៅរបស់គាត់ ហើយខ្ញុំក៏ឆ្លៀតឱកាសដែលលោក ចៅ នី បានអញ្ជើញមកនេះជម្រាបគាត់ ដូចបានជម្រាបពីព្រឹកមិញយ៉ាងនេះតែប៉ុណ្ណោះទេ ។

បន្ទាប់ពីមានការពិភាក្សាជាមួយមេធាវីរបស់ខ្លួន ខៀវ សំផន បានឆ្លើយតបនឹងអង្គជំនុំជម្រះនៅក្នុងសវនាការបន្ទាប់ថ្ងៃទី២៧ ខែមេសាថា «សូមគោរពអស់លោកលោកស្រីចៅក្រម សូមគោរពអង្គសវនាការទាំងមូល សូមគោរពព្រះសង្ឃ និងបងប្អូនរួមជាតិទាំងអស់ ។ ខ្ញុំបាទលើកបញ្ហា ដែលលោកប្រធានបានលើកនេះ សូមជូនចម្លើយដូចតទៅ៖ ដោយខ្ញុំបាទមានអាយុច្រើនណាស់ហើយ ហើយម្យ៉ាងទៀត ព្រឹត្តិការណ៍ដែលបានកើតឡើងនោះវាជាង៣០មកឆ្នាំហើយ ជិត៤០ឆ្នាំហើយ ។ ដូច្នេះ ខ្ញុំអាចមានការច្រឡំក្នុងការឆ្លើយតបនឹងសំណួរផ្សេងៗ ។ ដើម្បីនឹងជៀសវាងការច្រឡំនេះ ខ្ញុំមានសំណូមពរថា ចង់បានខ្លឹមសារឬយើងហៅថា និក្ខេបបទនៃសំណួរជាមុនដើម្បីយើងយកទៅពិនិត្យពិចារណាមុននឹងឆ្លើយជូនតុលាការ...» ។

ចំណែកជនជាប់ចោទ នួន ជា បានបង្ហាញជំហររបស់ខ្លួនតាមរយៈមេធាវីអន្តរជាតិ វិចទ័រ កុបប៉េ ថា ខ្លួននឹងមិនលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបទេ ។ នេះមានន័យថា នួន ជា នឹងឆ្លើយសំណួរទាំងឡាយណាដែលអាចធ្វើទៅបាន ។



ប្រជាជនកម្ពុជាកំពុងជីកប្រលាយ លើកទំនប់នៅទីជនបទ
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារក

# សវនាការស្តីពីការស្តាប់សេចក្តីថ្លែងទុក្ខសោក និងព្យសនកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី

## ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការបន្ទាប់ ដើម្បីស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសវនាការនេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤រូបនៅក្នុងរយៈពេលមួយថ្ងៃ ។ ដើមបណ្តឹងរដ្ឋប្បវេណី ទាំងបួនរូបនេះមានដូចជា ស៊ូ សុទ្ធាវី, អ៊ូន ដល្លី, សាំង រ៉ាត់ និង យស ផល ។ គួរបញ្ជាក់ថា នៅក្នុងសវនាការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គ្រប់ភាគីទាំងអស់ដូចជា អង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី បានចោទសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ។ បន្ទាប់ពីភាគីទាំងអស់បានសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីបានចោទសំណួរមួយចំនួនទៅជនជាប់ចោទ ហើយ ខៀវ សំផន បានផ្លាស់ប្តូរជំហររបស់ខ្លួនក្នុងការរក្សាសិទ្ធិ មិនឆ្លើយតបនឹងសំណួរទាំងឡាយនោះ ដោយយល់ព្រមឆ្លើយតបសំណួរមួយចំនួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបន្ទប់សវនាការវិញ ។



នៅក្នុងរបបខ្មែរក្រហម
ម្ពុជា)

### ១) ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី

#### ក) ប្រវត្តិសាវតា

ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី កើតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៤០ នៅភូមិកន្ទួតធំ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុក ឈ្មោះ ស៊ូ យឹម និងម្តាយឈ្មោះ កូវ សុគន្ធ ស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីបច្ចុប្បន្នមិនទាន់មានគ្រួសារទេ ។

នៅក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីកំពុងរស់នៅក្នុងស្ថានទូតអូឡាំពិក ជាមួយមិត្តភក្តិដែលជាភេទទីបីដូចគ្នា សុទ្ធាវី និងមិត្តភក្តិ ត្រូវខ្មែរក្រហមភ្ជង់នឹងកាំភ្លើង រួចបញ្ជាឲ្យចាកចេញពីកន្លែងស្នាក់នៅ ដោយមិនផ្តល់ពេលវេលាសម្រាប់រៀបចំឥវ៉ាន់នោះឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះ ខ្មែរក្រហមបានបាញ់សម្លាប់មិត្តភក្តិរបស់ខ្លួនស្លាប់ភ្លាមៗចំនួន៤នាក់រួមមាន សារ៉ាយ ឌី វណ្ណា និង ផល្លា ។ បន្ទាប់មក សុទ្ធាវី ត្រូវខ្មែរក្រហមបញ្ជូនចេញពីទីក្រុងភ្នំពេញ តាមផ្លូវជាតិលេខ១ ជាមួយប្រជាជនជាច្រើនទៀត ។ ពេលទៅដល់ស្ពានព្រះមុនីវង្ស ដើមបណ្តឹងរដ្ឋប្បវេណីបានឃើញខ្មែរក្រហមបាញ់សម្លាប់ប្រជាជនដែលពុំព្រមទៅតាមគោលដៅដែលគេបានកំណត់ ។ នៅតាមផ្លូវ សុទ្ធាវី បានឃើញខ្មែរក្រហមចាប់រំលោភមិត្តភក្តិរបស់ខ្លួនយ៉ាងឃោរឃៅ ។ នៅពេលធ្វើដំណើរ សុទ្ធាវី មានការតក់ស្លុតជាខ្លាំង ដោយសារបានឃើញសាកសពប្រជាជន ទាហានលន់នល់ រួមទាំងព្រះសង្ឃស្លាប់ជាច្រើននៅតាមផ្លូវ និងមានអ្នកត្រូវរបួស និងអ្នកជម្ងឺទ្រហោយំជាច្រើនទៀតផង ។ ក្រោយមកមិត្តភក្តិរបស់ សុទ្ធាវី បានស្លាប់ជាបន្តបន្ទាប់ ។ រាងកាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនោះមានសភាពទ្រុឌទ្រោម និងស្គមយ៉ាងខ្លាំង ដោយសារការអត់អាហារ ទឹក គ្មានពេលសម្រាក គ្មានថ្នាំព្យាបាលជម្ងឺ និងធ្វើដំណើរទាំងយប់ទាំងថ្ងៃ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីផលប៉ះពាល់នៅក្នុងរបបខ្មែរក្រហមថា គាត់ទទួលរងការចាប់រំលោភជាច្រើនដងដោយប្រើអំពើហឹង្សា វាយបំបាក់ឆ្អឹងថ្គាម បង្ខំរួមភេទ ដាក់ខ្នោះជើង និងមានស្នាមរបួសគ្រប់កន្លែង ព្រមទាំងដាក់ច្រវ៉ាក់ជើងបន្ទាំងក្នុងគុករហូតធ្វើឲ្យស្នូងជើងស្តាំមានដំបៅរលួយយ៉ាងខ្លាំង ។ ដើម

បណ្ដឹងរដ្ឋប្បវេណី ស៊ូ សុទ្ធារី បានបន្តទៀតថា ថ្កាមនិងខ្នងជើងនៅតែបង្កបញ្ហា ដែលធ្វើឲ្យឈឺចាប់រហូតដល់ពេលបច្ចុប្បន្ន ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ការផ្ដល់សក្ខីកម្មនៅក្នុងសវនាការនេះ មានសារសំខាន់ណាស់ ព្រោះគាត់បានរង់ចាំអស់រយៈពេល៣០ឆ្នាំមកហើយ ក្នុងបំណងស្វែងរកយុត្តិធម៌ និងពុំចង់ឲ្យក្មេងៗជំនាន់ក្រោយយកគំរូតាមខ្មែរក្រហម និងចង់បង្ហាញជនរួមជាតិខ្មែរ និងអន្តរជាតិឲ្យដឹងថា ជនរងគ្រោះនៃរបបខ្មែរក្រហមទទួលរងការឈឺចាប់មានទំហំប៉ុណ្ណា រហូតដល់ពេលបច្ចុប្បន្ននេះ ។ ចំពោះសំណងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឲ្យមានសំណងជាសមូហភាព ដូចជាបណ្ណាល័យសម្រាប់តាំងឯកសាររបបខ្មែរក្រហម និងស្តូបសម្រាប់ជនរងគ្រោះ ដើម្បីគោរពបូជា ។

### ១) ការចោទសំណួរដោយដើមបណ្ដឹងរដ្ឋប្បវេណីចំពោះជនជាប់ចោទ

ជាចុងក្រោយដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុទ្ធារី បានចោទសំណួរពីរទៅកាន់មេដឹកនាំខ្មែរក្រហមថា ១-តើមេដឹកនាំខ្មែរក្រហមបានដឹងអំពីរឿងរ៉ាវដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមដូចអ្វី ដែលខ្លួនបានលើកឡើងនៅក្នុងសក្ខីកម្មនេះដែរឬទេ? ២-តើមេដឹកនាំនៃរបបខ្មែរក្រហមទទួលស្គាល់ការស្លាប់របស់ប្រជាជនកម្ពុជា ដែលបានស្លាប់នៅគុកមួយចំនួនដូចជា គុកទួលស្លែង បឹងជើងឯក និងគុកក្រាំងតាចាន់ ដែរឬទេ?

### ក) ការឆ្លើយតបសំណួរដោយជនជាប់ចោទ ខៀវ សំផន

ជនជាប់ចោទ ខៀវ សំផន បានឆ្លើយតបនឹងសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុទ្ធារី នៅក្នុងបន្ទប់សវនាការថា “សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល សូមជម្រាបសួរលោកអ៊ំ! ខ្ញុំឡើងមកឆ្លើយនេះ គឺទៅតាមមនោសញ្ចេតនារបស់ខ្ញុំ មើលទៅលើទុក្ខសោករបស់អ៊ំ តែខ្ញុំសូមជម្រាបលោកអ៊ំថា ខ្ញុំគឺ ខៀវ សំផន មិនមែន ប៉ុល ពត មិនមែន នួន ជា មិនមែន អៀង សារី, វ៉ន វ៉ែត, សុន សេន អីនោះទេ ។ មានន័យថា ខ្ញុំមិនអាចភ្ជាប់ខ្លួនខ្ញុំទៅកម្ពុជាប្រជាធិបតេយ្យទាំងមូលនោះទេ ។ ហើយខ្ញុំ លោកអ៊ំក៏អាចជ្រាបដែរ ខិតខំទៅរៀនសូត្រ ហើយខិតខំធ្វើអ្វីៗទាំងអស់ រហូតក្នុងមួយជីវិតខ្ញុំនេះមិនមែនដើម្បីប្រល័យពូជសាសន៍ជាតិខ្ញុំទេ ។ ខ្ញុំជាជាតិខ្មែរដែរ ខ្ញុំមិនអាចទៅប្រល័យពូជសាសន៍ជាតិខ្មែរខ្ញុំ ។ តើខ្ញុំទៅប្រល័យពូជសាសន៍ជាតិខ្មែរខ្ញុំឲ្យអ្នកណាមកនៅជំនួស? សូមលោកអ៊ំជ្រាប ។ ខ្ញុំនិយាយប៉ុណ្ណឹង លោកអ៊ំក៏អាចជ្រាបហើយ ។

ខ្ញុំគ្រាន់តែក្រោយពេលរដ្ឋប្រហារ រួមចំណែកធ្វើម៉េចឲ្យកម្លាំងជាតិទាំងអស់ រួបរួមគ្នា សាមគ្គី តស៊ូ ។ ដល់ក្រោយរដ្ឋប្រហារមក វាសង្គ្រាមវៀតណាម វាហៀរចូលមកជាតិយើង ក្នុងដីយើង ។ មហាយក្សទាំងអស់ដែលគេច្បាំងគ្នាពីមុននៅវៀតណាមខាងត្បូង ក្រោយរដ្ឋប្រហារគេមកច្បាំងគ្នាក្នុងដីយើង នៅក្នុងជាតិយើង ។ ហើយយើងជាស្រមោចតូចមួយ ដរីៗមកជាន់ឈ្លីយ៉ាងនេះ តើជាតិយើង វាសនាជាតិយើងទៅយ៉ាងម៉េច? ដូច្នេះហើយ បានជានាំឲ្យខ្ញុំ វាទៅជាមានមកត្រូវតែខំធ្វើជាតំណាង ធ្វើម៉េចឲ្យសម្ដេច សីហនុ ដែលលោកនៅប៉េកាំង ហើយបក្សកុម្មុយនីស្តកម្ពុជា ដែលគេមានលទ្ធភាពដឹកនាំតស៊ូនៅក្នុងប្រទេសរួមគ្នាតស៊ូ ការពារជាតិឲ្យជាតិបានរស់នៅជាកម្ពុជាមួយឯករាជ្យ អធិបតេយ្យកុំឲ្យរលំរលាយសាបសូន្យ ។ នេះជាសេចក្ដីសង្ឃឹមរបស់ខ្ញុំ ក៏ប៉ុន្តែខ្ញុំមិនមែនជាអ្នកដឹកនាំទេ មិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ ។ សូមលោកពូជ្រាប ។ ពិតមែនតែខ្ញុំមិនមានអីនិយាយវែងឆ្ងាយ ខ្ញុំសូមជម្រាបលោកអ៊ំប៉ុណ្ណឹងឲ្យអស់ពីចិត្តពីថ្លើមរបស់ខ្ញុំ ។ យ៉ាងណាៗ សូមអ៊ំយល់អធ្យាស្រ័យដល់ខ្ញុំផង ។ សូមអរគុណបាទ” ។

### ២) ដើមបណ្ដឹងរដ្ឋប្បវេណី អូន ផល្លី

#### ក) ប្រវត្តិសាវតា

ដើមបណ្ដឹងរដ្ឋប្បវេណី អូន ផល្លី មានអាយុ៤៨ឆ្នាំ កើតនៅភ្នំពេញ ។ បច្ចុប្បន្នរស់នៅស្រុកពញាឮ ខេត្តកណ្ដាល និងជាយោធិនចូលនិវត្តន៍ ។ ឪពុកឈ្មោះ អុន (ស្លាប់) និងម្ដាយឈ្មោះ មាន (ស្លាប់) ។ ដើមបណ្ដឹងរដ្ឋប្បវេណីមានប្រពន្ធឈ្មោះ ពេជ ណាម ហើយបច្ចុប្បន្នពុំមានកូនទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ពីស្ថានភាពពេលជម្លៀសចេញពីទីក្រុងភ្នំពេញ ជូនអង្គជំនុំជម្រះ ។ អូន ផល្លី បានធ្វើដំណើរចាកចេញជាមួយក្រុមគ្រួសារ ហើយនៅពេលនេះ ផល្លី អាណិតឪពុកម្ដាយយ៉ាងខ្លាំង ដោយសារត្រូវវែកពុនឥវ៉ាន់មួយចំនួន និងត្រូវពកូនតូចទៀត ។ នៅក្នុងការធ្វើដំណើរនេះ ដើមបណ្ដឹងរដ្ឋប្បវេណីនិងគ្រួសារត្រូវ

ចំណាយពេល១៥ថ្ងៃទើបទៅដល់ ភូមិព្រែកក្អោខេត្តព្រៃវែង ។ ក្រោយមកខ្មែរក្រហមបានហៅឪពុករបស់ខ្លួនទៅបាត់រហូត ។ ដោយដឹងពីដោគវាសនារបស់ប្ដី ម្ដាយរបស់ ផល្លី បានឲ្យគាត់ទៅរស់នៅជាមួយនឹងជីដូន ។ បន្ទាប់ពីទៅរស់នៅជាមួយជីដូនបានមួយរយៈ ផល្លី ទទួលដំណឹងថាម្ដាយ និងប្អូនៗរបស់ខ្លួនត្រូវគេយកទៅសម្លាប់ចោលទាំងអស់ ។ នៅឆ្នាំ១៩៧៧ ដើមបណ្ដឹងរដ្ឋប្បវេណី បងប្អូនជីដូនមួយ និងជីដូន ត្រូវគេបញ្ជូនទៅស្រុកមោងឬស្សី ហើយក្នុងពេលធ្វើដំណើរនោះ ខ្មែរក្រហមបានផ្ដល់ចំណីបន្តិចបន្តួចដល់ប្រជាជន ។ នៅពេលទៅដល់ស្រុកមោងឬស្សី ដើមបណ្ដឹងរដ្ឋប្បវេណីបានឃើញប្រជាជនជាច្រើនស្លាប់ ដោយសារតែភាពអត់ឃ្លាន ហើយនៅក្នុងចំណោមអ្នកស្លាប់ទាំងនោះក៏មានបងប្អូនជីដូនមួយ និងជីដូនរបស់ខ្លួនដែរ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់ថា នៅពេលនោះ គាត់ត្រូវរស់តែម្នាក់ឯងពុំមានសាច់ញាតិណាម្នាក់ ហើយ ផល្លី ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅជាមួយកងកុមារ ។ ពេលខ្លះខ្មែរក្រហម បានបញ្ជាឲ្យកុមារវាយគ្នាទៀតផង ។ ផល្លី ទទួលរងការឈឺចាប់នៅក្នុងចិត្តយ៉ាងខ្លាំង ដោយសារតែខ្មែរក្រហមបានបំបែកឪពុកម្ដាយ និងបងប្អូន បណ្ដោយឲ្យរស់នៅដោយគ្មានទីពឹង ហើយគាត់តែងតែគិតថា គាត់ជាមនុស្សម្នាក់មានវាសនាខុសគេ ។ ហេតុផលនេះបានជំរុញឲ្យ ផល្លី ចូលបម្រើកងទ័ពនៅក្រោយពេលរបបខ្មែរក្រហមបានដួលរលំ ដែលបណ្ដាលឲ្យទទួលរងនូវពិការភាព និងឈឺគ្រុនចាញ់រហូតដល់បច្ចុប្បន្ន ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តទៀតថា នៅពេលស្នាក់នៅព្យាបាលក្នុងមន្ទីរពេទ្យម្ដងៗ គាត់តែងតែយំនៅពេលឃើញអ្នកនៅក្បែរខ្លួន មានបងប្អូនចាំមើលថែ ចំណែកដើមបណ្ដឹងរដ្ឋប្បវេណីមានតែម្នាក់ឯង ។ ដើមបណ្ដឹងរដ្ឋប្បវេណីរៀបរាប់ទុក្ខសោករបស់ខ្លួនរហូតដល់ទប់ទឹកភ្នែកពុំបាន ។

### ១) ការថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ជាចុងក្រោយដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូន ផល្លី បានថ្លែងនូវសេចក្ដីទុក្ខសោកដែលទទួលរងពីរបបកម្ពុជាប្រជាធិបតេយ្យ និងសំណូមពរជូនតុលាការដូចតទៅ៖

“បាទ! ក្រោយមកដោយសារតែទុក្ខសោកនេះហើយ បានជាធ្វើឲ្យខ្ញុំស្ម័គ្រចិត្ត ធ្វើជាកងទ័ពនាំឲ្យរងរបួសពិការ និងគ្រុនចាញ់ជាបន្តបន្ទាប់ បណ្ដាលឲ្យមានជំងឺប្រចាំកាយរហូតដល់បច្ចុប្បន្ន ។ ហើយកាលនោះខ្ញុំរស់នៅតែក្នុងបន្ទាយទេ យកបន្ទាយធ្វើជាភូមិកំណើតរហូតដល់មានមិត្តភក្ដិរួមអាវុធក្នុងអង្គភាពជាមួយគ្នា គេបានយកមកនិយាយលេង ក៏ដូចជាចំអកមើលងាយដល់រូបខ្ញុំថា ខ្ញុំមិនដឹងឪពុកម្ដាយឈ្មោះអី ស្រុកកំណើតនៅឯណា ដោយសារតែខ្ញុំមិនដែលទៅផ្ទះនឹងគេម្ដងសោះក្នុងមួយឆ្នាំ ។ រីឯចំណែកគេគ្រប់គ្នាវិញ គេបានធ្វើដំណើរពី៤ទៅ៥ដងក្នុងមួយឆ្នាំគេបានទៅលេងផ្ទះ ។ ខ្ញុំមានការឈឺចាប់ណាស់ ។ ខ្ញុំលាក់លៀមបៀមទុក្ករហូត ខ្ញុំមិនប្រកាន់នឹងគេទេ ។ គ្មានពាក្យអ្វីឆ្លើយតបនឹងគេទេ ដោយសារតែខ្ញុំចង់លាក់លៀមបៀមទុកនូវប្រវត្តិរបស់ខ្ញុំ ។ តើហេតុអ្វី? មកពីខ្ញុំចេះតែមានអារម្មណ៍គិតថា ស្រមោលអតីតកាលនៅតែតាមលងខ្ញុំ ទើបខ្ញុំលាក់លៀម ។ នេះជាលើកទីមួយហើយ ដែលជាទំព័រជីវិតជាប្រវត្តិសាស្ត្រដែលខ្ញុំត្រូវបានលាតត្រដាងទៅកាន់ពិភពលោក ។

ជាចុងក្រោយនេះខ្ញុំសូមសំណូមពរឲ្យតុលាការជួយស្វែងរកយុត្តិធម៌អ្នក ដែលបានបាត់បង់ជីវិតក្នុងរបបនេះ ជាពិសេសគ្រួសាររបស់ខ្ញុំផ្ទាល់ និងស្វែងរកយុត្តិធម៌សម្រាប់អ្នកដែលរស់រានមានជីវិតក្នុងរបបនេះ ជាពិសេសគ្រួសាររបស់ខ្ញុំផ្ទាល់ និងស្វែងរកយុត្តិធម៌ សម្រាប់អ្នកដែលរស់រានមានជីវិតដូចជារូបខ្ញុំ និងប្រជាជនកម្ពុជាទូទាំងប្រទេស ហើយ[ខ្ញុំ]ក៏សូមអង្វរកដល់អ្នកដឹកនាំក្នុងជំនាន់នេះ ឬក៏ជំនាន់ក្រោយៗទៀតក្ដី និងអ្នកដឹកនាំគ្រប់ជាតិសាសន៍នៅក្នុងពិភពលោក ទោះជាមានជំនឿប្រពៃណីសាសនាខុសគ្នាប៉ុណ្ណាក្ដី សូមឲ្យបញ្ចប់ការឈឺចាប់ ភាពវេទនាភាពខ្លោចផ្សារនេះទៅ ព្រោះជាក់ស្ដែង ខ្ញុំជាសក្ខីភាពស្រាប់ ខ្ញុំបានជួបអ្វីទាំងអស់គ្រប់បែបយ៉ាង ។ ឈឺចាប់ណាស់ ហើយការឈឺចាប់នេះ ក៏អាចទៅជាសង្គ្រាមលោកបានដែរ ។ ព្រោះតែខ្ញុំអស់រលីង បានខ្ញុំចង់ឲ្យពិភពលោកនេះខ្ទេច រលាយ កុំឲ្យការឈឺចាប់នេះរីកធំធាត់ដុះដាលរហូតដល់សង្គ្រាមលោក ។

សូមរួមគ្នាបញ្ចប់ទៅ ពិភពលោកទាំងឡាយអើយ ។ ការឈឺចាប់នេះ ការរស់នៅ ការតែលតោលឯកោម្នាក់ឯងនេះ បៀមទុក្ខនេះ គឺពិបាកទ្រាំណាស់ ។ ទោះជាយើងមានការហូបចុក ស៊ីចាយយ៉ាងណាក្ដី ក៏យើងនៅតែមានអារម្មណ៍ឈឺចាប់ក្នុងចិត្តរហូត

ព្រោះដោយសារតែយើងគ្មានអ្វីពឹងផ្អែក ថែមទាំងគ្មានកូនទៀត ដោយសារតែខ្ញុំមានជំងឺ ។ កាលនោះខ្ញុំបានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យពីមួយកន្លែងទៅមួយកន្លែងឃើញតែគេមានឪពុកម្តាយបងប្អូន ប្រពន្ធកូនមើលថែទាំចេញចូលបម្រើទឹកក្តៅ ទឹកត្រជាក់ ។ រីឯមើលមកខ្លួនឯងប្រឹងត្រដររស់ទៅតាមយថាកម្មរបស់ខ្លួន ។ គ្មាននរណាដឹង ដោយសារតែខ្ញុំចង់លាក់លៀមនូវជីវប្រវត្តិជីវិតរបស់ខ្ញុំអស់រយៈពេលជាង៣០ឆ្នាំ ។ សូមបញ្ចប់» ។

## ៣) ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់

ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់ មានអាយុ៧២ឆ្នាំ កើតនៅភូមិព្រៃស្វា ឃុំជីរះពេន ស្រុកសំរោង សព្វថ្ងៃរស់នៅខេត្តកំពង់ស្ពឺ ។ ម្តាយឈ្មោះ គីម និងឪពុកឈ្មោះ សាំង ។ បច្ចុប្បន្នដើមបណ្តឹងរដ្ឋប្បវេណីមានស្វាមីឈ្មោះ ភួន (ដែលត្រូវជាស្វាមីទី២) និងមានកូនម្នាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវខ្មែរក្រហមជម្លៀសចេញពីខេត្តកំពង់ស្ពឺទៅស្រុកមោងឫស្សី ខេត្តបាត់ដំបងនៅចុងឆ្នាំ១៩៧៥ ជាមួយស្វាមីដើម និងកូន៤នាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅតាមផ្លូវធ្វើដំណើរមានការលំបាកដោយសារឡានផ្ទុកមនុស្សជាច្រើនបណ្តាលឲ្យចង្អៀតយ៉ាងខ្លាំង ហើយពុំមានអ្វីហូបឡើយ សូម្បីតែទឹក ទោះបីជាកូនរបស់ខ្លួនយំខ្លាំងយ៉ាងណាក៏ដោយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តទៀតថា ក្រោយពេលទៅដល់ស្រុកមោងឫស្សី នៅចុងឆ្នាំ១៩៧៦ កូនៗទាំង៤នាក់ និងស្វាមីរបស់ខ្លួនបានស្លាប់បន្តបន្ទាប់នៅចំពោះមុខ ដោយសារការអត់អាហារ ។ ក្នុងរយៈពេលតែ២យប់ប៉ុណ្ណោះ ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់ បាត់បង់កូនចំនួន៤នាក់ ព្រមទាំងស្វាមីហើយគាត់ពុំមានសិទ្ធិយំឡើយ ដោយសារខ្លាចខ្មែរក្រហមចោទថាជាខ្មាំង ។ ក្រោយពេលប្តី និងកូនបានស្លាប់ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានរបបអាហារប្រសើរជាងមុនបន្តិច ប៉ុន្តែជីវភាពរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានភាពលំបាកវេទនាយ៉ាងខ្លាំងតែម្នាក់ឯង បន្ទាប់មកបានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ខ្មែរក្រហមបានបញ្ជូន សាំង រ៉ាត់ ទៅព្យាបាលនៅមន្ទីរពេទ្យមួយនៅវត្តចាស់ ហើយតាមអ្វី ដែលខ្លួនបានដឹងអ្នកជំងឺដែលត្រូវព្យាបាលនៅមន្ទីរពេទ្យនោះស្លាប់ទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឃើញបុគ្គលិកពេទ្យរបស់ខ្មែរក្រហមឲ្យថ្នាំទៅអ្នកជំងឺ ហើយក្រោយមកអ្នកជំងឺនោះស្លាប់ភ្លាមបន្ទាប់ពីលេបថ្នាំនោះ ។ ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណីក៏ទទួលបានថ្នាំនោះដូចគ្នា ។ ឃើញដូច្នេះ សាំង រ៉ាត់ បានគេចចេញពីការលេបថ្នាំ ហើយកុហកបុគ្គលិកពេទ្យនោះថា ខ្លួនបានលេបថ្នាំរួចហើយ ។ ក្រោយមក សាំង រ៉ាត់ ត្រូវគេបញ្ជូនទៅធ្វើការងារជាទម្ងន់ដូចមុនវិញ ។ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បន្ទាប់ពីខ្មែរក្រហមដួលរលំ ដើមបណ្តឹងរដ្ឋប្បវេណីបានត្រឡប់មករស់នៅស្រុកកំណើតវិញ ប៉ុន្តែការរស់នៅបន្ទាប់ពីរបបខ្មែរក្រហមពិតជាមានទុក្ខវេទនាគ្មានពេលណាស្មើយ ដោយសារតែការបាត់បង់ប្តី និងកូនៗទាំងអស់រួចត្រូវរស់តែម្នាក់ឯងគ្មានសាច់ញាតិ ។ ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់ បានស្នើសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យគ្រួសាររបស់ខ្លួន ដោយសារគាត់មានទុក្ខសោកយ៉ាងខ្លាំងចំពោះការបាត់បង់ប្តី និងកូនៗ ។ គួរបញ្ជាក់ថា ការស្តាប់សក្ខីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់ បានបញ្ចប់ក្រោយពេលសហព្រះរាជអាជ្ញាបញ្ចប់ការតាំងសំណួរ ដោយសារមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ពុំមានសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ។

## ៤) ដើមបណ្តឹងរដ្ឋប្បវេណី យស ផល

### ក) ប្រវត្តិសាវតា

ដើមបណ្តឹងរដ្ឋប្បវេណី យស ផល មានអាយុ៥៨ឆ្នាំ កើតនៅគោកញ៉ែរ ឃុំព្រៃស្វឹក ស្រុកទ្រាំង ខេត្តតាកែវ ។ បច្ចុប្បន្នរស់នៅភូមិគោកឃ្មោង ឃុំនោម ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ យស ស្លួង (ស្លាប់) ចំណែកម្តាយឈ្មោះ យុន សន ។ ប្រពន្ធឈ្មោះ យិន សុភាព និងមានកូន ៨នាក់ ។

នៅក្នុងរបប លន់ នល់ ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើជានគរបាល ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៩ ផល ត្រូវខ្មែរក្រហមប្រាប់ឲ្យចាកចេញពីទីក្រុងភ្នំពេញរយៈពេលបីថ្ងៃដើម្បីរៀបចំក្រុង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើដំណើរចេញតាមស្ពានជ្រោយចង្វារ កាត់តាមកំពង់ចម្លងព្រែកក្តាមរហូតដល់ស្រុកផ្សារ ។ នៅពេលធ្វើដំណើរសុខភាពរបស់ ផល មានសភាពចុះទ្រុឌទ្រោមយ៉ាងខ្លាំង ដោយសារមានជំងឺគ្រុនក្តៅយ៉ាងខ្លាំង ព្រមទាំងពុំមានថ្នាំព្យាបាល ។ ផល បានបេះស្លឹកស្មៅនៅតាមផ្លូវ ដើម្បីបុក

យកទឹកដីក ។ នៅតាមផ្លូវ ផល បានឃើញសាកសពទាហាន នគរបាល និងមនុស្សជាច្រើន មានចាស់ និងក្មេងរងរបួស ។ ផល បានឃើញឡានចិនធំៗចំនួន៣គ្រឿង បើកបរដោយខ្មែរក្រហម ដឹកមនុស្សចេញទៅតាមព្រែកក្ដាម ត្រើយខាងកើតឆ្ពោះទៅស្រុកផ្អាវ ។ នៅទីនោះ ខ្មែរក្រហមតម្រូវឲ្យប្រជាជនធ្វើប្រវត្តិរូប ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានកុហកប្រវត្តិរូបរបស់ខ្លួនថា ជាភ្នាក់ងារបម្រុងរដ្ឋការ ក្រោយមកត្រូវគេបញ្ជូនទៅខេត្តកំពង់ចាម ។ ផល បានឃើញខ្មែរក្រហមបញ្ជូនអតីតអ្នកដែលមានសក្តិចាប់ពី សក្តិ១ម្ដងមួយៗចេញទៅបាត់ ។ ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល មានការភិតភ័យជាខ្លាំងនៅពេលដែលខ្មែរក្រហមសួរពីប្រវត្តិរូប ដោយសារគាត់នឹកឃើញពីទិដ្ឋភាពសាកសពនៅតាមផ្លូវ ហើយមានការព្រួយបារម្ភចំពោះជោគវាសនារបស់ខ្លួន មិនដឹងថ្ងៃណាជួបរឿងបែបនេះឡើយ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់ថា គាត់ទទួលរងការប៉ះទង្គិចផ្នែកសុខភាពជាខ្លាំង ចំណែកបងប្អូនសាច់ញាតិក៏បាត់បង់អស់ ។ បច្ចុប្បន្ន ផល មានការពិបាកចិត្តរាល់ពេលដែលនឹកឃើញរឿងនេះ ។ ដើមបណ្ដឹងរដ្ឋប្បវេណីតែងតែភ័យញ័រ ឈឺក្បាល វិលមុខ ញ័រដៃញ័រជើង និងចុកទ្រូង ។

### ខ) ការថ្លែងទុក្ខសោកដោយដើមបណ្ដឹងរដ្ឋប្បវេណី

ជាចុងក្រោយដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានថ្លែងថា "បាទ ! ថ្ងៃនេះ ខ្ញុំសូមអរគុណ ។ ខ្ញុំបានរង់ចាំធ្វើសក្ខីកម្មអស់ជាង ៣០ឆ្នាំមកហើយ ។ ខ្ញុំពាំទុក្ខព្រួយពេញដើមទ្រូង ពេញខ្លួន ។ ខ្ញុំមិនដឹងនិយាយការពិតហ្នឹង យកស្ដែងហ្នឹងកន្លែងណាទេ ។ អញ្ចឹងមានតែស្ដែងនៅមុខតុលាការ សូមឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំ ហើយខ្ញុំក៏បានរីករាយតាមហ្នឹងដែរ ។ ខ្ញុំជាជនក្រីក្រទៅហើយ វាបាត់បង់អស់ហើយគ្មានសល់អីទេ ។ កម្មេចតាំងពីរបស់ទ្រព្យ កម្មេចតាំងពីមាមីង ឪពុកម្ដាយ និងអ្វីៗទៀត ។ ប៉ុន្តែខ្ញុំសំណូមពរសុំស្តូបដើម្បីតម្កល់អដ្ឋិធាតុបងប្អូនជនរួមជាតិ ឪពុកម្ដាយ ញាតិសន្ដានខ្ញុំ ទី១ ។ ទី២ ខ្ញុំសូមបណ្ណាល័យ ដែលមានឯកសារសម្រាប់ដាក់ទុកឲ្យក្មេងៗ និងប្អូនៗជំនាន់ក្រោយយកទៅសិក្សាឲ្យយល់ពីរបបខ្មែរក្រហម ហើយទី៣ខ្ញុំបាទសូមបណ្ណព្យាបាលជំងឺដោយមិនយកកម្រៃ ។ បាទសូមអរគុណ" ។

### គ) ការចោទសំណួរដោយដើមបណ្ដឹងរដ្ឋប្បវេណីចំពោះជនជាប់ចោទ

ក្រោយពេលបញ្ចប់សេចក្ដីថ្លែងរបស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណី បានតាំងសំណួរចំនួន៥ ទៅជនជាប់ចោទ នួន ជា និង ខៀវ សំផន ដូចតទៅ ៖

១) ហេតុអ្វីបានជាមានការកាប់សម្លាប់មិនរើសមុខ?

២) ហេតុអ្វីបានជាបង្ខំឲ្យធ្វើការដូចសត្វធាតុ គ្មានពេលសម្រាក មិនថាចាស់ មិនថាក្មេង និង មិនឲ្យហូបឆ្អែត?

៣) ហេតុអ្វីបានជាហាមប្រជាជនមិនឲ្យយករបស់ដែលខ្លួនដាំបាន បើហ៊ានហូប យកទៅកសាង ឬសម្លាប់ចោល?

៤) ប្រទេសកម្ពុជាជាប្រទេសសម្បូរភោគផល ហេតុអ្វីបានជាយកភោគផលហ្នឹងទៅឯណា?

៥) ហេតុអ្វីមិនឲ្យមានកម្មសិទ្ធិឯកជន ហើយប្រមូលទ្រព្យសម្បត្តិហ្នឹងដាក់ជារួម? ហេតុអ្វីមេដឹកនាំខ្មែរក្រហមសុទ្ធតែមានចំណេះដឹងខ្ពស់ៗ ហើយមិនបង្កើតសាលារៀន ហើយសម្លាប់អ្នកចេះដឹង?

### ឃ) ការឆ្លើយតបសំណួរដោយជនជាប់ចោទ ខៀវ សំផន

ជនជាប់ចោទ ខៀវ សំផន បានឆ្លើយតបសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណីថា ៖

"បាទ! សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រមទាំងអស់ សូមគោរពដល់អង្គសវនាការទាំងមូល ។ សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ។

ជាដំបូងខ្ញុំសូមជម្រាបលោកថា ខ្មែរក្រហមគឺមិនមែនជាខ្ញុំទេ ។ ហើយខ្ញុំក៏មិនអាចទទួលខុសត្រូវ ចំពោះអំពើដែលគេចោទនោះដែរ ។ ខ្ញុំយកឧទាហរណ៍ដូចជាលោក ហ៊ុន សែន ជាដើម លោកក៏តើលោកទទួលខុសត្រូវនឹងអំពើរបស់ខ្មែរក្រហមទេ? ហើយខ្ញុំវិញ ខ្ញុំរិតតែមិនដូច លោក ហ៊ុន សែន ទៅទៀត ។ ខ្ញុំអត់ដឹងអ្វីទាំងអស់ អ្វីដែលកើតមានឡើងក្នុងចន្លោះ ឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩ ។ និយាយយ៉ាងនេះហើយ ខ្ញុំក៏សូមរួមមនោសញ្ចេតនាខ្លោចផ្សាជាមួយលោក ដែលលោកបានជួបប្រទះនឹងការលំបាកវេទនា បាត់បង់ឪពុកម្ដាយ បាត់បង់បងប្អូន បាត់បង់អ្នកជាទីស្រលាញ់របស់លោក ។

ម្យ៉ាងទៀត ខ្ញុំក៏សូមឆ្លើយនឹងសំណួរមួយចំនួនទៀតរបស់

លោក ។ អំពីដែលថា ហេតុអ្វីបានជាមានការកាប់សម្លាប់? ដូចខ្ញុំបានជម្រាបហើយ ខ្ញុំជម្រាបលោកមិនបានទេពីរឿងនេះ ព្រោះខ្ញុំអត់ដឹងរឿងអ្វីទាំងអស់ ។ ខ្ញុំមកមានការទាក់ទិនជាមួយខ្មែរ-ក្រហម ដូចខ្ញុំបានជម្រាបពីព្រឹកមិញ អញ្ចឹងហើយ គឺដូរាក្ខាប់កម្លាំងទាំងអស់ដែលតស៊ូនៅពេលក្រោយរដ្ឋប្រហារ ដែលមាននាំឲ្យមានសង្គ្រាមវៀតណាមរីករាលដាលដល់កម្ពុជា ហើយយើងត្រូវតែតស៊ូ រួបរួមគ្នារតស៊ូដើម្បីឲ្យកម្ពុជាយើងរស់ កុំឲ្យរលាយបាត់បង់ចេញពីផែនទីសកលលោក ។ ចេតនាខ្ញុំមានតែប៉ុណ្ណឹង ។ ប៉ុន្តែថា ឲ្យខ្ញុំទៅធ្វើជាអ្នកដឹកនាំ? អត់ទេ ។ អាហ្នឹងខ្ញុំសូមជម្រាបលោកយ៉ាងនេះ ។ ដូច្នេះពីរឿងកាប់សម្លាប់អីនេះ ខ្ញុំក៏មិនយល់ដែរ ខ្ញុំក៏មិនចង់ឲ្យមានកើតរឿងរ៉ាវ ដ៏មហន្តរាយយ៉ាងនេះដែរ ។ ហើយខ្ញុំក៏គ្មានសិទ្ធិអំណាចអ្វីទៅទប់ទល់មិនឲ្យកើតមាន ក៏មិនបានដែរ ព្រោះខ្ញុំគ្មានសិទ្ធិអំណាចអ្វីទាល់តែសោះ ។ នេះសុំឆ្លើយនឹងសំណួរទី១ ។

សំណួរទី២ ហេតុអ្វីបានជាមិនឲ្យប្រជាជនយើងហូបគ្រប់គ្រាន់? រឿងហ្នឹងខ្ញុំសូមជម្រាបលោកដូចតទៅ ៖ ខ្ញុំនិយាយដោយខ្លីទេ ហើយដើម្បីងាយៗយល់នៅពេលនេះ ។ អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យក៏អត់សំបូរហូរហៀរទេ ។ ហូបប្រចាំថ្ងៃសម្លម្ជូរ សម្លកកូរ សម្លប្រហើរធម្មតា ។ អត់មានស្រាវីស្គី អត់មានអីទេប្រចាំថ្ងៃ ។ ហូបទឹកក្តៅៗគេដាក់នៅកន្លែងមួយ អញ្ចឹងម្នាក់ៗទៅដួសយកមកហូបខ្លួនឯងទៅ ។ ប៉ុន្តែ ហូបគ្រប់គ្រាន់ល្មមប៉ុណ្ណឹង មិនបរិបូរណ៍ហូរហៀរទេ ។ ឯកន្លែងផ្សេងទៀតនៅក្រសួងមន្ទីរផ្សេងៗទៀត តាមខ្ញុំដឹង មិនសំបូរហូរហៀរទេ តែគេហូបគ្រប់គ្រាន់ល្មមដែរ ។ ដូច្នេះ តាមកាលដែលខ្ញុំឃើញយ៉ាងនេះ ខ្ញុំស្មានតែនៅជនបទ ប្រជាជនយើងក៏ហូប ប្រហាក់ប្រហែលគ្នាពីហ្នឹងដែរ ។ ហើយខ្ញុំអ្នកចែកចាយឥវ៉ាន់ ។ អ្វីៗមានបញ្ជូនទៅជនបទទាំងអស់ ប្រមូលទៅហើយ ខំប្រមូលដូចសាក្សីខ្លះបាននិយាយហើយ ឡានរាប់រយរាប់ពាន់ដូនទៅដឹកជញ្ជូនទៅ ។ ដូច្នេះពីរឿងអត់បាយនោះខ្ញុំក៏សូមឆ្លើយជម្រាបលោកយ៉ាងនេះ ។

ឯពីរឿងថា ហេតុអ្វីបានជាមិនឲ្យអស់លោកបេះផលដំណាំដែលលោកដាំជុំវិញផ្ទះរបស់លោក? រឿងហ្នឹងក៏ខ្ញុំអត់ដឹង ។ ខ្ញុំមិនយល់ស្របទាល់តែសោះ ហាមប្រាមប្រជាជនមិនឲ្យមានបានទទួលផលពីដំណាំដាំផ្ទះដែលខ្លួនបានដាំជុំវិញផ្ទះរបស់ខ្លួននោះ ។

ឯពីរឿងរៀបការដោយបង្ខំ ក៏ខ្ញុំរឹតតែមិនដឹងទៅទៀត ដោយពីព្រោះអ្វី? ពីព្រោះនៅមន្ទីរនៅភ្នំពេញអត់មានរឿងនោះសោះ ។

ឥឡូវខ្ញុំសូមជម្រាបពីថា ហេតុអ្វីបានជាមិនឲ្យមានសាលារៀន មិនបើកឲ្យមានសាលារៀន? អាហ្នឹងខ្ញុំដឹងអំពីមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ គេឈរលើពិសោធដែលជំនាន់មុន ជំនាន់សម្តេចសីហនុកសាងបានអ្នកចេះធំៗបានបួននាក់បានបួនប្រាំនាក់ដែរ សុទ្ធតែវិស្វករធំៗ ។

ខ្ញុំសូមជូនឧទាហរណ៍ ដូចជាលោក ដួន មុំ លោកសញ្ញាបត្រខ្ពស់ជាងគេបំផុតហៅថា ពហុបច្ចេកទេស ។ ឧទាហរណ៍មួយទៀតលោក ផ្លេក ឆាត ។ លោកជាវិស្វករផ្នែកថ្នល់ និងខាងស្ពានប៉ុន្តែបានសញ្ញាបត្រហ្នឹងមក មកដល់កម្ពុជាមានធ្វើអ្វីកើត ដើម្បីជួយរួមចំណែកកសាងប្រទេសទេ បែរទៅជាធ្វើរដ្ឋមន្ត្រីវិញ ។ ហេតុម៉េច? ពីព្រោះចេះតែពីរបីនាក់ វាគ្មានអ្នកដែលបន្តដៃបន្តជើង ចេះល្មមៗហូរហែមកទៀត ។ និយាយមួយម៉ាត់ទៅ ចេះហ្នឹង ចេះដាច់ពីសង្គមម្តង ។ សេដ្ឋកិច្ចរបស់ប្រទេស វាមិនទាន់ដល់ថ្នាក់ហ្នឹង ។ ហើយយើងចេះ តែយើងទៅធ្វើអីកើត ។ ដូច្នេះហើយ បានជាយើងមាននយោបាយថា យើងកុំទាន់អាលបើកសាលាឥឡូវនេះ ។ កូនក្មេងទៅរៀនផងធ្វើផង ។ បើនៅស្រុកស្រែ ជួយធ្វើស្រែ ជួយរកជី ដូចជាលោកមានប្រសាសន៍អីចឹង ។ រកទន្រ្ទានខែត្រ រកជី អីអីចឹងទៅ សង្គមវាកាន់តែប្រទេសវាកាន់តែវិវត្តលឿនទៅ ។ ទើបយើងឈានទៅរៀនថ្នាក់ខ្ពស់ ។ ហើយក៏មានកម្មវិធីដែរ កម្មវិធីថាឲ្យរៀបចំសាលាមួយខ្ញុំឮសួរលោក ប៉ុល ពត សួរលោក ដួន មុំ «តើយើងអាចបង្រៀនតាមវិធីផ្លូវកាត់បានទេ កុំឲ្យមានទ្រឹស្តីច្រើនពេកបន្ថយទ្រឹស្តី? ប៉ុន្តែឲ្យតែល្មមៗ យល់ដឹងបណ្តើរៗពីទាបទៅខ្ពស់» ។ គេមានរៀបចំអីចឹង ។ ដូច្នេះមិនមែនថា បំបាត់សាលាហ្នឹង ដើម្បីបំបាត់រហូតនោះទេ ។ ខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង ។ សរុបមួយម៉ាត់មកទី១ ខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ ។ ទី២ ព្រឹត្តិការណ៍ជាច្រើនសំខាន់ៗ ខ្ញុំអត់បានដឹងក្នុងឆ្នាំ១៩៨៥ ទៅឆ្នាំ១៩៧៩ ។ សូមអស់» ។

# សវនាការស្តាប់សេចក្តីថ្លែងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី

## ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបើកសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤រូប រួមមាន ធុច ផាន់ដារ៉ា ស, ចាន់ សុជាតិ, ហូ ចន្ថា និង ឆេង អេងលី ។ សវនាការនេះធ្វើឡើងដើម្បីស្តាប់សក្ខីកម្ម និងសេចក្តីថ្លែងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង៤រូប អំពីផលប៉ះពាល់ដែលគាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

មុននឹងផ្តល់វេទិកាជូនភាគីទាំងអស់សួរដេញដោល ប្រធានអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗក្នុងការថ្លែងអំពីភាពទុក្ខសោក និងការខូចខាតទាំងផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈនានាដែលកើតចេញពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទ ខៀវ សំផន និង នួន ជា ។ នីតិវិធីនៃសវនាការនេះ ចាប់ផ្តើមដំបូងដោយការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗអាចសួរសំណួរមួយចំនួនទៅជនជាប់ចោទតាមរយៈប្រធានអង្គជំនុំជម្រះ ។ បន្ទាប់ពីជនជាប់ចោទឆ្លើយសំណួររួចភាគីនីមួយៗអាចសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីបាន ។ គួរកត់សម្គាល់ថា ក្នុងអំឡុងពេលសវនាការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលធ្លាប់បានរក្សាសិទ្ធិមិនឆ្លើយតបសំណួរកន្លងមក បានប្រែគោលជំហរ ដោយធ្វើការឆ្លើយតបស្ទើរគ្រប់សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ លើសពីនេះទៀត ជនជាប់ចោទទាំងពីររូបតែងតែសម្តែងនូវការរំលែកទុក្ខចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ។

### ១) ដើមបណ្តឹងរដ្ឋប្បវេណី ធុច ផាន់ដារ៉ា ស

លោកស្រី ធុច ផាន់ដារ៉ា ស កើតថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៤៧ មានស្រុកកំណើតនៅទីក្រុងភ្នំពេញ បច្ចុប្បន្នរស់នៅទីក្រុងប៉ារីស ប្រទេសបារាំង ។ និយាយជាភាសាបារាំង លោកស្រី ផាន់ដារ៉ា ស បញ្ជាក់ថា នៅពេលឃើញខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញភ្លាម លោកស្រី ក៏ដូចជាប្រជាជនផ្សេងទៀតដែរមានការសប្បាយរីករាយជាខ្លាំង ព្រោះគិតថាប្រទេសនឹងមានសន្តិភាព ។ ពេលនោះ ប្រជាជនជាច្រើន រួមទាំងម្តាយរបស់លោកស្រី បានកាន់ទង់ជ័យសគ្រវី ហើយស្រែកថា «យើងលែងមានសង្គ្រាមទៀតហើយ» ។ ក្រោយមកបន្តិច យោធាខ្មែរក្រហមស្រែកឲ្យប្រជាជនចេញពីផ្ទះដោយប្រាប់ថា អង្គការត្រូវការរៀបចំទីក្រុងឲ្យបានស្អាត និងដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ ពេលនោះ លោកស្រីមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះយោធាខ្មែរក្រហមបានបង្ហាញទឹកមុខយ៉ាងកាចសាហាវ ។ ភ្លាមៗនោះ ក្រុមគ្រួសាររបស់ ផាន់ដារ៉ា ស រួមមានឪពុកម្តាយ និងកូនក្មេងចំនួន៤នាក់ត្រូវធ្វើដំណើរចេញពីផ្ទះយ៉ាងប្រញាប់ប្រញាល់ ដោយពុំបានយកទ្រព្យសម្បត្តិ ទៅតាមច្រើនឡើយ មានតែអង្ករ និងថ្នាំសង្កូវបន្តិចបន្តួចប៉ុណ្ណោះ ។

ពេលធ្វើដំណើរ ផាន់ដារ៉ា ស បានឃើញសាកសពជាច្រើននៅតាមផ្លូវ ហើយពេលនោះ គាត់កាន់តែមានការភ័យខ្លាចកាន់តែខ្លាំង ។ យោធាខ្មែរក្រហមស្រែកសម្លុតយកនាឡិកាពីប្រជាជនដែលកំពុងធ្វើដំណើរ ក្រោយមកមានស្នូរបាញ់កាំភ្លើង ប៉ុន្តែលោកស្រីពុំឈប់នៅមើលឡើយ ហើយពេលនោះ លោកស្រីកាន់តែមានការភ័យខ្លាច ។ យោធាខ្មែរក្រហមប្រាប់ឲ្យប្រជាជនធ្វើដំណើរទៅមុខរហូត ប៉ុន្តែ ពុំប្រាប់ថាត្រូវទៅទីណាឡើយ ។ មានស្ត្រីឆ្លងទន្លេនៅតាមផ្លូវ អ្នកជំងឺព្យួរសេរ៉ូមជាប់ដៃ កូនក្មេង និងមនុស្សជាចាស់ជាច្រើន បានធ្វើដំណើរដោយថ្មើរជើងក្រោមពន្លឺថ្ងៃក្តៅហែង ដែលគួរឲ្យអាសូរបំផុត ។

ធ្វើដំណើរជាច្រើនថ្ងៃ ផាន់ដារ៉ា ស បានទៅដល់ភូមិអង្គរមាស ។ អ្នកភូមិបានខ្សឹបប្រាប់គាត់ឲ្យបំផ្លាញអត្តសញ្ញាណបណ្ណលិខិតស្នាមផ្សេងៗ និងប្តូរឈ្មោះ ផាន់ដារ៉ា ស ដាក់ឈ្មោះផ្សេង ។ ចាប់ពីពេលនោះមក ផាន់ដារ៉ា ស បានប្តូរឈ្មោះមក ធែល វិញ ។ នៅក្នុងភូមិនេះបានមួយរយៈខ្លី ផាន់ដារ៉ា ស ត្រូវបានខ្មែរក្រហមជម្លៀសទៅដល់ខេត្តកំពង់ឆ្នាំង បន្តទៅបាត់ដំបងចុងក្រោយទៅដល់ភ្នំដើងទិញ ។ នៅទីនោះពុំមានអ្វីទាំងអស់ ប្រជាជនដែលទៅ

ដល់ទីនោះត្រូវសង់ខ្ទមនៅខ្លួនឯង ហើយទទួលបានរបបអាហារតែបន្តិចបន្តួចប៉ុណ្ណោះ ។ ប្រជាជននៅទីនោះ មានការលំបាកជាខ្លាំង ។ ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមតម្រូវឲ្យធ្វើការដោយអូសនង្គ័លជំនួសគោក្របី ។ ថ្ងៃមួយ ក្រុមគ្រួសាររបស់ ផាន់ដារា ស ត្រូវបានខ្មែរក្រហមនាំទៅដល់បឹងកន្ទួត ដើម្បីសួរចម្លើយ ។ ពេលនោះ តាផន ដែលជាមេកង បានសួរម្តងហើយម្តងទៀតថា តើ ផាន់ដារា ស មានស្វាមីជាមន្ត្រីរាជការជាន់ខ្ពស់ ជាឧត្តមសេនីយ៍ ឬជាគ្រូពេទ្យដែរឬទេ? ប៉ុន្តែ ផាន់ដារា ស បានលាក់ប្រវត្តិប្តីរបស់គាត់ដែលជាគ្រូពេទ្យដោយប្រាប់ថា ជាប្រជាជនសាមញ្ញ និងលក់គ្រឿងទេសបន្តិចបន្តួច ។ ក្រោយមកក្រុមគ្រួសាររបស់ ផាន់ដារា ស ត្រូវបានដោះលែងឲ្យត្រឡប់មកកន្លែងវិញ ប៉ុន្តែត្រូវបានបំបែកឲ្យនៅដាច់ពីគ្នា ដោយមានគិញនៅឈ្លបយកការណ៍រហូត ។

បន្ទាប់ពីធ្វើសេចក្តីថ្លែងទុក្ខសោកចប់ ផាន់ដារា ស បានឆ្លើយតបសំណួរមួយចំនួនរបស់មេធាវី ម៉ារី ហ្គីរ៉ូដ ជាសហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ឆ្លើយតបសំណួរ ផាន់ដារា ស បានបញ្ជាក់ថា មូលហេតុដែលលោកស្រីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសម្រេចផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ គឺដើម្បីរកយុត្តិធម៌ជូនឪពុកដែលបានស្លាប់ទាំងវ័យក្មេង (៤៤ឆ្នាំ) ដោយខ្មែរក្រហមវាយទម្លាក់ចូលក្នុងរណ្តៅ ។ ចំណែកកូនរបស់របស់គាត់បានស្លាប់ដោយជំងឺរលាកខួរក្បាល ដោយសារគ្មានថ្នាំព្យាបាល ។ ដូច្នេះ ការទទួលយុត្តិធម៌នឹងធ្វើឲ្យព្រលឹងឪពុក និងកូនរបស់លោកស្រីបានស្ងប់ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ឃីត វែន័រ ពាក់ព័ន្ធនឹងបុគ្គលម្នាក់ឈ្មោះ ថាច់ សារី លោកស្រី ផាន់ដារា ស បានបញ្ជាក់ថា ថាច់ សារី ត្រូវជាបងប្អូនជីដូនមួយសាច់ថ្លៃរបស់គាត់ ។ នៅក្នុងរបប លន់ នល់ ថាច់ សារី មានឋានន្តរស័ក្តិជាឧត្តមសេនីយ៍ ។ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុង ថាច់ សារី ត្រូវបានកោះហៅតាមវិទ្យុឲ្យទៅបង្ហាញខ្លួននៅក្រសួងឃោសនាការ ក្រោយមកត្រូវបានសម្លាប់ចោល ។ ឃីត វែន័រ បានដកស្រង់ខ្លឹមសារការសែតដែលបានចុះផ្សាយថា *"ថ្ងៃទី២១ ខែឧសភា ខ្មែរក្រហមចាប់បានឧត្តមសេនីយ៍ ៥៤នាក់របស់កម្ពុជា នៅពេលកាន់កាប់ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ហើយបានរាយការណ៍ថា ខ្មែរក្រហមបានសម្លាប់អ្នកទាំងនោះ ហើយជាញឹកញាប់គឺសម្លាប់ទាំងក្រុមគ្រួសារផងដែរ..."* ។

នៅចុងបញ្ចប់ ក្នុងនាមជាបញ្ញាជន និងជាអ្នកដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា លោកស្រី ផាន់ដារា ស ស្នើឲ្យ ខៀវ សំផន លើកដៃសំពះ និងបួងសួងទៅដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមឲ្យទទួលបានទៅដល់សុខគតិភព ។ យល់ស្របតាមសំណើនេះ ខៀវ សំផន លើកដៃសំពះ និងថ្លែងថា *"ខ្ញុំបានរួមចំណែក ដែលខ្ញុំមិនដឹងថា បងប្អូនសាច់ញាតិ លោកស្រី*



ការដ្ឋានសាងសង់ទំនប់ក្នុងរបបខ្មែរ

*បានត្រូវជួបនឹងទុក្ខលំបាកវេទនា ហើយបងៗ ប្អូនៗ ជាច្រើនត្រូវជួបប្រទះ រួមទាំងបងប្អូនកសិករមូលដ្ឋានផងដែរ ជួបប្រទះនឹងទុក្ខសោកវេទនាជាច្រើន ។ ខ្ញុំរន្ធត់ចិត្តណាស់ ហើយរួមព្រមជាមួយនេះ ខ្ញុំមិនភ្លេចដល់វិញ្ញាណក្ខន្ធរបស់យុទ្ធជនយុទ្ធនារី ដែលលូនទៅរំដោះភ្នំពេញ ក្រោមគ្រាប់បែក បេ-៥២ ក្រាលព្រាំ ។ អ្នកស្លាប់ក៏ស្លាប់ទៅ អ្នកនៅក៏ចេះតែខំរុលទៅឲ្យជិតកងទ័ព លន់ នល់ ដើម្បីកុំឲ្យគ្រាប់បែកយន្តហោះ បេ-៥២ វាទម្លាក់ត្រូវ ។ ទៅកៀក*

ឲ្យដាប់ នល់ នល់ ។ ដូច្នេះបងប្អូនប្រយុទ្ធតស៊ូនេះ ក៏មានពលីជីវិតច្រើនណាស់ ។ ខ្ញុំសូមលើកដៃសំពះគោរពដោយសុភាពរាបសាដល់វិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារីទាំងអស់នេះ ក៏ដូចជា វិញ្ញាណក្ខន្ធបងប្អូនយើងទាំងអស់ ដែលត្រូវបានពលីជីវិតទៅក្នុងសភាព-ការណ៍ប្រទេសយើងដែលវាត្រូវជួបប្រទះអស់ពីសង្គ្រាមអាមេរិក វាជាប់នឹងសង្គ្រាមវៀតណាម ។ និយាយរួមកម្ពុជាប្រជាធិបតេយ្យ គ្មានទាន់បានស្គាល់សន្តិភាពមួយរយៈពេលណាមួយទេ ។ អានេះខ្ញុំសូមគោរពដល់វិញ្ញាណក្ខន្ធបងប្អូនទាំងអស់» ។ ក្នុងសវនា


...ក្រហម (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការនេះដែរ នួន ជា បានថ្លែងថា «...គ្រួសារខ្ញុំក៏បានទទួលនូវគ្រោះកម្មនេះខ្ញុំសូមបញ្ជាក់ជាក់ស្តែងដូចជា សួន កាសេត ។ សួន កាសេត នេះត្រូវជាក្មួយខ្ញុំបង្កើតស្រាប់តែស្លាប់ ។ ខ្ញុំស៊ើបសួរទៅថា ខ្ញុំមិនដែលបានដឹងផង ហើយ ភូ យឹង ដែលជាគ្រូបង្រៀន ស៊ីវហេង សុទ្ធតែជាសាច់ញាតិរបស់ខ្ញុំទាំងអស់ ។ ខ្ញុំត្រូវការអីទៅសម្លាប់គ្នាឯង ប្រជាជនឯងអត់ទេ ។ នេះខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ។ គ្រួសារខ្ញុំក៏ខ្ញុំការពារមិនបានផង ។ ពេលរំដោះ ហើយ ខ្ញុំទៅជួបម្តាយខ្ញុំ ម្តាយខ្ញុំយំថា អញ!អ្ហាំគេប្រាន អញដួលត្រឡប់ត្រលិនអ្ហាំ ។ ខ្ញុំថាប្រានរឿងអីម៉ែ? នៅពេលជម្លៀសចុះអញនៅ អញជម្លៀសទៅឯណាទៀត? ដូច្នោះ ខ្ញុំយល់ឃើញថា ក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹង ក៏មានអ្នកដែលមិនល្អដែរ ។ នេះខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀតដូចគទៅ ដូចអីចឹង» ។

## ២) ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ

ចាន់ សុជាតិ អាយុ ៥៦ឆ្នាំ មានស្រុកកំណើតនៅទីក្រុងភ្នំពេញ ។ បច្ចុប្បន្នរស់នៅភូមិចំការចេក សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ ចាន់ ស៊ីន ម្តាយឈ្មោះ អ៊ុយ យ៉ែម ស្វាមីឈ្មោះ ឡៅ យ៉ន និងមានកូនចំនួន ៥នាក់ ។

ថ្លែងជូនអង្គជំនុំជម្រះទាំងក្តីទុក្ខហោយយ៉ាងខ្លាំង សុជាតិ បានរៀបរាប់ថា នៅម៉ោងប្រហែល ៩ព្រឹក យោធាខ្មែរក្រហមបានស្ពាយកាំភ្លើងចូលដល់ក្នុងផ្ទះរបស់គាត់ ហើយស្រែកឲ្យចេញពីផ្ទះទាំងអស់ ដើម្បីឲ្យអង្គការរៀបចំទីក្រុងភ្នំពេញឲ្យបានស្អាត ៣ថ្ងៃក្រោយចាំត្រឡប់មកវិញ ។ ពេលនោះ សុជាតិ មានការភ័យខ្លាចជាខ្លាំង ហើយប្រញាប់ប្រញាល់នាំបងប្អូនទាំង១៣នាក់ និងឪពុកម្តាយចាកចេញពីផ្ទះ ដោយប្រមូលសម្ភារៈប្រើប្រាស់សម្រាប់ប្អូនតូចៗចំនួន៤នាក់ ដែលកំពុងនៅបៅប៉ុណ្ណោះ ។ នៅតាមផ្លូវព្រះមុនីវង្ស សុជាតិ ឃើញប្រជាជនជាច្រើនធ្វើដំណើរយ៉ាងកកកុញ ដោយអ្នកខ្លះដេកនៅលើគ្រែរុញមានសេរ៉ូមជាប់ដៃ មានទាំងក្មេងទាំងចាស់ ដើរប្រជ្រៀតគ្នា ហើយខ្លះទៀតដេកស្លាប់នៅតាមដងផ្លូវ ។ សុជាតិ ធ្វើដំណើរទៅដល់ស្រុកកៀនស្វាយ ហើយស្នាក់នៅ និងធ្វើការនៅទីនោះអស់រយៈពេល៦ខែ ។ នៅទីនោះពុំមានរបបអាហារគ្រប់គ្រាន់ឡើយ ទទួលបានតែរបបអង្ករ និងពោតបន្តិចបន្តួចប៉ុណ្ណោះ ចំណែកត្រីសាច់ផ្សេងៗ ពុំបានទទួលឡើយ ។ ប្អូនស្រីម្នាក់របស់ សុជាតិ បានស្លាប់បាត់បង់ជីវិតដោយសារដាច់ទឹកដោះ ។

បន្ទាប់មក ខ្មែរក្រហមប្រកាសថា ប្រជាជនដែលមកពីទីក្រុងភ្នំពេញ អង្គការអនុញ្ញាតឲ្យត្រឡប់ចូលទីក្រុងវិញ ។ ពេលនោះ ក្រុមគ្រួសាររបស់ សុជាតិ ក៏ដូចជាប្រជាជនផ្សេងៗទៀតមានការត្រេកអរយ៉ាងខ្លាំង ។ ប្រជាជនរាប់រយគ្រួសារត្រូវបានដឹកតាមកប៉ាល់សំដៅមកទីក្រុងភ្នំពេញ ។ ពេលមកដល់មុខព្រះបរមរាជ

វ៉ាំង ប្រជាជនទាំងដែលនៅក្នុងកប៉ាល់មានការត្រេកអរទាំងអស់គ្នា ។ ពេលនោះមានបុរសម្នាក់ស្រែកថា "ជ័យយោ! យើងមកដល់ភ្នំពេញហើយ" ភ្លាមនោះយោធាខ្មែរក្រហមហៅបុរសនោះចេញក្រៅ ហើយបាញ់សម្លាប់ចោល ។ ពេលនោះប្រជាជនទាំងអស់ស្ងាត់ជ្រៀប ហើយគិតថា ការណ៍ដែលខ្មែរក្រហមប្រកាសថាឲ្យមករស់នៅទីក្រុងភ្នំពេញវិញជាការបោកប្រាស់ ។ កប៉ាល់បានបន្តដំណើរទៅដល់ខេត្តកំពង់ឆ្នាំង បន្ទាប់មកប្រជាជនទាំងនោះត្រូវបានដឹកតាមឡានទៅដល់ខេត្តពោធិ៍សាត់ បន្តជិះរថភ្លើងទៅដល់ភូមិអូរគ្រៀត ស្រុកមោងឫស្សី ចុងក្រោយធ្វើដំណើរដោយថ្មើរជើងទៅដល់ភូមិព្រៃទទឹង ដែលមានសុទ្ធតែព្រៃ ។ ប្រជាជនដែលទៅដល់ទីនោះត្រូវតម្រូវឲ្យធ្វើការជាទម្ងន់ ដោយត្រូវកាប់ឆ្ការព្រៃ និងជីកប្រឡាយ៥ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំមានរបបអាហារគ្រប់គ្រាន់ ។ ប្រជាជនដែលធ្វើការនៅជួរមុខ ទទួលបានបបរមួយវែក ដែលមានជាតិអង្ករខ្លះ ប៉ុន្តែអ្នកដែលធ្វើការមិនកើត ដូចជា ឪពុកម្តាយ និងប្អូនៗរបស់លោកស្រី ទទួលបានបបរសុទ្ធតែកន្ទក់ និងខ្ទុត លាយជាមួយត្រកួន ។ ប្អូនៗ និងឪពុករបស់ សុជាតិ បានឈឺគ្រប់ៗគ្នា ហើយស្លាប់ជាបន្តបន្ទាប់ ដោយសារអត់អាហារ ។ ក្រោយមក ម្តាយរបស់ សុជាតិ ឈឺធ្ងន់ ហើយគាត់ស្នើសុំទៅមើលម្តាយមួយព្រឹក ប៉ុន្តែប្រធានកងពុំអនុញ្ញាតដោយស្រែកទាំងគំហកថា "មិត្តឯងពេទ្យ? មិត្តឯងទៅមើលម៉ែមិត្តឯង ម៉ែមិត្តឯងជា?" ។ ចាប់ពីពេលនោះមក សុជាតិ លែងបានជួបមុខម្តាយរបស់គាត់ជារៀងរហូត ។ ចំណែកបងរបស់ សុជាតិ ក៏បានស្លាប់ជាបន្តបន្ទាប់ ។ ក្រុមគ្រួសាររបស់ សុជាតិ ដែលមានសមាជិកទាំងអស់ ១៥នាក់ នៅសល់តែរូបគាត់ម្នាក់ប៉ុណ្ណោះ ។

បន្ទាប់ពីបញ្ចប់ការថ្លែងសេចក្តីទុក្ខសោករបស់ខ្លួន លោកស្រី ចាន់ សុជាតិ ឆ្លើយតបនឹងសំណួរមួយចំនួនរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គ្រីស្ទីន ម៉ាទីណូ អំពីមូលហេតុដែលធ្វើឲ្យគាត់សម្រេចដាក់ពាក្យបណ្តឹង និងផ្តល់សក្ខីកម្មជូនតុលាការ ។ សុជាតិ បានបញ្ជាក់ថា គាត់មានគោលបំណងស្វែងរកយុត្តិធម៌ជូនសមាជិកគ្រួសារទាំង១៨នាក់ និងប្រជាជនកម្ពុជា ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម និងសូមឲ្យជនជាប់ចោទដែលកំពុងត្រូវបានចោទប្រកាន់សារភាពទោសកំហុស និងសូមទោស ចំពោះប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតនៅក្នុងរបបនោះ ។

ឆ្លើយតបនឹងសំណួររបស់លោកស្រី ចាន់ សុជាតិ ដែលសួរថា "ហេតុអ្វីបានជារបបខ្មែរក្រហម ប្រព្រឹត្តអំពើយង់ឃ្នងចំពោះប្រជាជនខ្លួនឯង ហើយធ្វើដើម្បីអ្វី? ខៀវ សំផន បានថ្លែងនូវការសោកស្តាយដោយបញ្ចូលនូវការបដិសេធនូវតួនាទីជាថ្នាក់ដឹកនាំដែលមានអំណាចចេញគោលនយោបាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន បានលើកឡើងថា "សូមគោរពអង្គសវនាការទាំងមូល! សូមជម្រាបលោកស្រី ចាន់ សុជាតិ ។ ខ្ញុំស្តាប់លោកស្រីមានប្រសាសន៍អំពីទុក្ខសោកវេទនាដែលលោក-ស្រីបានជួបប្រទះ ស្លាប់បាត់បង់ឪពុកម្តាយដែលជាទីស្រឡាញ់ ។ ខ្ញុំរន្ធត់ចិត្តណាស់ ។ ខ្ញុំស្តាប់យ៉ាងនេះទៅនឹកថា អ្នកដែលធ្វើបាបលោកស្រី និងសាច់ញាតិលោកស្រីយ៉ាងនេះ មិនមែនជាមនុស្សធម្មតាទេ ជាស្តេចត្រាញ់ គេហៅថាស្តេចត្រាញ់ សង្គ្រាមគ្មានធម៌មេត្តាដល់មនុស្ស មិនគិតដល់អាយុជីវិតមនុស្សមិនគិតដល់អ្នកធ្លាប់ធ្វើ ឬមិនធ្លាប់ធ្វើ ។ ទុកពេលវេលាឲ្យម្នាក់ៗ មានពេលវេលាសម្រាប់ខ្លួន ខំពីមិនធ្លាប់ទៅជាធ្លាប់ ។ ការពិតវា ត្រូវធ្វើយ៉ាងនេះ ។ ប៉ុន្តែ បើយើងបន្ទំពេលឈឺអីទៅបន្ទត់បាយថា ធ្វើពុតអាហ្នឹងមនុស្សអីចឹងជាមនុស្សហៅថាស្តេចត្រាញ់ឃោរឃៅ ។ មនុស្សដែលឃោរឃៅដល់កម្រិតហ្នឹង ខ្ញុំមិនរួមជាមួយទេ ។ ពិតមែនតែខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យសម្រេច អំពីនយោបាយដែលនាំឲ្យលោកស្រី សាច់ញាតិលោកស្រី ជួបប្រទះនឹងទុក្ខសោកវេទនាក៏ដោយ ក៏ខ្ញុំសូមលើកដៃអភ័យទោស សូមទោសលោកស្រី សូមទោសបងប្អូនរួមជាតិទាំងអស់ ។ ដូចខ្ញុំបានជម្រាបពីព្រឹកមិញ ដែលបានត្រូវរងគ្រោះដោយអំពើឃោរឃៅព្រៃផ្សៃនេះ ខ្ញុំយល់ឃើញថា មិនមែនជាមនុស្សធម្មតាទេ ជាស្តេចត្រាញ់សង្គ្រាម ជាសក្តិភូមិ ។ បាទសូមអស់!" ។ នួន ជា បានបន្ថែមថា "...កម្ពុជាប្រជាធិបតេយ្យ មិនមានមាគ៌ានយោបាយទៅសម្លាប់ប្រជាជនឯង ទៅបង្អត់បាយបង្អត់ទឹកប្រជាជនឯងនោះទេ ។ ម្នាក់ៗសុខចិត្តលះបង់មកតស៊ូដើម្បីរំដោះជាតិ រំដោះប្រជាជន ។ ផុតពីចក្រពត្តិអាមេរិក ដល់ប្រទេសមួយទៀតគឺយួនឈ្លានពានកម្ពុជា ។ ដូច្នោះ កម្ពុជាប្រជាធិបតេយ្យត្រូវ

ទទួលតស៊ូរំដោះជាតិចេញពីចក្រពត្តិឈ្លានពាន ហើយពីយួនដែលមានមហិច្ឆតាឈ្លានពាន វាទី លេបទឹកដីយើង ។ ដូច្នេះ ក្នុងឱកាសនេះ ខ្ញុំសូមគោរពម្តងទៀតនូវវិញ្ញាណក្ខន្ធរបស់អ្នកស្នេហាជាតិទាំងអស់ ជាពិសេសរបស់លោកស្រី សុជាតិ ។ ខ្ញុំបានបញ្ជាក់ពីលើកមុនម្តងហើយ ត្រង់នេះខ្ញុំសូមបញ្ជាក់ម្តងទៀតថា កម្ពុជាប្រជាធិបតេយ្យមានបំណងល្អចំពោះប្រជាជាតិចំពោះប្រជាជន ។ ដូចខ្ញុំម្នាក់ៗលះបង់តស៊ូ ដើម្បីជាតិ ដើម្បីប្រជាជនរបស់ខ្លួន...” ។

### ៣) ដើមបណ្តឹងរដ្ឋប្បវេណី ហូ ចន្ថា

លោកស្រី ហូ ចន្ថា អាយុ៦០ឆ្នាំ មានស្រុកកំណើតនៅឃុំកំពង់សីត្ន ស្រុកបាភ្នំ ខេត្តព្រៃវែង ។ បច្ចុប្បន្នរស់នៅភូមិពកឫស្សី ឃុំពកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ហូ ហាង ម្តាយឈ្មោះ កោក ង៉ោ ប្តីឈ្មោះ ធួន សាអឹម មានកូនចំនួន៥នាក់ ។ នៅចំពោះមុខអង្គជំនុំជម្រះ លោកស្រី ហូ ចន្ថា បានរៀបរាប់អំពីដំណើរជីវិតដែលលោកស្រីបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទុក្ខសោកនានាដែល លោកស្រីបានទទួលរង ហើយបានបន្សល់ទុកមកដល់សព្វថ្ងៃ ។

នៅចំពោះអង្គជំនុំជម្រះ ហូ ចន្ថា បានរៀបរាប់ថា នៅក្នុងរបប លន់ នល់ ក្រុមគ្រួសាររបស់គាត់មានជីវភាពធូធារបន្តួរ ហើយបងរបស់គាត់សុទ្ធតែជាមន្ត្រីរដ្ឋការរបស់របប លន់ នល់ ។ ចំណែកប្តីរបស់ ចន្ថា ធ្វើជាគ្រូបង្រៀន និងមានជីវភាពធូរធារបន្តួរដែរ ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ចន្ថា ឮស្នូរកាំភ្លើងនៅម្តុំពោធិ៍ចិនតុង និងនៅជុំវិញទីក្រុងភ្នំពេញ ហើយគិតថា ជាថ្ងៃអវសាននៃរបប លន់ នល់ ។ លុះដល់ម៉ោងប្រហែល ៨ព្រឹក ថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ចន្ថា ឃើញប្រជាជនជាច្រើនរួមទាំងប្តីរបស់គាត់ឈរលើកទង់ជ័យស ហើយស្រែកអបអរសាទរ ដោយគិតថាសង្គ្រាមត្រូវបញ្ចប់ ហើយសន្តិភាពនឹងកើតមាន ។ ទោះបីជាយ៉ាងណា យោធាខ្មែរក្រហមដែលចូលមកទីក្រុងភ្នំពេញនោះពុំបានសម្តែងទឹកមុខទទួលយកការទទួលស្វាគមន៍របស់ប្រជាជនឡើយ ។ ប៉ុន្មានម៉ោងក្រោយមក យោធាខ្មែរក្រហមទាំងនោះស្រែកដោយបាញ់កាំភ្លើងឡើងទៅលើជាច្រើនគ្រាប់ឲ្យប្រជាជនចេញពីផ្ទះ ព្រោះអង្គការត្រូវរៀបចំទីក្រុងឲ្យបានស្អាត ។ ក្នុងអំឡុងពេលនោះ ចន្ថា ភ័យស្លន់ស្លោពុំដឹងយកអ្វីតាមខ្លួន ព្រោះសុទ្ធតែរបស់មានតម្លៃ ។

ចន្ថា ធ្វើដំណើរចេញពីទីក្រុងតាមផ្លូវពោធិ៍ចិនតុង ។ នៅតាមផ្លូវមានមនុស្សធ្វើដំណើរណែនណាន់តាន់តាប់ មានទាំងក្មេង ចាស់ អ្នកជំងឺ ។ កុមារយំទ្រហឹងរកឪពុកម្តាយ ។ ទាហាន លន់ នល់ ដេកស្លាប់នៅតាមផ្លូវ ដែលគួរឲ្យអាសូរបំផុត ។ ចន្ថា ធ្វើដំណើរអស់រយៈពេល ១៥ថ្ងៃទើបទៅដល់ស្រុកពកឫស្សី ។ ប្រជាជនម្នាក់ៗមានការអស់សង្ឃឹមជាខ្លាំងដោយសារនៅទីនោះពុំមានអ្វីទាំងអស់ មានតែព្រៃដុះទ្រុបទ្រុល ។ ទៅដល់ទីនោះបានមួយរយៈ ប្អូនថ្លៃរបស់ ចន្ថា ឈ្មោះ ស៊ិន ត្រូវគេហៅទៅប្រជុំរៀនសូត្រ ហើយបាត់ខ្លួនរហូត ។ ចន្ថា ត្រូវប្រមាថថា “ជានារី១៧មេសា ទន់ជ្រាយគ្មានចិត្តតស៊ូ” ។ ប្រជាជនត្រូវតម្រូវឲ្យធ្វើការហួសកម្លាំង ដោយទទួលបានរបបអាហារមិនគ្រប់គ្រាន់ ។

ម្តាយ និងប្អូនៗទាំង ៥នាក់របស់ ចន្ថា ត្រូវយកទៅ សម្លាប់ដោយចោទថា មានមាសច្រើន ហើយមិនយកទៅដាក់សហករណ៍រួម ។ ចំណែកឪពុកត្រូវស្លាប់ដោយសារគ្មានថ្នាំព្យាបាល ។ បងប្អូនសរុបទាំងអស់៩នាក់ នៅរស់រានមានជីវិតតែ ហូ ចន្ថា ម្នាក់ឯងប៉ុណ្ណោះ ។ បងប្រុសឈ្មោះ ហូ ហានី អតីតទាហានអាកាសចរណ៍នៅរបប លន់ នល់ ដែលរៀននៅប្រទេសថៃ បានត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយមានការអំពាវនាវរបស់ អៀង សារី ក្រោយមកត្រូវយោធាខ្មែរក្រហមចាប់យកសម្លាប់ចោល ។ ចំណែកបងស្រីទី២ ឈ្មោះ ហូ ឃឹម មានផ្ទៃពោះ៨ខែ និងកូន៣នាក់ រួមទាំងម្តាយក្មេកត្រូវបានដាក់ឲ្យឈរជាជួរ ហើយខ្មែរក្រហមវាយនឹងដងចបសម្លាប់ម្តងមួយៗគួរឲ្យតក់ស្លុតជាទីបំផុត ។ បន្ទាប់ពីបងថ្លៃឈ្មោះ នង គឹមអេង ត្រឡប់មកពីធ្វើការវិញ ដឹងថាប្រពន្ធ កូន និងម្តាយត្រូវខ្មែរក្រហមសម្លាប់ ក៏ទាញកាំបិតដើម្បីទៅសម្លាប់ជនដៃដល់វិញ ។ ប៉ុន្តែ ជាអកុសល ដោយខ្មែរក្រហមមានគ្នាច្រើន គាត់ក៏ត្រូវខ្មែរក្រហមកាប់សម្លាប់ដេកក្នុងថ្លុកឈាម ។ បងប្រុសទី៣ឈ្មោះ ហូ លីម ត្រូវខ្មែរក្រហមចោទថាមានទ្រព្យសម្បត្តិមិនដាក់ចូលជាមួយគេ ។ ក្រោយមក ហូ លីម ត្រូវខ្មែរក្រហមនាំខ្លួនទៅដោយប្រាប់ថាទៅគាស់គល់ឈើ ។ នៅពេលឮដំណឹងនេះ ប្រពន្ធរបស់គាត់ឈ្មោះ ស្រីមុំ និងកូនទាំង៤នាក់ បានទៅអង្វរសុំឲ្យដោះលែងប្តី ប៉ុន្តែត្រូវខ្មែរក្រហមសម្លាប់ទាំង

គ្រួសារ ។

នៅចុងបញ្ចប់នៃសេចក្តីថ្លែងទុក្ខសោក ចន្ថា ស្នើសុំឲ្យ តុលាការស្វែងរកយុត្តិធម៌ជូនសមាជិកក្រុមគ្រួសារ និងសាច់ញាតិរបស់លោកស្រីទាំង ២២នាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីអំពាវនាវឲ្យសហគមន៍អន្តរជាតិផ្តល់ជំនួយដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលសុទ្ធសឹងតែមានវ័យចំណាស់ និងគ្មានទីពឹង ។

បន្ទាប់ពីបញ្ចប់សេចក្តីថ្លែងទុក្ខសោក ចន្ថា បានសួរសំណួរមួយចំនួន ក្នុងនោះមានសំណួរមួយចោទសួរថា “លោកទាំងពីរ (ជនជាប់ចោទ នួន ជា និង ខៀវ សំផន) លោកព្យាយាមឆ្លើយថា លោកមិនបានដឹងពីការកាប់សម្លាប់មនុស្សជាច្រើនក្នុងរបបនេះទេ ។ តើលោកមានខ្មាសក្មេងជំនាន់ក្រោយដែរទេ ដែលលោកជាមេដឹកនាំកំពូល មិនបានដឹងអ្វីនោះ? ឆ្លើយតបនឹងសំណួរនេះ ខៀវ សំផន អះអាងថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មានតួនាទីជាប្រមុខរដ្ឋ ដែលពុំមានអំណាចដូច សម្តេច នរោត្តម សីហនុ ដែរ ។ ទោះបីគាត់ធ្លាប់បានចូលរួមប្រជុំជាមួយគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា គាត់ពុំមានសិទ្ធិសម្រេចអ្វីទាំងអស់ ។ ចំពោះកិច្ចប្រជុំទាក់ទងនឹងការចាប់ចងផ្សេងៗ គាត់ពុំដែលបានដឹងឡើយ ។

### ៤) ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី

លោកស្រី ឆេង អេងលី អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅទីក្រុងប៉ារីស ប្រទេសបារាំង ។ ឪពុកឈ្មោះ ឆេង សេងកែវ ម្តាយឈ្មោះ សុខ អេង ស្វាមីឈ្មោះ ឆាយ ហុកផេង មានកូនចំនួន៥នាក់ ។ លោកស្រី ឆេង អេងលី បានថ្លែងពីប្រទេសបារាំង តាមរយៈប្រព័ន្ធសោតទស្សន៍អំពីការរងទុក្ខវេទនា ដែលបានជួបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជូនអង្គជំនុំជម្រះស្តាប់ ។ លោកស្រី ឆេង អេងលី បានរៀបរាប់ថា ទោះបីព្រឹត្តការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានកន្លងផុតជាង៣០ឆ្នាំក៏ដោយ ក៏លោកស្រីមិនអាចបំភ្លេចបានឡើយ ព្រោះជាព្រឹត្តិការណ៍ដ៏សាហាវយង់ឃ្នងដែលលោកស្រីបានឃើញផ្ទាល់ភ្នែក ។ នៅពេលកំពុងធ្វើដំណើរចេញពីទីក្រុងភ្នំពេញ អេងលី បានឃើញយោធាខ្មែរក្រហមចាប់ហែកជើងទារកម្នាក់ដែលកំពុងយំ និងវ៉ារលើទ្រូងម្តាយរកជៅជាពីរ ។ ពេលនោះ អេងលី មានការតក់ស្លុតជាខ្លាំងដោយពុំនឹកស្មានដល់ ។ ធ្វើដំណើរនៅលើផ្លូវជាតិលេខ១ អេងលី ឃើញមនុស្សស្លាប់ជាច្រើននៅតាមដងផ្លូវ ហើយនៅតាមទន្លេមានសាកសពអណ្តែតជា បន្តបន្ទាប់ ។ ប្រជាជនរស់នៅដោយគ្មានសេរីភាព ត្រូវធ្វើការជាទម្ងន់ របបអាហារមិនគ្រប់គ្រាន់ ទទួលបានបបររាវៗបីវែកក្នុងមួយពេល ។ ពេលឈឺគ្មានថ្នាំព្យាបាល ហើយពេលឈឺខ្លាំងមានតែថ្នាំអាចម៍ទន្សាយតែប៉ុណ្ណោះ ។ ប្រជាជនម្នាក់ៗពុំហ៊ាននិយាយស្តីច្រើនឡើយ ។ អេងលី បានរំឭកដល់ស្ត្រីម្នាក់ឈ្មោះ មុយ ដែលរស់នៅជាមួយគ្នា ត្រូវបានខ្មែរក្រហមសម្លាប់ដោយសារស្ត្រីនោះគ្រាន់តែនិយាយថា មិនដឹងប្អូនស្រីទាំងពីរនាក់របស់គាត់ទៅដល់ទីណា ។ អេងលី បានរៀបរាប់ថា នៅពេលយប់ស្ត្រីឈ្មោះ មុយ នោះបាននិយាយអំពីការព្រួយបារម្ភអំពីសុខទុក្ខប្អូនស្រីទាំងពីររបស់គាត់ ស្រាប់តែភ្លឺឡើងស្រាងៗ យោធាខ្មែរក្រហមបាននាំស្ត្រីនោះចេញទៅ ហើយឲ្យជីករណ្តៅទំហំប៉ុនខ្លួនស្ត្រីនោះ និងមានជម្រៅប្រហែល ៥០សង់ទីម៉ែត្រ ។ នៅពេលស្ត្រីនោះកំពុងជីករណ្តៅទាំងអស់កម្លាំង ខ្មែរក្រហមសួរថា “មេ៉ចហើយ?” នេះជាពាក្យដែល អេងលី បានចាំយ៉ាងច្បាស់ ។ បន្ទាប់មក ខ្មែរក្រហមរុញទម្លាក់ស្ត្រីនោះចូលក្នុងរណ្តៅ ហើយកប់ទាំងរស់ព្រមទាំងពោលពាក្យថា “ហ្នឹងហើយជូនទៅជួបបងប្អូន” ។ អេងលី នៅតែចាំព្រឹត្តិការណ៍នេះនៅជាប់នឹងភ្នែក ព្រោះគាត់នៅទីនោះផ្ទាល់ ។ ពេលនោះ អេងលី មានការតក់ស្លុតជាខ្លាំង ហើយពេលខ្លះគាត់មានបំណងចង់សម្លាប់ខ្លួន ។ ប៉ុន្តែដោយគិតទៅដល់ម្តាយ អេងលី នៅតែខំតស៊ូ និងពង្រឹងស្មារតីរស់បន្តទៀត ។ ចុងក្រោយ អេងលី បញ្ជាក់ថា ព្រឹត្តិការណ៍ដែលគាត់បានឃើញទាំងអស់ និងស្ថានភាពដែលគាត់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមធ្វើឲ្យគាត់ពុំអាចបំភ្លេចបាន ។ គាត់នៅមានអារម្មណ៍ភ័យខ្លាច ហើយគាត់មានអារម្មណ៍ឆាប់ភ័យនៅពេលមើលខ្សែភាពយន្តណាដែលមានភាពរន្ធត់ ។ ទោះបីជាយ៉ាងណា អេងលី ពុំបានទាមទារសំណងអ្វីឡើយ ។ អ្វីដែលលោកស្រីចង់បាន គឺសុំឲ្យតុលាការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាដែលបានស្លាប់ និងទទួលរងទុក្ខវេទនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

# សវនាការស្តាប់សេចក្តីថ្លែងទុក្ខសោកវេទនា និងព្យសនកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី

## ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣

នៅក្នុងសវនាការដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានបន្តស្តាប់នូវសេចក្តីថ្លែងទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូបបន្ថែមទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនរូបរួមមាន លោក នូវ ហ៊ិន់ លោកស្រី សូផាន់ សុវណ្ណី លោក យិន រំដួល និងលោកស្រី ប៉ូ ឌីណា ។

ក្នុងអំឡុងពេលសវនាការនេះ អង្គជំនុំជម្រះបានផ្តល់ជូនពេលវេលាម្នាក់១ម៉ោងកន្លះ ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនរូប ដើម្បីថ្លែងរៀបរាប់អំពីទុក្ខសោក និងព្យសនកម្មដែលបានទទួលរង មានជាអាទិ៍ ការខូចខាត ខាងផ្លូវកាយ ខាងផ្លូវចិត្ត និងខាងសម្ភារៈ ដែលជាបច្ច័យដោយផ្ទាល់កើតចេញពីបទឧក្រិដ្ឋ ដែលបានកើតឡើងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះក៏បានផ្តល់ឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណីអាចចោទសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន និង នួន ជា តាមរយៈអង្គជំនុំជម្រះ ។ ឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនរូប ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថា នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់ពុំបានដឹងអំពីការបញ្ជាឲ្យចាប់ខ្លួនមនុស្សទេ ហើយក៏ពុំមានអំណាចឲ្យមានការចាប់ខ្លួននរណាម្នាក់ដែរ ។ រីឯជនជាប់ចោទ នួន ជា បានអះអាងថា ក្នុងឋានៈជាមេដឹកនាំមួយរូប គាត់នឹងមិនគេចវេះពីការទទួលខុសត្រូវទេ ។ ទោះបីជាយ៉ាងណាក្តី ជនជាប់ចោទទាំងពីររូបបានថ្លែងចូលរួមមរណទុក្ខជាមួយក្រុមគ្រួសាររបស់ជនរងគ្រោះ និងបានថ្លែងគោរពវិញ្ញាណក្ខន្ធដល់ព្រលឹងនៃជនរងគ្រោះ ដែលបានស្លាប់បាត់បង់ជីវិត និងយុវជនដែលបានពលីជីវិតនៅអំឡុងពេលនៃការតស៊ូប្រឆាំងនឹងរបប លន់ នល់ ។

អង្គជំនុំជម្រះក៏បានផ្តល់ឱកាសជូនភាគីនីមួយៗ នូវពេលវេលាប្រមាណ១៥នាទី ដើម្បីចោទសំណួរលើដើមបណ្តឹងរដ្ឋប្បវេណីដែរ ប៉ុន្តែដោយសារសំណួរទាំងអស់ជាប្រភេទសំណួរមានទម្រង់ជាការរំពុកឡើងវិញអំពីប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះផ្នែកនេះនឹងពុំផ្តោតសំខាន់លើការចោទសំណួររបស់ភាគីទេ ប៉ុន្តែនឹងផ្តោតលើសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយតបរបស់ជនជាប់ចោទ ខៀវ សំផន និង នួន ជា ចំពោះសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

### ១) ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់

#### ក) ប្រវត្តិសាវតារ

ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ អាយុ ៧៩ឆ្នាំ មានទីកន្លែងកំណើតនៅភូមិផ្សារថ្កូវ ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ បច្ចុប្បន្នរស់នៅរដ្ឋតិចសាស់ សហរដ្ឋអាមេរិក ។ ឪពុកឈ្មោះ នូវ ចាន់ និងម្តាយឈ្មោះ អាន ភៀវ និងមានកូនទាំងអស់៨នាក់ ។

#### ខ) ព្រឹត្តិការណ៍ជម្លៀសប្រជាជនថ្ងៃ១៧ ខែមេសា ឆ្នាំ ១៩៧៥

ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ ជាជនរងគ្រោះមួយរូបក្នុងចំណោមជនរងគ្រោះជាច្រើនរូប ដែលត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ហ៊ិន់ បានរៀបរាប់អំពីព្រឹត្តិការណ៍នៅពេលនោះថា ការជម្លៀសប្រជាជនចេញពីភ្នំពេញជាទិដ្ឋភាពថ្មីមួយ ដែលប្រជាជនកម្ពុជាពុំធ្លាប់ជួបប្រទះ ។ នៅពេលនោះ មនុស្សច្រើនកុះករត្រូវធ្វើដំណើរចាកចេញ នៅក្រោមកំដៅ ថ្ងៃខែចេត្រ ដោយអ្នកខ្លះពុំមានស្បែកជើង និងអ្នកផ្សេងទៀតត្រូវបង្ខំចិត្តយកស្រទបចេក ឬក្រណាត់ កន្ទបខោអាវមករុំជើង ដើម្បីធ្វើដំណើរ ។ ក្នុងអំឡុងពេលនោះ មានអ្នកខ្លះបាត់កូន ខ្លះបាត់ប្តី ខ្លះបាត់ប្រពន្ធ ។

ចំណែកក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជម្លៀសតាមផ្លូវជាតិលេខ១ ឆ្ពោះទៅទឹកដីខេត្តព្រៃវែង និងស្វាយរៀង ។ កង់ះស្បៀង និងថ្នាំសង្កូវ បានក្លាយជាឧបសគ្គចំបង ព្រោះនៅពេលនោះ លុយលែងមានតម្លៃទៀតហើយ ។ ដើម

បណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ បានបន្តថា លោកបានបាត់កូនស្រីម្នាក់ដែលមានអាយុពី៩ ទៅ១០ឆ្នាំ ។ នៅពេលជម្លៀស កូនស្រីរបស់គាត់រស់នៅជាមួយនឹងក្រុមគ្រួសាររបស់ប្អូនថ្លៃ ហើយនៅពេលចាកចេញពីទីក្រុងភ្នំពេញធ្វើដំណើរក្នុងទិសដៅផ្សេងគ្នា ។ គ្រួសារប្អូនថ្លៃរបស់គាត់ ត្រូវជម្លៀសទៅខេត្តកំពង់ស្ពឺ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ បានជួបជាមួយនឹងប្រជាជនដែលរស់នៅក្នុងសហករណ៍ជាមួយនឹងក្រុមគ្រួសាររបស់ប្អូនថ្លៃក្នុងខេត្តកំពង់ស្ពឺ ។ នៅពេលនោះហើយដែលលោកបានដឹងថា កូនស្រីរបស់គាត់ និងក្រុមគ្រួសាររបស់ប្អូនថ្លៃត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារគ្រាន់តែប្រើពាក្យថា "កូនខ្ញុំ អន្ទាល់ជាទៅ! បើឲ្យថ្នាំអាចម៍ទន្សាយអ៊ីចឹង" ។ លោកបានសន្និតថា កូនស្រីរបស់គាត់ពិតជាត្រូវបានសម្លាប់ដោយខ្មែរក្រហម ព្រោះថាប្រសិនបើកូនស្រីរបស់គាត់នៅរស់ កូននោះនឹងវិលមករកជីដូនជីតា និងឪពុកម្តាយវិញហើយ ដោយសារនៅពេលនោះកូនស្រី លោកអាយុ១០ឆ្នាំ អាចស្គាល់ពីទីលំនៅបាន ។ រីឯក្រុមគ្រួសារប្អូនស្រីបង្កើតរបស់គាត់ ដែលមានកូនចំនួន៥នាក់ រស់នៅខេត្តស្វាយរៀង ក៏ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ក្នុងឆ្នាំ១៩៧៨ បន្ទាប់មកអ្នកទាំងនោះបាត់ដំណឹងសូន្យរហូតមកដល់បច្ចុប្បន្ន ។

ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ បង្ហាញអំពីអារម្មណ៍ទុក្ខសោកថា គាត់មានការស្តាយស្រណោះ និងសោកសង្រេងជាខ្លាំង ដោយពុំមានវិធីណាអាចយកមកផ្សះផ្សាស្នាមរបួសផ្លូវចិត្ត ដែលបានបាត់បង់កូន ប្អូន និងក្មួយបាន ។

**ក) សំណើសុំសំណងការខូចខាត**

ទាក់ទងនឹងសំណងជួសជុលការខូចខាត ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ បានលើកឡើងនូវសំណើរបស់ខ្លួនថា ៖

"បើសិនជាជាតិ អង្គការសហប្រជាជាតិ ឬប្រទេសផ្តល់អំណោយផ្សេងៗថា នឹងផ្តល់អំណោយយ៉ាងណាដល់ជនរងគ្រោះ ខ្ញុំគិតថា ទំហំ បរិមាណមនុស្សដែលទទួលក្នុងនាមជាជនរងគ្រោះច្រើនណាស់ រាប់លាននាក់ ។ ដូច្នេះបរិមាណថវិកាហ្នឹងខ្ពស់ណាស់ ខ្ញុំបាទមិនសង្ឃឹមថា ចង់បានជាថវិកាសម្រាប់អ្វី សម្រាប់ផ្ទាល់ខ្លួន ដើម្បីជួសជុលផ្លូវចិត្ត ដែលបានរំជួលដោយការបាត់បង់កូន ប្អូន ដោយសារការបាត់បង់ក្រុមគ្រួសារ ប្អូនថ្លៃនេះទេ ។ ប៉ុន្តែសង្ឃឹមថា ថ្ងៃណាមួយដែលមានឱកាសមកថ្លែងទីនេះ នៅអង្គសវនាការទីនេះ ជម្រាបអង្គតុលាការ ហើយដែលទាំងអស់គ្នារង់ចាំតែយុត្តិធម៌នេះយូរមកហើយ ។ សង្ឃឹមថា យុត្តិធម៌នេះបានផ្តល់ទៅដល់ជនរងគ្រោះ ទាំងវិញ្ញាណក្ខន្ធអ្នកស្លាប់បាត់បង់ទៅ ទាំងវិញ្ញាណក្ខន្ធសាច់ញាតិដែលនៅរស់ទាំងអស់គ្នាក៏ជាយុត្តិធម៌មួយសម្រាប់អង្គតុលាការដែរ ក៏ជាយុត្តិធម៌មួយសម្រាប់ខាងចុងចោទផងដែរ ជាពិសេសថ្ងៃនេះ និងថ្ងៃខាងមុខទៀត ដែលជាទីបញ្ចប់របស់តុលាការ ។"

**ឃ) ការចោទសំណួរដោយបណ្តឹងរដ្ឋប្បវេណីទៅលើជនជាប់ចោទ**

ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ បានស្នើសុំអង្គជំនុំជម្រះដើម្បីចោទសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន និង នួន ជា ពីរសំណួរ ។ អង្គជំនុំជម្រះបានយល់ស្របចំពោះសំណើនេះ ប៉ុន្តែអង្គជំនុំជម្រះ បានពន្យល់បញ្ជាក់ជូនដើមបណ្តឹងរដ្ឋប្បវេណីថា យោងតាមវិធានផ្ទៃក្នុងដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចសួរសំណួរទៅកាន់ជនជាប់ចោទដោយផ្ទាល់បានទេ ការសួរសំណួរត្រូវធ្វើឡើងតាមរយៈអង្គជំនុំជម្រះ ។ ដូច្នេះ ដើមបណ្តឹងអាចលើកឡើងនូវសំណួររបស់ខ្លួន បន្ទាប់មកអង្គជំនុំជម្រះនឹងយកសំណួរទាំងនោះសួរជនជាប់ចោទដោយផ្ទាល់ ។

សំណួរទាំងពីររបស់ដើមបណ្តឹងរដ្ឋប្បវេណីបានសួរថា ៖

"សំណួរទី១ សួរថានៅក្នុងអំឡុងពេលសវនាការជនជាប់ចោទទាំងអស់បានផ្តល់សក្ខីកម្មថា ពួកគាត់មិនបានដឹងអំពីបទឧក្រិដ្ឋទាំងឡាយ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលរបស់កម្ពុជាប្រជាធិបតេយ្យទេ ។ ប៉ុន្តែ ខ្មែរក្រហម ឈ្លប និងខ្មែរក្រហម និងប្រជាជន ដទៃទៀត ត្រូវបានបាត់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ ទាំងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមក៏បាត់ តើនៅពេលបាត់ខ្លួននោះ គាត់នៅទីណា? អ្នកណាអ្នកកម្ទេចគាត់? អ្នកណាអ្នកសម្លាប់គាត់? តើអ្នកដឹងអំពីបទឧក្រិដ្ឋដែលបានកើតឡើងទេ នៅពេលដែលអស់លោកនៅកាន់អំណាចនៅពេលនោះ? សំណួរទី២ ជនជាប់ចោទទាំងពីររូប ពួកគាត់បាននិយាយថា ពួកគាត់បានការពារជាតិសង្គ្រោះជាតិ ប៉ុន្តែប្រជាជនជាច្រើនត្រូវបានសម្លាប់ ត្រូវបាន

កម្មេចដោយច្បាប់អន្ដការ ។ នៅពេលដែលប្រជាជនត្រូវបានសម្លាប់អស់ទៅ តើអស់លោកដឹកនាំខ្មែរក្រហមថា ការពារទឹកដីចុះទឹកដីហ្នឹង ការពារទឹកដីដែលសល់ហ្នឹងឲ្យអ្នកណានៅ បើទន្ទឹមនឹងហ្នឹងសម្លាប់ប្រជាពលរដ្ឋកម្ពុជាអស់រាប់លាននាក់?

**ង) ការឆ្លើយតបដោយ ខៀវ សំផន និង នួន ជា**

បន្ទាប់ពីទទួលបានសំណួរទាំង២របស់ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានផ្ដល់ឱកាសជូនជនជាប់ចោទ ខៀវ សំផន និង នួន ជា ដើម្បីឆ្លើយតប ។

ខាងក្រោម ជាសម្ដីដកស្រង់ទាំងស្រុងរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានឆ្លើយតបចំពោះសំណួរទាំងពីររបស់ដើមបណ្ដឹងរដ្ឋប្បវេណី នួរ ហ៊ីន់៖

“សូមគោរពលោកប្រធាន! សូមគោរពអស់លោក លោក-ស្រីចៅក្រមទាំងអស់! សូមគោរពអង្គសវនាការទាំងមូល! សូមជម្រាបសួរលោក នួរ ហ៊ីន់ ។ លោកបានបាត់បង់កូនស្រី ដែលជាទីស្រឡាញ់របស់លោកបាត់បង់បងថ្លៃរបស់លោក និងបាត់បង់បងប្អូនខ្លះទៀតមួយចំនួន ។ នេះជាសោកនាដកម្មមួយទៀត ដែលបន្ថែមលើសោកនាដកម្ម ដែលភាគីស៊ីវិល និងសាក្សីមុនៗបានមកថ្លែងរៀបរាប់ជម្រាបអង្គសវនាការជាបន្តបន្ទាប់ ។ ខ្ញុំសូមទោសលោក ដោយសូមជម្រាបលោកថា កាលជំនាន់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនបានដឹងទាល់តែសោះ នូវរឿងរ៉ាវជាទុក្ខសោកលំបាកវេទនារបស់ប្រជាជនយើងយ៉ាងនេះទេ ។ ជាថ្មីម្ដងទៀត ខ្ញុំសូមទោសលោក និងប្រជាជនយើងដែលរងគ្រោះ ។

ឥឡូវខ្ញុំសូមបែរមកឆ្លើយនឹងសំណួររបស់លោក ។ សំណួរទី១ លោកថា អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យចេះតែឆ្លើយថា អត់ដឹងៗរឿងអី ។ ខ្ញុំសូមជម្រាបលោកថា ខ្ញុំមិនដឹងមែន ។ មិនដឹងម៉េចបានមិនដឹង? ព្រោះខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ ។ ខ្ញុំជាបញ្ញាជនមួយរូប ដែលជំនាន់នោះគេចាត់ទុកថាជាមនុស្សទន់ជ្រាយ ។ ដូច្នេះ អ្វីគេឲ្យខ្ញុំដឹងតែរឿងដែលល្អៗ ។ ឯរឿងណាដែលមិនល្អ គេមិនឲ្យខ្ញុំដឹងទេ អានេះហើយដែលខ្ញុំវាអត់ដឹងមែន ។ ខ្ញុំវាមិនដឹងមែនទាល់តែសោះតែម្ដង ខ្ញុំសូមជម្រាបលោកដោយស្មោះយ៉ាងនេះ ។

ទី២ ខ្ញុំចូលរួមជាមួយកម្ពុជាប្រជាធិបតេយ្យសឹងដោយចៃដន្យទេ ហើយខ្ញុំគិតថា វាមករួមនេះ គឺមករួមចំណែកតស៊ូ ការពារជាតិដើម្បីជាតិរស់ ។ រួមចំណែកប្រមូលកម្លាំងជាតិទាំងអស់ តស៊ូប្រឆាំងនឹងសង្គ្រាម ។ កាលនោះ ប្រទេសយើងត្រូវរងគ្រោះរោលរាលឆាបឆេះដោយភ្លើងសង្គ្រាមយ៉ាងណាៗ លោកជ្រាបហើយ ។ ដូច្នេះ ដែលខ្ញុំមកចូលរួម គោលបំណងខ្ញុំមិនមែនមករួមកាប់សម្លាប់ ពិសេសកាប់សម្លាប់ខ្មែរគ្នាឯងសូត្រគ្រង់នោះទេ ។ ខ្ញុំធ្វើអីចឹងទៅមិនរួចទេ ។ ឯមនុស្សដែលសម្លាប់កូនស្រីរបស់លោក បងថ្លៃរបស់លោក និងបងប្អូនផ្សេងទៀតរបស់លោក ខ្ញុំយល់ថា គួរតែរកឲ្យឃើញ ដើម្បីយកមកកាត់ទោស ។ ធ្វើម៉េចរកឲ្យទាល់តែឃើញ ។ ខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង ។ សូមជម្រាបអង្គសវនាការប៉ុណ្ណឹង ។ សូមអត់ទោស ។ សូមអស់ ។”

បន្ទាប់ពីជនជាប់ចោទ ខៀវ សំផន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនជនជាប់ចោទ នួន ជា ដើម្បីឆ្លើយតបនឹងសំណួរទាំង២របស់ដើមបណ្ដឹងរដ្ឋប្បវេណី នួរ ហ៊ីន់ ។

“ខ្ញុំសូមគោរពលោកប្រធាន ។ ខ្ញុំសូមគោរពដើមបណ្ដឹងរដ្ឋប្បវេណី ។ ខ្ញុំមិនចាំឈ្មោះផង សូមអត់ទោស ។ ខ្ញុំសូមគោរពបងប្អូនជនរួមជាតិទាំងអស់ ដែលបានមកចូលរួមក្នុងអង្គប្រជុំនៅក្នុងប្រទេស និងក្រៅប្រទេស ។

ជាបឋម ខ្ញុំសូមបញ្ជាក់ម្ដងទៀតនូវតួនាទី និងភារកិច្ចរបស់ខ្ញុំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសូមបញ្ជាក់ដូចតទៅនេះ ៖

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ខ្ញុំទទួលភារកិច្ចជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា មានតួនាទីភារកិច្ចខាងការអប់រំឃោសនាផ្ទៃក្នុងបក្សនេះមួយ ។ មួយទៀត ខ្ញុំទទួលនាទីខាងប្រធានគណៈកម្មាធិការសភាតំណាងប្រជាជនកម្ពុជា ។ ខ្ញុំមានតួនាទីតែពីរប៉ុណ្ណោះទេ ។ ឯខាងនីតិប្រតិបត្តិខ្ញុំគ្មានតួនាទីអ្វីទេ ។ នេះសូមជម្រាប ។ ដូច្នេះ រឿងអ្វីទាំងអស់ មានរឿងខ្លះខ្ញុំផ្ទាល់ខ្លួនបានដឹងខ្លះ ក៏ប៉ុន្តែរឿងជាច្រើនដែលមិនបានដឹង ។ នេះខ្ញុំសូមជម្រាបឲ្យស្មោះអស់ពីចិត្ត ។ មិនមែនខ្ញុំគេចពីការទទួលខុសត្រូវទេ ។ ខ្ញុំសូមបញ្ជាក់ម្ដងទៀតថា ការខូចខាត ការគ្រោះថ្នាក់របស់ជាតិខ្ញុំ ក្នុងឋានៈខ្ញុំជាអ្នកទទួលនាទីដឹកនាំ ខ្ញុំត្រូវតែទទួលការខុសត្រូវ ។ ខ្ញុំសូមទទួលដោយស្មោះអស់ពីដួងចិត្ត ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

ភារកិច្ចរបស់ខ្ញុំ ដូចដែលខ្ញុំបានជម្រាបហើយ គឺថាខ្ញុំគ្មាន នាទីអីខាងនីតិប្រតិបត្តិទេ ។ ខ្ញុំនាទីខាងបក្ស ធ្វើខាងការអប់រំ ឃោសនាផ្ទៃក្នុងបក្ស ។ នាទីខាងរដ្ឋបាល គឺប្រធានគណៈកម្មាធិការ សភាតំណាងប្រជាជន ។ ឯភារកិច្ចខាងសភាតំណាងប្រជាជន កម្ពុជា ក៏មិនទាន់បានធ្វើអ្វីផង ស្រាប់តែកងទ័ពវៀតណាមចូល មកឈ្លានពានប្រទេសកម្ពុជា ។ នេះខ្ញុំសូមជម្រាបតែប៉ុណ្ណឹងដោយ សង្ខេប ។ ម្តងទៀត ខ្ញុំសូមចូលរួមមរណទុក្ខជាមួយលោកអ្នក លោកឈ្មោះ ខ្ញុំភ្លេចឈ្មោះទៅហើយ ដើមបណ្តឹងរដ្ឋប្បវេណីនេះ ខ្ញុំសូមចូលរួមគោរពវិញ្ញាណក្ខន្ធរបស់ឪពុកម្តាយ មាមីងរបស់ លោក កូនចៅរបស់លោក ក៏ដូចជាសាច់ឈាមរបស់ខ្ញុំ ។ នេះខ្ញុំ សូមបញ្ជាក់ម្តងទៀត ដូចអ៊ីចឹង ។ ខ្ញុំសូមអស់លោក សូមគោរព លោកប្រធាន ។»

## ២) សេចក្តីថ្លែងទុក្ខសោក

បន្ទាប់ពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីររូប អង្គ ជំនុំជម្រះបានប្រគល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីថ្លែង អំពីសេចក្តីទុក្ខសោក និងព្យសនកម្ម ដែលបានទទួលរងនៅអំឡុង ពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

«ខ្ញុំបាទផ្ទាល់ ជាគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ខ្ញុំបាទគិតថា អង្គការកាលនោះ អង្គការខ្មៅ អង្គការចិត្តខ្មៅកាលណោះ ។ លោក ចង់ឲ្យប្រជាពលរដ្ឋកម្ពុជារស់រានមានជីវិតនៅក្នុងឥស្សរភាព នៅក្នុង បូរណភាពទឹកដី លោកគិតថា លោកចង់ឲ្យម្នាក់ៗមានមួក ពាក់ចង់ឲ្យម្នាក់ៗមានស្បែកជើងមួយគូពាក់ ប៉ុន្តែ សម្ភារទាំងពីរ នេះ ទំហំមានតែមួយទេ ហើយទំហំតូចយកទៅប្រគល់ឲ្យអ្នកដែល ទទួលក្បាលធំ ជើងធំ ដើម្បីទទួលមួក និងរបស់អង្គការឲ្យយកទៅ ពាក់លើក្បាលរបស់ខ្លួនបានទាល់តែខ្លួនចាំងក្បាលរបស់ខ្លួនសិន បាន ពាក់មួកនោះត្រូវ ព្រោះមួកវាតូច ។ ស្បែកជើងក៏ដូចគ្នាដែរ ស្បែកជើងតូច ជើងវាធំ ស៊កម៉េចនឹងត្រូវទាល់តែបន្ទំចិត្តចាំង ជើងរបស់ខ្លួនដើម្បីទទួលយកស្បែកជើងមួយគូនោះ ។ អ៊ីចឹងទេ ខ្ញុំគិតថា នោះជាគំនិតតែមួយគត់ គឺអំណាចផ្តាច់ការ អ្នកណាទាំង អស់ត្រូវតែធ្វើតាមទាំងអស់ ពិបាកវេទនាប៉ុនណា ព្រាត់ប្រាស់កូន ប្រពន្ធប៉ុនណា ទុក្ខសោកប៉ុនណា សុខចិត្តទៅទ្រាំអត់ចប់ទឹកភ្នែកកុំ ឲ្យហូរ ។ ឃ្លានណាស់ក៏មិនហ៊ានថា ក្តៅណាស់ ត្រជាក់ណាស់ក៏មិន ហ៊ានថា ។ ដូច្នេះទាំងអស់គ្នាស្ងោកៗទាំងអស់រាបដូចកន្ទេល ។ នេះជាគំនិតខ្ញុំបាទសង្កេតឃើញ ហើយធ្វើការកត់សម្គាល់យ៉ាង ដូច្នេះ ។ ហើយមួយទៀត ខ្ញុំគិតថា ពាក្យស្លោកដែលអង្គការបាន លើកឡើងកាលនោះ ខ្ពស់ហួសហេតុពេក អង្គការមហាអស្ចារ្យ ។ បងប្អូនទាំងអស់ដែលមកធ្វើសក្ខីកម្មនៅទីនេះ ឃើញតែការបំផ្លិច បំផ្លាញ ស្លាប់ជីវិត បាត់បង់គ្រួសារ អស្ចារ្យៗក្នុងការពិឃាត ក្នុងការកម្ទេច ។ នេះជាគំនិតរបស់ខ្ញុំយល់ ហើយលោកផ្ទះហ្នឹង មិនដឹងលោកផ្ទះយ៉ាងម៉េច ។ អង្គការភ្នែកម្នាស់យ៉ាងម៉េចបើ អស់លោកជាពិសេសមេដឹកនាំខ្មែរក្រហមទាំងពីររូប លោក បាន មានប្រសាសន៍អម្បាញ់រួចហើយ លោកបានសារភាពថា លោក មិនបានទទួលដឹងឮអំពីភារកិច្ចខ្លះទៀតដែលមិនមែនជាភារកិច្ច របស់អស់លោក ខ្ញុំបាទជឿជាក់ថាអ៊ីចឹងមែនចុះ ។ ប៉ុន្តែ គួរកត់ សម្គាល់ថា ជារឿងមួយដែលយើងគិតថា យើងធ្វើឲ្យស្រុករីក ចម្រើន ប៉ុន្តែផ្ទុយទៅវិញ ស្រុកយើងត្រូវបានលិចលង់ តើវាលិច លង់ដោយសារអ្វី? វាមានរឿងដែលធ្វើឲ្យស្រុកលិចលង់នោះ? តើវាបណ្តាលមកពីអ្វី?

បើយើងមើលឃើញផ្ទាល់នឹងភ្នែក ឃើញតែការវិនាសហិន ហោចគ្រប់បែបយ៉ាងទាំងអស់ វាអត់សម ។ បញ្ញាជនជាមូលដ្ឋាន គ្រឹះសម្រាប់បន្តធនធានមនុស្សទៅជំនាន់មួយៗ ។ គ្រឿង ក្បូន ខ្នាតអ្វីៗផ្សេងៗ ។ ចុះទាំងអស់បាត់លើង ដល់អ៊ីចឹងទេ យើងមាន ការសោកស្តាយទាំងអស់គ្នា រួមសោកស្តាយ ។ ហើយខ្ញុំបាទចុង ក្រោយ ខ្ញុំបាទគ្រាន់តែធ្វើការកត់សម្គាល់ប៉ុណ្ណោះ គឺចំពោះលោក ខៀវ សំផន ។ ក្នុងទសវត្សរ៍៦០ ខ្ញុំបាទតែងតែឮ ឃើញសារ ព័ត៌មានផ្សេងៗ ឃើញគេនិយាយពីមួយទៅមួយថា លោកមាន ភាពស្អាតស្អំ មិនពុករលួយអ្វីគ្រប់បែបយ៉ាងទាំងអស់ លោក ស្អាតស្អំ លោកគិតពីរឿងជាតិ ។ ប៉ុន្តែវាអកុសលអី ពេលនោះ លោកអញ្ជើញទៅចូលរួមក្នុងត្រកជាមួយនឹងត្រីស្អុយ ។ ត្រកហ្នឹង គឺទ្រុង ។ ហើយធម្មតាខ្មែរយើង ត្រីមួយត្រកស្អុយតែមួយ ស្អុយ ទាំងអស់ ។ បាទសូមរួមសោកស្តាយផង ប៉ុន្តែ ការពិតមានត្រីខ្លះ មិនស្អុយទេ ប៉ុន្តែវានៅក្នុងត្រកជាមួយនឹងត្រីស្អុយ ។ ខ្ញុំបាទចូល រួមសោកស្តាយកន្លែងហ្នឹងមួយផង ។ អានេះជាគំនិតរបស់ខ្ញុំបាទ ហើយខ្ញុំបាទសង្ឃឹមថា ចុងក្រោយអង្គតុលាការនឹងខិតខំព្យាយាម

ធ្វើម៉េច យោងឯកសារផ្សេងៗ យោងសក្ខីកម្មរបស់សាមីខ្លួនម្នាក់ៗ និងបន្តបន្ទាប់ទៅទៀត នឹងរកយុត្តិធម៌ជូនទាំងអស់គ្នាសម្រាប់ជនរងគ្រោះ អ្នកបាត់បង់ជីវិត អ្នកដែលនៅសល់ជីវិតសម្រាប់ប្រជាពលរដ្ឋទូទៅសម្រាប់អ្នកនៅក្រៅប្រទេស សម្រាប់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យផងដែរនោះ ជាយុត្តិធម៌សម្រាប់ទាំងអស់គ្នា ។ ខ្ញុំបាទសង្ឃឹមថា អង្គតុលាការនឹងសម្រេចជោគជ័យនៅទីបញ្ចប់ ។ ខ្ញុំបាទសូមថ្លែងអំណរគុណ ខ្ញុំបាទមានគំនិតតែប៉ុណ្ណោះ ។ សូមអរគុណ ។»

## ២) ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី

### ក) ប្រវត្តិសាវតា

ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី អាយុ ៥៧ឆ្នាំ មុខរបរជាកសិករ មានទីកន្លែងកំណើត នៅសង្កាត់លេខ១ ក្រុងភ្នំពេញ ។ បច្ចុប្បន្នរស់នៅភូមិបន្ទាយដីក្រោយ ឃុំបន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ សូផាន់ សូដៃ និងម្តាយឈ្មោះ លឹម គីមសាយ និងស្វាមីឈ្មោះ ង៉ែត វណ្ណដេត មានកូន៣នាក់ ។

### ខ) ព្រឹត្តិការណ៍ជម្លៀសប្រជាជនថ្ងៃ១៧ ខែមេសា ឆ្នាំ ១៩៧៥

ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី បានរៀបរាប់ទាក់ទងនឹងព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថានៅពេលចូលមកដល់ទីក្រុងភ្នំពេញ យោធាខ្មែរក្រហមបានប្រកាសតាមមេក្រូឲ្យប្រជាជនចាកចេញពីលំនៅដ្ឋានរបស់ខ្លួន ដោយសារខ្លាចមានការទម្លាក់គ្រាប់បែកពីអាមេរិកាំង ។ ប៉ុន្តែនៅពេលនោះ គាត់ និងឪពុក ពុំជឿអំពីការប្រកាសនោះទេ ដោយគិតថា ស្រុកសន្តិភាពហើយ ដូច្នេះពុំមាននរណាមកទម្លាក់គ្រាប់បែកទៀតទេ ។ បន្តិចក្រោយមក មានយោធាខ្មែរក្រហមពីបីទៅបួននាក់ បានមកដល់មុខផ្ទះ និងប្រាប់ឲ្យចាកចេញពីផ្ទះ ដោយពុំចាំបាច់រៀបចំអីវ៉ាន់អ្វីឡើយ ។ នៅពេលចេញមកដល់ខាងក្រៅ លោកស្រីឃើញទិដ្ឋភាពមានសភាពរញ៉េរញ៉ៃ មនុស្សច្រើនកកកុញណែនណាន់តាន់តាប់ និងក៏មានអ្នករងរបួសដែរ ។ អ្នកដែលចាកចេញត្រូវបានបង្ខំឲ្យដើរទៅមុខមិនឲ្យត្រឡប់ក្រោយជាដាច់ខាត ។ ទិដ្ឋភាពនៅសងខាងផ្លូវមានសភាពស្មោកគ្រោកជាខ្លាំង មានទាំងលាមក និងសាកសពដែលប្រទះឃើញស្លាប់នៅតាមដងផ្លូវថែមទៀត ។

នៅតាមផ្លូវ ពីគីឡូម៉ែតលេខ៦ រហូតដល់ព្រែកព្នៅ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចំណាយពេលធ្វើដំណើរ២ថ្ងៃ ដោយគ្មានចំណីអាហារ និងទឹកស្អាត ប្រើប្រាស់ដោយសារតែខ្មែរក្រហមបានប្រាប់ថា ការចាកចេញនេះត្រឹមតែរយៈពេល៣ថ្ងៃប៉ុណ្ណោះ ដូច្នេះ ពុំមានត្រៀមអ្វីច្រើន សម្រាប់ការហូបចុករយៈពេលយូរទេ ។ ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី បានបន្តទៀតថា លោកស្រី និងក្រុមគ្រួសារ បានបន្តដំណើរដោយថ្មើរជើងរយៈពេល១៥ថ្ងៃ ទើបទៅដល់សាឡាង ព្រែកក្តាម និងឆ្លងទៅត្រើយខាងកើត ដើម្បីបន្តដំណើរទៅខេត្តកំពង់ធំ ។ ប៉ុន្តែឪពុករបស់លោកស្រីមានបំណងចង់ឲ្យកូនៗរត់ភៀសខ្លួនទៅទល់ដែន ដោយហាក់បីដូចបានដឹងអំពីរឿងអ្វីមួយមុនជាស្រេច ប៉ុន្តែពុំប្រាប់កូនៗឲ្យបានដឹង ។ នៅតាមផ្លូវធ្វើដំណើរទៅខេត្តកំពង់ធំ ដោយសារពុំមានកន្លែងស្នាក់នៅក្រុមគ្រួសាររបស់លោកស្រីបានចូលសម្រាកនៅក្នុងវត្តមួយជាបណ្តោះអាសន្ន ។ ក្នុងវត្តនោះពុំមានព្រះសង្ឃគង់នៅទេ មានតែរូបបដិមាករ ដែលត្រូវបានបំផ្លិចបំផ្លាញ ។ បន្ទាប់មក ឈ្លបខ្មែរក្រហម៣ទៅ៤នាក់ បានមកសួរឪពុក លោក-ស្រីថាចង់ទៅទីណា? ឪពុកលោកស្រីបានឆ្លើយថា ចង់ធ្វើដំណើរទៅខេត្តកំពង់ធំ ដើម្បីជួបជុំគ្រួសារបងប្អូន ។ ប៉ុន្តែឈ្លបខ្មែរក្រហមទាំងនោះពុំអនុញ្ញាតឲ្យក្រុមគ្រួសាររបស់លោកស្រីធ្វើដំណើរបន្តទៅមុខទៀតទេ ដោយនិយាយថា «ទៅធ្វើស្អី? នៅធ្វើការនៅទីនេះ ក៏ធ្វើការឲ្យអង្គការ ទៅធ្វើដល់កំពង់ធំ មិត្តឯងក៏ធ្វើការឲ្យអង្គការដែរ ។ មិត្តឯងចង់ធ្វើស្អី នៅធ្វើការហ្នឹងឲ្យអង្គការស្អែក មិត្តឯងចុះទៅជួយធ្វើការប្រជាជននៅក្នុងភូមិ! គេកំពុងតែធ្វើការសស្រាក់សស្រាំមិត្តឯងចង់ដើរទៅណាទៀត?» ។ ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី បានបន្តថា នៅទីនោះ ខ្មែរក្រហមបានបង្ខំឲ្យក្រុមគ្រួសាររបស់ខ្លួនធ្វើស្រែ ។ ធ្វើនៅទីនោះបានរយៈពេល៥ថ្ងៃ ឪពុករបស់ សូវណ្ណី បានស្នើសុំអ្នកគ្រប់គ្រងនៅទីនោះដើម្បីទៅខេត្តកំពង់ធំម្តងទៀត ប៉ុន្តែសំណើនេះ ត្រូវបានបដិសេធ ហើយខ្មែរក្រហមនៅទីនោះចាត់ទុកឪពុកដើមបណ្តឹងរដ្ឋប្បវេណីថា ជានាយទុនចង់គេចវេះពីការងារ និងមានបំណងសម្លាប់ក្រុមគ្រួសារនេះចោលតែម្តង ។ សំណាងល្អបុរសម្នាក់បានដឹងដំណឹងនេះ និងបានប្រាប់ឲ្យគ្រួសារ សូវណ្ណី ចាកចេញពីទីនោះ ។

បន្ទាប់មក ដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមគ្រួសារបានសម្រេចចិត្តរត់រហូតមកដល់រកាកោង ។ ប៉ុន្តែនៅទីនោះ បានប្រមាណមួយសប្តាហ៍ អ្នកគ្រប់គ្រងនៅទីនោះបានប្រកាសឲ្យប្រជាជនថ្មី ដែលកំពុងរស់នៅភូមិរកាកោង ឲ្យចេញពីភូមិទាំងអស់ ដោយអង្គការដាក់ទិសដៅឲ្យទៅធ្វើស្រែនៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។

នៅពេលទៅដល់ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ អ្នកគ្រប់គ្រងសហករណ៍នៅទីនោះតម្រូវឲ្យគ្រួសារលោកស្រីកាប់ព្រៃ ធ្វើទីលំនៅដោយខ្លួនឯង និងទទួលបានរបបអង្ករមួយកំប៉ុងសម្រាប់គ្នា៥នាក់ ។ ឪពុក និងបងប្អូនលោកស្រីចំនួន៤នាក់ផ្សេងទៀត បានស្លាប់បាត់បង់ជីវិត ដោយសារជំងឺ និងការអត់ឃ្លាននៅទីនោះ ។

ក្រោយមក ដើមបណ្ដឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី ត្រូវផ្លាស់ឲ្យទៅធ្វើការនៅសហករណ៍មួយផ្សេងទៀត ឈ្មោះសហករណ៍តាសោ ដោយត្រូវបានប្រធានសហករណ៍តម្រូវឲ្យដឹកប្រឡាយ ។ ដោយសារសហករណ៍មានផែនការចង់ផ្លាស់ឲ្យចូលទៅធ្វើការក្នុងកងចល័ត ដើមបណ្ដឹងរដ្ឋប្បវេណី សូវណ្ណី បានលួចរត់ចូលក្នុងព្រៃរហូតដល់ភូមិដំណាក់ឈើក្រំនៅលើភ្នំក្រវាញ ។ លោកស្រីបានប្រាប់ប្រធានសហករណ៍ថា ដោយសារតែវង្វេងផ្លូវនៅពេលចូលកាប់ព្រៃ ទើបចូលទៅដល់សហករណ៍នោះ ។ ប្រធានសហករណ៍បានអនុញ្ញាតឲ្យលោកស្រីធ្វើការនៅទីនោះ ដោយឲ្យជួយជីកប្រឡាយ ។ ធ្វើការក្នុងសហករណ៍នោះ ដើមបណ្ដឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី បានឃើញនូវហេតុការណ៍ជាច្រើនដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជន ។ លោកស្រីបានរំឭកអំពីហេតុការណ៍ ដែលបានឃើញផ្ទាល់ភ្នែកជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងការនាំយកនារីម្នាក់ ដែលមានអាយុប្រមាណ១៤ទៅ១៥ឆ្នាំ ទៅសម្លាប់ ដោយសារតែកងឈ្លបខ្មែរក្រហមឃើញនារីម្នាក់នោះមានខ្សែកផ្លាកទីនមួយខ្សែនៅក្នុងចង្កេះខោរបស់នាង ។ បន្ទាប់មក កងឈ្លបទាំងនោះបាននិយាយមកកាន់ប្រជាជនថា "ពួកមិត្តឯងកុំឲ្យមានគំនិតប្រតិកិរិយា នាយទុន នៅចង់បានរបស់ទ្រព្យទុកក្នុងខ្លួន ។ បើអង្គការឲ្យយកចេញ យកចេញឲ្យអស់ពីខ្លួនទៅ កុំកម្មសិទ្ធិក្រាស់ ប្រយ័ត្ន! មេរៀនមានហើយ" ។ រីឯហេតុការណ៍មួយទៀត ដែលលោកស្រីបានឃើញផ្ទាល់ភ្នែក គឺមាននារីម្នាក់អាយុជាង២០ឆ្នាំ ត្រូវឈ្លបខ្មែរក្រហមចាប់ចង ហើយយកព្រនង់ឈើប៉ុនកងដៃវាយលើនារីនោះ រហូតទាល់តែស្លាប់ ហើយអូសចូលទៅក្នុងព្រៃ ដោយសារតែនារីម្នាក់នោះលួចបេះដំឡូងយកមកដុតហូប ។ ឈ្លបទាំងនោះ បានគំរាមប្រជាជនថា "នេះជាមេរៀន ជាគំរូទុកឲ្យមិត្តឯងរាល់គ្នាហ្នឹងមើល ។ កុំឲ្យគ្រាប់តាមហ្នឹង ។ វាមិនល្អទេ ។ មីមិត្តហ្នឹងវាក្បត់អង្គការ វាហ៊ានមានដំឡូងហូប!" ។ ហេតុការណ៍មួយទៀត ដែលដើមបណ្ដឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី បានឃើញផ្ទាល់ភ្នែក គឺមិត្តនារីម្នាក់ឈ្មោះ សាន ដែលបានខុសសីលធម៌រហូតដល់មានទម្ងន់៧ខែ ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ក្នុងព្រៃយ៉ាងសាហាវព្រៃផ្សៃ ។

### គ) សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

"ឆាកជីវិតខ្ញុំសែនកំសត់មែនទែន ព្រោះអត់ឪពុក អត់បងប្អូន ។ ខ្ញុំនៅជាមួយម្តាយ នៅផ្ទះបាយ ។ នៅសមរភូមិ ខ្ញុំទទួលដំណឹងថា ម្តាយខ្ញុំឈឺធ្ងន់ ។ ខ្ញុំរត់ពីសមរភូមិ ខ្ញុំលួចរត់ ។ សុទ្ធតែលួចរត់ លួចរត់ពេលយប់ ។ ខ្ញុំលែងខ្លាចស្លាប់ហើយ ខ្ញុំរត់មកមើលម្តាយខ្ញុំ ។ ខ្ញុំឮគេប្រាប់ថា ម្តាយខ្ញុំហ្នឹងគេឲ្យថ្នាំពេទ្យ ។ ពេទ្យហ្នឹងគេឲ្យត្រកួនទែក ។ ហ៊ឹះ! ដាំត្រកួនទែកឲ្យម្តាយខ្ញុំហូប ។ ម្តាយខ្ញុំហូបត្រកួនទែកហ្នឹងហើយ រាកដេកផ្ទាល់នឹងកន្ទេលហ្នឹង ។ ខ្ញុំមិនដឹងថា ហេតុអ្វីគេឲ្យដាំត្រកួនទែកឲ្យម្តាយខ្ញុំហូបទេចាស ។ គាត់រាកដល់ស្លាប់ ។ ខ្ញុំអស់ឪពុកម្តាយ ។ ខ្ញុំអស់បងប្អូន អស់ទីពឹងអស់ស្អីៗរលីងពីក្នុងខ្លួន ។ ខ្ញុំគ្មានស្អីទៀតទេ ។ ទុក្ខវេទនារបស់ខ្ញុំ ខ្ញុំមិនអាចរៀបរាប់ប្រាប់អស់លោកថាពេលហ្នឹងខ្ញុំលំបាកប៉ុនណា ។ ខ្ញុំវេទនាប៉ុនណា ខ្ញុំអត់អាចនិយាយបាន" ។

## ៣) ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល

### ក) ប្រវត្តិសាវតា

ដើមបណ្ដឹងរដ្ឋប្បវេណី យិន រំដួល អាយុ៤៨ឆ្នាំ មុខរបរជាមន្ត្រីរាជការ មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ។ បច្ចុប្បន្នដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ យិន ស៊ីផារ៉េត, ម្ដាយឈ្មោះ គីម ឈន និងមានកូន២នាក់ ។

#### ១) ព្រឹត្តិការណ៍ជម្លៀសប្រជាជនថ្ងៃ១៧ ខែមេសា ឆ្នាំ ១៩៧៥

នៅមុនពេលចាប់ផ្ដើមរៀបរាប់អំពីព្រឹត្តិការណ៍ជម្លៀស

ប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានបញ្ជាក់ជូនអង្គសវនាការថា នៅពេលនោះ គាត់នៅជាកុមារដែលទើបតែមានអាយុ១០ឆ្នាំ កំពុងស្ថិតនៅក្រោមការបីបាច់ថែរក្សាពីសំណាក់ឪពុកម្តាយ និងកំពុងស្ថិតក្នុងការសិក្សា ។ ប៉ុន្តែ ព្រឹត្តិការណ៍នៃការចូលមកដល់នៃយោធាខ្មែរក្រហម និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បានដិតដាមជាប់ក្នុងអារម្មណ៍ជានិច្ច ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានរំឭកថា នៅពេលកងទ័ពខ្មែរក្រហមស្លៀកសំលៀកពាក់



ខៀវ សំផន លើកដៃសំពះជនរងគ្រោះនៅក្នុងបន្ទប់សវនាការ

ពណ៌ខ្មៅចូលមកដល់ទីក្រុងភ្នំពេញ លោកបានឃើញជនរួមជាតិទាំងអស់ចូលរួមអបអរសាទរ អ្នកខ្លះលើកទង់ស និងបានស្រែកថា «យើងមានសន្តិភាពហើយ!» ។ នៅវេលាម៉ោង១១កន្លះព្រឹក ខ្មែរក្រហមចាប់ផ្តើមឲ្យប្រជាជនចាកចេញពីទីលំនៅ ដោយមានប្រើកាំភ្លើងដើម្បីបង្ខំឲ្យចាកចេញ ។ ប៉ុន្តែ ដោយសារតែជីតារបស់គាត់មានជំងឺ និងពិការមួយចំហៀងខ្លួន គ្រួសាររបស់ដើមបណ្តឹងមិនបានចាកចេញភ្លាមៗ តាមការអំពាវនាវរបស់ខ្មែរក្រហមទេ ។ គ្រួសាររបស់គាត់សម្ងំនៅក្នុងផ្ទះរហូត ដល់ពេលយប់ ។ ដោយសារមានពន្លឺចង្កៀងដែលជីដូនគាត់អុជបំភ្លឺ នៅពេលយប់ យោធាខ្មែរក្រហមបានបាញ់សំដៅមកផ្ទះរបស់គាត់ និងបានស្រែកសួរថា «ហេតុអ្វីក៏ពុំព្រមចាកចេញ?» បន្ទាប់មកក្រុមគ្រួសាររបស់គាត់ក៏សម្រេចចិត្តចាកចេញពីលំនៅដ្ឋាននៅជិតទួលស្វាយព្រៃទាំងយប់ ដោយធ្វើដំណើរឆ្ពោះទៅផ្ទះជីតានៅព្រែកឯង ។ នៅទីនោះ ដោយសារពុំមានអាហារហូបចុកគ្រប់គ្រាន់ ក្រុមគ្រួសាររបស់ រំដួល បានសម្រេចចាកចេញទៅស្រុកកំណើតខាងម្តាយនៅឃុំកោះខកញ៉ាតី ស្រុកខ្សាច់កណ្តាល ។ ប៉ុន្មានខែបន្ទាប់មក ខ្មែរក្រហមក៏បានជម្លៀសប្រជាជនពីស្រុកខ្សាច់កណ្តាល ទៅស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ពេលទៅដល់ ខ្មែរ ក្រហមបានបំបែកដើមបណ្តឹងរដ្ឋប្បវេណីចេញពីគ្រួសារ ដោយដាក់ឲ្យស្ថិតនៅ ក្នុងកងកុមារជាមួយនឹងកុមារដទៃទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានបន្តថា ក្នុងកងកុមារ ខ្មែរក្រហមបានធ្វើទារុណកម្ម មកលើរូបគាត់ដូចសត្វធាតុ ដោយសារតែបានលួចអំពៅ និងលួចសំណាបយកមកទទួលទាន ។ ក្រោយមកទៀត ដើមបណ្តឹងរដ្ឋប្បវេណី និងម្តាយត្រូវឈ្លបខ្មែរក្រហមចាប់ដាក់មន្ទីរឃុំឃាំង មេទឹកក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ និងទទួលរងការធ្វើទារុណកម្មថែមទៀត ។ នៅពេលមួយនោះ មេភូមិនៅទីនោះបានកោះប្រជុំជាមួយប្រជាជន ដោយនិយាយថា «ប្រសិនបើគ្រួសារណាមួយរត់ចេញពីគុក ខ្មែរក្រហមនឹងកម្ទេចគ្រួសារនេះចោល» ។

ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានពិភាក្សាជាមួយម្តាយរកមធ្យោបាយដើម្បីរត់គេចចេញពីគុក ។ ពេលនោះម្តាយរបស់គាត់បានផ្តល់យោបល់ឲ្យរត់គេចខ្លួន ដោយនិយាយថា «ប្រសិនបើកូនទៅ កូនអាចមានសំណាងនឹងរស់» ។ ពេលនោះ រំដួលបានសម្រេចចិត្តលួចរត់នៅពេលយប់ ។ ប៉ុន្តែនៅប៉ុន្មានថ្ងៃក្រោយមក គាត់បានទទួលដំណឹងថា ម្តាយរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅយប់ថ្ងៃដែលរំដួលលួចរត់ចេញពីគុក ។ ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានបង្ហាញពីអារម្មណ៍ឈឺចាប់ថា «ក្នុងឋានៈជាកូនម្នាក់... ខ្ញុំទទួល នូវសោកនាដកម្មយ៉ាងកំសត់ ។ ក្នុងឋានៈជាកូនខ្មែរម្នាក់ និងជាកុមាររងគ្រោះនៃរបបដែលដឹកនាំដោយលោក ខៀវ សំផន, អៀង សារី, ប៉ុល ពត និង នួន ជា នេះ

ខ្ញុំចុកចាប់ណាស់» ។

បន្ទាប់ពីឪពុកម្ដាយត្រូវបានខ្មែរក្រហមសម្លាប់ ដើមបណ្ដឹងរដ្ឋប្បវេណី យិន រំដួល មានសំណាងបានទៅរស់នៅជាមួយនឹងប្រធានកងដឹកជញ្ជូន ឈ្មោះ ពូតឿ ដែលបានជួយសង្គ្រោះជីវិតរបស់គាត់ជាច្រើនលើកច្រើនសារ ដោយសារតែខ្មែរក្រហមចង់យកទៅសម្លាប់ចោល ។

ដើមបណ្ដឹងរដ្ឋប្បវេណី យិន រំដួល បានបញ្ជាក់ជូនអង្គជំនុំជម្រះថា អំឡុងពេលរស់នៅជាមួយ ឈ្មោះ តឿ ក្នុងកងដឹកជញ្ជូន គាត់បានឃើញខ្មែរក្រហមសម្លាប់ប្រជាជនដែលត្រូវបានជម្លៀសពីខេត្តស្វាយរៀង មកខេត្តពោធិ៍សាត់ដោយផ្ទាល់ភ្នែក នៅពេលដែលខ្លួនកំពុងឃ្វាលក្របី ។ ខ្មែរក្រហមបានយកប្រជាជនពីខេត្តស្វាយរៀង ទៅសម្លាប់នៅហុងទឹក នៅក្នុងឃុំមេទឹក ។ ក្រោយពីឃើញព្រឹត្តិការណ៍នេះ ដើមបណ្ដឹងបានសួរទៅឈ្មោះ តឿ ថា «គេសម្លាប់មនុស្សច្រើនម្ល៉េះពូ?» ពេលនោះ ឈ្មោះ តឿ បានប្រាប់ថា «នៅឲ្យស្ងៀមៗ ឯងកុំមាត់» ។ ក្រោយមកទៀត នៅពេលផ្លាស់ទៅធ្វើការជាមួយឈ្មោះ តឿ នៅទន្លេសាប រំដួល បានឃើញសាកសពប្រជាជនមួយគ្រួសារមានគ្នាប្រមាណ៥ ទៅ៦នាក់ ដែលខ្មែរក្រហមយកទៅសម្លាប់ចោលនៅក្រោមដើមរាំង នៅក្នុងព្រៃត្រែង បន្ទាប់ពីមេភូមិនៅទីនោះ បានហៅអ្នកទាំងនោះឲ្យទៅចាំចម្ការ ប៉ុន្តែតាមការពិតគ្រួសារនេះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ។

**គ) សេចក្ដីថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

«អង្គសវនាការទាំងមូលជាទីគោរព! អ្វីៗដែលខ្ញុំបានស្ដែងឡើងនៅថ្ងៃនេះ ខ្ញុំសូមជម្រាបទៅអង្គសវនាការ និងជនរួមជាតិ និងប្រជាជននៅលើពិភពលោកឲ្យបានជ្រាបថា សោកនាដកម្មនៅក្នុងរបប ប៉ុល ពត គឺឃោរឃៅព្រៃផ្សៃជាងសត្វតិរច្ឆានទៅទៀត ។ ខ្ញុំចុកចាប់ណាស់ ។ ខ្ញុំបាត់បង់ឪពុក បាត់បង់ម្ដាយ បាត់បង់ឪពុកមាជាទីស្រឡាញ់របស់ខ្ញុំ ។ ខ្ញុំចង់ឲ្យគាត់សងមកវិញនូវអ្វីដែលគាត់ជំពាក់ខ្ញុំ ក្នុងឋានៈជាមេដឹកនាំរដ្ឋមួយ ។ គាត់ត្រូវតែហ៊ានទទួលខុសត្រូវចំពោះទង្វើដ៏លាមករបស់គាត់ ។ គាត់ត្រូវតែបើកកកាយនូវទំព័រប្រវត្តិសាស្ត្រ សម្រាប់ប្រជាជាតិកម្ពុជា និងប្រជាជនពិភពលោកឲ្យគេដឹងថា អំពីអាក្រក់របស់គាត់ដែលបង្កឡើងដោយរបបខ្មែរក្រហមនេះវាឃោរឃៅប៉ុនណា ក្នុងឋានៈជាមេដឹកនាំរដ្ឋមួយ ។

អ្វីៗទាំងអស់មកទាល់ថ្ងៃនេះ ខ្ញុំរង់ចាំ៣៨ឆ្នាំហើយ ពីកុមារភាព ខ្ញុំបានចងចាំទុកក្នុងខួរក្បាលខ្ញុំថា ខ្ញុំនឹងបើកកកាយនូវអំពើអាក្រក់របស់គាត់ បើសិនជាខ្ញុំមានឱកាស ។ បើសិនជាខ្ញុំមានឱកាសខ្ញុំនឹងបើកកកាយនូវទង្វើដ៏លាមក និងអាក្រក់របស់គាត់ឲ្យប្រជាជាតិនៅលើពិភពលោក និងប្រជាជនខ្មែរដែលរងគ្រោះដោយការកាប់សម្លាប់របស់គាត់បានជ្រាប បានដឹងនូវអ្វីដែលគាត់បានបង្កឡើង ។

សោកនាដកម្មដ៏ចុកចាប់នេះ គាត់មកធ្វើចំពោះខ្ញុំជាកូនក្មេង បំបែកបំបាក់ខ្ញុំពីឪពុកម្ដាយ មិនឲ្យខ្ញុំរៀនសូត្រ មិនឲ្យខ្ញុំសិក្សា តើសីលធម៌ជាមេដឹកនាំនៅត្រង់ណា? លោក ខៀវ សំផន ពិចារណាទៅ! លោក នួន ជា ពិចារណាទៅ! ក្នុងឋានៈជាបញ្ញាជនជាន់ខ្ពស់ម្នាក់ លោកពិចារណាទៅ! លោកត្រូវតែហ៊ានបកស្រាយការពិតចំពោះមុខជាតិ និងប្រជាជាតិទាំងមូល លោកមិនត្រូវសោកស្ដាយ ឬមានវិប្បដិសារីក្នុងការបកស្រាយទេ ។ ខ្ញុំចុកចាប់ណាស់ ។ ថ្ងៃនេះខ្ញុំសូមទោសអង្គសវនាការទាំងមូល ។ ខ្ញុំសូមបញ្ចេញនូវទស្សនៈនូវភាពចុកចាប់របស់ខ្ញុំ ។ ចិញ្ចើមរបស់ខ្ញុំស្នាមរហូតដល់កូនរបស់ខ្ញុំ និងចៅរបស់ខ្ញុំ តាមរយៈការវ៉ៃនឹងដំបងរបស់លោក ក្រុមរបស់លោក បក្សពួករបស់លោក ក្នុងឋានៈលោកជាមេដឹកនាំ ។ លោកអត់បានស្រឡាញ់ជាតិរបស់ខ្លួនទេ ។ លោកបំផ្លាញជាតិរបស់ខ្លួន ។ លោកធ្វើឲ្យជាតិរបស់ខ្លួនរងគ្រោះវេទនា អាប់ឱនកិត្តិយសនៅក្នុងពិភពលោកនេះ ។ គេគ្រាន់តែនិយាយថា ខ្មែរ គេខ្លាចតាមរយៈបញ្ញាជនដ៏ពុំគួរឲ្យកោតសរសើរនេះ ។ លោកពិចារណាចុះ!» ។

ជាចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណី យិន រំដួល បានស្នើសុំឲ្យតុលាការស្វែងរកយុត្តិធម៌ឲ្យរូបលោក និងប្រជាជាតិទាំងមូល ព្រមទាំងដាក់ទណ្ឌកម្មលើជនជាប់ចោទឲ្យសក្ដិសមទៅនឹងទម្ងន់ទោស ដើម្បីជៀសវាងកុំឲ្យមេដឹកនាំខ្មែរជំនាន់ក្រោយ និងមេដឹកនាំដទៃទៀតនៅលើពិភពលោកយកគំរូ អាក្រក់តាម ។

**ឃ) ការចោទសំណួរពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះជនជាប់ចោទ**

*អង្គជំនុំជម្រះបានផ្តល់ឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល ដើម្បីចោទសំណួរទៅជនជាប់ចោទ តាមរយៈអង្គជំនុំជម្រះ ។ លោក យិន រំដួល បានបញ្ជាក់ថា លោកមានសំណួរ៥ ដើម្បីសួរជនជាប់ចោទ ខៀវ សំផន និង នួន ជា ។ សំណួរទាំង៥ នោះ មានដូចខាងក្រោម ៖*

*សំណួរទី១ តើលោកបានដឹងអំពីការចាប់ខ្លួន និងបាត់ខ្លួនឪពុករបស់ខ្ញុំបាទ ឈ្មោះ យិន ស៊ីដារ៉េត ជាសាស្ត្រាចារ្យ និងជាវរសេនីយ៍ឯក មេបញ្ជាការកងទ័ពលេខ២៤ បេ.អ៊ី មានទីតាំងនៅបន្ទាយដែកមុនអ្នកលឿងឬទេ?*

*សំណួរទី២ តើលោកមានដែលគិតដល់ផលវិបាកនៃការកាប់សម្លាប់ ការព្រាត់ប្រាស់គ្រួសារ ដែលខ្មែរក្រហមបានបង្កឡើងដល់រូបលោកផ្ទាល់ដែរឬទេ? តើលោកមានការភ្ញាក់រឭក និងមានវិប្បដិសារីចំពោះការចូលរួមរបស់លោកក្នុងរបបនេះដែលបានបង្កការឈឺចាប់ដល់ប្រជាជនខ្មែរទាំងមូលដែរឬទេ?*

*សំណួរទី៣ ក្នុងឋានៈលោកជាបញ្ញាជនជាន់ខ្ពស់ម្នាក់ តើលោកហ៊ានធ្វើការបកស្រាយនូវការពិតនូវហេតុការណ៍ដែលកើតឡើងក្នុងរបបខ្មែរក្រហមឲ្យប្រជាជាតិ និងប្រជាជនពិភពលោកទាំងមូលបានដឹងដែរឬទេ ក្នុងឋានៈលោកជាមេដឹកនាំកំពូល ហើយក្នុងឋានៈលោកជាបញ្ញាជនជាន់ខ្ពស់ ដែលលោកបានប្រើប្រាស់កន្លងមក ហើយបានទទួលនូវភាពល្បីល្បាញពីសម័យសង្គមរាស្ត្រនិយម និងសាធារណរដ្ឋខ្មែរតាមរយៈការដឹង និងការស្រាវជ្រាវរបស់ខ្ញុំ ។*

*សំណួរទី៤ តើលោកមានគំនិតក្នុងការសុំទោសដល់ប្រជាជនកម្ពុជា ជាពិសេសក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីនេះ ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ។*

*សំណួរទី៥ ក្នុងនាមប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ តើលោកបានដឹងអ្វីខ្លះអំពីកម្រិតជីវភាពនៃការរស់នៅរបស់ប្រជាជន ដែលរងគ្រោះដោយការអត់ឃ្លាន និងការកាប់សម្លាប់ ការឃុំឃាំង ការចាប់ខ្លួន ការធ្វើទារុណកម្មដ៏ឃោរឃៅក្នុងរបបរបស់លោកដែរឬទេ?*

### ង) ការឆ្លើយតបសំណួរដោយ ខៀវ សំផន និង នួន ជា

*បន្ទាប់ពីទទួលបានសំណួរទាំង៥របស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានផ្តល់ឱកាសជូនជនជាប់ចោទ ខៀវ សំផន និង នួន ជា ដើម្បីឆ្លើយតប ។*

*ខាងក្រោម ជាសម្តីដកស្រង់ទាំងស្រុងរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានឆ្លើយតបចំពោះសំណួរទាំង៥របស់ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល ៖*

*"សូមគោរពលោកប្រធាន! សូមគោរពអស់លោក លោកស្រីចៅក្រមទាំងអស់ ។ សូមគោរពអង្គសវនាការទាំងមូល ។ សូមជម្រាបសួរលោក យិន រំដួល ។ ខ្ញុំសូមជម្រាបលោកថា បើខ្ញុំជាលោកវិញ ខ្ញុំក៏ឈឺចាប់ ហើយសោកសង្រេងដូចលោកដែរ ។*

*ចំពោះសំណួរទី១របស់លោក ខ្ញុំសូមជម្រាបលោកថា ខ្ញុំមិនដែលបានស្គាល់ឪពុកលោកនោះទេ ។ ខ្ញុំមិនដែលបានស្គាល់លោក យិន ស៊ីដារ៉េត នោះទេ ។ ហើយខ្ញុំសោកស្តាយណាស់ ដោយឪពុកលោកត្រូវបានគេសម្លាប់ដោយឃោរឃៅ ។ ខ្ញុំសូមជម្រាបលោកថា ចាប់ពីខ្ញុំពេលដែលខ្ញុំរត់គៀសខ្លួនចេញពីភ្នំពេញពេលណាមក ខ្ញុំបានត្រូវការពារដោយមេខ្មែរក្រហមរហូតដល់ឆ្នាំ ១៩៧៩ ។ ដូច្នេះ ខ្ញុំត្រូវរស់នៅ ហៅថាដោយដាច់ពីជីវភាពជាក់ស្តែងរបស់ប្រជាជនរហូតមកដែរ ។ រាប់សិបឆ្នាំ កាលពីឆ្នាំ៧០ ដល់ឆ្នាំ៧៩ ដោយខ្ញុំត្រូវរស់នៅជាប់ជាមួយនឹងអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងដោយតួនាទីខ្ញុំនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ខ្ញុំបានរួចខ្លួន មិនបានជួបប្រទះនឹងអំពើឃោរឃៅដ៏អាក្រក់លើលោរបស់ស្តេចត្រាញ់ផ្សេងៗ ដែលបានបង្កជាសោកនាដកម្មដល់ជាតិ និងប្រជាជនយើងយ៉ាងនេះទេ ។ តែមុខមួយទៀត ក៏នាំឲ្យខ្ញុំមិនបានដឹងឮអំពីអំពើឃោរឃៅអាក្រក់លើលោដូចដែលដើមបណ្តឹងរដ្ឋប្បវេណីជាបន្តបន្ទាប់ ហើយក្រោយនេះ លោកបានអញ្ជើញមករៀបរាប់នៅតុលាការនេះដែរ ។*

*ពិតមែនហើយ ខ្ញុំមិនមែនជាអ្នកមនោគមន៍វិជ្ជាទេ ក៏ប៉ុន្តែខ្ញុំជាអ្នកដែលមានឧត្តមគតិមួយ គឺឧត្តមគតិរួមចំណែកធ្វើម៉េចកសាងប្រទេសយើងឲ្យបានរីកចម្រើនជឿនលឿន និងការពារប្រទេសយើងឲ្យបានរស់គង់វង្ស ។*

*ដូច្នេះចំពោះសំណួរទី២របស់លោក ក៏ខ្ញុំមានការសោកស្តាយ ហើយខ្ញុំយល់ឃើញថា ត្រូវតែចាប់ស្តេចត្រាញ់ដែលបានប្រព្រឹត្តអំពើឃោរឃៅដ៏អាក្រក់លើលោទាំងនោះយកមកកាត់ទោសឲ្យស័ក្តិសម*

ទៅតាមធាតុឃោរឃៅឆ្កួតលីលារបស់វា ។ ដែលខ្ញុំបានមករួមជាមួយកម្ពុជាប្រជាធិបតេយ្យ មិនមែនដើម្បីសម្លាប់ផ្ដាលខ្មែរគ្នាឯងទេ គឺដើម្បីរួមចំណែកការពារជាតិឲ្យរស់គង់វង្ស ហើយក្រោយតទៅទៀតកសាងជាតិឲ្យបានរីកចម្រើន ។ ប៉ុន្តែ ខ្ញុំស្ដាយណាស់វាបែរទៅជាអីចឹងវិញ ។

ឥឡូវ ចំពោះសំណួរទីពីរបស់លោក ខ្ញុំបានជម្រាបតុលាការរួចហើយថា ខ្ញុំនឹងរួមជាមួយតុលាការឲ្យអស់លទ្ធភាពរបស់ខ្ញុំ ដើម្បីស្វែងរកការពិត ។ ដូច្នេះហើយបានជាខ្ញុំសម្រេចចិត្តឆ្លើយនឹងសំណួររបស់លោក ។ ហើយត្រៀមខ្លួនដើម្បីឆ្លើយនឹងសំណួររបស់ភាគីទាំងអស់នៅក្នុងសវនាការនេះ ។

ចំពោះសំណួរទី៤របស់លោក ខ្ញុំសូមជម្រាបលោកថា ពីម្សិលមិញខ្ញុំបានលើកដៃសំពះសូមទោសលោកស្រី ហួ ចន្ទា ហើយតាមរយៈលោកស្រី ហួ ចន្ទា ក៏ខ្ញុំសូមទោស ប្រជាជនខ្មែរយើងទាំងមូល ទាំងអស់ ដែលបានរងគ្រោះរួចមកហើយនេះ ។ ថ្ងៃនេះ ខ្ញុំក៏សូមទោសលោកទៀត ខ្ញុំសូមលំឱនកាយគោរពដល់វិញ្ញាណក្ខន្ធឪពុករបស់លោក ម្ដាយរបស់លោក និងសាច់សាលោហិតរបស់លោកដែលបានចែកឋានទៅក្នុងក្ដីឈឺចាប់ខ្លោចផ្សារ កនិយាយមិនបាន ។

សំណួរទី៥ មើលពីក្រៅមក គេអាចសន្និដ្ឋានថាខ្ញុំជាមេដឹកនាំធំ ។ ពិតមែនហើយ ខ្ញុំមានស្លាកចំណាស់ តែខ្ញុំគ្មានអំណាចជាក់ស្ដែងដើម្បីចាប់អ្នកនេះ ចាប់អ្នកនោះទេ ។ ហើយដូចខ្ញុំបានជម្រាបខាងលើ ខ្ញុំមិនបានដឹងនូវសភាពការណ៍ប្រជាជនយើងត្រូវរស់នៅជាក់ស្ដែងយ៉ាងណាៗនោះទេ ។ ត្រូវគេធ្វើទុក្ខធ្វើបាបយ៉ាងណាៗនោះទេ ។ ឬមួយក៏ត្រូវគេចាប់ចង ដាក់គុកច្រវាក់យ៉ាងណាៗនោះទេ ។ ខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង ។

ម្ដងទៀត ខ្ញុំសូមទោសលោក ខ្ញុំសូមទោស ពិតមែនតែខ្ញុំមិនបានចូលសម្រេចនៅនយោបាយអ្វីរបស់កម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ខ្ញុំសូមទោស ពីព្រោះដូចពីព្រឹកមិញអីចឹង គេហៅថា "ត្រីមួយត្រកស្អុយ វាស្អុយទាំងអស់" ។ ការពិតទៅខ្ញុំមិនស្អុយទេ ក្នុងន័យថា ខ្ញុំមិនបានប្រព្រឹត្តអំពើឃោរឃៅដ៏ល្វីងខ្លោចដូចដែលលោកហើយនិងភាគីដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតបានរៀបរាប់ជាបន្តបន្ទាប់មកនោះទេ ។ ខ្ញុំសូមអស់ហើយ ។ អរគុណលោក ។

បន្ទាប់ពីជនជាប់ចោទ ខៀវ សំផន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនជនជាប់ចោទ នួន ជា ដើម្បីឆ្លើយតបនឹងសំណួរទាំង៥ របស់ដើមបណ្ដឹងរដ្ឋប្បវេណី យិន វំដួល ។

ខ្ញុំបានមានមតិជាហូរហែមកហើយ គឺថា ខ្ញុំសូមទទួលខុសត្រូវទាំងអស់នូវអ្វីដែលកើតមានកន្លងមកក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នោះ ខ្ញុំមិនគេចវេះទៅណាទេ ។ ខាងផ្លូវចិត្ត ខ្ញុំសូមទទួលការខុសត្រូវទាំងអស់ដោយស្មោះអស់ពីចិត្ត ។ នេះសូមជម្រាបដោយត្រង់ ពីព្រោះក្នុងឋានៈជាសមាជិកម្នាក់របស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំហ៊ានទទួលខុសត្រូវ ទោះបីជាខ្លួនខ្ញុំបានប្រព្រឹត្តដោយផ្ទាល់ ឬមិនដោយផ្ទាល់ក៏ដោយ តែខ្ញុំសោកស្ដាយណាស់ចំពោះព្រឹត្តិការណ៍ទាំងឡាយដែលកើតឡើងដោយចេតនា ឬដោយអចេតនា ។ ហើយទោះបីជាខ្ញុំដឹង ឬមិនដឹងក៏ដោយ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀតថា ខ្ញុំទទួលខុសត្រូវទាំងអស់ ។ ខាងផ្លូវចិត្ត ខ្ញុំសូមជម្រាបបញ្ជាក់អីចឹង ។

ក្នុងឱកាសនេះ ខ្ញុំសូមចូលរួមមរណទុក្ខ ការសោកស្ដាយចំពោះការបាត់បង់គ្រួសាររបស់លោក វំដួល ។ តាមខ្ញុំចាំឈ្មោះលោក វំដួល ។ ដូច្នោះ ហើយតទៅនេះ ខ្ញុំសូមបញ្ជាក់ម្ដងទៀតនូវតួនាទី និងភារកិច្ចរបស់ខ្ញុំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ខទី១ ខ្ញុំជាសមាជិកអចិន្ត្រៃយ៍ អនុលេខាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ទទួលខាងការអប់រំរៀនសូត្រផ្ទៃក្នុងបក្ស ។ ខទី២ ខ្ញុំទទួលភារកិច្ចជាប្រធានគណៈកម្មាធិការសភាតំណាងប្រជាជនកម្ពុជា ។ ភារកិច្ចរបស់ខ្ញុំមានពីរប៉ុណ្ណឹងទេ ។ ឯខាងនីតិបញ្ញត្តិ នីតិប្រតិបត្តិ ខ្ញុំមិនមានអ្វីក្រៅពីការស្មោះត្រង់ ចូលរួមការតស៊ូដើម្បីជាតិប្រជាជនរបស់ខ្ញុំប៉ុណ្ណោះទេ ។ សូមបញ្ជាក់ សូមគោរពលោកប្រធាន" ។

## ៤) ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា

### ក) ប្រវត្តិសាវតា

ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា អាយុ៦០ឆ្នាំ មុខរបរបោកអ៊ុតសំលៀកបំពាក់ មានទីកន្លែងកំណើតនៅឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល ។ បច្ចុប្បន្នលោកស្រីរស់នៅភូមិកាប់ទូក សង្កាត់កណ្ដាលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ

កុយ ប៉ូ និង ម្តាយឈ្មោះ ប្រែង រ៉េន និងស្វាមីឈ្មោះ សៅ សារិន មានកូន១នាក់ ។

### ១) ព្រឹត្តិការណ៍ជម្លៀសប្រជាជនថ្ងៃ១៧ ខែមេសា ឆ្នាំ ១៩៧៥

ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានបញ្ជាក់ជូនអង្គសវនាការថា ក្រោយពេលយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលក្នុងផ្ទះ ដែលលោកស្រីបានស្នាក់អាស្រ័យជាមួយ ។ បន្ទាប់មក យោធាខ្មែរក្រហមទាំងនោះបានស្រែកសួររកម្ចាស់ផ្ទះ ប៉ុន្តែលោកស្រីបានឆ្លើយប្រាប់យោធាខ្មែរក្រហមវិញថា គាត់ពុំមែនជាម្ចាស់ផ្ទះទេ គ្រាន់តែជាអ្នកយាមផ្ទះឲ្យគេប៉ុណ្ណោះ ។ យោធាខ្មែរក្រហមពុំជឿការបញ្ជាក់នេះទេ និងបានចូលលុកលុយ បោកប្រាស់សម្ភារៈ និងទ្រព្យសម្បត្តិនៅគេហដ្ឋាននោះចោលតែម្តង ។ បន្តិចក្រោយមក យោធាខ្មែរក្រហមបានឃើញស្វាមីរបស់លោកស្រីដែលស្ថិតនៅក្នុងផ្ទះជាមួយគ្នា និងបានវាយធ្វើបាបយ៉ាងឃោរឃៅ ដោយសារពុំជឿថា លោកស្រី និងប្តីជា អ្នកយាមផ្ទះ ។ បន្ទាប់មក ព្រះអង្គម្ចាស់ នរោត្តម កន្តុល បានយាងមកដល់ និងស្នើសុំទាហានខ្មែរក្រហមកុំឲ្យវាយធ្វើបាបប្តីរបស់លោកស្រីឌីណា ដោយសារអ្នកទាំងពីរគ្រាន់តែជាអ្នកយាមផ្ទះប៉ុណ្ណោះ ។ មួយសន្ទុះក្រោយមកយោធាខ្មែរក្រហមក៏ព្រមចាកចេញពីទីនោះ ។ ប៉ុន្តែ នៅវេលាយប់ម៉ោង៨ យោធាខ្មែរក្រហមមួយក្រុមផ្សេងទៀត បានមកបណ្តេញអ្នកនៅក្នុងលំនៅដ្ឋានដែលលោកស្រីស្នាក់នៅឲ្យចាកចេញពីទីនោះទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានបន្តថា គាត់ និងស្វាមី ព្រមទាំង កូនម្នាក់ ត្រូវបានបង្ខំឲ្យចាកចេញពីលំនៅដ្ឋានទាំងយប់ ដោយធ្វើដំណើរឆ្ពោះទៅតាមស្ពានមុនីវង្ស ហើយត្រូវចំណាយពេលដើរ២ ទៅ៣ថ្ងៃ ទម្រាំដល់ព្រែកឯង និងត្រូវបន្តដំណើរប្រមាណ៣ថ្ងៃទៀត ទើបទៅដល់ស្រុកកំណើតនៅឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ។

ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានពណ៌នាថា នៅតាមផ្លូវដំណើរអំឡុងពេលនៃការជម្លៀស លោកស្រីបានឃើញដោយផ្ទាល់ភ្នែកនូវទិដ្ឋភាពនៃការចាប់ចងទាហាន លន់ នល់ ទាំងខ្សែៗ ដោយយោធាខ្មែរក្រហមបណ្តើរតាមផ្លូវ ប៉ុន្តែពុំដឹងថាអ្នកទាំងនោះត្រូវនាំយកទៅទីណា ។ ចំពោះការធ្វើដំណើរតាមផ្លូវ ដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាកយ៉ាងខ្លាំង អត់ទាំងស្បៀងអាហារ និងខ្វះទីជំរក ។

ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា និងគ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ ។ នៅទីនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ពុំមានស្បៀងអាហារហូបចុកគ្រប់គ្រាប់ និងគ្មានទីជំរកស្នាក់នៅច្បាស់លាស់ ។ មួយរយៈក្រោយមក ប្តីរបស់លោកស្រីត្រូវខ្មែរក្រហមហៅទៅរៀនសូត្រ ប៉ុន្តែចាប់តាំងពីពេលនោះមក ប្តីលោកស្រីពុំដែលត្រឡប់មកវិញឡើយ ។ ការហៅទៅរៀនសូត្រនេះ ដោយសារតែខ្មែរក្រហមសង្ស័យថា ប្តីលោកស្រីជាអតីតទាហានស័ក្តិ៥ក្នុងរដ្ឋការ លន់ នល់ ។ ចំណែកឯខ្លួនជាប្រពន្ធ ត្រូវខ្មែរក្រហមតាមដាន និងបង្ខំឲ្យធ្វើការគ្មានពេលសម្រាក ។ លោកស្រីបញ្ជាក់ថា ប្តីរបស់គាត់ពុំធ្លាប់ធ្វើជាទាហានម្តងណាទេ ។

បន្ទាប់ពីបាត់ប្តី កូនរបស់ ប៉ូ ឌីណា បានធ្លាក់ខ្លួនឈឺដោយសារអត់ចំណីអាហារហូបចុកគ្រប់គ្រាន់ និងបានស្លាប់បាត់បង់ជីវិតដោយការអត់ឃ្លាន ។ បន្ទាប់ពី បាត់បង់កូន ម្តាយរបស់លោកស្រីបានស្លាប់ដោយសារជំងឺទៀត ។ ក្រោយពីម្តាយ ស្វាមី និងកូនបានស្លាប់បាត់បង់ជីវិត ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា ត្រូវខ្មែរក្រហមបង្ខំឲ្យយកគ្រួសារថ្មី ប៉ុន្តែលោកស្រីបានបដិសេធ ។ ការបដិសេធនេះ បានធ្វើឲ្យលោកស្រីត្រូវទទួលរងការធ្វើទារុណកម្ម និងត្រូវដាក់នៅក្នុងគុក ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានបញ្ជាក់ថា លោកស្រីបានឃើញហេតុការណ៍ប្លែកៗជាច្រើន ដូចជាការធ្វើទារុណកម្មលើរូបអ្នកទោស ការដាក់ខ្នោះដែកជាប់នឹងជើងជាដើម ។

នៅមុនពេលបញ្ចប់ លោកស្រី ប៉ូ ឌីណា បានរៀបរាប់អំពីទុក្ខសោកថា ៖

*«ពេលនោះនាងខ្ញុំបាត់បង់អ្វីៗទាំងអស់ បាត់បង់បងប្អូន ម៉ែឪ ស្វាមី ព្រមទាំងកូនអស់ហើយ ។ ឥឡូវហ្នឹង ទឹកចិត្តរបស់ខ្ញុំមានការតក់ស្លុត មានការឈឺចាប់អារម្មណ៍របស់នាងខ្ញុំនេះ វាដូចចង់ឆ្កួត ដូចវិកលចរិត ។ ភ្លេចមុខភ្លេចក្រោយ គ្មានគិតអ្វីដឹងទាំងអស់ ដោយសារអាឡោះអាល័យក្រុមគ្រួសារ ដែលបានបាត់បង់ជីវិត»* ។

# សវនាការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី, សឿន សុវណ្ណឌី និង សេង ស៊ីវត្ថា

## ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការស្តាប់សេចក្តីថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបីរូបឈ្មោះ បេ សុផានី, សឿន សុវណ្ណឌី និង សេង ស៊ីវត្ថា ។ ដូចគ្នានឹងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតដែរ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូបត្រូវបានអង្គជំនុំជម្រះផ្តល់ឱកាស ដើម្បីថ្លែងអំពីទុក្ខសោករបស់ខ្លួនដែលធ្លាប់បានឆ្លងកាត់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីបានសួរសំណួរមួយចំនួនទៅកាន់ជនជាប់ចោទទាំងពីរនាក់ទាក់ទងនឹងគោលនយោបាយនៃការជម្លៀសប្រជាជន ការធ្វើទុក្ខបុកម្នេញលើកុមារ និងការសម្លាប់ប្រជាជនស្លូតត្រង់ ។ សវនការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូប មានការចូលរួមពីជនជាប់ចោទ ខៀវ សំផន ដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ។ ដោយឡែក ជនជាប់ចោទ នួន ជា ពុំមានលទ្ធភាពចូលរួមដោយផ្ទាល់ ប៉ុន្តែបានចូលរួមពីចម្ងាយនៅបន្ទប់ខាងក្រោមសាលសវនាការ ហើយជនជាប់ចោទបានឆ្លើយសំណួរមួយចំនួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈប្រព័ន្ធសោតទស្សន៍ ។

មុនពេលចាប់ផ្តើម ចៅក្រម និល ណុន បានប្រកាសអំពីអវត្តមានរបស់ចៅក្រម យូ ឧត្តរា ដោយសារបញ្ហាសុខភាព ហើយអង្គជំនុំជម្រះក៏បានតែងតាំងចៅក្រម ធូ មណី ដើម្បីជំនួសចៅក្រម យូ ឧត្តរា នៅក្នុងសវនាការនេះ ។

### ១) ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី

ជាការចាប់ផ្តើម ចៅក្រម និល ណុន បានសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ទាប់មក អង្គជំនុំជម្រះបានផ្តល់វេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរសំណួរមួយចំនួនមុនពេលផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងការណ៍អំពីទុក្ខសោករបស់ខ្លួន ។ គួរបញ្ជាក់ថា សវនាការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី ពុំត្រូវបានសួរដេញដោលពីមេធាវីការពារក្តី នួន ជា ទេ ដោយមេធាវីបានបញ្ជាក់ថា ពុំមានសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។

ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី បានរៀបរាប់ថា លោកស្រីមានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង ហើយសព្វថ្ងៃរស់នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកឈ្មោះ អ៊ុយ ងឹម ម្តាយឈ្មោះ សៀង សៀន ប្តីឈ្មោះ បេ សារិត និង មានកូនបីនាក់ ប្រុសម្នាក់ និងស្រីពីរនាក់ ។

#### ក) ការសួរដេញដោលដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ជាការចាប់ផ្តើម សហមេធាវីអន្តរជាតិ នូស៊ីន សាកាវ៉ាទីបានសួរទាក់ទងនឹងស្ថានភាពរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅមុនថ្ងៃទី១៧ ខែមេសា សុផានី មានមុខរបរជាគ្រូបង្រៀន ចំណែកប្តីរបស់លោកស្រីជាវិរសេនីយ៍ទោទ័ពជើងគោកនៅក្នុង របប លន់ នល់ និងត្រូវជាប្អូនប្រុសបង្កើតរបស់ភរិយា លន់ នល់ ។ នៅឆ្នាំ១៩៧៤ ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរដ្ឋាភិបាល លន់ នល់ បញ្ជូនទៅបន្តការសិក្សាជាទាហានជាន់ខ្ពស់នៅសហរដ្ឋអាមេរិក ចំណែកលោកស្រីបានរស់នៅជាមួយកូនទាំងបីនាក់ នៅទីក្រុងភ្នំពេញ ។ លោកស្រីបានបន្តរៀបរាប់ថា នៅថ្ងៃ១៧ខែមេសា កងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញដោយមានកាំភ្លើងគ្រប់ដៃ និងមានទឹកមុខមាំ ។ បន្ទាប់មក យោធាទាំងនោះបានបាញ់កាំភ្លើងឡើងលើដើម្បីបណ្តេញប្រជាជនឲ្យចេញពីទីក្រុងព្រមទាំងប្រាប់ថា សហរដ្ឋអាមេរិកនឹងទម្លាក់គ្រាប់បែក ។ នៅក្នុងស្ថានភាពភ័យរន្ធត់បែបនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានប្រញ៉ាប់ប្រញ៉ាល់នាំកូនទាំងបីនាក់ចាកចេញពីផ្ទះឲ្យបានលឿនព្រោះខ្លាចខ្មែរក្រហមចូលមកដល់ផ្ទះ ដោយសារនៅក្នុងផ្ទះមានឯកសណ្ឋានទាហាន និងមានរូបថតដែលថតជុំគ្នាជាមួយ លន់ នល់ ។ នៅពេលនោះ សុផានី បានចាកចេញទាំងពុំបានយកអីវ៉ាន់

អ៊ីច្រើនទៅជាមួយទេ ដោយសំដៅទៅផ្ទះបងថ្លៃ (បងស្រីរបស់ប្ដីឈ្មោះ វ៉ាន់ សារិន ជាអនុរដ្ឋមន្ត្រីក្រសួងកំពែនទូទៅ) ប៉ុន្តែត្រូវបានយោធាខ្មែរក្រហមបិទផ្លូវមិនឲ្យឆ្លងកាត់ ហើយត្រូវដើរតាមកាណុងកាំភ្លើង ដែលយោធាទាំងនោះបង្ហាញផ្លូវឲ្យធ្វើដំណើរតាមផ្លូវមុនីវង្សកាត់តាមច្បារអំពៅ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បេ សុផានី បានថ្លែងរៀបរាប់ថា ក្នុងពេលធ្វើដំណើរនៅតាមផ្លូវនោះ មានការលំបាកខ្លាំងណាស់ ដោយសារមានមនុស្សច្រើន ហើយគាត់ត្រូវដើរជាមួយកូនតូចៗទាំងក្ដៅ ទាំងភ្លៀង ។ ជាងនេះទៅទៀត សុផានី បានឃើញសាកសពទាហាន លន់ នល់ និងប្រជាជនទាំងចាស់ទាំងក្មេង ជនពិការ និងស្ត្រីមានផ្ទៃពោះ បានស្លាប់ជាច្រើននាក់នៅតាមផ្លូវ ។ នៅពេលនោះ សុផានី បានចូលជ្រកភ្លៀងនៅក្រោមដើមស្វាយជាមួយកូនទាំងបីទាំងកំពុងធ្លាក់ខ្លួនឈឺទៅហើយ ប៉ុន្តែយោធាខ្មែរក្រហមបានបន្តបណ្ដេញឲ្យខ្លួនធ្វើដំណើរបន្តទៅមុខទៀត ។ លុះទៅដល់ភូមិត្រើយស្លា ដើមបណ្ដឹងរដ្ឋប្បវេណីបានចូលទៅជ្រកក្រោមផ្ទះអ្នកភូមិ ដែលសុទ្ធតែជាប្រជាជនមូលដ្ឋាន ហើយប្រជាជនទាំងនោះបានឲ្យអាហារមកគាត់និងកូនបរិភោគ ។ ប៉ុន្តែយោធាខ្មែរក្រហមបានប្រាប់មិនឲ្យប្រជាជនទាំងនោះផ្ដល់ឲ្យអាហារទៀតទេ ព្រមទាំងបណ្ដេញឲ្យចេញទៅនៅឯចុងភូមិ ដែលពុំមានមនុស្សរស់នៅទាល់តែសោះ ដោយសារតែជាប្រជាជន១៧ខែមេសា ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តទាំងអួលដើមកថា បន្ទាប់ពីត្រូវខ្មែរក្រហមបណ្ដេញចេញពីភូមិ សុផានី និងកូនតូចៗបានទៅរកស្លឹកត្នោតមកបាំងដើម្បីស្នាក់នៅ ។ នៅពេលនោះ ទារកតូចរបស់គាត់មានជំងឺគ្រុនក្ដៅកាន់តែខ្លាំង ដូច្នេះ គាត់បានយកចិញ្ចៀនមួយវង់ ដែលភរិយារបស់ លន់ នល់ ចងដៃក្នុងថ្ងៃរៀបការ ទៅដូរនឹងអង្ករពីប្រជាជនមូលដ្ឋានបាន២៥កំប៉ុង ទើបខ្លួនយកអង្ករខ្លះទៅដូរនឹងថ្នាំអាស្ពីរីនឲ្យកូនលេប ប៉ុន្តែ ថ្នាំនោះមិនអាចជួយកូនគាត់បានទេ ។ បន្ទាប់មក សុផានី បាននាំកូនទាំងបីនាក់ទៅរកពេទ្យ ហើយបានជួបនឹងអ្នកភូមិម្នាក់ដែលប្រាប់ឲ្យគាត់ទៅរកពេទ្យយោធាខ្មែរក្រហម ។ ក្រោយពេលធ្វើដំណើរប្រហែល៤ទៅ៥គីឡូម៉ែត្រ សុផានី បានទៅដល់មន្ទីរពេទ្យខ្មែរក្រហម ហើយជួបនឹងពេទ្យប្រុសម្នាក់ ។ នៅពេលនោះ សុផានី បានសំពះសុំឲ្យពេទ្យនោះជួយថា "សូមលោកមេត្តាជួយកូនខ្ញុំផង កូនខ្ញុំឈឺខ្លាំងណាស់ ។ កូនខ្ញុំក្ដៅខ្លួន ហើយរាគខ្លាំងណាស់ ទទួលអាហារអត់បានទេ ។ ឥឡូវនេះដាក់តែពីមាត់ចេញតាមគូទវិញអស់" ។ ពេទ្យខ្មែរក្រហមនោះបានឆ្លើយថា "យកមក យកកូនមក" ។បន្ទាប់មក លោកស្រីបានយកកូនតូចទៅដាក់នៅលើគ្រែ ហើយពេទ្យនោះបានយក ថ្នាំម្យ៉ាងមកចាក់នៅលើក្បាលរបស់កូនតូច ។ គ្រាន់តែដកម្ជុលចេញភ្លាមកូនតូចនោះក៏ប្រកាច់ស្លាប់ភ្លាមតែម្ដង ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា គាត់បានស្រែកយំខ្លាំងៗដោយសារបាត់បង់កូន ហើយនៅពេលល្ងាចគាត់ និងកូនពីរនាក់ទៀតបានយកកូនតូចនោះទៅកប់នៅក្នុងព្រៃ ដោយមានមនុស្សពីរនាក់បានជួយជីករណ្ដៅ ។ ដើមបណ្ដឹងបានយកមែកឈើទៅដោតទុកជាចំណាំ ។ ចាប់ពីពេលនោះមក សុផានី ក្លាយទៅជាមនុស្សវង្វេង និងត្រូវខ្មែរក្រហមបង្ខំឲ្យទៅដាំពោតតាំងពីព្រលឹមដល់ព្រលប់ ។ កូនទាំងពីរនាក់ត្រូវនៅផ្ទះ ប៉ុន្តែពុំមានអ្នកមើលថែឡើយ ។ សុផានី បានបន្តរៀបរាប់ថា ថ្ងៃមួយពេលត្រឡប់មកពីធ្វើការវិញ គាត់រកកូនមិនឃើញក៏ភ័យស្លន់ស្លោ ប៉ុន្តែក្រោយមកកូនទាំងពីរបានត្រឡប់មកវិញ ដោយប្រាប់ថា ពួកគេយកឈើទៅជីករណ្ដៅមើល ប៉ុន្តែពុំឃើញប្អូននោះទេ ។ ព្រុដូច្នោះ លោកស្រីស្ទើរតែក្លាយទៅជាមនុស្សឆ្កួត ។ មិនយូរប៉ុន្មាន សុផានី បានសម្រេចចិត្តចាកចេញពីទីនោះ ដោយសារគាត់ខ្លាចបាត់បង់កូនទាំងពីរទៀត ព្រោះតែកូនទាំងពីរនាក់តែងតែទៅជីករណ្ដៅរាល់ថ្ងៃ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់បន្តថា គាត់បានព្យាយាមចាកចេញពីទីនោះច្រើនដង ប៉ុន្តែមិនត្រូវបានខ្មែរក្រហមអនុញ្ញាត ។ លើកទីបី សុផានី បានលួចរត់ដោយឆ្លងតាមទូក រួចជិះឡានទៅជាមួយចិនៗ ដែលខ្មែរក្រហមបំរុងនឹងយកទៅឲ្យដាំបន្លែនៅជិតទីក្រុងភ្នំពេញ ។ ប៉ុន្តែ ពេលមកដល់កន្លែងដាំបន្លែ ឡាននោះបានបង្ហួសទៅដល់វត្តទួលស្លែង នៅជិតកំពង់កន្ទួត ដែលជាកន្លែងយោធាកងវរសេនាតូចលេខ៤០៧ ។ នៅទីនោះ ប្រជាជនមានច្រើននាក់ ហើយខ្មែរក្រហមបានបញ្ជូនឲ្យទៅធ្វើការជាទម្ងន់ ដោយកាប់ដើមឈើធំៗ កាប់ព្រៃដើម្បីធ្វើស្រែ ។

ថ្ងៃមួយ ពេលដើមបណ្ដឹងចេញទៅធ្វើការ កូនប្រុសឈ្មោះ ពង្ស ហៅ ប៉ូល បានយំយ៉ាងខ្លាំងព្រោះ ពង្ស ចង់តាមគាត់ទៅ

ធ្វើការ ប៉ុន្តែត្រូវបានខ្មែរក្រហមពីរនាក់ចាប់ ពង្ស និងយកកាំភ្លើងមកភ្ជង់នៅក្នុងមាត់ ។ ប៉ុន្តែ ពង្ស កាន់តែយំខ្លាំងឡើង ហើយពុំមានទឹកភ្នែកទេ ។ ពេលនោះ ខ្មែរក្រហមទាំងនោះបាននិយាយថា "កូនអ្នកឯងមិនមែនជាកូនខ្មែរទេ កូនអ្នកឯងជាកូនអាមេរិកកាំងឬកូនបារាំង វាយំអត់ស្រក់ទឹកភ្នែកទេ" ។ បន្ទាប់មក សុផានី បានសួរខ្មែរក្រហមទាំងនោះថា "តើអ្នកឯងចង់សម្លាប់កូនខ្ញុំឬ?" ប៉ុន្តែយោធានោះឆ្លើយថា "ខ្ញុំមិនសម្លាប់ទេ ។ ខ្ញុំធ្វើឲ្យវាខ្លាច កុំឲ្យយំតាមអ្នកឯងត្រូវទៅធ្វើការ" ។ យោធានោះបានយកកាំភ្លើងមកភ្ជង់ពីក្រោយខ្នងគាត់ថា "ទៅធ្វើការភ្លាម បើមិនទៅ ខ្ញុំនឹងសម្លាប់កូនអ្នកឯង សម្លាប់អ្នកឯង" ។ សុផានី បានប្រាប់យោធានោះថា "កុំសម្លាប់កូនខ្ញុំ ។ បើចង់សម្លាប់កូនខ្ញុំ សម្លាប់ខ្ញុំមក" ។ បន្ទាប់មក យោធាទាំងពីរ បានដោះខោអាវ ពង្ស ហើយយកក្រមាមកចងដៃទម្លាក់ចូលទៅក្នុងត្រលុកទឹក ។ ពេលនោះ កូនស្រីឈ្មោះ ពីន ដែលមានអាយុ៥ឆ្នាំ បានរត់ទៅមើលពង្សដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់ទាំងទឹកភ្នែកថា លោកស្រីដើរបណ្តើរងាកក្រោយបណ្តើរ ខ្លាចក្រែងខ្មែរក្រហមសម្លាប់កូន ។ ភ្លាមៗនោះ កូនទាំងពីរបានរត់សំដៅមករកគាត់ទាំងដៃរបស់ ពង្ស ជាប់ចំណង ។ សុផានី បានរៀបរាប់ថា ចាប់ពីពេលនោះមក ពង្ស បានធ្លាក់ខ្លួនឈឺខ្លាំង ដោយសារយោធាខ្មែរក្រហមធ្វើបាប ។ ដូច្នេះ គាត់បានយកនាឡិកាដៃម៉ាកសេកូ ដែលបានលាក់ទុកជាយូរមកទៅដូរនឹងថ្នាំវីតាមីន(បេអង) ពីប្រជាជនមូលដ្ឋាន ប៉ុន្តែថ្នាំនោះមិនអាចជួយឲ្យកូនគាត់ជាបានទេ ។ ក្រោយមក ខ្មែរក្រហមបានបញ្ជូន សុផានី ឲ្យទៅនៅកន្លែងយោធាមួយទៀត ដែលមានលេខ ៣២០ ។ នៅទីនោះ គាត់ត្រូវធ្វើការរែកដី ជាទម្ងន់ដើម្បីធ្វើទំនប់ ។ នៅទីនោះបានបីខែ ខ្មែរក្រហមបានបញ្ជូនទៅនៅកន្លែងផ្សេងទៀត ដែលគាត់មិនចាំឈ្មោះហើយ ត្រូវធ្វើប្រវត្តិរូប ។ សុផានី បានសរសេរនៅក្នុងប្រវត្តិរូបថា គាត់ជាគ្រូបង្រៀន ប៉ុន្តែខ្មែរក្រហមបានចោទថា គាត់ជាអ្នកផ្សាយទូរទស្សន៍នៅជំនាន់ លន់ នល់ ហើយចាប់ពីពេលនោះមក គាត់ស្ថិតនៅក្រោមការឃ្លាំមើលរបស់ខ្មែរក្រហមរហូត ។ មិនយូរប៉ុន្មាន ដើមបណ្តឹងរដ្ឋប្បវេណី សុផានី ត្រូវផ្លាស់ឲ្យមកនៅភ្នំជីសូរដើម្បីធ្វើការងាររវាយថ្ម ។ នៅទីនោះ កូនប្រុសរបស់គាត់ឈឺកាន់តែធ្ងន់ធ្ងរទៅៗ ហើយខ្មែរក្រហមបានបង្អត់បាយប្រជាជនដែលនៅទីនោះរយៈពេលពីរថ្ងៃ ។ ដូច្នេះ លោកស្រីបានរស់ ដោយសារតែបរិភោគស្លឹកឈើ និងកន្ទុក់តែប៉ុណ្ណោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមថា "នៅពេលយប់នោះ គឺយប់ដែលយើងអត់អ្វីហូបសោះ យើងហូបស្លឹកឈើ ។ ខ្ញុំដេកឱបកូនៗ ឈឺនឹងកូនមួយទៀត ខ្ញុំមិនបានដឹងថា កូនប្រុសរបស់ខ្ញុំស្លាប់ពីពេលថ្មើរម៉ោនសោះ ព្រោះដេកយប់ទៅមិនដឹងថាកូនស្លាប់ថ្មើរម៉ោនផង" ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា គាត់បានយកសពកូនទៅកប់នៅក្បែរភ្នំជីសូរ ដោយយកថ្មមកចារឈ្មោះ "ប៉ូល" នៅចំពីមុខផ្នូរដើម្បីខ្លួនអាចត្រឡប់មករកផ្នូរនេះនៅពេលក្រោយ ។ បន្ទាប់មក កូនស្រីក៏ចាប់ផ្តើមឈឺខ្លាំងឡើងរាគស្គមសល់តែស្បែកនិងឆ្អឹង ។ មួយខែក្រោយពីបាត់បង់កូនប្រុស កូនស្រីក៏បានស្លាប់ ដោយបាននិយាយជាលើកចុងក្រោយថា "សូមម៉ែ យក ពីន ទៅពេទ្យមើល ។ សូមម៉ែយកថ្នាំឲ្យ ពីន ញ៉ាំផង ។ ពីន ចង់រស់នៅជាមួយម៉ែ" ។ បន្តិចក៏និយាយទៀតថា "ម៉ែ ពីន អត់រស់ទេ ពីន ងាប់ហើយ ។ តើពេលណាលោកឪពុកត្រឡប់ពីសហរដ្ឋអាមេរិកវិញ? ម៉េចក៏ទៅអាមេរិកយូរម្ល៉េះ? ម៉ែត្រូវតែរកពុកឲ្យឃើញ" រួចហើយ ពីន ក៏ដកចង្កាមាន់ស្លាប់មួយរំពេច ។

បន្ទាប់មក សុផានី បាននិយាយរៀបរាប់ថា "ដល់កូនស្រីនេះស្លាប់ ខ្ញុំយំបោកខ្លួន ខ្ញុំក្លាយទៅជាមនុស្សឆ្កួត ។ ខ្ញុំពាក់អាវខុសរាល់ថ្ងៃ ខ្ញុំវង្វេងទាំងអស់ ។ នេះជាលើកចុងក្រោយដែលខ្ញុំអស់រលីងអស់កូនរលីងពីខ្លួន ។ ខ្ញុំដូចជាមនុស្សឆ្កួត ខ្ញុំពាក់អាវខុស ខ្ញុំមិននិយាយជាមួយអ្នកណាទាំងអស់ ព្រោះខ្ញុំចង់ស្លាប់ជាមួយកូន ។ កូនខ្ញុំស្លាប់អស់ហើយ ។ ស្លាប់អស់ហើយកូនខ្ញុំ ។ ក្រោយពីនោះមក ជីវិតខ្ញុំក្លាយទៅដូចជាមនុស្សឆ្កួត ឬអ្នកខ្លះហៅខ្ញុំថា ជានាងបងាចារ ។ នេះជាជីវិតទុក្ខសោករបស់កូនខ្ញុំទាំងបីដែលបានបាត់បង់ទៅ ដោយការធ្វើបាប ដោយការសម្លាប់ពីពួកខ្មែរក្រហមពីយោធាខ្មែរក្រហម ។

សូមលោកប្រធានមេត្តាជ្រាប! ហើយសូមអស់លោកក្នុងអង្គប្រជុំនេះ មេត្តាជ្រាបពីជីវិតដ៏សោកសៅរបស់ខ្ញុំនេះជាមួយកូន" ។

បន្ទាប់មក សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបាន

បន្តសំណួរ ដោយលើកយករូបថតមួយសន្លឹកឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ ។ សុផានី បានបញ្ជាក់ថា រូបនោះជារូបថតកូនស្រីពៅរបស់គាត់ដែលត្រូវខ្មែរក្រហមចាក់ថ្នាំនៅលើក្បាល ហើយរូបថតនោះ គាត់បានផ្ញើទៅឲ្យប្តីដែលនៅសហរដ្ឋអាមេរិកមួយអាទិត្យមុនពេលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកថា អ្នកដែលចាក់ថ្នាំឲ្យកូនគាត់នោះ ជាពេទ្យខ្មែរក្រហម ហើយ សុផានី ដឹងច្បាស់ដោយសារតែប្រជាជននៅទីនោះបានប្រាប់ ។ សុផានី បានបន្តថា *«នៅក្រោយរបបខ្មែរក្រហមបានដួលរលំហើយ ខ្ញុំគ្មានសេសសល់អ្វីទេ ។ ខ្ញុំបានទៅរកឪពុកម្តាយខ្ញុំនៅឡឺមខេត្តកំពង់ឆ្នាំង តែគ្មានទាល់តែសោះ ឃើញតែដីទទេ និងដើមត្នោត ដែលម្តាយខ្ញុំបានដាំប៉ុណ្ណោះ ។ អ្នកភូមិបានប្រាប់ថា ខ្មែរក្រហមបានសម្លាប់គ្រួសារខ្ញុំទាំងមូល ហើយសម្លាប់ឪពុកខ្ញុំមុនគេបង្អស់ ។ ខ្ញុំខំរកគ្រួសារខាងប្តីទៀត តែគ្មានសល់អ្វីទាំងអស់ គឺសម្លាប់ទាំងអស់មួយពូជ ទាំងខ្ញុំ ទាំងខាងខ្ញុំ ទាំងខាងប្តីខ្ញុំអស់មួយពូជ ។ ខ្ញុំគ្មានសល់អ្វីឡើយសូម្បីតែក្បួយបង្កើតមួយក៏អត់ដែរសព្វថ្ងៃនេះ ។ ខ្ញុំនៅសល់តែប្តីខ្ញុំម្នាក់ដែលនៅសហរដ្ឋអាមេរិក»* ។

ឆ្លើយតបនឹងសំណួរចុងក្រោយរបស់សហមេធាវីអន្តរជាតិដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ក្រោយពេលរបបខ្មែរក្រហមដួលរលំ សុផានី បានបាត់បង់សាច់ញាតិទាំងអស់ មិនតែប៉ុណ្ណោះក្លាយជាមនុស្សដែលមានវិបត្តិផ្លូវចិត្ត និងមានជំងឺផ្លូវកាយជាពិសេសគាត់បានរងរបួសនៅត្រង់ជើង ដោយសារធ្វើការងារវាយថ្មនៅភ្នំជីសូរ ។ សុផានី មានសុខភាពមិនដូចមុន អស់កម្លាំងវិលមុខ និងយល់សប្តិមមើមមាយជាដើម ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ក្រោយពេលបានទៅជួបប្តីនៅសហរដ្ឋអាមេរិកដើមបណ្តឹងពុំអាចមានកូនទៀតទេ ដោយសារសុខភាពប្រែប្រួល ។ នៅទីនោះ សុផានី ប្រកបការងារជាអ្នកប្រឹក្សាផ្លូវចិត្តដល់ប្រជាជនជួយផ្តល់យោបល់ ជួយសម្រាលទុក្ខជនភៀសខ្លួនខ្មែរ ពិសេសអ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម ហើយទុក្ខសោករបស់ប្រជាជនទាំងនោះជាទុក្ខសោករបស់គាត់ដែរ ។ សុផានី បានបន្តថា ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅយូរឆ្នាំមក ប៉ុន្តែជំងឺផ្លូវចិត្តនៅតែបន្តរាំរៃនៅក្នុងចិត្តប្រជាជនខ្មែរដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមក៏ដូចជារូបគាត់ផ្ទាល់ដែរ ។

## ១) សេចក្តីថ្លែងទុក្ខសោក និងព្យសនកម្ម

បន្ទាប់ពីបញ្ចប់ការសួរ សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី នូស៊ីន សាការ៉ាទី បានស្នើសុំអង្គជំនុំជម្រះឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងការណ៍អំពីទុក្ខសោក និងព្យសនកម្មរយៈពេល៥នាទី ហើយអង្គជំនុំជម្រះក៏បានអនុញ្ញាតតាមសំណើរនេះដូចតទៅ ៖

*«ចាស! សូមជម្រាបលោកប្រធាន និងជម្រាបអង្គប្រជុំ ។ ពេលដែលខ្ញុំជួបជាមួយប្តីខ្ញុំ ហើយនៅឆ្នាំ១៩៨៣ ក្នុងសភាពប្តីខ្ញុំជាជនពិការ ។ ដោយសារការទុក្ខព្រួយទុក្ខសោកពីរបប ប៉ុល ពត នេះហើយ ដែលធ្វើឲ្យខ្ញុំមានវិបត្តិផ្លូវចិត្តមានជំងឺនៅក្នុងខ្លួន ។ ឧទាហរណ៍ ដូចជា ឈឺក្បាល វិលមុខ យល់សប្តិអាក្រក់ មិនដែលយល់សប្តិល្អទេ ។ ជួនកាលខ្ញុំដេកមមើមមាយស្រែកនៅពេលយប់ ។ ខ្ញុំភ័យខ្ញុំមានការតក់ស្លុតដោយសារការ ដែលខ្ញុំទទួលទុក្ខសោកពីរបបខ្មែរក្រហមនេះហើយ រហូតមកដល់សព្វថ្ងៃនេះ ក៏ខ្ញុំនៅតែមានជំងឺមមើមមាយដេកយល់សប្តិអាក្រក់ពីសង្គម ប៉ុល ពត ឃើញតែពួកយោធាខ្មែរក្រហម ប៉ុល ពត ដេញតាមចាប់ដេញតាមសម្លាប់ខ្ញុំគ្មានឈប់ឈរ ។ ជំងឺនេះ គឺអន្ទោលតាមប្រាណខ្ញុំជានិច្ច ញាំញីអារម្មណ៍ខ្ញុំ ព្រោះអ្វី? ព្រោះនៅសហរដ្ឋអាមេរិកដែលខ្ញុំមកដល់ ខ្ញុំឃើញ ក្រឡេកមើលកូនគេដែលបានទទួលការសិក្សាខ្ពង់ខ្ពស់ ។ ខ្ញុំនឹកទៅដល់កូនខ្ញុំ ស្រណោះកូនខ្ញុំដែលគ្មានវាសនានឹងគេត្រូវពួកខ្មែរក្រហម ធ្វើបាបសម្លាប់អស់រលីង ។ រូបភាពកូនខ្ញុំទាំងប៉ុន្មានគឺបានថតជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ ។ ខ្ញុំនៅចាំជានិច្ចមុខមាត់ ពាក្យសម្តីកូនខ្ញុំទាំងប៉ុន្មាន គឺខ្ញុំនៅចាំទាំងអស់ ។*

*ពេលខ្ញុំនឹករឿងហ្នឹងឡើង ខ្ញុំឈឺចាប់ ខ្ញុំណែនទ្រូង ខ្ញុំអួលដើមក ទឹកភ្នែកខ្ញុំនៅតែស្រក់នៅឡើយ ពេលណាដែលខ្ញុំនឹកឃើញរឿងអស់ទាំងនេះ នឹកឃើញរឿងកូនខ្ញុំដែលត្រូវសម្លាប់យ៉ាងវេទនាបំផុតដោយសារស្នាដៃខ្មែរក្រហម ។*

*ខ្ញុំសូមជម្រាបថា ការឈឺចាប់របស់ខ្ញុំនៅចាប់ក្នុងខ្លួនខ្ញុំទឹកភ្នែកខ្ញុំនៅស្រក់ ។ ដូច្នេះ ខ្ញុំដាក់ពាក្យប្តឹងផ្នែករដ្ឋប្បវេណី ដើម្បីចង់បានយុត្តិធម៌មួយដ៏ត្រឹមត្រូវ ដ៏ពិតប្រាកដឲ្យកូនខ្ញុំ ឲ្យឪពុកខ្ញុំ ឲ្យគ្រួសារខ្ញុំ ដែលត្រូវបានខ្មែរក្រហមសម្លាប់អស់ទាំងពូជគ្មាន*

សល់អ្វី គ្មានសេសសល់អ្វីនោះ ។ កាលបើខ្ញុំពុំបានឃើញមិនឃើញនូវពន្លឺយុត្តិធម៌នោះ ខ្ញុំស្លាប់ទៅខ្ញុំបិទភ្នែកមិនជិតទេ ព្រោះខ្ញុំមិនបានបំពេញភារកិច្ចជាមាតាជាកូន ដែលត្រូវរកយុត្តិធម៌ឲ្យឪពុកម្តាយ ឲ្យកូនជាទីស្នេហារបស់ខ្ញុំ ។ ខ្ញុំសូមយុត្តិធម៌មួយដ៏ពិតប្រាកដ ។ ដូច្នេះហើយ ថ្ងៃនេះ ជាថ្ងៃដែលខ្ញុំមានវាសនាខ្ពស់បានជួបលោកប្រធាន ជួបអស់លោកទាំងអស់នៅក្នុងអង្គប្រជុំដើម្បីយុត្តិធម៌ ដែលជាថ្ងៃដែលខ្ញុំទន្ទឹង ជាយូរថ្ងៃឆ្នាំខែណាស់មកហើយ ដែលបានមកឃើញក្នុងថ្ងៃនេះ ។ ថ្ងៃនេះជាថ្ងៃដែលខ្ញុំចង់បាន ។សូមជម្រាបលោកប្រធាន និងអស់លោកទាំងអស់សូមមេត្តាជ្រាប» ។

បន្ទាប់មក អង្គជំនុំជម្រះបានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរមួយចំនួនទៅកាន់ជនជាប់ចោទ ដែលធ្វើឡើងតាមរយៈអង្គជំនុំជម្រះ ។ គួររំឭកថាការដែលដើមបណ្តឹងរដ្ឋប្បវេណីចោទសំណួរទៅកាន់ជនជាប់ចោទ គឺអាចធ្វើបានតែតាមរយៈអង្គជំនុំជម្រះប៉ុណ្ណោះ ដោយយោងទៅលើវិធាន៩០ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ក) ការចោទសំណួរទៅកាន់ជនជាប់ចោទដោយដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី បានចោទសំណួរចំនួនបីទៅកាន់ជនជាប់ចោទដូចតទៅ៖

សំណួរទី១ ខ្ញុំចង់សួរលោកថា លោក ខៀវ សំផន លោក នួន ជា លោកជាមេដឹកនាំប្រទេស ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ របបខ្មែរក្រហម តើលោកមានដឹងទេថាខ្មែរក្រហមសម្លាប់កូនក្មេងសូម្បីតែកូនក្មេងតូចដែលមិនដឹងអ្វីក៏សម្លាប់ដែរ ដូចជាកូនខ្ញុំនេះជាដើម ។

សំណួរទី២ តើលោកមានដឹងដែរឬទេ ថាខ្មែរក្រហម យោធាខ្មែរក្រហមដើរវៃ ដើរធ្វើបាបកូនក្មេង បង្ខំឲ្យកូនក្មេងឆ្លើយឲ្យប្រាប់ពីរឿងឪពុក ពីរឿងម្តាយ តើលោកមានដឹងទេ? ហើយលោកមានបានបង្គាប់ឲ្យខ្មែរក្រហមធ្វើដូច្នេះទេ?

សំណួរទី៣ បើលោកមិនបានដឹង មិនបានឮ មិនបានបង្គាប់ឲ្យយោធាខ្មែរក្រហមធ្វើដូច្នេះទេ តើអ្នកណាធ្វើ? តើអ្នកណាបង្គាប់? តើអ្នកណាឲ្យធ្វើយ៉ាងនេះ? ក្នុងនាមលោកជាអ្នកដឹកនាំប្រទេស ខ្ញុំសូមលោកជម្រាបប្រាប់ខ្ញុំរឿងនេះបានដែរឬទេ?

**ឃ) ការឆ្លើយតបដោយ ខៀវ សំផន និង នួន ជា**

**ខៀវ សំផន**

សូមគោរពលោកប្រធាន ។ សូមគោរពអស់លោក លោកស្រីចៅក្រម ។ សូមគោរពអង្គសវនាការទាំងមូល ។ សូមគោរពបងប្អូនរួមជាតិទាំងអស់ដែលនៅទីនេះ ។

សូមជម្រាបសួរលោកស្រី បេ សុផានី ។ ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកស្រី ។

ទី១ ខ្ញុំសូមជម្រាបលោកស្រីថា ខ្ញុំមិនមែនជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ ។ ពិតមែនតែខ្ញុំមានស្លាកជាប្រមុខរដ្ឋ ។ ស្លាកធំណាស់ ក៏ប៉ុន្តែខ្ញុំគ្មានអំណាចអីទេ ។ ខ្ញុំមិនដឹងទេថា កូនក្មេងត្រូវបានយោធាខ្មែរក្រហមសម្លាប់ ។ ខ្ញុំសូមទោសលោកស្រី ខ្ញុំមិនដឹងទាល់តែសោះ ។ អានេះជាការពិតលោកស្រី ។ ខ្ញុំមិនដឹងមែនទាល់តែសោះតែម្តង ។

សំណួរទី២ តើហេតុអ្វីបានជាគេយកកូនក្មេងទៅវៃដំសួរចម្លើយយ៉ាងនេះ? តើទាហានខ្មែរក្រហមបានទទួលបញ្ជាឲ្យធ្វើយ៉ាងនេះ? ឬយ៉ាងណា? ឬយ៉ាងម៉េច? ចំពោះសំណួរទី២នេះខ្ញុំក៏អត់ដឹងដែរលោកស្រី ។ តាមខ្ញុំដឹង ខ្ញុំដូចជាគ្មានបញ្ជាអីឲ្យទៅធ្វើយ៉ាងនេះទាល់តែសោះ ហើយខ្ញុំផ្ទាល់ ខ្ញុំក៏មិនបានបញ្ជាឲ្យយោធាទៅធ្វើយ៉ាងនេះទាល់តែសោះ ។ ខ្ញុំគ្មានសិទ្ធិអំណាចលើកងទ័ព សូម្បីតែមួយក្រុមតូចក៏គ្មានដែរលោកស្រី ។ ដូច្នេះ ខ្ញុំមិនអាចមានសិទ្ធិអីទៅបញ្ជាយ៉ាងនេះទេ ។ ហើយជាផ្ទាល់ខ្លួន ខ្ញុំមិនមែនមនុស្សសាហាវឃោរឃៅល្ងង់ខ្លៅរបៀបនេះទេ ។ ហ្នឹងខ្ញុំសុំថែមសំណួរទី២តែប៉ុណ្ណឹង ។

សំណួរទី៣ បើខ្ញុំមិនដឹងតើអ្នកណាធ្វើ? តាមដែលខ្ញុំស្តាប់លោកស្រីលោកស្រីថាបានឃើញទៅត្រើយស្លាបើត្រើយស្លាវា មានន័យថា អ្នកដែលទទួលខុសត្រូវតំបន់នោះ គេធ្វើហើយគេអ្នកចាត់ចែងហើយតាមខ្ញុំយល់ ។ ដូច្នេះខ្ញុំប្រឆាំងដាច់ខាតនឹងអំពើឃោរឃៅឆ្គួតលីលាបែបនេះ ។ ប៉ុន្តែ ខ្ញុំសោកស្តាយណាស់ ដែលត្រូវតែជម្រាបលោកស្រីថា ខ្ញុំវាអត់ដឹង ខ្ញុំសូមទោសលោកស្រី ។ សូមជម្រាបតែប៉ុណ្ណឹងបាទ ។ ខ្ញុំអរគុណលោកប្រធាន ។

**នួន ជា**

"សូមគោរពអង្គសវនាការទាំងមូល សូមគោរពលោកប្រធាន ។ ខ្ញុំ នួន ជា សូមគោរពទៀតចំពោះលោកស្រី សុផានី នេះ បើខ្ញុំចាំមិនខុស ។ ខ្ញុំសូមសម្តែងនូវមរណទុក្ខសោកស្តាយចំពោះការបាត់បង់អាយុជីវិតក្រុមគ្រួសាររបស់លោកស្រី ដូចលោកស្រីបានពណ៌នាមកហើយនេះ ។ ខ្ញុំសូមចូលរួមមរណទុក្ខជាមួយលោកស្រីផងដែរ ។ ខ្ញុំមិនបានដឹងទេរឿងនេះ ហើយខ្ញុំសូមបញ្ជាក់ម្តងទៀតថា កម្ពុជាប្រជាធិបតេយ្យមិនមានគោលនយោបាយឯណាទៅសម្លាប់ប្រជាជនឯងនោះទេ ។

ផ្ទុយទៅវិញ មានតែគោលនយោបាយជួយស្រោចស្រង់អប់រំកសាងឲ្យទៅជាពលរដ្ឋល្អទាំងអស់គ្នា ជាអ្នកស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាក្រុមគ្រួសារទាំងអស់គ្នា ។ ដូច្នោះយ៉ាងណាមិញ វាដូចជាកូនចៅរបស់លោកស្រីក៏ដោយ ក៏កម្ពុជាប្រជាធិបតេយ្យ គ្មានគោលនយោបាយណាដើម្បីទៅសម្លាប់កុមារសម្លាប់កូនក្មេងទេ ។ នេះខ្ញុំសូមបញ្ជាក់ម្តងហើយម្តងទៀត ។ ហើយម្តងទៀត ខ្ញុំសូមចូលរួមមរណទុក្ខចំពោះក្រុមគ្រួសាររបស់លោកស្រី ។ សូមអស់ សូមគោរពលោកប្រធាន" ។

### ង) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វាំងសង់ ដឺវ៉ាយដេស្តាឯល បានចាប់ផ្តើមសំណួរថា តើមូលហេតុដែលនាំឲ្យបាត់បង់សមាជិកគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែជាប់សាច់ញាតិ ជាមួយ លន់ នល់ ឬយ៉ាងណា? តើហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីដឹងអំពីព័ត៌មាននេះ? ចំពោះបញ្ហានេះ សុផានី បានពន្យល់ថា គាត់បានទទួលព័ត៌មាននេះតាមរយៈអ្នកស្រុក ដែលមានស្រុកកំណើតជាមួយម្តាយក្មេកប្រាប់ថា ពេលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ឪពុកម្តាយក្មេក និងបងប្អូនថ្លៃរបស់គាត់ទាំងអស់ បានជម្លៀសទៅនៅភូមិរុនខេត្តតាកែវ ដូច្នេះ អ្នកភូមិដែលនៅទីនោះ ស្គាល់ក្រុមគ្រួសារខ្លួនយ៉ាង ច្បាស់ ។ សុផានីបានបន្ថែមថា ដោយសារតែគ្រួសារសាច់ថ្លៃរបស់គាត់សុទ្ធតែជាអ្នកដែលមានឋានៈធំនៅក្នុងរបប លន់ នល់ ដូច្នេះ ហើយគ្រួសាររបស់ខ្លួនផ្ទាល់ដែលនៅក្នុងខេត្តកំពង់ឆ្នាំង ក៏ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដែរ ។ ទោះបីជាយ៉ាងណា សុផានី បានបញ្ជាក់ថា គាត់ពុំប្រាកដថា ទាហាន លន់ នល់ ត្រូវយោធាខ្មែរក្រហមស្វែងរកចាប់ខ្លួននៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ នោះទេ ប៉ុន្តែជាក់ស្តែង អ្នកដែលមានឋានៈធំៗនៅជំនាន់នោះ បានស្លាប់អស់ជាច្រើននាក់ ហើយមួយចំនួនតូចប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតនៅសហរដ្ឋអាមេរិក ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរអំពីមូលហេតុដែលខ្មែរក្រហម ហាមមិនឲ្យប្រជាជនមូលដ្ឋានផ្តល់អាហារទៅកូនរបស់ដើមបណ្តឹងរដ្ឋប្បវេណីបរិភោគ ។ សុផានី បានរៀបរាប់ថា នៅពេលនោះ ខ្មែរក្រហមបានប្រាប់ខ្លួនយ៉ាងច្បាស់ថា គាត់មានឋានៈខុសគ្នាពីប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ ដូច្នេះ មិនអាចទាក់ទងគ្នាបានទេ ។ ជាងនេះទៅទៀត ការរស់នៅរវាងប្រជាជនចាស់ និងប្រជាជនថ្មី មានភាពខុសគ្នាស្រឡះ ។ ប្រជាជនចាស់មានបាយហូបគ្រប់គ្រាន់ ចំណែកប្រជាជនថ្មី ហូបតែបបររាវជាមួយត្រីបន្តិចបន្តួច ឬអំបិលជាពិសេសនៅពេលដែលកូនរបស់គាត់ស្លាប់នោះ មានតែស្លឹកឈើនិងកន្ទុកសម្រាប់បរិភោគប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងការប្រកាន់វណ្ណៈ សុផានី បានរៀបរាប់ថា ខ្មែរក្រហមបានចាត់ទុកប្រជាជន១៧មេសា មានឋានៈផ្សេងដែលត្រូវបានខ្មែរក្រហមតាមដានគ្រប់ជំហាន ។ សុផានី បានរំឭកថា នៅពេលខ្លួនទៅធ្វើការងាររវាយថ្មនៅភ្នំជីសូរ ដើម្បីយកទៅធ្វើថ្នល់នោះ គាត់បានរងរបួសដោយថ្មផ្ទាត់ត្រូវជើង និងក្លាយជាដំបៅធំ ប៉ុន្តែគាត់នៅតែអូសគូទទៅធ្វើការ ព្រោះខ្លាចអង្គការមិនឲ្យបបរហូប ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសំណួរទាក់ទងនឹងស្ត្រីម្នាក់ដែលត្រូវខ្មែរក្រហមវាយសម្លាប់នៅកន្លែងវៃថ្ម ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់យ៉ាងម៉ឺងម៉ាត់ថា ជាធម្មតាពេលដែលឪពុកម្តាយចេញទៅធ្វើការ ខ្មែរក្រហមតែងតែទៅវាយក្មេងៗដែលនៅតាមផ្ទះដើម្បីសួរចម្លើយអំពីប្រវត្តិរូបរបស់ឪពុកម្តាយ ។ ជាក់ស្តែងកូនទាំងពីរនាក់ត្រូវបានខ្មែរក្រហមយករំពាត់មកវាយ និងយកធ្យូងមកគូសនៅលើខ្នងដែលកំពុងតែហើមធ្វើជាល្បែងលេង ដើម្បីឲ្យក្មេងទាំងពីរនោះប្រាប់ពីប្រវត្តិរូប ។ ប៉ុន្តែ សុផានី បានផ្តាំកូនទាំងពីរថា បើខ្មែរក្រហមសួរត្រូវនិយាយថា ឪពុកជាគ្រូបង្រៀនដូចម្តាយដែរ ប៉ុន្តែបានបែកគ្នាមិនដឹងទៅណាទេ ហើយកូនទាំងពីរបាននិយាយដូច្នោះមែន ទើបគាត់បានរស់មកដល់សព្វថ្ងៃ ។ ចំណែកស្ត្រីដែលត្រូវបានខ្មែរក្រហម

វាយនោះ ដោយសារតែកូនរបស់គាត់ភ័យពេកក៏និយាយប្រាប់ខ្មែរក្រហមថា ម្តាយមានល្ពៅមួយនៅឯផ្ទះ ។ ពេលនោះ ខ្មែរក្រហមបួននាក់ បានកាន់ដំបងបួនកំណាត់មកវាយស្ត្រីនោះនៅកន្លែងធ្វើការរហូតទាល់តែប្រេះសាច់ ហើយនារីខ្មែរក្រហមម្នាក់បានធាក់ត្រង់ដើមទ្រូងរបស់ស្ត្រីនោះ ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមបានហៅអ្នកដែលវាយថ្មឲ្យមកជួយវាយខ្ទាំង ប៉ុន្តែគ្មាននរណាម្នាក់ហ៊ានចេញមកវាយទេ ហើយស្ត្រីនោះក៏សន្លប់បាត់ស្មារតីទៅ សំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងព្រឹត្តិការណ៍ដែលកើតឡើងចំពោះប្រជាជន១៧មេសា នៅពេលដែលកងទ័ពវៀតណាមជិតចូលមកដល់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានយកប្រជាជន១៧មេសា ទៅដាក់នៅភូមិមួយទៀតហៅថា "ភូមិអ្នក១៧មេសា" ហើយខ្មែរក្រហមបានឲ្យប្រជាជនទាំងនោះជីករណ្តៅមួយគ្រួសារមួយរណ្តៅដើម្បីដាក់ដី ។ ចំពោះគ្រួសារណាដែលមានសមាជិកច្រើនត្រូវជីករណ្តៅឲ្យធំ ចំណែកគាត់មានតែម្នាក់ខ្មែរក្រហមឲ្យជីករណ្តៅដែលមានបណ្តោយពីរម៉ែត្រ ជម្រៅកន្លះម៉ែត្រ និងទទឹងកន្លះម៉ែត្រ ប៉ុន្តែរណ្តៅនោះជីកពុំទាន់រួចនៅឡើយផងកងទ័ពវៀតណាមក៏បានចូលមករំដោះ ។

### ច) ការសួរដេញដោលដោយមេធាវីការពារក្តី នួន ជា

សហមេធាវីជាតិ សុន អរុណ បានផ្តើមសួរទាក់ទងនឹងការចូលមកដល់នៃយោធាខ្មែរក្រហមនៅទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅមុនថ្ងៃ១៧មេសា គាត់រស់នៅជិតចំការមន ហើយនៅពេលខ្មែរក្រហមចូលមកដល់ ក៏បានបាញ់កាំភ្លើងឡើងលើ និងជម្លៀសប្រជាជនឲ្យចាកចេញពីផ្ទះក្នុងរយៈពេលបីថ្ងៃព្រោះខ្លាចអាមេរិកមកទម្លាក់គ្រាប់បែកនៅក្នុងទីក្រុង ។ នៅពេលខ្មែរក្រហមបានចូលមកដល់ផ្ទះអ្នកជិតខាង ខ្លួនបានប្រញ៉ាប់ប្រញ៉ាល់ចាកចេញ ព្រោះខ្លាចយោធាទាំងនោះចូលមកដល់ផ្ទះឃើញរូបថត និងឯកសណ្ឋានទាហានរបស់ប្តី ។ បន្ទាប់មកមេធាវីជាតិបានបន្តសួរបញ្ជាក់ថាតើនៅក្នុងស្ថានភាពនោះដើមបណ្តឹងរដ្ឋប្បវេណីបានចាកចេញពីផ្ទះដោយស្ម័គ្រចិត្តឬយ៉ាងណា? សុផានី បានបញ្ជាក់ថា ខណៈពេលនោះគាត់ត្រូវតែចាកចេញពីផ្ទះដោយបង្ខំ ពីព្រោះខ្មែរក្រហមបានបណ្តេញប្រជាជនទាំងអស់ឲ្យចេញ ហើយនៅពេលនោះនៅសល់តែផ្ទះមួយទៀតប៉ុណ្ណោះ ខ្មែរក្រហមនឹងមកដល់ផ្ទះគាត់ ។ ទាក់ទងនឹងសំណួរនេះមេធាវីបានសួរម្តងហើយម្តងទៀត ទោះបីជាមានការជំទាស់ពីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ទាប់មក មេធាវីសុន អរុណ បានសួរទាក់ទងនឹងចរិកលក្ខណៈរបស់ខ្មែរក្រហមបណ្តេញប្រជាជនចេញពីទីក្រុង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅពេលនោះខ្មែរក្រហមមានចរិតកាចសាហាវ ស្រែកគំរាមកំហែងប្រជាជន និងមានបាញ់កាំភ្លើងឡើងលើទៀតដើម្បីឲ្យប្រជាជនចាកចេញពីផ្ទះ ។

បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងបុគ្គលដែលដើមបណ្តឹងរដ្ឋប្បវេណីបានយកចិញ្ចៀនប្តូរយកអង្ករ និងថ្នាំមកព្យាបាលកូន ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ប្រជាជនមូលដ្ឋាននៅភូមិត្រើយស្លា ដែលគាត់បានយកចិញ្ចៀនទៅដោះដូរជាមួយនោះ ពិតជាស្គាល់តម្លៃមាសពេជ្រច្បាស់ណាស់ មិនមែនជាអ្នកដែលមិនស្គាល់ទីក្រុងសោះនោះទេ ។ ទាក់ទងនឹងការជីករណ្តៅនៅមុនពេលទាហានវៀតណាមចូលមកដល់ក្នុងឆ្នាំ១៩៧៩វិញ ដើមបណ្តឹងរដ្ឋប្បវេណី សុផានី បានបញ្ជាក់ថា អនុប្រធានភូមិអ្នក១៧មេសា បានបង្ខំឲ្យប្រជាជនជីករណ្តៅម្នាក់មួយគ្រួសារៗចំណែកឯ សុផានី ដែលមានតែម្នាក់ឯង ក៏ត្រូវជីករណ្តៅដែលមានប្រវែងពីរម៉ែត្រ ទទឹងកន្លះម៉ែត្រ និងជម្រៅកន្លះម៉ែត្រ ប៉ុន្តែការងារនោះត្រូវបានបង្អាក់ដោយសារកងទ័ពវៀតណាមចូលមកដល់ ។

បន្ទាប់មក សវនាការស្តាប់សេចក្តីថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី ត្រូវបានបញ្ចប់ដោយសារតែមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន មិនមានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

## ២) ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ណី

បន្ទាប់ពីបញ្ចប់ការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី អង្គជំនុំជម្រះបានបន្តកោះហៅដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតឈ្មោះ សឿន សុវណ្ណី មកសួរដេញដោល ។

### ក) ប្រវត្តិសាវតារ

ជាដំបូង ប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន បានសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតារបស់ដើមដើមបណ្ដឹងរដ្ឋប្បវេណី ។ ដើមបណ្ដឹងរដ្ឋប្បវេណី សុវណ្ណឌី បានបញ្ជាក់ថា គាត់មានអាយុ៥៧ឆ្នាំមានស្រុកកំណើតនៅម្ដុំផ្សារដើមគ ទីក្រុងភ្នំពេញ ។ សព្វថ្ងៃ ដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅក្នុងភូមិបឹងវែង ឃុំរាំងបុស្សី ស្រុកសង្កែ ខេត្តបាត់ដំបង មានរបរជាកសិករ ។ ឪពុកឈ្មោះ ម៉ក់ ចេន ម្ដាយឈ្មោះ គីម លាង ប្រពន្ធឈ្មោះ សុង សុដៃ និងមានកូនម្នាក់ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា មុនពេលយោធាខ្មែរក្រហមចូលមកដល់ ឪពុកម្ដាយរបស់គាត់បានជម្លៀសចេញពីផ្ទះ ។ ចំណែកឯរូបគាត់ និងបងស្រីនៅចាំចេញដំណើរទៅតាមក្រោយ ។ ពេលនោះ ឪពុកម្ដាយបានផ្ដាំថា ឲ្យទៅរកពួកគាត់នៅតាមផ្លូវមាត់ទន្លេ ។ មួយសប្ដាហ៍ក្រោយមក សុវណ្ណឌី និងបងស្រីបានចេញពីទីក្រុងដើម្បីទៅរកគ្រួសារ ប៉ុន្ដែពេលនោះ អ្នកដែលចេញទៅមុនៗប្រាប់ថា ឪពុកម្ដាយរបស់គាត់បានទៅទទួលសម្ដេចឪ ។ ក្រោយមកគាត់បានទៅធ្វើការនៅក្នុងការដ្ឋានដូចប្រជាជនផ្សេងទៀតដែរ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្ដរៀបរាប់ថា គាត់ត្រូវធ្វើការងារទាំងបង្ខំ និងគ្មានអាហារគ្រប់គ្រាន់ ព្រមទាំងទទួលរងនូវការតិះដៀលថា ជាពួកភ្នំពេញ ពួកដេកស៊ី ពួកសក្ដិភូមិ មិនចេះធ្វើការងារជាដើម ។ សុវណ្ណឌី បានបន្ដថា ខ្មែរក្រហមបានហៅខ្មែរកម្ពុជាក្រោមឲ្យទៅធ្វើចម្ការ ប៉ុន្ដែភាពពិតអ្នកទាំងនោះត្រូវបានយកទៅសម្លាប់ដោយចោទថាជាយួន ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្ថែមថា គាត់ក៏ជាខ្មែរកម្ពុជាក្រោមដែរ ប៉ុន្ដែ ដោយសាររស់នៅភ្នំពេញទើបការនិយាយស្ដីខុសគ្នាពីខ្មែរកម្ពុជាក្រោម ។

## ១) ព្រឹត្តិការណ៍ជម្លៀសនៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥

មេធាវីជាតិ សំ សុគង់ បានផ្ដើមសំណួរទាក់ទងនឹងមូលហេតុដែលចាកចេញពីទីក្រុងភ្នំពេញ ក្រោយពេលដែលក្រុមគ្រួសារបានចាកចេញមុនរយៈពេលមួយសប្ដាហ៍ ។ សុវណ្ណឌីបានរៀបរាប់ថា ឪពុករបស់គាត់ជាទាហាន លន់ នល់ និងម្ដាយជាកសិករ ។ នៅថ្ងៃ១៧មេសា ឪពុកម្ដាយ និងសមាជិកគ្រួសារដទៃទៀតបានចាកចេញពីផ្ទះ ដោយទុកតែគាត់ និងបងស្រីឲ្យនៅចាំផ្ទះសិនទើបធ្វើដំណើរទៅរកគ្នា នៅតាមមាត់ទន្លេដោយនឹកស្មានថាចេញទៅតែមួយរយៈប៉ុណ្ណោះ ។ ក្នុងពេលមួយសប្ដាហ៍នេះ គាត់បានឃើញប្រជាជនដឹកអីវ៉ាន់ និងធ្វើដំណើរចាកចេញជាបន្ដបន្ទាប់ ដោយមានការគំរាមពីយោធាខ្មែរក្រហម ដោយការបាញ់កាំភ្លើងឡើងលើ ។ ឃើញស្ថានភាពដូច្នោះ គាត់ និងបងស្រីបានចាកចេញដើម្បីទៅរកឪពុកម្ដាយ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្ដថា នៅពេលធ្វើដំណើរតាមផ្លូវ គាត់បានឃើញសាកសពជាច្រើន ព្រមទាំងមានក្លិនយ៉ាងអសោច ហើយខ្មែរក្រហមបានយកត្រាក់ទ័រមកកៀរសាកសពទាំងនោះទម្លាក់ចូលទៅក្នុងក្រលុក និងចូលក្នុងទន្លេ ។នៅពេលឃើញស្ថានភាពដូច្នោះ គាត់មានការរន្ធត់ និងសោកស្ដាយដោយនឹកស្មានថា អង្គការនឹងនាំទៅរកកន្លែងដែលមានអាហារហូបចុកគ្រប់គ្រាន់ ។ ទាក់ទងនឹងការធ្វើប្រវត្តិរូបវិញ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅពេលទៅដល់ស្រុកស្អាង ខ្មែរក្រហមបានឲ្យប្រជាជនទាំងអស់ធ្វើប្រវត្តិរូប ។ នៅពេលនោះមានស្ដ្រីម្នាក់បានខ្សឹបប្រាប់ថា ប្រសិនបើខ្មែរក្រហមសួរគាត់មិនត្រូវឆ្លើយថាជាអ្នកភ្នំពេញទេ ។ ដូច្នេះ គាត់បានប្រាប់ខ្មែរក្រហមថា គ្រួសារស្លាប់អស់ដោយសារត្រូវគ្រាប់បែកធ្លាក់ចំផ្ទះ ហើយមានតែគាត់ម្នាក់គត់ដែលនៅរស់ ។ សុវណ្ណឌី បានរៀបរាប់ថា នៅទីនោះ ខ្មែរកម្ពុជាក្រោមត្រូវឲ្យធ្វើប្រវត្តិរូប និងបញ្ជូនទៅធ្វើចំការ ។ ប៉ុន្ដែ ភាពពិតអ្នកទាំងនោះត្រូវបានបញ្ជូនយកទៅសម្លាប់ ។ បន្ទាប់មក ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញរូបថតក្រុមគ្រួសារដែលបានថតតាំងពីជំនាន់មុន ដែលនៅក្នុងរូបនោះមាន ឪពុកម្ដាយ មីងពូ និងប្អូនខ្លួនទាំង៤នាក់ ហើយដែលក្រោយមកបានបែកបាក់គ្នា ខ្លះស្លាប់ និងខ្លះបានបាត់ខ្លួន ។

ឆ្លើយតបនឹងសំណួរមួយចំនួនរបស់សហព្រះរាជអាជ្ញារងជាតិ ចាន់ តារាស្មី សុវណ្ណឌី បានរៀបរាប់ថា ពូរបស់គាត់ ឈ្មោះ ទៀង កិប ជាទាហានសក្ដិ៤កន្ទះ នៅក្នុងអង្គភាព៤៧ និងជាកងទ័ពម៉ៃហ្វុក ត្រូវបញ្ជូនទៅកម្ពុជាក្រោមជាមួយអ៊ំរបស់គាត់ម្នាក់ទៀតឈ្មោះ ថាច់ ឡុង ដែលនៅក្នុងអង្គភាពជាមួយគ្នាដឹកនាំដោយ សឹង ង៉ុកថាញ់ ។ ប៉ុន្ដែ អ្នកទាំងពីរត្រូវខ្មែរក្រហមផ្លោងគ្រាប់ស្លាប់នៅកំពង់ចាម ។ ទាក់ទងនឹងការភៀសខ្លួនទៅប្រទេសវៀតណាម ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ដោយសារតែស្ថានភាពរស់នៅកាន់តែលំបាក បន្ទាប់ពីមានការចាប់ខ្លួនកម្មាភិបាលនៅភូមិភាគបូព៌ា ដើមបណ្ដឹងរដ្ឋប្បវេណី និងមិត្តភក្ដិ

បានសម្រេចចិត្តរត់ទៅប្រទេសវៀតណាម នៅក្នុងឆ្នាំ១៩៧៧ ។ នៅពេលនោះ គាត់បានហែលទឹកទន្លេហើយបានជួបនឹងអ្នកនេសាទ ទើបអ្នកនេសាទនោះបានរាយការណ៍បន្តទៅឲ្យវៀតណាម ។ ពេលទៅដល់វៀតណាម គាត់បានរៀបរាប់អំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា ដើម្បីសុំឲ្យវៀតណាមជួយសង្គ្រោះ ។ សុវណ្ណី បានរៀបរាប់ថា គាត់មានការរំភើបក្នុងចិត្តនៅពេលបានឃើញប្រទេសវៀតណាម មានការរីកចម្រើន ផ្ទុយពីប្រទេសកម្ពុជាដែលមានតែការធ្វើការងារ ការកាប់សម្លាប់ជារៀងរាល់ថ្ងៃ ។ បន្ទាប់មក មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន អង់តា ហ៊ុសសេ បានសួរដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនលើកច្រើនសារ ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឲ្យច្បាស់ អំពីកាលបរិច្ឆេទដែលឪពុកម្តាយ និងដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់បានចាកចេញពីទីក្រុងភ្នំពេញ ។

### ក) សេចក្តីថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

*“រឿងការឈឺចាប់ហ្នឹង ឥឡូវនេះខ្ញុំវាដូចថា ពីដើមដូចមានការឈឺចាប់ជាខ្លាំងដល់ពេលមកឥឡូវនេះ ដូចថាវារំសាយបន្តិចម្តងៗដែរ ពីព្រោះនឹកឃើញថា រយៈកាលកន្លងមកដូចជាវាកាលនោះព្រៃផ្សៃ បើសិនជាគាត់ក្តីភ្លាមៗហ្នឹងគឺអាចបាន ។ តែណ្ហើយចុះប៉ុណ្ណឹងក៏បានទៅហើយ បើការឈឺចាប់ខ្ញុំវារំសាយបន្តិចម្តងៗដែរ ។ បើសិនជាកាលណាធ្វើនូវអ្វីមួយដែលមិនគប្បីនោះ គឺវាត្រូវតែបន្តសង្គ្រាមតទៅទៀត វាមិនអាចឈប់ឈរបានទេ ។ ការសងសឹកនោះ ខ្មែរឃើញតែសម្លាប់ខ្មែរមិនដឹងថាមូលហេតុអ្វី? មិនដែលថាជនបរទេសណាមកនេះដង់ដូចថា កាលសម័យយៀកកុងៗមិនឃើញយៀកកុងឯណា? ឃើញតែខ្មែរវ៉ៃ លន់ នល់ វ៉ៃខ្មែរក្រហម គ្មានឃើញយៀកកុងផង ។ ការសំណើហ្នឹងសុំឲ្យដូចអស់លោកដឹងស្រាប់ហើយ ដូចថា សំណើនោះដូចខ្ញុំរសាយការឈឺចាប់ ។ សំណើនោះគឺសុំឲ្យថាឲ្យមកជាសាលារៀនផ្លូវថ្នល់ ហើយនៅតាមវត្តសុំធ្វើចេតិយមួយសម្រាប់តាំង ធ្វើជាកន្លែងគោរពវិញ្ញាណក្ខន្ធរបស់ខ្មែរកម្ពុជាក្រោម ដែលបានចែកឋានទៅនោះដែលអត់ដឹងរឿងអីនោះ ។ សូម្បីតែកូននៅកន្ទេលពនឹងដៃ ក៏យកទៅបោកនឹងគល់ឈើដែរហ្នឹង ហើយគ្នាដឹងអីហើយសាច់ឈាមជ័រថា កម្ពុជាក្រោមហ្នឹងយកទៅបោកនឹងគល់ឈើលេងទៅសម្លាប់ឪពុកម្តាយ ។ អាហ្នឹងហើយសងសឹក បើតាមខ្ញុំយល់ឃើញ” ។*

### ឃ) ការតាំងសំណួរទៅកាន់ជនជាប់ចោទ ដោយដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការធ្វើសេចក្តីថ្លែងទុក្ខសោក ដើមបណ្តឹងបានតាំងសំណួរចំនួនបី ដូចខាងក្រោម៖

*ទី១) តើហេតុអ្វីបានជាគេសម្រិតសម្រាំង និងប្រមូលផ្តុំខ្មែរកម្ពុជាក្រោមយកទៅសម្លាប់ដែលចោទថា ក្បាលយួនខ្លួនខ្មែរ?*

*ទី២) តើលោកមានវិប្បដិសារីឬទេ ក្នុងការបង្កើតគោលនយោបាយដែលធ្វើឲ្យជនរងគ្រោះមានការឈឺចាប់ពីក្នុងរបបនោះដែរឬទេ?*

*ទី៣) ប្រសិនណាជាលោកត្រឡប់ទៅជាមេដឹកនាំរបបនេះវិញ តើលោកមានដឹងអ្វី ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរប្រសើរឡើងវិញដែរឬទេ?*

**កំណត់សម្គាល់** ៖ បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីបានចោទសំណួរទៅកាន់ជនជាប់ចោទមេធាវីការពារក្តី នួន ជា លោក វិចទ័រ កុបប៉េ បានធ្វើការការកត់សម្គាល់ទៅលើសំណួរទី១ ដោយអះអាងថា សំណួរនេះមិនពាក់ព័ន្ធនឹងអង្គហេតុដែលកំពុងតែពិភាក្សានោះទេ ។ ចំណែកមេធាវីការពារក្តី ខៀវ សំផន លោក គង់ សំអុន បានជំទាស់នឹងសំណួរទី៣ ដោយលើកឡើងថា ការសួរនេះជារបៀបសួរបែបឧបមាណវិធី ។ ឆ្លើយតបនឹងការជំទាស់របស់មេធាវីការពារក្តី នួន ជា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ទោះបីជាសំណួរទី១ទាក់ទងនឹងការសម្លាប់ខ្មែរកម្ពុជាក្រោម ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីអាចថ្លែងអំពីទុក្ខសោករបស់ខ្លួនបានទទួលនៅនៅក្នុងរបបខ្មែរក្រហមទាំងមូលបាន ។ ចំណែកសំណួរទី៣វិញ ដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់តែចង់ឲ្យជនជាប់ចោទឆ្លើយបញ្ជាក់ជូនដើមបណ្តឹងរដ្ឋប្បវេណីថា តើនឹងមានការផ្លាស់ប្តូរអ្វីខ្លះតែប៉ុណ្ណោះ ។ ដើម្បីដោះស្រាយនូវបញ្ហាដែលលើកឡើងដោយភាគី អង្គជំនុំជម្រះបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យថ្លែងទុក្ខសោកវេទនានៅគ្រប់អង្គហេតុ ដែលកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ។ ចំណែកសំណួរទី៣ ដែលលើកឡើងនោះមានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល

ទៅនឹងសេចក្ដីទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនេះជាឱកាសដែលដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងបង្ហាញអំពីការពិចារណារបស់ខ្លួនក្នុងការតាំងសំណួរចំពោះជនជាប់ចោទ ។

### ង) ការឆ្លើយតបនឹងសំណួរដោយជនជាប់ចោទ

#### ខៀវ សំផន

“សូមជម្រាបសួរលោក សឿន សុវណ្ឌី ។ ខ្ញុំរីករាយនឹងឆ្លើយនឹងសំណួររបស់លោកទាំងបី ។ សំណួរទី១ ថាតើហេតុអ្វីបានជាខ្មែរក្រហមបែងចែកបងប្អូនកម្ពុជាក្រោម ហើយយកបងប្អូនទៅសម្លាប់ចោល? រឿងនេះបើតាមខ្ញុំដឹងដូចជាមិនអ៊ីចឹងទេ ។ បើតាមខ្ញុំដឹង ជំនាន់នោះ មេៗខ្មែរក្រហមទាំងអស់មានទិសដៅប្រមូលរួមជាមួយបងប្អូនខ្មែរកម្ពុជាក្រោមដើម្បីជាកម្លាំងរួមគ្នាតស៊ូទប់ទល់នឹងអំពើឈ្លានពានរបស់វៀតណាម ។ អត់មានសំណូមពរអីទៅបែងចែកអ៊ីចឹងទេ ។ នេះខ្ញុំសូមជម្រាបលោកប៉ុណ្ណឹង ។

សំណួរទី២ តើខ្ញុំសោកស្ដាយដែលខ្ញុំបានបង្កើតនយោបាយមួយដែលបង្កឲ្យមានជាទុក្ខសោកវេទនាឥតគណនារបស់ប្រជាជនយើងយ៉ាងនេះ? ខ្ញុំសូមជម្រាបលោកថា ខ្ញុំអត់បានបង្កើតនយោបាយយ៉ាងនេះទេ ពីព្រោះមួយជីវិតរបស់ខ្ញុំនេះ ខ្ញុំមិនដែលនឹកឃើញទៅធ្វើបាប ធ្វើទុក្ខសម្លាប់អ្នកណាទេ ពិសេសខ្មែរគ្នាឯង ។ នេះចំពោះសំណួរទី២ ។ សំណួរទី៣ ថាបើអាចត្រឡប់ថយក្រោយវិញ តើខ្ញុំនឹងប្រកាន់អាកប្បកិរិយាយ៉ាងម៉េចវិញ? សំណួរទី៣របស់លោកនេះ ខ្ញុំពិបាកឆ្លើយដែរ ពីព្រោះជីវិតមនុស្ស វាមិនអាចថយក្រោយវិញទេ ។ ចាស់ហើយវាមិនអាចទៅជាក្មេងវិញទេ ។ ក៏ប៉ុន្តែឧបមាថា យើងអាចត្រឡប់ថយក្រោយទៅវិញបាន តើខ្ញុំនឹងធ្វើយ៉ាងម៉េច? ខ្ញុំបើអាចត្រឡប់ថយក្រោយបាន ខ្ញុំនឹងទាមទារឲ្យមានសិទ្ធិដឹងឮនូវព្រឹត្តិការណ៍ជាសោកនាដកម្មផ្សេងៗគ្រប់បែបយ៉ាងទាំងអស់ដែលកើតមាននៅក្នុងពេលនោះ ឲ្យខ្ញុំមានសិទ្ធិដឹងឮផង ហើយខ្ញុំនឹងទាមទារដាច់ខាតឲ្យបក្សកុម្មុយនីស្តកម្ពុជាត្រឡប់មកទិសដៅវិញ ទិសដៅដើមរបស់ខ្លួនវិញនៅពេលដែលខ្លួនបានបដិសន្ធិនោះ គឺទិសដៅអ្វី? ទិសដៅនោះគឺ ប្រទេសបានឯករាជ្យ សន្តិភាពប្រជាជនមានហូបមានចុកគ្រប់គ្រាន់ ហើយសម្បូរសប្បាយ ហើយសល់ផលស្រូវខ្លះឬផលអ្វីៗ ផ្សេងទៀតនាំចេញយកទៅដើម្បីទិញថ្នាំសង្កូវព្យាបាលប្រជាជនយើងពីព្រោះជំនាន់នោះ ប្រជាជនយើងខ្វះថ្នាំសង្កូវច្រើនណាស់ ហើយក្រៅពីថ្នាំសង្កូវ ប៉ុន្តែទិញថ្នាំសង្កូវ និងទិញថ្នាំបម្រើជីវភាពប្រជាជនហ្នឹងជាសំខាន់ បានកំណត់អ៊ីចឹងច្បាស់ថា អាហ្នឹងជាបុព្វសិទ្ធិទី១ហើយ ។

ហើយបន្ទាប់ពីហ្នឹង បើមានលទ្ធភាពនឹងទិញរោងចក្រទិញអីមក ដើម្បីប្រទេសយើងចេះតែមានទៅជាប្រទេសឧស្សាហកម្មបណ្ដើរៗ ។ ខ្ញុំនឹងជម្រាបលោកថា ខ្ញុំនឹង ទាមទារយ៉ាងនេះបើខ្ញុំដឹង ប៉ុន្តែវាទាស់តែខ្ញុំវាអត់ដឹងសោះតែម្ដង នូវអ្វីដែលបានកើតឡើងនោះពេលនោះ ។ ខ្ញុំអត់បានដឹងទាល់តែសោះ ខ្ញុំសូមជម្រាបលោកច្បាស់អ៊ីចឹង ។ សូមលោកអធ្យាស្រ័យដល់ខ្ញុំ ហើយខ្ញុំសូមជម្រាបអស់ប៉ុណ្ណឹងហើយ ។ ខ្ញុំដឹងថា លោកអាចមិនពេញមិនអស់ចិត្តទេ ប៉ុន្តែធ្វើម៉េចខ្ញុំវាអត់ដឹងអ៊ីចឹងមែន ។ ខ្ញុំសូមជម្រាបលោក ។ សូមអគុណលោកប្រធាន ។

#### នួន ជា

“សូមគោរពអង្គជំនុំជម្រះ សូមគោរពលោកប្រធាន ។ ខ្ញុំ នួន ជា សូមជម្រាជូនលោកសុវណ្ឌីដូចតទៅនេះ ៖

ខទី១ កម្ពុជាប្រជាធិបតេយ្យមិនមានគោលនយោបាយអ្វីបែងចែក ឬប្រកាន់ថា អ្នកនេះជាខ្មែរកម្ពុជាក្រោម អ្នកនោះជាខ្មែរកណ្ដាល ខ្មែរលើទេ គឺសាមគ្គីខ្មែរទាំងអស់ទាំងបងប្អូនខ្មែរកម្ពុជាក្រោម ក៏ដូចជាបងប្អូនខ្មែរខាងលើ ដើម្បីពេលនោះតស៊ូការពារប្រទេសជាតិ ។ ដូច្នេះ កម្ពុជាប្រជាធិបតេយ្យទុកទាំងអស់ជាខ្មែរតែមួយ ។ នេះខ្ញុំសូមជម្រាបដោយស្មោះស្ម័គ្រមិនមានអ្វីទៅបែងចែកថា ខ្មែរកម្ពុជាក្រោមយ៉ាងនេះយ៉ាងនោះទេ ។ នេះខ្ញុំសូមជម្រាបហើយជម្រាបទៀត ។

ខទី២ដូចជាខទី១ដែរ គឺខទី២នេះតាមខ្ញុំដឹងគឺវាទាក់ទងនឹងខទី១ ។ ឯខទី៣ ខ្ញុំសូមជម្រាបថាកន្លងមកវាជាង៣៨ឆ្នាំកន្លងមកហើយ ។ ហេតុដូច្នេះតទៅមុខទៀតឧបមាទេគឺ ថាតើកម្ពុជាប្រជាធិបតេយ្យមានគោលនយោបាយយ៉ាងម៉េច? ខ្ញុំឃើញថា ទៅតាមសហករណ៍ទៅតាមប្រទេសនាពេលបច្ចុប្បន្ននេះគឺថា កសាងប្រទេសការពារប្រទេសធ្វើយ៉ាងម៉េចឲ្យប្រទេសចម្រើនទៅមុខ ។ ដូច្នេះយើងមិនអាចទៅយកអារឿងចាស់មកកសាងធ្វើជាថ្មីដែរទេ ។ នេះខ្ញុំសូមជម្រាបដោយខ្លីតែប៉ុណ្ណឹងទេ ។ សូមជម្រាបសូមអរគុណ សូមអរគុណលោកប្រធាន” ។

### ៣) ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា

បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ណី អង្គជំនុំជម្រះបានបន្តកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតដើម្បីសួរដេញដោល និងស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ សូមបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា មានសភាពពិការភ្នែកទាំងសងខាង ដូច្នេះ អង្គជំនុំជម្រះបានចាត់តាំងអ្នកជំនាញមួយរូបមកពីអង្គការធី.ភី.អូ គឺ លោកស្រី ឆាយ ម៉ារីដែត ដើម្បីជួយសម្របសម្រួលបញ្ហាផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ គួរបញ្ជាក់ថា ការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា ពុំបានការសួរដេញដោលពីសំណាក់មេធាវីការពារក្តីទេ ដោយមេធាវីការពារក្តីទាំងពីរក្រុមបានបញ្ជាក់ថា ពុំមានសំណួរទេ ។ ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា មានអាយុ៤៧ឆ្នាំបានកើត និងរស់នៅក្នុងភូមិពោធិ៍ ស្រុកគិរីវង្ស ខេត្តតាកែវ ។ ឪពុកឈ្មោះ ព្រំ ថន ម្តាយឈ្មោះ ម៉ៅ ផាន ប្តីឈ្មោះ ជា គឿន និង មានកូនបួននាក់ ។

សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេម៉ានូអែល ហ្សាកូមី បានសួរសំណួរមួយចំនួនដែលទាក់ទងនឹងបទពិសោធដែលដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ។ សេង ស៊ីវត្ថា បានរៀបរាប់ដំបូងអំពីមូលហេតុដែលនាំឲ្យខ្លួនពិការភ្នែកថា នៅក្នុងរបបខ្មែរក្រហមនៅពេលគាត់មានអាយុ ១១ឆ្នាំ ខ្មែរក្រហមបានចាត់តាំងឲ្យទៅកើបដីអាចម៍ជ្រូកមួយថ្ងៃម្តងបន្តិចពីក្នុងអន្លង់យ៉ាងជ្រៅ ។ ដោយសារតែនៅពេលនោះគ្មានអាហារហូបចុកគ្រប់គ្រាន់ រួមនឹងការធ្វើការងារធ្ងន់ធ្ងរផង វត្ថាមានការនឿយហត់ហើយពេលដែលរែកដីឡើងមកពីក្នុងរណ្តៅគាត់វិលមុខ និងដួលធ្វើឲ្យកំពប់ដី បណ្តាលឲ្យអ្នកដែលរែកមកតាមក្រោយបានដើរជាន់ វត្ថា ធ្វើឲ្យកំពប់ដីទៀត ។ ពេលនោះខ្មែរក្រហមក៏យកដងរែកមកវ៉ៃ ។ ដោយសារគាត់ព្យាយាមរត់ និងស្រែកយំខ្លាំងពេក ខ្មែរក្រហមបានចាប់ខ្លួនយកទៅចងនឹងដើមត្រាចរួចវ៉ៃនឹងខ្សែកោចងបន្ថែមទៀត ។ បន្ទាប់ពីខ្លួនត្រូវស្រាយពីចំណង ខ្មែរក្រហមបានវាយបន្តទៀតរហូតត្រូវចំភ្នែកខាងឆ្វេងទើបឈប់ ។ ចំណែកអ្នកផ្សេងទៀតបានបន្តរែកដីទៅដាក់នៅក្នុងឃ្លាំងអស់ខណៈពេលដែលគាត់នៅយំតែម្នាក់ឯង ហើយក៏រែកដីនោះទៅចាក់នៅក្នុងឃ្លាំងតាមក្រោយ ។ ដោយសាររងរបួសធ្ងន់ គាត់បានទៅរកម្តាយ ប៉ុន្តែពេលទៅដល់នោះពុំមានអ្នកណាម្នាក់នៅផ្ទះទេ ទើបវត្ថាបានទៅរកជីតាដែលកំពុងធ្វើការលើកផ្ទួកចំបើង ។ បន្ទាប់ពីបានសួរនាំដឹងរឿងហេតុមក ជីតា វត្ថាបានយកក្រមាមកជុំដើម្បីស្អំ ហើយគាត់ក៏ត្រឡប់ទៅកងវិញដោយរែកដីទៅមួយអម្រែកផង ។ ចាប់ពីពេលនោះមក វត្ថា ពុំមានអ្នកណាមើលថែ ពុំមានពេទ្យព្យាបាល ។ វត្ថា មានរបួសភ្នែកជាប់រហូតមក ។ ថ្ងៃមួយខ្លួនបានទៅរកម្តាយម្តងទៀត ប៉ុន្តែនៅតែមិនបានជួបរហូតដល់ពេលដួលរលំនៃរបបខ្មែរក្រហម ទើបបានជួបជុំគ្រួសារវិញ ។ នៅពេលនោះ ម្តាយរបស់គាត់បានទៅទិញថ្នាំពីវៀតណាម មកព្យាបាល ប៉ុន្តែស្ថានភាពភ្នែកនោះកាន់តែធ្ងន់ធ្ងរឡើង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅឆ្នាំ១៩៨០គាត់បានចូលរៀននៅក្នុងសាលា ប៉ុន្តែ ភ្នែកខាងឆ្វេងមិនអាចមើលអក្សរច្បាស់ទេ ។ ម្យ៉ាងទៀត ក្មេងៗដែលរៀនជាមួយខ្លួនតែងតែជៀលជេរថា “មីខ្វាក់” ។ នៅឆ្នាំ១៩៨២ គាត់បានរៀបការខណៈពេលដែលភ្នែកខាងឆ្វេងមិនអាចមើលឃើញអ្វីទៀតទេ ហើយភ្នែកខាងស្តាំក៏កាន់តែព្រិលមិនអាចមើលបានច្បាស់ដែរ ។ ក្រោយមក វត្ថា បានទៅព្យាបាលភ្នែកនោះអស់រយៈពេលជាយូរ ប៉ុន្តែនៅតែមិនអាចជាសះស្បើយរហូតដល់ឆ្នាំ២០០៨ ភ្នែកស្តាំរបស់គាត់បានងងឹតសូន្យឈឹងតែម្តង ។ ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ទាំងទឹកភ្នែកថា នៅពេលនោះ គាត់ពិបាកចិត្តជាខ្លាំងដោយសារប្តីសុំបែកគ្នា ព្រោះគាត់បានក្លាយជាមនុស្សពិការភ្នែក ។ ចំណែកកូនទាំងបួននាក់ត្រូវឈប់រៀនដើម្បីជួយរកប្រាក់ផ្គត់ផ្គង់គ្រួសារ ។

### ការរៀបរាប់អំពីព្រឹត្តិការណ៍ជម្លៀសនៅថ្ងៃ១៧មេសា

ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា បានរៀបរាប់ទាក់ទងនឹងការជម្លៀសចេញពីភ្នំពេញថា នៅឆ្នាំ១៩៧៥ គាត់ទើបតែមានអាយុ ៩ឆ្នាំ ហើយដោយសារតែពេលជម្លៀសនោះមានប្រជាជនច្រើនកកកុញ ជីដូនរបស់ វត្ថា បានយកក្រមាមកចងដៃគាត់ និងបងស្រីម្នាក់ទៀតដើម្បីកុំឲ្យវង្វេងគ្នា ។ ស៊ីវត្ថា បានបញ្ជាក់ថា ស្ថានភាពនៅពេលនោះមានការលំបាកជាខ្លាំងដោយសារធ្វើដំណើរទាំងក្តៅ ទាំងឃ្លាន ។ ជាងនេះទៅទៀត ដើមបណ្តឹង

បានដើរដាន់សាកសពដែលស្លាប់នៅតាមផ្លូវ ហើយបានធ្វើដំណើរទៅដល់ភូមិតាម៉េង (១០៩) ស្ថិតក្នុងខេត្តតាកែវ ។ នៅទីនោះ គាត់ត្រូវបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃដូចជាបោចស្មៅចេក ស្មៅពោត ដកសំណាប ។ នៅពេលនោះ វត្ថា មិនដែលស្គាល់ឈ្លើងទេ ប៉ុន្តែមានស្រ្តីម្នាក់បានប្រាប់ថា ឈ្លើងនោះគេយកទៅលីងហូបបាន ។ ដូច្នេះ វត្ថា បានចុះទៅត្រាំទឹកដើម្បីឲ្យឈ្លើងទាម ប៉ុន្តែសំណាងល្អ មានស្រ្តីម្នាក់ទៀតខ្វាចឈ្លើងនោះខ្លាំងណាស់ ទើបខ្ទួនទៅននៀលនឹងស្មៅដើម្បីឲ្យជ្រុះឈ្លើងនោះអស់ ។ ចាប់ពីពេលនោះមក ស៊ីវត្ថា បានគេចមិនទៅធ្វើការងារ និងត្រូវដករបបអាហារ ហើយក៏សម្រេចចិត្តរត់ទៅនៅក្នុងព្រៃប្រហែលប្រាំខែរស់នៅលើដើមឈើ និងហូបស្លឹកឈើ ជួនកាលក៏លួចទៅដកដើមស្រូវមកហូប ឬហូបដីខ្សាច់ជាដើម ។ ពេលត្រឡប់មកដល់ភូមិវិញ វត្ថា ត្រូវបានជម្លៀសទៅនៅតំបន់ ១០៥ ក្នុងភូមិសិរីដំណាក់ ឃុំត្រពាំងធំខាងជើង ហើយនៅទីនោះ គាត់ត្រូវធ្វើការរែកទឹកស្រោចដំណាំមួយថ្ងៃប្រាំរង ។ ថ្ងៃមួយ វត្ថា បានរអិលជើងធ្លាក់ទៅក្នុងទឹកត្រពាំង ប៉ុន្តែពុំមានការស្តីបន្ទោសអ្វីទេ ។ ដោយសារនៅទីនោះហូបចុកមិនគ្រប់គ្រាន់ គាត់បានលួចបេះផ្លែក្រូចមួយហូប ប៉ុន្តែពេលមេកងមកដល់ធុំក្លិនក្រូច មេកងនោះក៏បានសួរថា បានលួចក្រូចមកហូបដែរទេ ប៉ុន្តែគាត់បានប្រកែក ។ បន្ទាប់មក មេកងនោះបានយកក្រមាមកចងវិតករបស់គាត់ ទើបវត្ថាបានសារភាពថាពិតជាបានបេះក្រូចនោះមែន ។ ពេលនោះ មេកងនៅតែរិតក គាត់ទៀតរហូតមានក្មេងៗដែលជាកូនប្រជាជនមូលដ្ឋានបានអង្វរឲ្យមេកងនោះទើបត្រូវបានដោះលែង ហើយទៅរែកទឹកបន្តទៀត ។ ពេលខ្វះជើងរបស់ វត្ថា ហើម ដូច្នេះ គាត់បានយកក្រមាមករុំជើង ដើម្បីធ្វើការងារថែមទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅពេលយប់មានការប្រជុំស៊ុយទិតៀន ប៉ុន្តែគាត់មិនបានយល់ពីអ្វីជាការទិតៀនទេ ដូច្នេះ វត្ថា ធ្លាប់បាននិយាយទិតៀនខុសពីការពិត ហើយត្រូវគេមកវាយថែមទៀត ។

ទាក់ទងនឹងការស្លាប់របស់ប្អូនស្រី ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ប្អូនរបស់គាត់មានជំងឺគ្រុនក្តៅ និងមានពងបែកពេញខ្លួនដូច្នេះម្តាយរបស់វត្ថា បានយកទៅមន្ទីរពេទ្យ ប៉ុន្តែនៅទីនោះមិនមានថ្នាំសម្រាប់ព្យាបាល ហើយអាហារហូបចុកក៏គ្មានទើបប្អូនរបស់ វត្ថា ស្លាប់បាត់ទៅ ។ ឆ្លើយតបបន្ថែមនឹងស្ថានភាពក្នុងពេលជម្លៀស ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា គាត់បានឃើញអ្នកជំងឺមនុស្សចាស់ ក្មេង និងជនពិការ ដែលដេកនៅតាមចិញ្ចើមផ្លូវរួមទាំងមានអ្នកស្លាប់ជាច្រើននាក់ទៀត ។ ស៊ីវត្ថាបានបន្តថា "មានតាចាស់ម្នាក់ ខ្ញុំសង្វេគក្នុងចិត្តដល់សព្វថ្ងៃ ឃើញគាត់ដេក ហើយគាត់បើកភ្នែកសម្លឹងមើលខ្ញុំ ហើយមានបាយមួយចាន ទឹកមួយកំប៉ុងរីហ្គោនៅក្បែរក្បាលដេកគាត់ ហើយមានស្រមោច ចូលខាំត្របៀកគាត់ហ្នឹង ហើយក្នុងចិត្តរបស់ខ្ញុំ ក្នុងអារម្មណ៍របស់ខ្ញុំហ្នឹងដូចថា ឃើញបែបហ្នឹង ខ្ញុំដើរបណ្តើរ ខ្ញុំយំបណ្តើរ ។ ពេលដើរទៅទៀត ក៏ឃើញអ្នកស្លាប់ និយាយទៅឃើញអ្នកស្លាប់បន្តបន្ទាប់តាមផ្លូវតែរហូតអត់មានថាអត់ឃើញទេ ។ ហើយបើមិនអ៊ីចឹងបានថា ឲ្យខ្ញុំដើរទៅដាន់ខ្មោច ពារខ្មោច ជំពប់ខ្មោចដួលហ្នឹងដោយក្តីសង្វេគណាស់ខ្ញុំពេលនោះ ។ នៅពេលទៅដល់ភូមិតាម៉េង ខ្ញុំរស់នៅក្នុងសភាពវេទនាដោយហូបអាហារអត់គ្រប់គ្រាន់ ។ អ្នកមូលដ្ឋានត្រូវហូបរបបផ្សេងតែគេហូបបែបណាខ្ញុំអត់បានដឹងទេ គ្រាន់តែដឹងថា គេហូបមួយជួរផ្សេងទៅមួយផ្នែកផ្សេងអ៊ីចឹងទៅ ។ ពួកអ្នក១៧ មេសា ហូបផ្សេង ។ ការធ្វើការក៏អ៊ីចឹងដែរ អ្នក១៧មេសាត្រូវធ្វើការផ្សេង ។ អ្នកមូលដ្ឋានគេនឹងមើលថែយើង គេហ្នឹងបញ្ជាលើយើង គេអត់បានធ្វើដូចយើងទេ ។ គេដើរបញ្ជាលើយើង ប្រាប់យើងអ៊ីចឹង តែគេក៏ធ្វើការដែរ តែគ្រាន់ថា មិនធ្វើដូចយើងអ៊ីចឹងទេ» ។

បន្ទាប់មក សហព្រះរាជអាជ្ញារង ចាន់ តារាស្មី បានសួរសំណួរមួយចំនួនទាក់ទងនឹងការរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅឯសណ្ឋាគារកាំបូឌីយ៉ាណានៅចន្លោះឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា បានរៀបរាប់ថា កាលនោះ គាត់និងបងប្អូនទាំងអស់បានរស់នៅក្នុងនាមជាជនភៀសខ្លួន ដែលមានអង្គការកាកបាទក្រហម និងអង្គការរបស់សហរដ្ឋអាមេរិជួយចិញ្ចឹមផ្គត់ផ្គង់ទាំងអាហារហូបចុក សម្ភារៈប្រើប្រាស់ និងការសិក្សារៀនសូត្រជាដើម ។ ស៊ីវត្ថា បានបន្ថែមថា ការរស់នៅក្នុងរបបខ្មែរក្រហម និងរបប លន់ នល់ គឺខុសគ្នាស្រឡះ ដោយសារនៅក្នុងរបបខ្មែរក្រហម វត្ថា មិនអាចរៀនសូត្របាន

មិនអាចរស់នៅជាមួយឪពុកម្តាយ និងបងប្អូនឡើយ ។ ចំណែកការហូបចុក ក៏មិនគ្រប់គ្រាន់ ត្រូវហូបបបរលាយជាមួយពោតព្រលិត ត្រកួនជាដើម ។ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីក្រុងវិញ វត្តា គ្រាន់តែដឹងថា ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចាកចេញមួយរយៈ ដើម្បីសម្អាតខ្មាំងសត្តិភូមិ នាយទុន ដោយប្រាប់ឲ្យចាកចេញមួយរយៈតែប៉ុណ្ណោះ ។ យោធាខ្មែរក្រហមបានប្រាប់ឲ្យប្រជាជនដើរទៅមុខរហូត ហើយអ្នកដែលធ្វើដំណើរតាមផ្លូវជាតិលេខ៣ត្រូវយកទៅនៅខេត្តតាកែវ ។ ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្តា បានបន្ថែមថា នៅពេលទៅដល់ខេត្តតាកែវ គាត់បានរស់នៅក្នុងកងកុមារដែលមានការបែងចែកកុមារានិងកុមារីឲ្យរស់នៅ និងធ្វើការផ្សេងគ្នា ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ គាត់បាត់បង់សាច់ញាតិជាច្រើននាក់មិនដឹងថា ស្លាប់ ឬក៏រស់ទេ រហូតមកដល់សព្វថ្ងៃនេះ ។

### ខ) សំណើរសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី

*"ចាស! នៅនាទីចុងក្រោយនេះ ខ្ញុំទន្ទឹងឲ្យតុលាការកាត់ក្តីសាលាក្តីខ្មែរក្រហមនេះ សូមឲ្យបានលឿនជាទីបំផុត ហើយខ្ញុំក៏សប្បាយចិត្តដែរដែលខ្ញុំបានលើកឡើងមកសវនាការនេះ ។ ហើយមួយទៀតខ្ញុំក៏ចង់បញ្ជាក់ថា ពេលដែលខ្ញុំធ្លាក់ខ្លួនពិការភ្នែកមើលអ្វីមិនឃើញ នេះដោយក្នុងរបបបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ។ ខ្ញុំចង់បញ្ជាក់ថា តើបានអ្នកណាជួយចិញ្ចឹមខ្ញុំ បើខ្ញុំរងទុក្ខលំបាកវេទនាដោយក្តីលំបាករកទីបំផុតគ្មានបែបនេះ"* ។

### គ) ការចោទសំណួរទៅកាន់ជនជាប់ចោទដោយដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយភាគី អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីចោទសំណួរទៅកាន់ជនជាប់ចោទដូចតទៅ ៖

*"ខ្ញុំចង់សួរសំណួរពីរ ។ សំណួរទី១) ខ្ញុំចង់សួរថា ហេតុអ្វីបានជាសម័យនោះ របបនោះត្រូវបង្ខំឲ្យក្មេងដែលមិនទាន់គ្រប់អាយុដូចជារូបខ្ញុំត្រូវធ្វើការដូចមនុស្សចាស់? ហើយសំណួរទី២) ខ្ញុំចង់សួរថាហេតុអ្វីដែលភោគផលដែលធ្វើបាននោះ គឺច្រើនណាស់ តើយកទៅណាបានមិនឲ្យពួកយើងខ្ញុំហូប?"*

### ឃ) ការឆ្លើយតបដោយជនជាប់ចោទ ខៀវ សំផន

*"បាទ!សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព សូមគោរពអង្គសវនាការទាំងមូល ។ សូមជម្រាបសួរលោកស្រី សេង ស៊ីវត្តា ។*

*រឿងរ៉ាវដែលលោកស្រីបានរៀបរាប់នេះ ធ្វើឲ្យខ្ញុំតក់ស្លុតចិត្តខ្លាំងណាស់ ។ ខ្ញុំមិនដឹងទាល់តែសោះថា គេប្រើកូនក្មេងឲ្យធ្វើការដូចលោកស្រីមានប្រសាសន៍យ៉ាងនេះ ។ អាយុទើបតែ១១ឆ្នាំ គេឲ្យចុះទៅក្នុងរណ្តៅអាចម៍ជ្រូក រែកហើយដួល គេវ៉ៃទាល់តែលោកស្រីពិការភ្នែក ។ ជើងលោកស្រីហើមដើរជ្រាំងពៀចៗ ស្ទើរតែមិនរួចហើយ គេនៅតែបង្ខំឲ្យលោកស្រីធ្វើការទៀត ។ ខ្ញុំនឹកស្មានមិនដល់ទាល់តែសោះហើយ ។ ដូច្នេះ នេះជាចម្លើយទី១ចំពោះសំណួរទី១របស់លោកស្រី ។*

*លោកស្រីមានប្រសាសន៍ថា លោកស្រីខំធ្វើការបង្កបង្កើនបានផលច្រើន ហេតុម៉េចក៏គេអត់ឲ្យបាយលោកស្រីទៅវិញ? សភាពការណ៍មុនដំបូង វាលំបាកអីចឹងមែន ក៏ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំក៏សភាពការណ៍វាប្រែប្រួលមកល្អគ្រាន់បើដែរ គួរណាស់តែគេឲ្យគេជូនលោកស្រីពិសាដូចប្រជាជនយើងផ្សេងទៀត ដែលខំធ្វើការនោះពិសារឲ្យបានគ្រប់គ្រាន់ ។ អាម៉េចបានជាបង្អត់បាយប្រជាជនអីចឹងទៅវិញ? ស្រូវហ្នឹងគេយកទៅណា? អានេះក៏ខ្ញុំឆ្លើយជូនលោកស្រីមិនរួចដែរ សូមលោកស្រីអធ្យាស្រ័យដល់ខ្ញុំផងចុះ ។ សុំទោសលោកស្រី ។ សូមអរគុណលោកប្រធាន"* ។

### ៣.៤) សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

*"សព្វថ្ងៃខ្ញុំមានជំងឺធ្ងន់នៅក្នុងខ្លួន ។ ទី១ ត្រចៀករបស់ខ្ញុំមានអាការៈស្រៀវមកសសៃភ្នែក មកពីសរសៃក្បាលហ្នឹង ស្រៀវៗជាប្រចាំ ហើយដួនក៏ហឹង ដួនក៏ស្រៀវ ហើយធ្វើឲ្យខ្ញុំពិបាកដកដង្ហើម ។ ពេលដង្ហើមខ្ញុំដកដុតៗ ដកអត់ដល់គ្នាធ្វើឲ្យខ្ញុំរៀងស្ទះៗ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំពិបាកនឹងរស់មែនទែនពេលដែលខ្ញុំបាត់បង់ភ្នែក ។ ពេលដែលខ្ញុំបាត់បង់អ្វីៗគ្រប់យ៉ាង ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំលែងចង់រស់ ខ្ញុំសម្រេចចិត្តទិញថ្នាំកណ្តុរទិញថ្នាំដង្កូវមកសម្លាប់ខ្លួន ។ប៉ុន្តែខ្ញុំបានបងស្រីនិងម្តាយគាត់បានណែនាំថាមិនឲ្យខ្ញុំធ្វើបែបនេះរស់ដើម្បីមើលថែកូន ។ អីចឹងហើយខ្ញុំសម្រេចចិត្តថាត្រាំរស់តទៅទៀតនៅក្នុងសភាពវេទនា ហើយការឈឺចាប់របស់ខ្ញុំនេះ សព្វថ្ងៃខ្ញុំមិនអាចមានសមត្ថភាពទៅពេទ្យ*

ព្យាបាល ឬទៅទិញថ្នាំអ្វីមកព្យាបាលជំងឺខ្ញុំដែរ ។ ត្បិតអីខ្ញុំឈឺនេះ បើតាមពិតទៅមិនដឹងឈឺបែបណា ។

បើយប់ឡើងខ្ញុំដេកតែងតែយល់សប្តិអាក្រក់ៗ ហើយដូចថា បេះតែធ្លាក់ថ្លើម ។ សូម្បីតែសម្លេងបើកទ្វារខ្លាំងក៏ខ្ញុំធ្លាក់ថ្លើមគ្គុក ហើយញ័រសាច់ ជួនកាលមានអារម្មណ៍អត់ល្អធ្វើឲ្យខឹងកូន អាចវ៉ៃកូនបើមិនវ៉ៃដូចថាអារម្មណ៍របស់យើងអត់ស្ងប់» ។ សវនាការស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ បានបញ្ចប់នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ ។



កម្មាភិបាលខ្មែរក្រហមកំពុងផលិតអំបិល នៅការដ្ឋានស្រែអំបិល ខេត្តកំពត ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តីពីសក្ខីកម្មសាក្សីជំនាញ ឈឹម សុធារ៉ា

## ថ្ងៃទី៥ - ៦ ខែមិថុនា ឆ្នាំ២០១៣

នៅរសៀលថ្ងៃទី៥ និងរសៀលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សីជំនាញមួយរូបទៀត ។ ការស្តាប់សក្ខីកម្មរបស់សាក្សីជំនាញ ឈឹម សុធារ៉ា ធ្វើឡើងឆ្លាស់គ្នាជាមួយសាក្សី ស៊ីដនី ស្តេនបឺក ដោយសាក្សី ស្តេនបឺក ធ្វើនៅពេលព្រឹក ហើយសាក្សីជំនាញ ឈឹម សុធារ៉ា ធ្វើនៅពេលរសៀល ។ គួរបញ្ជាក់ថា សាក្សីជំនាញ ឈឹម សុធារ៉ា ធ្លាប់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ ម្តងហើយ ។ នៅក្នុងសវនាការស្តាប់សក្ខីកម្មនេះ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងប្រវត្តិសិក្សាបទពិសោធន៍របស់សាក្សីក្នុងការងារជាវេជ្ជបណ្ឌិតឯកទេសផ្លូវចិត្ត និងការគ្រប់គ្រងអង្គការចិត្តសង្គមអន្តរវប្បធម៌ (ធី.ភី.អូ) ។ ការសួរដេញដោលសាក្សីធ្វើតាមលំដាប់លំដោយ ចាប់ផ្តើមពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ។

### ១) ប្រវត្តិសាវតា

សាក្សីជំនាញ ឈឹម សុធារ៉ា មានអាយុ៤៥ឆ្នាំ សព្វថ្ងៃស្នាក់នៅផ្ទះលេខ៤ ផ្លូវខកញ៉ាវាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ។ មុខរបរបច្ចុប្បន្ន ជាគ្រូពេទ្យឯកទេសខាងជំងឺផ្លូវចិត្ត និងជានាយកអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា ។ សាក្សីបានបញ្ចប់ការសិក្សាផ្នែកវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលភ្នំពេញក្នុងឆ្នាំ១៩៩២ ។ នៅឆ្នាំ១៩៩៤ សាក្សីបានបន្តការសិក្សាឯកទេសខាងជំងឺផ្លូវចិត្ត ដែលជាការសហការរវាងសាកលវិទ្យាល័យអូស្លូរបស់ប្រទេសន័រវេស និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រយៈពេល៤ឆ្នាំ និងបញ្ចប់នៅឆ្នាំ១៩៩៨ ។ បន្ទាប់មក សាក្សីបានបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យញូវសៅវេល ប្រទេសអូស្ត្រាលី និងបញ្ចប់នៅឆ្នាំ២០០០ ។ បច្ចុប្បន្នសាក្សីកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតទស្សនៈវិជ្ជាខាងផ្នែកសុខភាពផ្លូវចិត្តនៅសាកលវិទ្យាល័យម៉ូណាសនៃប្រទេសអូស្ត្រាលី ។ សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា គាត់មានបទពិសោធព្យាបាលសុខភាពផ្លូវចិត្តអស់រយៈពេលប្រហែល១៩ឆ្នាំ និងបានធ្វើការព្យាបាលជនរងគ្រោះនៃរបបខ្មែរក្រហមដោយផ្ទាល់ និងជាពិសេសទាក់ទងនឹងជនរងគ្រោះនៅក្នុងមន្ទីរឃុំឃាំងស-២១ ។ ជនរងគ្រោះទាំងនោះទទួលរងការរំលោភ អំពើទារុណកម្ម និងការប៉ះទង្គិច ផ្លូវចិត្តជាដើម ។ បច្ចុប្បន្ន អង្គការដែលគ្រប់គ្រងដោយសាក្សី កំពុងធ្វើការជាមួយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០១ និង០០២ ។

### ២) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការតាំងសំណួរទៅសាក្សីជំនាញ ឈឹម សុធារ៉ា មុនភាគីផ្សេងទៀត ។ មេធាវី ពេជ អង្គ បានចាប់ផ្តើមសំណួរទាក់ទងនឹងការរំឭកឡើងវិញនូវប្រវត្តិសិក្សា និងបទពិសោធន៍ការងាររបស់សាក្សី ។ ទាក់ទងនឹងការងារព្យាបាលជនរងគ្រោះនៃរបបខ្មែរក្រហម សាក្សីបានបញ្ជាក់ថា ជនរងគ្រោះដែលត្រូវផ្តល់សេវាសុខភាពផ្លូវចិត្តទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង ។ ប្រសិនបើយើងមើលតែសំបកក្រៅដោយពុំបានសួរនាំ ពួកគាត់ហាក់ដូចជាមានលក្ខណៈធម្មតា ។ ប៉ុន្តែ នៅពេលដែលយើងសួរពីប្រវត្តិរបស់គាត់ឲ្យបានជ្រៅ សួរនាំអំពីការរស់នៅក្នុងរបបខ្មែរក្រហម សួរអំពីបងប្អូននៅពេលនោះ យើងចាប់ផ្តើមដឹងថា គាត់ទទួលរងការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង ។ ប៉ុន្តែ ដោយសារជីវភាពរស់នៅប្រចាំថ្ងៃ ជនរងគ្រោះទាំងនោះអាចមានលក្ខណៈមួយមើលទៅឃើញថា ពុំមានការប៉ះពាល់ផ្លូវចិត្តទេ ដោយសារតែអាចបន្តសកម្មភាពបាន ។ សាក្សីបានពន្យល់ពីសញ្ញានៃការប៉ះទង្គិចផ្លូវចិត្តថា ជាទូទៅជនរងគ្រោះមានការយល់សប្តិច្រើន ហើយប្រតិកម្មដែលមាន គឺជាលក្ខណៈជំងឺ ។ អ្នកខ្លះមានជំងឺដែលភាសាអង់គ្លេសហៅថា Post-Truamatic Stress Disorder ឬក៏ (P.T.S.D) ដែលអាចមានជាជំងឺបាក់ស្បាត ជំងឺធ្លាក់ទឹកចិត្ត ជំងឺថប់អារម្មណ៍ ជំងឺសង្ស័យ ជំងឺផាវ៉ាណយ ដែលកើតមកពីការធ្វើទារុណកម្មធ្ងន់ធ្ងរ និងការតាម

ដានទៅលើជនរងគ្រោះជាដើម ។ សាក្សីបានបន្តពន្យល់ពីប្រភេទជំងឺ ភី.ធី.អេស.ឌី ដែលជាវិបត្តិផ្លូវចិត្តក្រោយពីការប៉ះទង្គិច ហើយរោគសញ្ញាទី១ ជនរងគ្រោះតែងតែនឹកឃើញឡើងវិញនូវរឿងរ៉ាវដែលកើតឡើង ។ រោគសញ្ញាទី២ គឺការគេចវេះ ។ អ្នកជំងឺមិនចង់និយាយពីរឿងរ៉ាវដែលកើតឡើងនោះទេ មិនចង់ជួបទីកន្លែងដែលខ្លួនទទួលទារុណកម្ម ឬក៏មិនចង់ពិភាក្សាអំពីស្ថានភាពដែលធ្វើឲ្យគាត់នឹកឃើញឡើងវិញនូវអ្វីដែលធ្លាប់ជួបប្រទះ ។ រោគសញ្ញាទី៣ ជារោគសញ្ញាដែលទាក់ទងនឹងរាងកាយ ដែលទន្ទឹមនឹងការគេចវេះ និងការយល់សប្តិអាក្រក់ អ្នកជំងឺញ័រខ្លួន ថប់ដង្ហើម ត្រជាក់ដៃជើង មានលក្ខណៈភ្ញាក់ដូចជា មានរំញោចធ្វើឲ្យភ្ញាក់នឹកឃើញដល់អ្វីដែលធ្លាប់កើតឡើង ។ អ្នកជំងឺគេងមិនលក់ ឈឺក្បាល ឈឺចុកចាប់ដៃជើង និងតានតឹងនៅក្នុងសាច់ដុំជាដើម ។ សាក្សីបានបញ្ជាក់ថា តាមការយល់ដឹងរបស់គាត់ លក្ខណៈប៉ះទង្គិចរបស់ប្រជាជនខ្មែរមានលក្ខណៈខុសគ្នាខ្លះពីប្រទេសផ្សេងដោយសារបញ្ហាវប្បធម៌ ។ ចំពោះរោគសញ្ញាផារ៉ាណយ ពុំសូវជួបប្រទះទេ សម្រាប់ប្រជាជនកម្ពុជា ហើយសាក្សីបានជួបម្ដងម្កាលចំពោះអ្នកជំងឺដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ ។ ទាក់ទងនឹងផលប៉ះពាល់ស្ដីពីអន្តរហេតុជម្លៀសប្រជាជនដោយបង្ខំ សាក្សីបានបញ្ជាក់ថា ផលប៉ះពាល់កើតឡើងចំពោះមនុស្សចាស់ និងកុមារ ។ ចំពោះមនុស្សចាស់ គឺប្រភេទនៃត្រូម៉ា ដែលជាកាប៉ះទង្គិចធ្វើឲ្យអ្នកជំងឺមិនអាចទប់ទល់ ឬដោះស្រាយបញ្ហាដែលកើតឡើងបាន ។ ចំពោះកុមារ បញ្ហាគឺកាន់តែធ្ងន់ធ្ងរដោយសារបានកាត់ផ្ដាច់ពីចំណងផ្លូវចិត្តមួយហៅថា “Attachment” ដែលកើតមានដូចជានៅកន្លែងរស់នៅ និងជាមួយគ្រួសារជាដើម ។ ការប៉ះទង្គិចនេះធ្វើឲ្យចក្ខុវិស័យរបស់កុមារនៅថ្ងៃអនាគត ពុំមានលក្ខណៈច្បាស់លាស់ ដូចមនុស្សពេញវ័យនោះទេ ។ ការប៉ះទង្គិចនេះធ្វើឲ្យកុមារមានវិបត្តិនៅក្នុងការលូតលាស់ផ្នែកផ្លូវកាយ និងផ្លូវចិត្តដែរ ដែលវានឹងបង្កឲ្យមានផលវិបាកនាពេលអនាគត ជាពិសេសទាក់ទងនឹងការរស់នៅ ការទំនាក់ទំនង និងមានជំងឺអាកប្បកិរិយាហៅថា “Anti-Social” ដែលចូលចិត្តធ្វើបាបគេ ។ កុមារនៅក្នុងរបបខ្មែរក្រហមបានទទួលនូវទារុណកម្មខណៈ ដែលខ្លួនមានការលូតលាស់ ដូច្នេះអ្វីដែលខ្លួនបានជួបពីកុមារនឹងប៉ះពាល់បន្តមកលើកូនៗជំនាន់ក្រោយតាមរយៈការចិញ្ចឹមបីបាច់កូនៗបន្ត ។

មេធាវីអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត បានសួរទាក់ទងនឹងពាក្យថា បាក់ស្បាត ។ សាក្សីពន្យល់ថា ពាក្យនេះជាភាសាអង់គ្លេសមានន័យថា ប្រូកខិន ខៅរេជ (Broken Courage) បានន័យថា បាត់បង់សេចក្ដីក្លាហាន ។ សាក្សីបានពន្យល់ទៀតថា ពាក្យនេះនៅក្នុងវចនានុក្រមសម្ដេច ជួន ណាត មានន័យថា ការបាក់បែករូបរាង ដែលមិនអាចត្រឡប់មកភាពដើមវិញ ។ ប៉ុន្តែផ្នែកចិត្តសាស្ត្រវិញ ពាក្យ“បាក់ស្បាត” មានន័យជ្រៅសម្រាប់រៀបរាប់អំពីទុក្ខលំបាក ទារុណកម្ម ការឈឺចាប់ផ្សេងៗ ដែលប្រជាជនកម្ពុជាបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ជនរងគ្រោះដែលរងការប៉ះទង្គិចផ្លូវចិត្តមានរោគសញ្ញាគេចវេះមិនចង់និយាយ ហើយសាក្សីរកឃើញថា ប្រជាជនកម្ពុជាមានសញ្ញាគេចវេះនេះច្រើនជាងជនជាតិដទៃ ។

## ៣) ការសួរដេញដាលដោយព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដឺវ៉ាល់ ដេស្មាឯល បានសួរផ្ដោតទៅលើជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ទាក់ទងនឹងផលប៉ះពាល់អវិជ្ជមានក្នុងរយៈពេលខ្លី ដូចជាធ្វើឲ្យជនរងគ្រោះ កាន់តែឈឺចាប់ឡើង ហើយអាចនឹងចេញនូវផលវិជ្ជមានប្រសិនបើពួកគាត់និយាយបានច្រើន ។ សាក្សីបានឆ្លើយដោយលើកយកជនរងគ្រោះនៅក្នុងសំណុំរឿង០០១ថា ពួកគាត់បានបង្ហាញនូវបទពិសោធន៍ ល្អៗតាមរយៈឱកាសផ្ដល់សក្ខីកម្ម ។ ប្រាកដណាស់ ដំបូងធ្វើឲ្យគាត់មានអារម្មណ៍នឹកឃើញឡើងវិញ មានការតានតឹងក្នុងចិត្តអារម្មណ៍មិនល្អសព្វបែបយ៉ាង ។ ប៉ុន្តែអារម្មណ៍បែបនេះ អាចរសាយទៅវិញ នៅពេលដែលគាត់ធ្វើសក្ខីកម្ម និងមានអារម្មណ៍ថា អង្គសវនាកាទទួលស្គាល់នូវការឈឺចាប់របស់គាត់ ។ សាក្សីបានបន្តថា ករណីទាំងអស់នេះជួយជនរងគ្រោះច្រើនណាស់ ។ ទាក់ទងនឹងការដែលជនរងគ្រោះយល់ថា ពួកគាត់មានវិប្បដិសារីចំពោះការរស់រានមានជីវិត ប៉ុន្តែមិនអាចការពារសាច់ញាតិឲ្យរស់រានមានជីវិតដែរនោះ សាក្សីបានបំភ្លឺថា ជាទូទៅគាត់បានរកឃើញក្នុងចំណោមអ្នកជំងឺរបស់ខ្លួនដែរ ហើយតាមការសិក្សារបស់មជ្ឈមណ្ឌលព្យាបាលជំងឺទារុណកម្មនៅទីក្រុង

# សវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក

## ថ្ងៃទី៤-៧ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី៤-៧ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក ។ នៅក្នុងការស្តាប់សក្ខីកម្មរបស់សាក្សី ស៊ីដនី ស្កេនប៊ឺក អង្គជំនុំជម្រះបានបើកសវនាការនៅម៉ោង៨ៈ៣០ ព្រឹកដល់ម៉ោង ១១ៈ៣០នាទី ដែលធម្មតាអង្គជំនុំជម្រះតែងតែចាប់ផ្តើមសវនាការនៅម៉ោង៩ៈ០០ ព្រឹក ដល់ម៉ោង ១២ៈ០០ ។ ការផ្លាស់ប្តូរពេលវេលាក្នុងការបើកសវនាការនេះ ដោយសារសាក្សីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក ដែលខុសប្លែកពីពេលវេលានៅប្រទេសកម្ពុជា ។ គួរបញ្ជាក់ថា ការស្តាប់សក្ខីកម្មសាក្សី ស្កេនប៊ឺក បានធ្វើឆ្លាស់គ្នាជាមួយការស្តាប់សក្ខីកម្មសាក្សីជំនាញ ឈឹម សុធារ៉ា ដែលត្រូវស្តាប់នៅពេលរសៀលថ្ងៃទី៥ និងទី៦ ខែមិថុនា ឆ្នាំ២០១៣ ។ នៅក្នុងការផ្តល់សក្ខីកម្ម សាក្សី ស្កេនប៊ឺក បានជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងស្ថានភាពជម្លៀស នៅក្នុងទីក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយផ្តោតលើទីកន្លែងមួយចំនួន ដូចជានៅស្ថានទូតអាមេរិក និងមន្ទីរពេទ្យធំៗ ។ ការសួរដេញដោលសាក្សីចាប់ផ្តើមតាមលំដាប់លំដោយពីសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ។ គួររំឭកថា នៅពេលដែលសាក្សី ស្កេនប៊ឺក កំពុងផ្តល់សក្ខីកម្ម អង្គជំនុំជម្រះបានឆ្លៀតយកឱកាសដើម្បីផ្តល់ឲ្យជនជាប់ចោទ នួន ជា ធ្វើសេចក្តីថ្លែងការណ៍តបចំពោះអង្គហេតុជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

### ១) ប្រវត្តិសាវតារ

សាក្សី ស៊ីដនី ស្កេនប៊ឺក មានអាយុ ៧៩ឆ្នាំ សញ្ជាតិអាមេរិក បច្ចុប្បន្នរស់នៅញូវជល នៅអាប់ស្ទេត ញូវយ៉ក ។ សាក្សី ជាអ្នកនិពន្ធសៀវភៅ ។ ប្រពន្ធរបស់សាក្សីមាន ឈ្មោះ ចេន ហ្វ្រាយមេន និងកូនស្រីពីរនាក់ ។ សាក្សីបានធ្វើសម្បថនៅក្នុងបន្ទប់សវនាការ ។ នាពេលកន្លងមក សាក្សីពុំធ្លាប់ផ្តល់សក្ខីកម្មជាមួយភាគីណាមួយទេ ។

### ២) ការសួរដេញដោលដោយសហព្រះរាជអាជ្ញា

តំណាងព្រះរាជអាជ្ញាជាតិ វេង ហ៊ត់ បានតាំងសំណួរមួយចំនួនដោយផ្តោតលើស្ថានភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងបានលើកយកអត្ថបទដកស្រង់ដើម្បីឲ្យសាក្សីបំភ្លឺបន្ថែម ។ សាក្សីបានរៀបរាប់ពីរូបភាព ដែលបានឃើញថាកន្លែងដំបូង ដែលគាត់បានឃើញ គឺមន្ទីរពេទ្យព្រះកេតុមាលា ។ សាក្សីថា ពុំឃើញមានគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យនោះទេ ឃើញមានតែគិលានុបដ្ឋាយិកា អ្នកជំងឺ អ្នករបួស និងសាច់ញាតិមួយចំនួនបានស្លាប់ ។ សាក្សីបានឃើញឈាមនៅតាមជណ្តើរនៅពេលដែលមនុស្សមួយក្រុមតូចចេញពីមន្ទីរពេទ្យនោះ ហើយខ្មែរក្រហមបានចាប់ខ្លួនសមាជិកក្រុមរបស់សាក្សីទៅជាមួយ ។ បន្ទាប់មក ខ្មែរក្រហមបានដឹកជញ្ជូនក្រុមរបស់សាក្សីទៅមន្ទីរពេទ្យមួយក្បែរទន្លេមេគង្គ ។ សាក្សីបានបញ្ជាក់ថា ក្នុងចំណោមសមាជិកក្រុមរបស់ខ្លួន ពុំមាននរណាម្នាក់ត្រូវសម្លាប់ទេ ។ ប៉ុន្តែ នៅតាមផ្លូវ សាក្សីបានឃើញមនុស្សម្នាដើរចេញពីទីក្រុង ខ្លះត្រូវគេរុញច្រាន ហើយឃើញមានគេរុញមនុស្សសម្រាកនៅលើគ្រែ ខ្លះកំពុងព្យួរសេរ៉ូម ឃើញមានអីវ៉ាន់រប៉ាត់រប៉ាយពេញផ្លូវ និងឃើញគ្រប់រូបភាព ។ សាក្សីបានឃើញមនុស្សរាប់រយនាក់ រួមទាំងស្ត្រី កុមារ និងមនុស្សគ្រប់ប្រភេទ ភាគច្រើនជាជនស៊ីវិល ហើយខ្លះបានព្យាយាមដោះសម្លៀកបំពាក់ទាហានចេញ ព្រមទាំងមានការបាញ់កាំភ្លើង ដែលជាសញ្ញានៃជ័យជម្នះរបស់ទាហានខ្មែរក្រហមទៀតផង ។ អ្នកជំងឺនៅមន្ទីរពេទ្យព្រះកេតុមាលា ត្រូវបញ្ជូនទៅមន្ទីរពេទ្យនៅផ្នែកខាងត្បូងទីក្រុងភ្នំពេញ ដែលជាមន្ទីរពេទ្យឆ្កួត ពុំមានសម្ភារៈ និងលទ្ធភាពព្យាបាលដល់អ្នកជំងឺ និងអ្នករបួសបានទេ ។ ខ្មែរក្រហមពុំអនុញ្ញាតឲ្យមានអ្នកណាស្នាក់នៅក្នុងមន្ទីរពេទ្យនោះទេ ។ ក្រោយមក លោកបានឃើញមនុស្សស្លាប់ លោកគិតថា មនុស្សទាំងនោះស្លាប់ក្នុងពេលធ្វើដំណើរចាកចេញពីភ្នំពេញ ។ សាក្សីពុំបានឃើញអាមេរិកម្នាក់គ្រាប់បែកទេ ដូច្នេះ ព័ត៌មានដែលថាអាមេរិកទម្លាក់គ្រាប់បែក គឺជារឿងមិន

ពិតប្រាកដឡើយ ។ សាក្សីហ៊ានអះអាងបែបនេះដោយហេតុថា រយៈពេលប្រហែល២សប្តាហ៍ ដែលលោកបានស្នាក់នៅក្នុងស្ថានទូតបារាំង គឺពុំមានឃើញមានការទម្លាក់គ្រាប់បែកឡើយ ។ ប្រជាជនទាំងអស់ជិត២លាននាក់ ត្រូវបញ្ជូនចេញពីភ្នំពេញនៅថ្ងៃដំបូង ។

តំណាងសហព្រះរាជអាជ្ញា ថារីក អាប់ឌុលហាក់ បានធ្វើការតាំងសំណួរចំពោះសាក្សីទាក់ទងនឹងព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ដោយសារសាក្សីនៅពេលនោះគឺជាអ្នកការសែត បាញ់សម្រុកចូលមកទីក្រុងភ្នំពេញ គឺសំដៅមកដល់សាលារៀនដែលមានសុទ្ធតែសិស្សនៅសាលាបឋមសិក្សា និងវិទ្យាល័យភ្នំពេញ ... 



ប្រជាជនកម្ពុជាកំពុងឈរស្វាគមន៍កងទ័ពវៀតណាមនៅខេត្តសៀមរាប ក្នុងទសវត្សរ៍១៩៨០ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សាក្សីថា គាត់ពុំមានពត៌មានណាដែលបញ្ជាក់ថា អាមេរិកនឹងទម្លាក់គ្រាប់បែកទៀតទេ ។ អាមេរិកធ្លាប់ទម្លាក់នៅអំឡុងឆ្នាំ១៩៧០ តែក្រោយមកមិនមានព័ត៌មានណាថានឹងទម្លាក់ទៀតទេ ។ សាក្សីបានឃើញខ្មែរក្រហមចង់ឲ្យប្រជាជនចេញពីផ្ទះរហ័ស ហើយបានបាញ់កាំភ្លើងឡើងលើទៀតផង ។ ចំពោះអ្នកជំងឺកំពុងស្នាក់ព្យាបាលនៅក្នុងមន្ទីរពេទ្យវិញ ខ្មែរក្រហមពុំមានចាត់វិធានការណាមួយ ដើម្បីដឹកអ្នកជំងឺទាំងនោះចេញពីមន្ទីរពេទ្យទេ ។ សាក្សីបានឃើញប្រជាជនរាប់ពាន់នាក់ធ្វើដំណើរចេញតាមផ្លូវជាតិលេខ៥ ទៅសៀមរាប ។ ព្រះរាជអាជ្ញា បានដកស្រង់អត្ថបទមួយសរសេរដោយសាក្សីថា «នៅមុនម៉ោង១០ព្រឹក គ្រាប់រ៉ុក្កែត ទៅលើអាកាសនោះទេ ប៉ុន្តែបានភ្ជាប់ជាមួយឈើ ដើម្បីបាញ់ផ្ដេងមកគោលដៅណាមួយ ។ ការបាញ់ធ្វើឡើងដោយអសីលធម៌ ហើយបង្កឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជន ហើយនៅតែបន្តបាញ់ជាប់រហូតដល់ថ្ងៃ ដែលគេជម្លៀសប្រជាជនចេញពីស្ថានទូតអាមេរិក ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញា សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្មែរក្រហមបានចេញសេចក្ដីថ្លែងការណ៍មួយ ហៅមន្ត្រីនៃរបបសាធារណៈរដ្ឋខ្មែរ ដូចជា លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, និង សូស្ថែន ហ្វែណង់ដែស ថា «ជនក្បត់ទាំងប្រាំពីរ» និងត្រូវតែសម្លាប់ចោល ។ ជាការពិត អ្នកទាំងប្រាំពីរ

នាក់នោះ ពុំត្រូវបានសម្លាប់ទាំងអស់ទេ ដោយហេតុថា លន់ នល់ បានចាកចេញពីប្រទេស ជាមួយគ្រួសាររបស់គាត់ ដោយនាំយកប្រាក់រាប់លានដុល្លាទៅជាមួយ ។ សាក្សីបានបន្ថែមថា ការនាំយកប្រាក់នេះ បានរកឃើញនៅប៉ុន្មានឆ្នាំចុងក្រោយ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងការជួយជ្រោមជ្រែងរបស់ ឌិត ប្រន ចំពោះក្រុមរបស់គាត់ក្នុងការប្រឈមមុខជាមួយខ្មែរក្រហមថា ឌិត ប្រន បានទៅក្រសួងព័ត៌មានជាមួយកម្មាភិបាលខ្មែរក្រហម និងបានជួយការពារជីវិតរបស់សាក្សី និងក្រុមការងារ ។ សាក្សីបានបន្តជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងព្រឹត្តិការណ៍ទូទៅនៅក្នុងស្ថានទូតបារាំង ក្នុងហេតុការជម្លៀសប្រជាជនចេញពីទីក្រុងដូចអ្វី ដែលបានសរសេរនៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ ។ “ខ្មែរក្រហមបីនាក់ស្លៀកសម្លៀកបំពាក់ខ្មៅជាមួយនឹងកាំភ្លើងខ្លី និងសៀវភៅបានចូលមកក្នុងស្ថានទូត ។ មន្ត្រីកុងស៊ុល ឌីរ៉ាក់ សួរពួកគេ ហើយគាត់បានដើរជាមួយខ្មែរក្រហមដោយទឹកមុខស្ងៀមស្ងាត់ ។ នៅពេលនោះ ខ្មែរក្រហមបានសួរ និងធ្វើកំណត់ហេតុរួចក៏បានពិភាក្សាគ្នា ។ បន្ទាប់មកពលរដ្ឋកម្ពុជា មួយចំនួនបានចេញមកពីកន្លែងរោងជាងមួយ នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ហើយសូមឲ្យពួកគេបានស្នាក់នៅក្នុងស្ថានទូត ។ ពួកគេបានព្យាយាមអំពាវនាវ ក៏ប៉ុន្តែជនកុម្មុយនីស្តមិនខ្វល់ទេ ហើយបានរុញច្រានអ្នកទាំងនោះ ចេញពីស្ថានទូត” ។ ចំណែកស្ថានភាពទីក្រុងភ្នំពេញនៅពេលសាក្សី ស្កេនបឺក ធ្វើដំណើរទៅកាន់ព្រំដែនថៃ ដោយធ្វើដំណើរកាត់តាមផ្លូវមុនីវង្ស សាក្សីបានប្រទះឃើញស្ថានភាពគួរឲ្យខ្លាច ។ ភ្លើងតាមផ្លូវបើក និងមានពន្លឺស្មុង់ៗ មានក្រដាសរប៉ាត់រប៉ាយ និងឡានដែលគេបោះបង់ចោល និងមានសត្វដើរកាត់ពាសពេញតាមផ្លូវ ។ សាក្សីពុំឃើញមានប្រជាជនស៊ីវិលទេ មានតែខ្មែរក្រហមប៉ុណ្ណោះ ។ អ្នកខ្លះដើរតាមចិញ្ចើមផ្លូវ អ្នកខ្លះនៅក្នុងហាង ហើយពេលខ្លះឃើញមានសកម្មភាព ឆក់ ប្លន់ នៅក្នុងហាងទៀតផង ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានធ្វើការតាំងសំណួរតិចតួចទៅកាន់សាក្សី ស៊ីដនី ស្កេនបឺក ទាក់ទងនឹងការចូលរួមរបស់ទាហានអាមេរិក ជាមួយទាហាន លន់ នល់ នៅក្នុងការប្រឆាំងនឹងខ្មែរក្រហម ។ សាក្សីបានបញ្ជាក់ថា ក្រោយពីការបញ្ចប់ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៣ សហរដ្ឋអាមេរិក បានផ្តល់យោបល់ដល់រដ្ឋាភិបាល លន់ នល់ ឲ្យបន្តប្រឆាំងខ្មែរក្រហមទៀត ប៉ុន្តែពុំបានចូលរួមដោយផ្ទាល់ទេ ។ មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គ្រីស៊ីន ម៉ាទីញូ បានបន្តសំណួរស្តីពីរយៈពេលដែលសាក្សីស្នាក់នៅប្រទេសកម្ពុជា និងការទទួលបានព័ត៌មានទាក់ទងនឹងស្ថានភាពរបស់ប្រទេសកម្ពុជា នៅក្នុងចន្លោះឆ្នាំ១៩៧០ ដល់១៩៧៥ ដើម្បីផ្តល់ជូនការសែតញូវយ៉កថាមស៍ ។ សាក្សីថា គាត់ទទួលបានព័ត៌មានពីកន្លែងជាច្រើន ដូចជា ស្ថានទូតអាមេរិក ដែលពេលខ្លះបានឆ្លើយតបសំណួរអំពីការរុលចូលរបស់ខ្មែរក្រហម ឧត្តមសេនីយ៍កម្ពុជា ពេលខ្លះបានផ្តល់បទសម្ភាសន៍អំពីការបរាជ័យធ្ងន់ធ្ងរជាដើម ដែលបង្ហាញថារដ្ឋាភិបាល លន់ នល់ នៅពេលនោះចាប់ផ្តើមរួញតូចទៅៗ ទំនងជាទទួលបរាជ័យនៅក្នុងពេលណាមួយ ។ មនុស្សចាប់ផ្តើមចូលមកទីក្រុងភ្នំពេញ ហើយខ្មែរក្រហមបានកៀរប្រជាជនធ្វើទាហាន ។ សាក្សីទទួលបានព័ត៌មានទាំងនេះដោយសារគាត់មានពេលវេលាគ្រប់គ្រាន់ និងអាចធ្វើដំណើរទៅច្រើនកន្លែង ។ បើទោះបីជាមិនបានគ្រប់កន្លែង ប៉ុន្តែសាក្សីអាចសួរប្រជាជន និងដឹងពីការវាយលុករបស់ខ្មែរក្រហម ។ សាក្សីបានដឹងថា ខ្មែរក្រហមកំពុងសំរុកចូលមក ហើយបានបន្តការបំផ្លិចបំផ្លាញទៅលើអគាររដ្ឋាភិបាល រោងចក្រ ឬតំបន់ទេសចរណ៍ ព្រមទាំងដឹងពីលទ្ធភាពដែលខ្មែរក្រហមកំពុងកាន់កាប់ទីតាំងណាមួយតាមរយៈការផ្តល់ព័ត៌មានរបស់ប្រជាជន ។

### ៤) ការតាំងសំណួរដោយមេធាវីការពារក្តី

#### ក) មេធាវីការពារក្តី នួន ជា

បន្ទាប់ពី នួន ជា បានបញ្ចប់សេចក្តីថ្លែងការណ៍ អង្គជំនុំជម្រះបានប្រគល់វេទិកា ជូនមេធាវីការពារក្តី ដើម្បីមានឱកាសសួរដេញដោលសាក្សី ស៊ីដនី ស្កេនបឺក ។ មេធាវី វិចទ័រ កុបប៉េ មានបំណងតាំងសំណួរទៅសាក្សីទាក់ទងនឹងប្រធានបទមួយចំនួនដូចជាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងការខ្វះស្បៀងអាហារ ស្ថានភាពជនភៀសខ្លួននៅតាមជំរំ និងការគំរាមកំហែងរបស់ប្រទេសវៀតណាម ។ ទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់

សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ភូមិករណ៍នៅតាមផ្លូវត្រូវបំផ្លិចបំផ្លាញ ប៉ុន្តែសាក្សីពុំមានមធ្យោបាយ ដើម្បីចូលទៅតាមតំបន់ ដែលកាន់កាប់ដោយខ្មែរក្រហមទេ ។ ដូច្នេះ សាក្សីពុំអាចដឹងថាមានផលប៉ះពាល់សេដ្ឋកិច្ច និងបណ្ដាលឲ្យមនុស្សស្លាប់ប៉ុន្មាននាក់នោះឡើយ ។ សាក្សីក៏ពុំមានព័ត៌មានណាមួយបញ្ជាក់ថា ការទម្លាក់គ្រាប់បែកនេះបានជំរុញឲ្យបុរសក្មេងៗ ចូលរួមវាយប្រយុទ្ធជាមួយខ្មែរក្រហម ឬយ៉ាងណានោះទេ ។ សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះទាក់ទងនឹងការខ្វះខាតចំណីអាហារ និងអាហារូបត្ថម្ភនានា ដោយសារបញ្ហាសំខាន់ គឺពុំមានការផ្គត់ផ្គង់មកទីក្រុងភ្នំពេញ ។ ពួកខ្មែរក្រហមទទួលជោគជ័យក្នុងការរារាំងមិនឲ្យមានការផ្គត់ផ្គង់ស្បៀងចូលក្នុងទីក្រុងទាំងផ្នែកផ្លូវគោក និងផ្លូវទឹក ។

## ១) មេធាវីការពារក្ដី ខៀវ សំផន

មេធាវី គង់ សំអុន បានសួរសាក្សីទាក់ទងនឹងទីតាំងសមរភូមិដែលសាក្សីបានចូលទៅយកព័ត៌មាននៅពេលដែលខ្មែរក្រហមកំពុងវាយលុក ។ សាក្សីពុំបានចាំពីឈ្មោះទីតាំងណាមួយជាក់លាក់នោះទេ ដោយសារនៅក្នុងសៀវភៅកំណត់ត្រារបស់លោកពុំបានចុះពីឈ្មោះទីតាំងទាំងនោះឡើយ ។ នៅក្នុងអំឡុងឆ្នាំ១៩៧០ ដល់១៩៧៥ សាក្សីធ្លាប់រាយការណ៍សារព័ត៌មានជូនការសែតញូវយ៉កថាមស៍ ទាក់ទងនឹងទំនាក់ទំនងរវាងស្ថានទូតអាមេរិកជាមួយសាធារណៈរដ្ឋខ្មែរ និងការទម្លាក់គ្រាប់បែករបស់អាមេរិកជាដើម ។ សាក្សីបានផ្ដល់យោបល់ជូនមេធាវី ដើម្បីជ្រាបពីព័ត៌មានលម្អិតអាចដែលស្វែងរកនៅក្នុងគេហទំព័ររបស់កាសែតនោះវិញ ។ សាក្សីបានបញ្ជាក់ថា ទំនាក់ទំនងនេះគឺប្រាកដជាមានការរួមបញ្ចូលទាំងផ្នែកផ្គត់ផ្គង់ជំនួយសព្វាវុធ និងសម្ភារៈផ្សេងៗជូនរដ្ឋាភិបាលកម្ពុជានាពេលនោះ ។

មេធាវីអន្តរជាតិ អង់តា ហ៊្គីសសេ បានធ្វើការតាំងសំណួរទាក់ទងនឹងបទពិសោធរបស់សាក្សី ក្នុងនាមជាអ្នកកាសែតនៅក្នុងប្រទេសមានសង្គ្រាម ។ សាក្សីបានជម្រាបថា គាត់មិនត្រឹមតែធ្វើជាអ្នកយកព័ត៌មាននៅក្នុងប្រទេសមានសង្គ្រាមដូចជានៅកម្ពុជា និងប្រទេសវៀតណាមទេ សាក្សីបានធ្វើជាអ្នកយកព័ត៌មាននៅប្រទេសឥណ្ឌា និងប៉ាគីស្ថាន នៅអំឡុងឆ្នាំ១៩៧១ ដែលពេលនោះគឺមានការទម្លាក់គ្រាប់បែកនៅបង់ក្លាដែស ។ មានអត្ថបទជាច្រើនដែលសាក្សីបានសរសេរនៅក្នុងកាសែតញូវយ៉កថាមស៍ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះទៀតថា នៅក្នុងអំឡុងពេលប្រទេសកម្ពុជា កំពុងមានសង្គ្រាមនោះ ពុំមែនមានតែបណ្ដាញសារព័ត៌មានពីសហរដ្ឋអាមេរិកមួយនោះទេ ដែល


ខៀវ សំផន នៅក្នុងបន្ទប់សវនាការ

រង់ចាំតាមដានពីស្ថានភាពសង្គ្រាម និងសុក្រិតភាពរបស់សារព័ត៌មាន ប៉ុន្តែមានអ្នកសារព័ត៌មានរបស់ស្ថានទូតអូស្ត្រាលី និងជប៉ុនជាដើម ដែលរង់ចាំឃ្លាំមើលសង្គ្រាម ។ មេធាវីបានដកស្រង់នូវអត្ថបទនៅក្នុងសៀវភៅរបស់សាក្សីដើម្បីសួរដេញដោល ។ នៅត្រង់ចំណុចមួយ មេធាវីបានលើកឡើងពីឈ្មោះអ្នកកាសែត ហង់រី បេកយ័រ ដែលសាក្សីបានជួបនៅក្នុងស្ថានទូត ហើយសាក្សីបានសរសេរថា «បេកយ័រ មានរឿងដែលគួរឲ្យចាប់អារម្មណ៍ទៅប្រាប់គាត់ ដោយនិយាយថា ខៀវ សំផន មេដឹកខ្មែរក្រហមកំពូលមិនទាន់មកដល់ភ្នំពេញនៅឡើយទេ» ។ សាក្សីបានបញ្ជាក់ថា ក្រុមរបស់ខ្លួនបាននិយាយជាមួយអ្នកកាសែតរូបនោះ ក្នុងនាមជាអ្នកកាសែតដូចគ្នា ។ លោក ស្អេនប៊ឺក បានបន្តថា បេកយ័រ នៅខាងក្រៅស្ថានទូត ប្រហែលជាអាចឃើញ និងដឹងរឿងណាមួយដែលក្រុមរបស់សាក្សីពុំបានដឹង ដូច្នេះហើយនៅពេលនោះមានការជជែកគ្នា ជាច្រើនដែរ ។

# សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា ឆ្លើយតបនឹងអង្គហេតុជម្លៀស

គួរបញ្ជាក់ថា បន្ទាប់ពីសហព្រះរាអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ចប់ការតាំងសំណួរចំពោះសាក្សី ស្តេនបឺក អង្គជំនុំជម្រះសាលាដំបូងបានប្រគល់វេទិកាឲ្យជនជាប់ចោទ នួន ជា បានដើម្បីមានឱកាសធ្វើអត្ថាធិប្បាយពាក់ព័ន្ធនឹងអង្គហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កាលពីអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងចេញពីទីប្រជុំជនមួយចំនួនទៀត ។ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា មានដូចតទៅ ៖

"សូមអរគុណលោកប្រធាន ។ សូមគោរពអង្គប្រជុំ សូមគោរពបងប្អូនរួមជាតិទាំងអស់ ជាពិសេសសូមគោរពលោកប្រធាន ។

ខ្ញុំមានសេចក្តីរីករាយដែលមានឱកាស បំភ្លឺដល់តុលាការដល់ជនរួមជាតិរបស់ខ្ញុំទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។ អំពីហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្រោយពីបានរំដោះថ្ងៃទី១៧ មេសា ១៩៧៥ តាមខ្ញុំចាំ មតិរបស់គណៈអចិន្ត្រៃយ៍នៃកម្ពុជាប្រជាធិបតេយ្យ ឬនិយាយឲ្យច្បាស់របស់បក្សកុម្មុយនីស្តកម្ពុជា សម្រេចដូចតទៅនេះ ៖ ពេលណារំដោះទីក្រុងភ្នំពេញតើយើងត្រូវជម្លៀសប្រជាជនចេញពីទីក្រុងឬទេ?

ពីព្រោះ ខទី១ បើកងទ័ពយើងចូលទៅក្នុងទីក្រុង កាន់កាប់ទីក្រុងភ្នំពេញ តើអាមេរិកទម្លាក់គ្រាប់បែកឬទេ? បញ្ហានេះយើងមិនអាចប៉ាន់ស្មានបានទេ ពីព្រោះអាមេរិកធ្លាប់ទម្លាក់គ្រាប់បែកនៅតាមជនបទមកហើយចំនួន២០០-៣០០ថ្ងៃ ៣០០យប់ ដើម្បីកម្ទេចកម្លាំងតស៊ូស្នេហាជាតិ និងកម្ទេចសេដ្ឋកិច្ចរបស់យើង ។

ខទី២ មូលហេតុទី២ ហេតុទី២ បើប្រសិនជាអាមេរិកទម្លាក់គ្រាប់បែកអ៊ីចឹងមែន តើវៀតណាមឈរឱបដៃមើលទេ? គណៈអចិន្ត្រៃយ៍ មានមតិថា វៀតណាមចាំតែឱកាស ដើម្បីគេចូល គេធ្វើជាចូលទៅជួយកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះក្នុងឱកាសនោះ វៀតណាម ក៏បញ្ជូនកងទ័ព ដោយយកលេសថា ទៅជួយកម្ពុជា ក៏ប៉ុន្តែទៅគ្រប់គ្រងកម្ពុជា ។

ដោយហេតុផលទាំងនេះហើយ មានពីរហេតុផល បើយើងជម្លៀសវាមានការស្រួល ការលំបាកយ៉ាងម៉េច? បញ្ហានេះគណៈអចិន្ត្រៃយ៍បានអញ្ជើញគណៈភូមិភាគមកជម្រាប តើ ភូមិបើមានមុខជាមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញហើយ ពេលណាដែលយើងបានរំដោះ? តើភាគណាអាចយកប្រជាជនបានប៉ុន្មាន? តាមខ្ញុំចាំគឺថាភូមិភាគដែលមានភោគផលស្រូវអង្ករ ធ្វើស្រែចម្ការបានច្រើន គឺភូមិភាគពាយ័ព្យ ។ ដូច្នេះបានពិភាក្សាជាមួយគណៈភូមិភាគពាយ័ព្យ ។ គណៈភូមិភាគពាយ័ព្យបានសម្រេចចិត្តថា យក១លាន៥សែននាក់ ។ ឯសល់ពីនេះ ប្រជាជនភ្នំពេញដែលពេលនោះមានចំនួន២លាននាក់ ត្រូវបែកទៅតាមភាគផ្សេងៗ ។ និរតីយកប៉ុន្មាន? បូព៌ាយកប៉ុន្មាន? តែបញ្ហានេះក៏បានបែកគ្នាដាច់ស្រេច ហើយបានបញ្ជាក់ទៀតថាប្រជាជនយើងនៅក្នុងមូលដ្ឋានចាស់ត្រូវមានអាកប្បកិរិយាឲ្យត្រឹមត្រូវចំពោះប្រជាជនដែលជម្លៀសទៅនៅថ្មី ជាពិសេសខាងស្មារតីសាមគ្គីរាប់អានគ្នាជាបងប្អូន ជាជាតិមួយ ជាតិខ្មែរ កម្ពុជាជាតិខ្មែរដូចគ្នា ។ ដូច្នេះ មិនត្រូវរើសអើងថា អ្នកនេះមកក្រោយអ្នកនោះជាអ្នកមូលដ្ឋានអីទេ ។ បញ្ហានេះ គណៈភូមិភាគ បានប្រជុំហើយធ្វើការងារសតិអារម្មណ៍ ជាមួយសហករណ៍ជាមួយអីទាំងអស់សព្វគ្រប់ ។

ដូច្នេះ មិនមែនកម្ពុជាប្រជាធិបតេយ្យលេងៗ សម្រេចការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ នេះដោយអារម្មណ៍មិនទទួលខុសត្រូវនេះ ដោយអារម្មណ៍មិនទទួលខុសត្រូវនោះទេ គឺទទួលខុសត្រូវពេញទី ។ ហេតុដូច្នេះហើយបានជាប្រជុំឡើងប្រជុំចុះ សម្រេចឡើង សម្រេចចុះ ។ នេះខ្ញុំសូមជម្រាប ។

ប៉ុន្តែ យើងឃើញច្បាស់ហើយថា ពេលណាដែលរំដោះហើយ ច្បាស់ហើយគឺថា រំដោះត្រូវតែជម្លៀស បើមិនជម្លៀសទេ បង្ការក្រែងលោអាមេរិកមកទម្លាក់គ្រាប់បែក ព្រោះអាមេរិក

ធ្លាប់ទម្លាក់គ្រាប់បែកមកហើយ ២-៣០០លានតោន ២០០ថ្ងៃ ៣០០ថ្ងៃ ៣០០យប់ រណ្តៅប៉ុនស្រះ ។ ហើយពេលនោះ ប្រយ័ត្នមិត្តដែលទំនាស់ ។ អ្នកណាមិត្តដែលមានទំនាស់? គឺវៀតណាម ។ នេះតាមមតិរបស់លេខាបក្ស គឺ ប៉ុល ពត គាត់បានសម្រេចថា វៀតណាមគឺជាមិត្ត ប៉ុន្តែមានទំនាស់ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង តើវៀតណាមមើលនឹងភ្នែកទេ? អត់ទេ វៀតណាមមុខជាយកលេសធ្វើជាទៅជួយកម្ពុជា ហើយពេលនោះ


នួន ជា (រូបមុខបង់កក្រមា) កំពុងដើរអមទីប្រឹក្សាចិន (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

គេរៀបចំចាត់តាំងរដ្ឋអំណាចគេ តាមកម្លាំងកងទ័ពគេ ចូលទៅក្នុងប្រទេសកម្ពុជាយើង ។ នេះបញ្ហាស្មុគស្មាញណាស់ ខ្ញុំសូមជម្រាបបងប្អូនរួមជាតិឲ្យយល់ ។ ដូច្នេះ មិនមែនបញ្ហាធ្វើអី ធ្វើតាមចិត្តទេ សុទ្ធតែវិភាគ ។

ខទី២ បើប្រជាជននៅទីក្រុងភ្នំពេញ តើមធ្យោបាយដឹកជញ្ជូនស្បៀងយកទៅចែកជូនប្រជាជនយ៉ាងម៉េច? យើងពេលនោះ តាមក្តាប់បានគឺថាក្នុងទីក្រុងភ្នំពេញជួបបញ្ហា ១) គ្មានប្រេង ២) មធ្យោបាយដឹកជញ្ជូនឡានខ្វះខាត ។ ដូច្នោះ បើយើងទុកឲ្យ ប្រជាជននៅក្នុងទីក្រុងភ្នំពេញយ៉ាងនេះ គឺមុខជាមានការវេទនា អត់ស្បៀង អត់អាហារ ។ ហើយទោះបីជាផ្តល់បានខ្លះក៏ដោយ ស្បៀងអាហារនេះធ្លាក់លើដៃអ្នកណា? មិនមែនលើដៃប្រជាពលករ អ្នកក្រីក្រលំបាកតោកយ៉ាកទេ ធ្លាក់លើដៃអ្នកដែលគេ មានលុយទិញណ៎ះ គេទិញដើម្បីគេមានគ្រប់គ្រាន់បរិភោគ ។ ឯអ្នកដែលក្រគ្មាន គឺគ្នាអត់ដូចដើម ។ នេះជាហេតុផលទី២ គឺបញ្ហាមធ្យោបាយដឹកជញ្ជូនខ្ញុំសូមជម្រាប ។ ហើយជាពិសេសទៀត ដូចខ្ញុំជម្រាប ហើយជម្រាបទៀត គឺថាបញ្ជាក់តាមភូមិភាគត្រូវអប់រំសហករណ៍ឲ្យមានអាកប្បកិរិយា មាននយោបាយឲ្យត្រឹមត្រូវចំពោះអ្នកជម្លៀសមកថ្មី ។ ដូច្នេះ ឲ្យគេធ្វើពលកម្មដូចយើងធ្វើមិនបានទេ គឺត្រូវចេះអធ្យាស្រ័យគ្នា ចេះស្រឡាញ់រាប់អានគ្នា ។ ក៏ប៉ុន្តែបញ្ហានេះ កន្លែងខ្លះមានការខ្វះខាតច្រើនតាមខ្ញុំចាំបាន ។ បើទោះមានការណែនាំទៀតក៏ដោយ ក៏ប៉ុន្តែបញ្ហាពួកបំផ្លាញក៏មាន ។ ខ្ញុំសូមជម្រាបអង្គប្រជុំ សូមជម្រាបដូចតទៅនេះ ។

សរុបមកវិញ មតិខ្ញុំក្នុងឋានៈពេលនោះ ខ្ញុំក៏ជាអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ ខ្ញុំចាំហ្នឹងគឺមានពីរខធំ ។

១) បញ្ហាអាមេរិកកាំងទម្លាក់គ្រាប់បែកឬទេ? គឺថាបញ្ហាទី២ គឺមធ្យោបាយដឹកជញ្ជូនយ៉ាងម៉េចដើម្បីផ្តល់ស្បៀងឲ្យអ្នកនៅទីក្រុង? ដូច្នោះ សុខចិត្តឃើញការលំបាកហើយការឈឺថ្កាត់អីខ្លះក៏មាន ហើយយើងចេះជួយដោះស្រាយតាមលទ្ធភាពរបស់យើងទៅ ។ ដូច្នោះ សុខចិត្តជម្លៀសមកឲ្យប្រជាជនមករស់នៅតាមសហករណ៍ល្អជាងយើងទុកឲ្យប្រជាជនលំបាកវេទនានៅទីក្រុង ។

មូលហេតុនេះហើយ ដូចខ្ញុំបានជម្រាបហើយ គឺដោយមនុស្សធម៌ មិនមែនដោយចង់យកប្រជាជនមកឲ្យលំបាកវេទនាដូចជាអ្នកខ្លះបានប៉ាន់ប្រមាណនោះទេ ។ ការណ៍នេះ ខ្ញុំសូមជម្រាបដោយសេចក្តីស្មោះត្រង់អស់ពីដួងចិត្តរបស់ខ្ញុំក្នុងឋានៈទទួលខុសត្រូវពេលនោះដែរ ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង ។

# សវនាការស្តាប់សក្ខីកម្មសាក្សី សុខ រឿ

## ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បើកសវនាការស្តាប់សក្ខីកម្មសាក្សី សុខ រឿ អតីតកងការពារសន្តិសុខឲ្យ ខៀវ សំផន ចន្លោះឆ្នាំ១៩៨៩ ដល់១៩៩៦ នៅតាមព្រំដែនថៃ និងប៉ៃលិន ។ សវនាការនេះធ្វើឡើងដើម្បីសួរដេញដោលសាក្សី សុខ រឿ អំពីអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ។ ដូច្នេះ ក្នុងការសួរដេញដោលសាក្សីរូបនេះ ភាគី រួមទាំងចៅក្រមបានផ្តោតសំខាន់អំពីអត្តចរិតរបស់ជនចោទ ខៀវ សំផន ។ ចំពោះអត្តចរិតរបស់ជនជាប់ចោទ នួន ជា ពុំត្រូវបានសួរនាំឡើយ ។ ដោយសាក្សី សុខ រឿ ត្រូវបានស្នើសុំកោះហៅដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ដូច្នេះ នីតិវិធីសួរដេញដោលសាក្សីរូបនេះ ចាប់ផ្តើមពីក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា និងចុងក្រោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណែកក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ពុំមានសំណួរឡើយ ។

មុននឹងប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលសាក្សី ប្រធានអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិ និងករណីកិច្ចរបស់សាក្សីនៅចំពោះមុខភាគី និងសាធារណជនទូទៅថា សាក្សីមានសិទ្ធិក្នុងការមិនឆ្លើយសំណួរទាំងឡាយណាដែលអាចដាក់បន្ទុកនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង (មានន័យថា តាមរយៈចម្លើយនោះ សាក្សីខ្លួនឯងអាចនឹងត្រូវបានចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌណាមួយ) ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះបានផ្តល់មេធាវី មៀន សុវណ្ណ ជូនសាក្សីដើម្បីពិភាក្សាមុននឹងឆ្លើយតបនឹងសំណួរណាដែលអាចដាក់បន្ទុកលើខ្លួនឯង ។ អង្គជំនុំជម្រះក៏ប្រាប់សាក្សីផងដែរអំពីករណីកិច្ចឆ្លើយគ្រប់សំណួរទាំងអស់របស់ភាគី នូវអង្គហេតុទាំងឡាយណាដែលខ្លួនបានដឹង ឬឃើញផ្ទាល់ដាក់ស្តែង ពោលគឺមិនត្រូវឆ្លើយដោយធ្វើការស្មានឡើយ ។

សុខ រឿ អាយុ ៥២ឆ្នាំ ជាជនជាតិទំពួនមានស្រុកកំណើតនៅខេត្តរតនគិរី ។ បច្ចុប្បន្នរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ឪពុកឈ្មោះ យ៉ា ជយ ម្តាយឈ្មោះ យ៉ា ញៀវ ប្រពន្ធឈ្មោះ ទុយ មួយ ។ រឿ ចូលរួមក្នុងចលនាបដិវត្តរបស់ខ្មែរក្រហមនៅខេត្តរតនគិរី ។ ក្នុងអំឡុងពេលនោះ រឿ ពុំស្គាល់ចេះសរសេរ និងនិយាយភាសាខ្មែរឡើយ ។ ដូច្នេះ ក្នុងពេលចូលរួមចលនាបដិវត្តនេះ រឿ បានខិតខំរៀនសូត្រភាសាខ្មែរ ។ រឿ បានធ្វើដំណើរចេញពីខេត្តរតនគិរី មករស់នៅតាមដងស្ទឹងសេសានក្នុងខេត្តស្ទឹងត្រែង ហើយបានមកដល់ទីក្រុងភ្នំពេញក្នុងឆ្នាំ



យោធាខ្មែរក្រហមកំពុងតម្រង់ជួរ ក្រោយខ្មែរក្រហមទទួលជ័យជម្នះ ។ រូបថត
(បណ្ណសារ : មជ្ឈមណ

១៩៧៦ ។ រឿ ត្រូវបានអង្គការជ្រើសរើសឲ្យមកបម្រើការងារនៅទីក្រុងភ្នំពេញដោយសារគាត់មានប្រវត្តិរូបជាកូនកសិករ និងឧស្សាហ៍ព្យាយាមចំពោះការងារ ។

មកដល់ទីក្រុងភ្នំពេញ រឿ ត្រូវបានចាត់តាំងឲ្យបំពេញការងារនៅមន្ទីរក-៨ ក្រោមការដឹកនាំរបស់ ហាន ជាប្រធានមន្ទីរ ។ មន្ទីរនេះមានទីតាំងនៅជិតមន្ទីរក-១ នៅជិតមាត់ទន្លេ ។ រឿ

បម្រើការងារនៅមន្ទីរនេះជាអ្នកដាំបន្លែ និងបោសសម្អាតនៅជុំវិញមន្ទីរអស់រយៈពេល៤ខែ ក៏ត្រូវបានអង្គការចាត់តាំងឲ្យទៅបម្រើការនៅមន្ទីរក-១ ។ នៅមន្ទីរក-១ រឿ នៅតែមានតួនាទីជាអ្នកដាំបន្លែ និងបោសសម្អាតដដែល ។ នៅមន្ទីរនេះ រឿ បានជួបឌីម ដែលជាជនភាគតិចដូចគ្នា ធ្វើការនៅទីនោះដែរ ។ រឿ បញ្ជាក់ថា មន្ទីរក-១ ជាកន្លែងធ្វើការរបស់ថ្នាក់ដឹកនាំធំៗ ប៉ុន្តែពុំដឹងថាមានមេដឹកនាំណាខ្លះឡើយ ។ បន្ទាប់ពីធ្វើការនៅមន្ទីរនេះបាន៦ខែ រឿ ត្រូវបានអង្គការចាត់តាំងឲ្យទៅបម្រើការងារនៅមន្ទីរក-៣ ក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៨ ។ នៅមន្ទីរនេះ រឿ



...កនេះត្រូវបានប្រើប្រាស់ជាបណ្ណប្រៃសនីយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។
...ណ្ឌលឯកសារកម្ពុជា)

ក៏នៅតែមានតួនាទីជាដាំបន្លែ និងបោសសម្អាតដដែល ។ ប៉ុន្តែមានពេលខ្លះ រឿ ជួយយាមកាមម្តងម្កាលនៅពេលកងការពារជាប់រវល់ ។ រឿ បានបម្រើការងារនៅមន្ទីរនេះបានរយៈពេលប្រមាណ ៣ខែ វៀតណាមក៏វាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងរយៈពេលនេះ រឿ ធ្លាប់ឃើញប្រពន្ធរបស់ ខៀវ សំផន ជាញឹកញាប់ ប៉ុន្តែពុំដែលបានសួរនាំអ្វីឡើយ ។ រឿ បញ្ជាក់បន្ថែមថា មន្ទីរក-៣ ជាកន្លែងរស់នៅរបស់ ខៀវ សំផន ។ ទោះបីជាយ៉ាងណា រឿ ពុំដែលបានជួបទល់មុខនឹង ខៀវ សំផន ឡើយ ។ រឿ ស្គាល់ ខៀវ សំផន ច្បាស់ចាប់ពីឆ្នាំ១៩៨៩មក ។ គាត់ធ្វើជាកងការពារសន្តិសុខឲ្យ ខៀវ សំផន ចាប់ពីឆ្នាំ១៩៨៩ ដល់ ១៩៩៦ ។ ក្នុងអំឡុងពេលនោះ រឿ នៅជាប់ជាមួយ ខៀវ សំផន ដោយបានការពារ ខៀវ សំផន ធ្វើដំណើរចេញចូលព្រំដែនប្រទេសថៃជាញឹកញាប់ ។

ឆ្លើយតបសំណួររបស់មេធាវី គង់ សំអុន ពាក់ព័ន្ធនឹងអត្តចរិតរបស់ ខៀវ សំផន សាក្សី សុខ រឿ បញ្ជាក់ថា ខៀវ សំផន ជាមនុស្សធ្វើការហ្មត់ចត់ មិនឆេវឆាវ ចេះពិចារណាវែងឆ្ងាយ តែងតែផ្តល់យោបល់ណែនាំអំពីរបៀបរកស៊ីដើម្បីធ្វើយ៉ាងណាឲ្យមានជីវភាពធូរធារ មិនដែលមើលងាយជីវិតរបស់កសិករ និងពុំដែលស្តីបន្ទោស ឬធ្វើអ្វីដែលនាំឲ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់គាត់ឡើយ ។ ចំពោះទស្សនៈនយោបាយ ខៀវ សំផន ផ្តោតសំខាន់ទៅលើប្រព័ន្ធទីផ្សារសេរី ។ ពាក់ព័ន្ធនឹងអត្តចរិតនេះដែរ លោកចៅក្រម ហ្សង់ម៉ាក ឡាវែង ចោទសំណួរទៅ រឿ ថាតើ ខៀវ សំផន ធ្លាប់បានសំដែងនូវការសោកស្តាយចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរទេ? ឆ្លើយតបនឹងសំណួរនេះ រឿ បញ្ជាក់ថា ក្នុងអំឡុងពេលដែលគាត់រស់នៅជាមួយ ខៀវ សំផន ពីឆ្នាំ១៩៨៩ ដល់១៩៩៦ គាត់ពុំដែលបានព្ទុម្ពងណាឡើយ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ឃីត រេន័រ អំពីទំនាក់ទំនងរវាង ប៉ុល ពត និង ខៀវ សំផន នៅចន្លោះឆ្នាំ ១៩៨៩ ដល់១៩៩៦ រឿ បានបញ្ជាក់ថា ក្នុងអំឡុងពេលនោះ អ្នកទាំងពីរនេះមានការជួបប្រជុំគ្នាជាញឹកញាប់នៅខេត្តកោះកុង ប៉ៃលិន ហើយមានពេលខ្លះនៅក្នុងព្រៃ ។ ទោះបីជាយ៉ាងណា រឿ ពុំបានដឹងថា អ្នកទាំងពីររូបនេះពិភាក្សាគ្នាអំពីបញ្ហាអ្វីឡើយ ព្រោះគាត់នៅការពារជាមួយកងការពាររបស់ ប៉ុល ពត ពីចម្ងាយតែប៉ុណ្ណោះ ។ ចុងក្រោយ តំណាងសហព្រះរាជអាជ្ញា បានដកស្រង់ចម្លើយរបស់សាក្សីម្នាក់ដែលថា ប៉ុល ពត និង ខៀវ សំផន ជាអ្នកដែលបានចេញបញ្ជាដោយផ្ទាល់នៅមន្ទីរក-១៨ (មន្ទី ដែល ប៉ុល ពត និង ខៀវ សំផន ធ្វើការក្នុងអំឡុងឆ្នាំ១៩៨៩-១៩៩៦) ។ ប៉ុន្តែ រឿ បញ្ជាក់ថា ពុំបានដឹងអំពីបញ្ហាទាំងនេះ ឡើយ ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ទុន សឿន ស្តីពីអត្តចរិត របស់ជនជាប់ចោទ ខៀវ សំផន

## *ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣*

*នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម បានបើកសវនាការស្តាប់សក្ខីកម្មសាក្សី២រូបទាក់ទងនឹងអត្តចរិត និងការប្រព្រឹត្តរបស់ជនជាប់ចោទ ខៀវ សំផន ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីទី១ ឈ្មោះ ទុន សឿន ត្រូវជាកូនប្រសារ និងអតីតអ្នកនាំសាររបស់ជនជាប់ចោទ ខៀវ សំផន ។ សាក្សីទី២ ឈ្មោះ សូ សុជាតិ ជាភរិយាជនជាប់ចោទ ខៀវ សំផន ។ សវនាការស្តាប់សក្ខីកម្មរបស់សាក្សី ទុន សឿន មានរយៈពេលត្រឹមតែមួយព្រឹកតែប៉ុណ្ណោះ ។ បន្ទាប់មក អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់សាក្សី សូ សុជាតិ រហូតដល់ព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ។ សូមបញ្ជាក់ថា សក្ខីកម្មរបស់សាក្សី សូ សុជាតិ នឹងមានចុះនៅក្នុងព្រឹត្តិបត្រសង្កេតការណ៍លេខបន្ទាប់ ។*

*ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម សាក្សី ទុន សឿន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ខៀវ សំផន ជាបុគ្គលស្មោះត្រង់ សុភាពរាបសា សាមញ្ញ ហើយប្រជាជននៅតំបន់ម៉ាឡៃ នៅគោរពស្រឡាញ់ចំពោះ ខៀវ សំផន ។ ចំណែកសាក្សី សូ សុជាតិ ដែលជាភរិយារបស់ ខៀវ សំផន បានបញ្ជាក់ជូន អង្គជំនុំជម្រះថា ខៀវ សំផន ជាមនុស្សស្លូតបូត រាបសា ទន់ភ្លន់ ស្មោះត្រង់ ហើយមានទាំងសីលធម៌ គុណធម៌ និងពុំមានសិទ្ធិអំណាចអ្វីឡើយ ។*

*ការសួរដេញដោលសាក្សីទាំង២រូប ចាប់ផ្តើមដោយក្រុមមេធាវីការពារក្តី ខៀវ សំផន បន្ទាប់មកវេទិកាសួរដេញដោលត្រូវប្រគល់ជូនសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយវេទិកាសួរដេញដោលត្រូវប្រគល់ជូនក្រុមមេធាវីការពារក្តី នួន ជា ។*

### ១) *ប្រវត្តិសាវតារ*

*នៅមុនពេលប្រគល់វេទិកាជូនភាគីដើម្បីសាកសួរដេញដោល ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សី ទន់ សឿន ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះ សាក្សី ទន់ សឿន សព្វថ្ងៃមានទីលំនៅខេត្តប៉ៃលិន មុខរបរធ្វើចម្ការ ។ ឪពុកឈ្មោះ ទន់ សុំ និងម្តាយឈ្មោះ កង សេង និងមានភរិយាឈ្មោះ ខៀវ រតនា និងមានកូនបីនាក់ ។*

*សាក្សី ទន់ សឿន បានអះអាងថា គាត់ពុំធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ។ ទាក់ទងនឹងការធ្វើសម្បថមុនពេលចូលផ្តល់សក្ខីកម្ម សាក្សី ទន់ សឿន បានបញ្ជាក់ថា គាត់បានធ្វើសម្បថរួចហើយមុនពេលចូលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ គួរបញ្ជាក់ថា ដោយសារសាក្សី ទន់ សឿន មានជាប់សាច់ញាតិជាមួយ ខៀវ សំផន តាមច្បាប់ ពុំតម្រូវឲ្យសាក្សីរូបនេះធ្វើសម្បថឡើយ ប៉ុន្តែការណ៍ដែលអង្គជំនុំជម្រះតម្រូវឲ្យសាក្សីធ្វើសម្បថ ក៏ព្រោះតែអង្គជំនុំជម្រះត្រៀមទុកជាមុន ករណីដែលសក្ខីកម្មរបស់សាក្សី ទន់ សឿន មានជាប់ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា ដែលពុំមែនជាញាតិរបស់ខ្លួន ។*

*បន្ទាប់មក អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីសួរដេញដោលសាក្សី ទន់ សឿន មុនប្រគល់វេទិកាជូនសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តី នួន ជា ។*

### ២) *ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី ខៀវ សំផន*

*លោក គង់ សំអុន មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បានចាប់សំណួរដំបូងរបស់ខ្លួនដោយផ្តោតជាសំខាន់លើប្រវត្តិនៃការសិក្សារបស់សាក្សី ទន់ សឿន ។ សាក្សី ទន់ សឿន បានរៀបរាប់ថា គាត់បានទទួលបានការសិក្សាអំពីអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យារយៈពេលមួយឆ្នាំកន្លះនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអតីតវិទ្យាល័យសុធារស ជាមួយឈ្មោះ ផង់ (មានឈ្មោះពេញថា នង់ សុផង់ ដែលធ្លាប់បានចូល*

ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២) ។ បន្ទាប់មកខ្លួនបានធ្វើការក្នុងមន្ទីរក-៣ ដោយធ្វើជាអ្នកវាយអង្គុលីលេខរយៈពេល៤ខែ រហូតដល់ចុងឆ្នាំ១៩៧៨ ។ សាក្សី ទន់ សឿន បានបន្តថា នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់ពុំធ្លាប់បានជួបមុខមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយក៏ពុំធ្លាប់ជួប ខៀវ សំផនដែរ ។ រហូតដល់ឆ្នាំ១៩៨២ ទើបសាក្សីបានជួប ខៀវ សំផន លើកដំបូងក្នុងរយៈកាលនៃការតស៊ូត្រីភាគី ។ ពេលនោះ សាក្សីមានតួនាទីជាអ្នកបកប្រែសារទូរលេខ និងជាអ្នកនាំសារឲ្យ ខៀវ សំផន នៅស្រុកម៉ាឡៃ រហូតដល់ចុងឆ្នាំ១៩៨៣ ដោយសារគាត់មានបេសកកម្មទៅប្រទេសបារាំង ។ នៅឆ្នាំ១៩៨៩ សាក្សី ទន់ សឿន បានត្រឡប់មកធ្វើការជាអ្នកនាំសារឲ្យ ខៀវ សំផន សារជាថ្មីម្តងទៀត ។ នៅក្នុងឆ្នាំ១៩៩០ សាក្សីបានទៅធ្វើការនៅទីក្រុងប៉េកាំង រហូតដល់ឆ្នាំ១៩៩១ ទើបត្រឡប់មកធ្វើការនៅស្រុកខ្មែរវិញ ។ សាក្សីបានបញ្ជាក់ថា គាត់បានរៀបការជាមួយកូនស្រីរបស់ ខៀវ សំផន នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ក្នុងឋានៈជាយុទ្ធជនធម្មតា ។

ទាក់ទងនឹងអត្តចរិតរបស់ ខៀវ សំផន សាក្សី ទន់ សឿន បញ្ជាក់ថា ខៀវ សំផន ជា មនុស្សស្លូតបូត និងស្មោះត្រង់ ហើយរាបសាជាមួយមហាជន និងពុំមែនជាមនុស្សឃោរឃៅទេ ។ សាក្សីបន្តថា នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ពុំមានតួនាទីខាងផ្នែកយោធាទេ ។ ទាក់ទងនឹងជីវភាពប្រចាំថ្ងៃនៅក្នុងគ្រួសារ ខៀវ សំផន ជាមនុស្សសាមញ្ញពុំរើសអើង និងខិតខំណែនាំកូនៗឲ្យធ្វើល្អគោរពច្បាប់ និងខិតខំរកស៊ីបង្កបង្កើនផល និងពុំដែលបែងចែកថា កូនប្រសា ឬកូនបង្កើតទេ គឺស្រឡាញ់ស្មើៗគ្នា ។ ចំណែកឯប្រជាជននៅតំបន់ប៉ៃលិនវិញ គឺនៅតែមានការគោរពស្រឡាញ់ចំពោះ ខៀវ សំផន ដដែល ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងទស្សនៈនយោបាយរបស់ ខៀវ សំផន សាក្សីបានបញ្ជាក់ថា ចំពោះគោលនយោបាយនដឹកនាំប្រទេស ខៀវ សំផន យកលំនាំតាមគំរូរបស់សម្តេច សីហនុ ដែលប្រកាន់យកនយោបាយ អព្យាក្រឹត និងឯករាជ្យ ។

### ៣) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

លោក ឃីត រេន័រ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានបន្តសួរសាក្សី ទន់ សឿន ដោយផ្តោតលើការបកប្រែសារ



ការបង្រៀនអក្សរដល់កុមារា កុមារី ដែលរួចរស់ជីវិតពីរបបខ្មែរក្រហម ក្នុងឆ្នាំ១៩៨០ នៅព្រំដែនកម្ពុជា-ថៃ ។ រូបថតដោយ J. Kaufmann (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទូរលេខ ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា គាត់ពុំធ្លាប់រៀនអំពីការបកប្រែសារទូរលេខជាមួយនឹង ផង់ ទេ ដោយគ្រាន់តែរៀនអំពីរបៀបវាយអក្សលីលេខប៉ុណ្ណោះ ។

ទាក់ទងនឹងកន្លែងធ្វើការរបស់ ខៀវ សំផន និង ប៉ុល ពត នៅក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សី ទន់ សឿនបញ្ជាក់ថា ក្រោយឆ្នាំ១៩៧៩ កន្លែងធ្វើការរបស់ ខៀវ សំផន និង ប៉ុល ពត មានទីតាំងផ្សេងគ្នា ពុំមែននៅមន្ទីរក-១៨ទេ ។ សាក្សីបានបន្តថា ខៀវ សំផន ធ្លាប់បានធ្វើចំណារនៅលើសារទូរលេខ ដែលអ្នកការទូតនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផ្ញើមកពីស្ថានទូតកម្ពុជានៅបរទេសដើម្បីផ្តល់យោបល់ត្រឡប់ទៅវិញ ប៉ុន្តែសាក្សីពុំបានដឹងច្រើនអំពីកិច្ចការរបស់ ខៀវ សំផន ទេ ដោយសារ ខៀវ សំផន មានលេខាផ្ទាល់ខ្លួនម្នាក់ ឈ្មោះ ឃន ជាអ្នកទទួលបន្ទុកលើកិច្ចការទាំងនេះ ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលសួរថា តើ ខៀវ សំផន មានធ្លាប់ប្រាប់ថា មានជនស៊ីវិល៣០០០នាក់ត្រូវបានសម្លាប់ខុសនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សាក្សី ទន់ សឿន បានបញ្ជាក់ថា ខៀវ សំផន ពុំធ្លាប់និយាយប្រាប់អំពីបញ្ហានេះទេ ។ នៅពេលដែលសួរថា តើសាក្សីធ្លាប់ឮ ខៀវ សំផន លើកឡើងនៅក្នុងវិទ្យុក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធបិតេយ្យអំពីការបោសសម្អាតខ្លាំងដែរឬទេ? និងថាតើមានការចាប់ខ្លួនបុគ្គលិកនៅមន្ទីរក-៣ដែរឬយ៉ាងណា? សាក្សីអះអាងថា គាត់ពុំធ្លាប់ឮ ខៀវ សំផន ប្រកាសតាមវិទ្យុអំពីការបោសសម្អាតទេ ហើយក៏ពុំមានការចាប់ខ្លួនមនុស្សនៅមន្ទីរក-៣ដែរ ។

### ៤) ការសួរដេញដោលសាក្សីដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោក ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមសំណួរ ដោយស្នើឲ្យសាក្សីបញ្ជាក់ឡើងវិញទាក់ទងនឹងមន្ទីរក-៣ ។ បន្ទាប់មក មេធាវី ពេជ អង្គ បានបន្តសួរទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ដោយស្នើឲ្យសាក្សីពន្យល់អំពីមូលហេតុដែលនាំឲ្យសាក្សីលើកឡើងថា ខៀវ សំផន ជាមនុស្សស្មោះត្រង់ ។ សាក្សី ទន់ សឿន បានពន្យល់ថា មូលហេតុដែលគាត់លើក ឡើងថា ខៀវ សំផន ជាមនុស្សស្មោះត្រង់ដោយសារតែ ខៀវ សំផន មិនលោភលន់ មិនរំលោភអំណាច មិនចង់មានចង់បានដោយអំពើខុសច្បាប់ ឬបំផ្លិចបំផ្លាញប្រទេសជាតិ ។ ម្យ៉ាងវិញទៀត ខៀវ សំផន ជា បុគ្គលដែលមានមហិច្ឆតាស្នេហាជាតិ ។



កុមារា កុមារី ដែលជាកូនរបស់កម្មាភិបាលខ្មែរក្រហម អង្គុយនៅក្នុងថ្នាក់រៀន ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ពន្យល់ពាក្យសំខាន់

ជនរងគ្រោះ : សំដៅទៅលើរូបបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះ វិសាមញ្ញ ។

ដើមបណ្តឹងរដ្ឋប្បវេណី : សំដៅទៅលើជនរងគ្រោះដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

ជនជាប់ចោទ : សំដៅទៅលើបុគ្គល ដែលត្រូវចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

ភាគី : សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

អង្គជំនុំជម្រះវិសាមញ្ញ : សំដៅទៅលើតុលាការពិសេស នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ដែលបង្កើតឡើងដោយច្បាប់ស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។


មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : dccam@online.com.kh

គេហទំព័រ : www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

John D. and Catherine T. MacArthur Foundation and

British Embassy-Cambodia.


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០ , ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។



**លីម ជ័យវ័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសរនាការប្រឌិតឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។



**ចាន ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។



គណៈប្រតិភូចិន ដឹកនាំដោយ វ៉ាំង ដុងស៊ីង (ឆ្វេង) អំឡុងពេលធ្វើដំណើរទស្សនកិច្ចមកប្រទេសកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ទៅទទួល និង អមដំណើរពីព្រលានយន្តហោះពោធិចិនតុង ដោយ ប៉ុល ពត (ស្តាំ) និងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមជាច្រើនរូបផ្សេងទៀត ។

(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែកក្កដា ឆ្នាំ២០១៣